ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការបាត់បង់ជីវិតគ្រាន់តែជារង្វាន់សម្រាប់ការដោះដូរអធិបតេយ្យភាពរបស់កម្ពុជា
- មេឃុំធ្វើទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញ

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៧៨ ខែមិថុនា ឆ្នាំ២០០៦

ស្វែងរកការពិត
លេខ៧៨ ខែមិថុនា ឆ្នាំ២០០៦

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ វិចារណកថា ៖ ខៀវ សំផន ៖ ការបាត់បង់ជីវិតគ្រាន់តែជារឿងវ៉ាន់ ..........១

**ផ្នែកឯកសារ**

◆ ស៊ុន ទី ហៅ ទាញ ៖ ភ័ស្តុតាងសេនាធិការ ..........២

◆ ឃាតកម្មនៅភូមិក្បាលហុងចាស់ ..........៦

◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្ទេចនៅមន្ទីរ ស-២១ ..........១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រឿងរ៉ាវដែលមិនចេះសាបសូន្យ ..........១២

◆ ចំណងខក្រិដ្ឋកម្មមន្ទីរសន្តិសុខភូមិភាគនិរតី ..........១៦

◆ មេឃុំធ្វើទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញ ..........២៤

◆ គុកខ្មែរក្រហម ..........២៥

**ផ្នែកច្បាប់**

◆ អង្គជំនុំជម្រះវិសាមញ្ញ ៖ សំណូមពរមានអង្គភាពវាយតម្លៃ ..........៣១

**វេទិកាពិភាក្សាសាធារណៈ**

◆ សំណងចំពោះជនរងគ្រោះនៃរបបខ្មែរក្រហម ..........៣៨

◆ សង្គ្រាមគឺជាអំពើឃោរឃៅ ..........៤០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ប្រលោមមុខនឹងអតីតកាល ..........៥០

◆ សូមតុលាការជួយរកយុត្តិធម៌ឲ្យឪពុក ប្តី និងបងប្អូនរបស់ខ្ញុំ ..........៥៨





**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** ប៉ាង ពីរ៉ែន, ស៊ិរិ សាវីណា, ប៉ាន សុភាព, វ៉ាន់ថាន់ ពៅដារ៉ា, សួ ប៊ុនស៊ូ, អៀ ម៉េងទ្រី, ព្រំ ដល្លា, នី វរៈ **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** លី សុផល, ណយ សុផារី **អ្នកបកប្រែ ៖** បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយករង ៖** សាន់ កល្យាណ **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ ៖** គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ ៖** រ័ត្ន គារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*វិចារណកថា :*

# ខៀវ សំផន : ការបាត់បង់ជីវិតគ្រាន់តែជារឿងបន្ទាប់បន្សំសម្រាប់ការរំដោះដូរយកអធិបតេយ្យភាពរបស់កម្ពុជា

នៅតាមផ្លូវដីមួយក្នុងក្រុងប៉ៃលិនដ៏ស្ងាត់ជ្រងំ ផ្ទះម៉ូតបស្ចិមប្រទេសដ៏សាមញ្ញរបស់ ខៀវ សំផន អតីតមេដឹកនាំខ្មែរក្រហម ស្ថិតនៅពីខាងក្រោយរបងផ្ទះយ៉ាងចាស់ធ្វើពីឈើ ។ បន្ទប់ទទួលភ្ញៀវមានតុបតែងទៅដោយគ្រឿងសង្ហារឹមបន្តិចបន្តួច ។ ពូកសម្រាប់ទ្រាប់អង្គុយពណ៌បៃតងខ្ចីនៅអមជុំវិញតុ ។ ស៊ុមរូបថតគរលើគ្នានៅជ្រុងម្ខាងនៃបន្ទប់ ។ រូបថត សម្តេចព្រះបាទនរោត្តម សីហនុ និងសម្តេចព្រះអគ្គមហេសីព្យួរនៅក្នុងបន្ទប់នោះ ដែលខណ្ឌផ្តាច់ពីគ្នាដោយនាឡិកាប៉ោលកញ្ចាស់មួយដែលទ្រនិច បន្លឺសំឡេងរាល់មួយវិនាទីម្តងៗ ។


ខៀវ សំផន (២០០៦)

ខៀវ សំផន ហាក់ដូចជាមានសុខភាពល្អនិងស្វាហាប់ជាងបងប្អូនរួមអាវុធជាមួយគាត់គឺ តាម៉ុក ។ ស្នាមញញឹមរបស់ ខៀវ សំផន អាចលាក់អាយុ៨០ឆ្នាំរបស់គាត់បាន ក៏ប៉ុន្តែផ្ទៃមុខមិនអាចលាក់វ័យ៨០ឆ្នាំរបស់គាត់បានឡើយ ។ ខៀវ សំផន នៅតែនៅមានភាពស្អាតបាត ភាពបញ្ចុះបញ្ចូល និងភាពជឿជាក់ការលើភាពគ្មានទោសរបស់គាត់ចំពោះអំពើព្រៃផ្សៃ ដែលប្រព្រឹត្តឡើងដោយរដ្ឋាភិបាលដែលខ្លួនគាត់ធ្លាប់បានដឹកនាំ ។

ខៀវ សំផន ទទួលស្គាល់ថាគាត់មានមុខតំណែងខ្ពស់មួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ប៉ុន្តែ ខៀវ សំផន បន្ថែមទៀតថាគាត់ត្រូវបង្ខំចិត្តទទួលយកមុខតំណែងនោះដោយសារស្ថានភាពរបស់ប្រទេសកម្ពុជានៅពេលនោះ ។ ដោយចេះនិយាយភាសាអង់គ្លេសបានល្អដែរនោះ ខៀវ សំផន បានរៀបរាប់ប្រវត្តិឡើងកាន់អំណាចរបស់ខ្មែរក្រហម ដោយបានដាក់ភាពព្រៃផ្សៃរបស់បក្សរបស់គាត់ទៅក្នុងស្ថានភាពនៃការតស៊ូរំដោះខ្លួនចេញពីក្រញាំដៃរបស់វៀតណាមនិងអាមេរិក ។ ដោយបង្ហាញពីស្មារតីជាតិនិយមដ៏មុតមាំរបស់គាត់ ។ ខៀវ សំផន សង្កត់ធ្ងន់ម្តងហើយម្តងទៀតថារបបកម្ពុជាប្រជាធិបតេយ្យដែលដឹកនាំដោយ ប៉ុល ពត គឺគិតតែខិតខំប្រឹងប្រែងតស៊ូរំដោះប្រទេសជាតិប៉ុណ្ណោះ ។ សូម្បីតែត្រង់ចំណុចនេះ ខៀវ សំផន នៅតែជាអ្នកគាំទ្រដ៏ស្មោះស្ម័គ្រម្នាក់របស់ ប៉ុល ពត ។ ខៀវ សំផន មើលឃើញ ប៉ុល ពត ថាជាមេដឹកនាំម្នាក់ដែលគិតគូបានវែងឆ្ងាយ ហើយដែលគោលបំណងល្អរបស់គាត់ចំពោះប្រទេសកម្ពុជាមិនបានកើតឡើងត្រឹមត្រូវតាមការរៀបចំរបស់ ប៉ុល ពត នេះ មិនមែនជាកំហុសរបស់ ប៉ុល ពត ទេ ។ ប៉ុល ពត គ្មានកងទ័ពនៅក្រោមបង្គាប់បញ្ជារបស់ខ្លួនឡើយ ហើយ ប៉ុល ពត ត្រូវអំពាវនាវសុំជំនួយផ្នែកយោធាពី តាម៉ុក និង សោ ភឹម ដើម្បីអនុវត្តនូវគោលនយោបាយរបស់ខ្លួន ។ នៅពេលដែល ខៀវ សំផន និយាយសង្កត់ធ្ងន់ទៅលើការបាត់បង់ជីវិតមនុស្សយ៉ាងច្រើន ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ឆ្លើយដោយស្ងប់ស្ងៀមថា វាចាំបាច់ត្រូវតែមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយគ្រោះទុរ្ភិក្ស គឺមិនអាចជៀសវៀងបាន ។ ការបាត់បង់អាយុជីវិតមនុស្ស គឺត្រូវតែចំណាយដើម្បីដោះដូរយកអធិបតេយ្យភាពរបស់កម្ពុជា ។

នៅពេលជាមួយគ្នានោះដែរ ពាក្យសម្តីនិងវោហាររបស់អតីតមេដឹកនាំខ្មែរក្រហមរូបនេះមានលក្ខណៈការទូតនិងយល់ដឹងយ៉ាងវាងវៃអំពីស្ថានភាពបច្ចុប្បន្នរបស់គាត់ ។ បើទោះបីជាមិនមានការពេញចិត្តនឹងរាជរដ្ឋាភិបាលបច្ចុប្បន្ននេះ ដែលថារាជរដ្ឋាភិបាលហាក់ដូចជាមិនអាចធ្វើទំនើបកម្មក្នុងវិស័យកសិកម្ម និងជំរុញឲ្យមានការអភិវឌ្ឍន៍យ៉ាងណាក៏ដោយ ក៏ ខៀវ សំផន ប្រកាន់

ខ្ជាប់នូវពាក្យសម្តីមិនលម្អៀងរបស់គាត់ជានិច្ចនៅពេលនិយាយដល់បញ្ហាសាលាក្តីខ្មែរក្រហម ។ ខៀវ សំផន មានការប្រុងប្រយ័ត្ននឹងពាក្យសម្តីរបស់គាត់ និងឈប់មួយសន្ទុះមុនពេលគាត់និយាយបន្តដោយសម្លឹងមើលទៅឆ្ងាយ ដែលប្រហែលជាសម្លឹងមើលទៅស្រមោលនៃការសម្លាប់ និងការអត់អាហារដែលបេះតែតាមលងគាត់ក៏មិនដឹង ។ ចុងបញ្ចប់ ខៀវ សំផន លើកដៃទាំងពីរឡើងទៅលើហើយនិយាយថា "ឥឡូវមានសាលាក្តីខ្មែរក្រហមហើយ ។ សាលាក្តីខ្មែរក្រហមនេះ មានភាពត្រឹមត្រូវផងនិងភាពមិនត្រឹមត្រូវផងក្នុងពេលជាមួយគ្នា" ។

ចៅក្រមអន្តរជាតិនិងជម្រះវិសាមញ្ញបានចូលធ្វើសច្ចាប្រណិធានចូលកាន់មុខតំណែងកាលពីថ្ងៃទី៣ ខែកក្កដា នៅក្នុងព្រះបរមរាជវាំង ។ ខៀវ សំផន នៅមានទស្សនៈយល់ឃើញថា តើសាលាក្តីខ្មែរក្រហមនឹងមានភាពត្រឹមត្រូវឬមិនត្រឹមត្រូវដែរឬក៏យ៉ាងណាទេ ។ ទោះបីជាយ៉ាងក៏ដោយសម្រាប់កម្ពុជា ការចាប់ផ្តើមសាលាក្តីខ្មែរក្រហមនេះបង្ហាញពីជំហានដ៏សំខាន់ដំបូងឆ្ពោះទៅរកយុត្តិធម៌ ។ **រេមហ្គា ចនណាឡាហ្គាដា**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ស៊ុន ទី ហៅ ទាញ : ភ័ស្តុភារសេនាធិការ

ស៊ុន ទី ហៅ ទាញ មានស្រុកកំណើតនៅភូមិថ្មី ឃុំថ្មី ខេត្តក្រមួនស កម្ពុជាក្រោម ។ ទី បានមករស់នៅប្រទេសកម្ពុជានៅអាយុ១២ឆ្នាំ និងបានប្រលងជាប់ចូលរៀននៅរោងជាងរទេះភ្លើងក្នុងឆ្នាំ១៩៥៧ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទី បានទទួលតួនាទីជាអនុប្រធានភស្តុភារសេនាធិការនៅក្រសួងការពារជាតិ ។ នៅថ្ងៃទី១០ ខែ១២ឆ្នាំ១៩៧៨ ទី ត្រូវអង្គការចាប់ខ្លួនពីបទពាក់ព័ន្ធក្នុងផែនការផ្តួលរំលំបក្ស ។ ខាងក្រោមនេះជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ ស៊ុន ទី ហៅ ទាញ ÷

នៅថ្ងៃទី៩ ខែ៨ឆ្នាំ១៩៦២ ទី បានក្លាយជាសមាជិកបក្សពលករកម្ពុជា ។ នៅពេលថ្ងៃ ទី ធ្វើការនៅរោងជាងរថភ្លើងពេលល្ងាចចាប់ពីម៉ោង៧រត់សំបុត្រឲ្យ វន ហៅ តែ (សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជាក្រោយខ្មែរក្រហមវាយយកទីក្រុងភ្នំពេញបាននៅឆ្នាំ១៩៧៥) ។ ពេលថ្ងៃ ទី នាំសំបុត្ររបស់ វន ឬរបស់ សរ គឹមលុត ទៅឲ្យនារីម្នាក់លក់កាសែតនៅជិតផ្សារដេប៉ូ ។ នៅពេលយប់ ទី ត្រូវនាំសំបុត្រពីផ្ទះរបស់ វន ទៅឲ្យ ខៀវ ឬ បង៨៩ (ជាឈ្មោះហៅក្រៅរបស់ សុន សេន) ។ វន បញ្ជាក់ប្រាប់ ទី ថាសំបុត្រដែលត្រូវនាំយកទៅមានសញ្ញាសម្គាល់ពីរប្រភេទ គឺមានសញ្ញាខ្វែងមួយ និងមានសញ្ញាខ្វែងពីរ ។ សំបុត្រដែលមានសញ្ញាខ្វែងមួយជាសំបុត្រការងារផ្ទៃក្នុងមិនសូវប្រញាប់ទេ អាចយឺតមួយម៉ោងឬពីរម៉ោងក៏បាន ។ ចំណែកសំបុត្រដែលមានសញ្ញាខ្វែងពីរ គឺប្រញាប់ និងជាសំបុត្រសម្រាប់ការងារប្រជាចលនា ។

ឆ្នាំ១៩៦៣ ក្រោមការណែនាំរបស់ វន, ទី បានចូលរួមក្នុងក្រុមប្រជាចលនានិងធ្វើសកម្មភាពខ្មែរសេរីនៅក្នុងរោងជាងរថភ្លើង ។ ទី បានទទួលការអប់រំជាច្រើនអំពីរបបសាធារណរដ្ឋនិងរបបសង្គមនិយម ហើយបានធ្វើសកម្មភាពប្រមូលកម្លាំងខ្មែរសេរីនៅតាមរោងចក្រ ហើយ ទី ត្រូវរាយការណ៍ពីសកម្មភាពរបស់ខ្លួនឲ្យ វន ជាប្រចាំ ។

ខែ៨ឆ្នាំ១៩៦៨ ការងាររបស់ ទី នៅក្នុងរោងជាងរទេះភ្លើងត្រូវបែកការណ៍ព្រោះមានមនុស្ស នៅក្នុងក្រុមរាយការណ៍ទៅបក្សចាប់ខ្មែរក្រហមដែលជាខ្មែរសេរី ហើយអ្នករាយការណ៍នោះស្គាល់ទាំងផ្ទះរបស់ វន និងផ្ទះរបស់ ទី ថែមទៀត ។ សែ បានប្រគល់ប្រាក់ចំនួនដប់ម៉ឺនរៀលឲ្យ ទី យកទៅឲ្យកម្លាំងខ្មែរសេរី ហើយបំបែកអ្នកទាំងនោះទៅតាមស្រុកកំណើតរៀងៗខ្លួន ។ ទី បានផ្អាកសកម្មភាពខ្មែរសេរី រហូតដល់ចុងខែ៩ឆ្នាំ១៩៦៩ ប៉ុន្តែក្នុងរយៈពេលមួយឆ្នាំនេះ ទី បានទាក់ទងទិញកាំភ្លើង (តាមរយៈឪពុកមាជាទាហាន) ឲ្យខ្មែរក្រហម ។ ទី ត្រូវទិញឲ្យបានកាំភ្លើង ការ៉ាប៊ីន២០ ដើម និងគ្រាប់ពី១០ ទៅ២០ កេស ក្នុងរយៈពេលមួយឬពីរសប្តាហ៍ ។

នៅចុងខែ៩ឆ្នាំ១៩៦៩ វន បានចាត់តាំងឲ្យ ទី ធ្វើដំណើរទៅភូមិភាគឦសានដើម្បីហាត់រៀនច្នៃគ្រាប់កាំភ្លើងត្បាល់៦០ មីលីម៉ែត្រឬ៨០មីលីម៉ែត្រធ្វើជាមីន ។ មួយឆ្នាំក្រោយមក ទី

បានត្រឡប់មកវិញ ហើយទទួលមុខនាទីជាសមាជិកមន្ទីរភូមិភាគពិសេស (ខាងជើង) ទទួលបន្ទុកខាងជីវភាពមន្ទីរ ។

នៅឆ្នាំ១៩៧២ វន ចាត់តាំង ទី ធ្វើជាស្នងការនយោបាយវរសេនាតូចលេខ១២ជាមួយ ណាត ដែល វន ណែនាំថាជាភ្នាក់ងារ សេ.អ៊ី.អា. ។ ទី មានការព្រួយបារម្ភជាខ្លាំងចំពោះការងារលើកនេះ ព្រោះ ទី ខ្លាចអ្នកដទៃដឹងពីសមាសភាពខ្លួនជាខ្មែរសេរី ប៉ុន្តែ វន បានណែនាំឲ្យ ទី បន្លំចូលជាសេ.អ៊ី.អាដើម្បីធានាសុវត្ថិភាពខ្លួនឯង ។ ចាប់តាំងពីពេលនោះមក ទី បានប្តូរទិសដៅកសាងកម្លាំងជាសេ.អ៊ី.អា.ទាំងអស់វិញ ។ ក្នុងរយៈពេលជាង៦ខែ ទី បានអប់រំនិងបញ្ចូល រុន និង សុន ជាភ្នាក់ងារសេ.អ៊ី.អា. ក្នុងអង្គភាពអនុសេនាធំរបស់ ណាត ។

នៅថ្ងៃទី២១ខែ១២ឆ្នាំ១៩៧២ ទី បានទៅជួប ណាត និង ឡាយ នៅភូមិដីឆ្នងក្នុងតំបន់២៥ ដើម្បីចូលរួមប្រជុំពិនិត្យការងារ និងលើកទិសការងារបក្ស និងប្រជុំសម្ងាត់ការងារខាងសេ.អ៊ី.អា. ។

ចុងឆ្នាំ១៩៧២ វិត មកពីភូមិភាគខាងជើង បានរៀបចំមន្ទីរភូមិភាគពិសេសខាងត្បូង ហើយផ្លាស់ ទី និង ណាត ឲ្យទៅធ្វើការនៅមន្ទីរនោះ ទទួលបន្ទុកខាងសេដ្ឋកិច្ច ។

## ការវាយចូលទីក្រុងភ្នំពេញឆ្នាំ១៩៧៥

នៅខែ៤ឆ្នាំ១៩៧៤ ទី បានទៅជួប វន នៅផ្ទះរបស់គាត់ក្បែរមន្ទីរយោធាតាមមាត់ទន្លេ ។ វន បានចាត់តាំងឲ្យ ទី ធ្វើជាស្នងការនយោបាយកងពល ដោយយកវរសេនាតូចតំបន់ចំនួនពីរមកបញ្ចូលគ្នា ហើយបង្កើតជាពីរកងពលគឺ កងពលលេខ១១ និងកងពលលេខ១២ ។ ទី និង សោម ជាកម្មាភិបាលគ្រប់គ្រងកងពល១១ ។ សោម ទទួលបន្ទុកប្រចាំការនិងគិតគូរខាងនយោបាយ ទី ទទួលបន្ទុកដឹកនាំទ័ពនៅសមរភូមិមុខ ។

កងពល១១ និងកងពល១២ វាយខ្លាំងនៅសងខាងទន្លេបាសាក់ ហើយដណ្តើមបានវត្តចំពុះក្អែក និងវត្តព្រែកអំបិល ។ ក្នុងអំឡុងពេលប្រយុទ្ធនៅភាគខាងត្បូងទីក្រុងភ្នំពេញ ទី បានប្រជុំកម្មាភិបាលទាំងវរសេនាធំនិងវរសេនាតូចដើម្បីជំរុញឲ្យពង្រីកកម្លាំងសេ.អ៊ី.អាឲ្យបានច្រើនថែមទៀត ។ អង្គការបានដកកម្លាំងចំនួនពីរវរសេនាធំពីកងពល១១ទៅជួយវាយប្រយុទ្ធនៅតាមផ្លូវជាតិលេខ៥ បណ្តាលឲ្យកម្មាភិបាលសេ.អ៊ី.អា. ដែល ទី កសាងបានបានស្លាប់អស់មួយចំនួន ។

ខែ៩ឆ្នាំ១៩៧៤ កងពល១២របស់ ណាត បានចេញទៅវាយប្រយុទ្ធនៅទន្លេមេគង្គ ហើយកងពល១១របស់ ទី បានវាយឆ្លងពីផ្លូវជាតិលេខ២មកជំនួសទ័ពនៅសមរភូមិទន្លេបាសាក់ ។ ទី និង សោម ធ្វើជាធ្វេសប្រហែសរាយការណ៍ឲ្យគ្នាតាមវិទ្យុទាក់ទងម៉ាកសេ២៥ដើម្បីឲ្យខ្មាំងក្នុងក្តាប់ព្ទុ ហើយលើកទ័ពមកវាយចូលក្នុងតំបន់រំដោះនៅម្តុំវត្តឈូងលាប (ក្នុងស្រុកស្អាង) និងកាន់កាប់ទីតាំងនោះមួយរយៈពេលខ្លី ។ បន្ទាប់ពីបំពេញភារកិច្ចនៅទន្លេមេគង្គរួចរាល់ហើយ ណាត បានត្រឡប់មកទន្លេបាសាក់សហការជាមួយ ទី វាយចូលក្រុងភ្នំពេញ ។ ឆ្លៀតឱកាសនោះ ទី ឆ្លៀតផ្សព្វផ្សាយថាការវាយចូលតាខ្មៅមានការយឺតយ៉ាវ ពីព្រោះសមរភូមិនោះតឹងតែង ដោយសារនៅកៀកទីក្រុងភ្នំពេញ ។ នៅទីបំផុតចលនាបដិវត្តន៍រំដោះបានទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

## ការបញ្ជូនកម្លាំងសេ.អ៊ី.អាទៅបង្កប់នៅតាមក្រសួង

ក្រោយថ្ងៃជ័យជម្នះបាន១០ថ្ងៃ វន បានហៅ ទី ទៅជួបនៅផ្ទះរបស់ខ្លួនដើម្បីរាយការណ៍អំពីសកម្មភាពកងរួម និងសភាពការណ៍សម្ងាត់សេ.អ៊ី.អា និងណែនាំឲ្យខិតខំកសាងកម្លាំងសេ.អ៊ី.អា. ក្នុងជួរកម្មាភិបាល ។ ទី បានប្រជុំជាមួយទ័ពកងពលលេខ១២ របស់ ណាត នៅចម្ការដូងដើម្បីស្ទង់មើលនិងលើកទឹកចិត្តកម្លាំងសេ.អ៊ី.អាក្នុងកងពល ។ នៅឆ្នាំ១៩៧៥ដដែល ចេង អន បានស្នើសុំកម្លាំងយុទ្ធជន២០០នាក់ទៅធ្វើការនៅក្នុងក្រសួងឧស្សាហកម្ម ហើយ វន បានណែនាំឲ្យ ទី បញ្ជូនកម្លាំងពីកងពល១១ទៅឲ្យ ចេង អន ដោយបង្កប់សមាសភាពមិនល្អមួយចំនួនផង ធ្វើដូច្នេះដើម្បីឲ្យសមាសភាពមិនល្អមាននៅរាយប៉ាយគ្រប់រោងចក្រ ។ ក្រៅពីនេះ ទី ឧស្សាហ៍តាមដានសភាពការណ៍សេ.អ៊ី.អា.តាមអង្គភាពផ្សេងៗដែរដូចជា ចិន នៅកងរថក្រោះ, ភាព នៅកងកាំភ្លើង ធំ, វ៉ែន និង រឿង នៅផ្នែកពេទ្យសេនាធិការ, កងពល៥០២របស់ ស៊ូ ម៉េត និងកងពលលេខ១២របស់ ណាត ជាដើម ។

## ការងារនៅភស្តុភារសេនាធិការ

វន បានប្រាប់ ទី អំពីផែនការបក្សចង់រំសាយកងពលលេខ១១ ហើយក៏ចាត់តាំង ទី ឲ្យទៅកាន់ខាងភស្តុភារសេនាធិការនៅ

ក្រសួងការពារប្រទេស ។

នៅពាក់កណ្តាលខែ៥ឆ្នាំ១៩៧៦ ទី បានចូលរួមប្រជុំជាមួយកម្មាភិបាលកងពលនិងកម្មាភិបាលវរសេនាធំចំនួន៤០នាក់ ដើម្បីពិនិត្យមើលទិដ្ឋភាពគ្រប់ផ្នែកក្នុងកងពលនីមួយៗនិងពិភាក្សាអំពីបញ្ហាបង្កបង្កើនផល ។ នៅក្រៅអង្គប្រជុំ ខៀវ បានជួបនិយាយជាមួយ ទី ថា "សមមិត្តត្រូវខំធ្វើការងារ ។ សម្ភារគ្រាប់រំសេវត្រូវរក្សាវាទុក ថ្ងៃនេះវាជារបស់យើង ថ្ងៃក្រោយក៏វាជារបស់យើងដែរ" ។

នៅដើមខែ៦ឆ្នាំ១៩៧៦ ទី បានទៅផ្ទះរបស់ ខៀវ ម្តងទៀត ។ ខៀវ បានណែនាំឲ្យ ទី ប្រើងប្រែងធ្វើការជូនបក្សឲ្យបានល្អ ហើយត្រូវគ្រប់គ្រងគ្រាប់រំសេវឲ្យបានហ្មត់ចត់ ។ ខៀវ បញ្ជាក់បន្ថែមថាគ្រាប់រំសេវអាចបើកឲ្យ វន ដរាបណា វន កាន់លិខិតអនុញ្ញាតមកបង្ហាញ ។ លើសពីនេះ ខៀវ បានណែនាំឲ្យ ទី សហការការងារជាមួយ ណាត ទោះជាការងារនោះធំក្តីតូចក្តី និងស្តាប់ការណែនាំរបស់ ណាត ។ ចាប់ពីពេលនោះមក ទី បានទាក់ទងការងារជាមួយ ណាត ជាញឹកញាប់ និងជួបពិភាក្សាការងារនិងរាយការណ៍ឲ្យគ្នាទៅវិញទៅមកអំពីសកម្មភាពកសាងកម្លាំងសេ.អ៊ី.អានៅក្នុងអង្គភាពរបស់ខ្លួនម្តងឬពីរដងជារៀងរាល់ខែ ។ បន្ទាប់ពី ណាត ចេញទៅខេត្តស្វាយរៀង ទី បានទាក់ទង ការងារបន្តជាមួយ វ៉ែន និង រឿង ដែលឡើងមកជំនួសបន្តបន្ទាប់គ្នានៅសេនាធិការ ។

រយៈពេល៤ឬ៥ខែដំបូងចាប់ពេលមកធ្វើការនៅភ័ស្តុភារសេនាធិការ ការកសាងកម្មាភិបាលឲ្យទៅជាសេ.អ៊ី.អា.មិនទាន់បានសម្រេចនៅឡើយ ។ ថ្ងៃមួយ វន បានសួរនាំអំពីទំនាក់ទំនងរវាង ទី និង ខៀវ ។ ទី ឆ្លើយថា ខៀវ បានផ្តាំខ្លួនថាបើមានការងារអ្វីត្រូវពិភាក្សាជាមួយ វន ព្រោះ វន នៅជាប់នឹងអង្គការ ។

នៅក្នុងឆ្នាំដដែលនោះ ទី បានទៅលេងមន្ទីររបស់ អឿន, មន្ទីររបស់ ស្វង និងរោងចក្រកែវ របស់ គួ ។ ក្រោយមកអង្គការចាប់ខ្លួន អឿន និង ស្វង ។ វន បានណែនាំ ទី ឲ្យរក្សាការសម្ងាត់ឲ្យបានខ្ពស់បំផុត ពីព្រោះសភាពការណ៍កាន់តែច្របូកច្របល់ហើយ ។ យប់មួយ ទី បានទៅលេង ញ៉ ដែលទើបឡើងមកជំនួសកន្លែង អឿន ហើយបានជួប ណាត នៅទីនោះដែរ ។ ទី ក៏បានពិភាក្សាជាមួយ ណាត អំពីការសម្រិតសម្រាំងសមាសភាពសេ.អ៊ី.អា. ពីព្រោះចាប់តាំងពីបែកការណ៍រហូតនាំឲ្យមានការចាប់ខ្លួនអឿន ការកសាងកម្មាភិបាលនៅក្នុងភ័ស្តុភារឲ្យទៅជាកម្លាំងសេ.អ៊ី.អា.មានសភាពគាំងគាំងជាខ្លាំង ។

ក្នុងខែ១១ឆ្នាំ១៩៧៦ ខៀវ ត្រូវចេញទៅសមរភូមិប្រយុទ្ធជាមួយវៀតណាមនៅខេត្តស្វាយរៀង ។ មុនពេលចេញទៅ ខៀវ បានហៅ ទី មកណែនាំរំឭកអំពីភារកិច្ចនិងខ្លឹមសារមួយចំនួនដែលត្រូវធ្វើ ។ ខៀវ រំឭកដដែលថាសម្ភារសឹក (ពិសេសគ្រាប់ និងកាំភ្លើង) មិនត្រូវអនុញ្ញាតឲ្យដឹកចេញដោយគ្មានការអនុញ្ញាតទេ ទាល់តែមានការសម្រេចពីខ្លួនទើបអាចដឹកចេញបាន ហើយក្នុងករណីខ្លួនគាត់មិននៅ គឺអង្គការ ឬ វន ជាអ្នកសម្រេច ។ ក្រៅពីនេះ ទី អាចទាក់ទងជាមួយ វ៉ែន និង រឿង បើសិនមានការចាំបាច់ ។

ក្រោយពេល ខៀវ ទៅបាត់ វន បានទូរស័ព្ទឲ្យ ទី ទៅជួបនៅមន្ទីរសេដ្ឋកិច្ច ដើម្បីសួរនាំអំពីការចំណាយគ្រាប់រំសេវនិងអំពីទំនាក់ទំនងរវាង ទី និង ខៀវ ។ វន ប្រាប់ ទី ថាអ្វីដែល ខៀវ និយាយគ្រាន់តែជាការបន្លែងជានប៉ុណ្ណោះ ដូច្នេះកុំព្រួយបារម្ភពេក ។

## ផែនការវាយបក្សនៅរដូវប្រាំងឆ្នាំ១៩៧៨

នៅប្រហែលខែ២ឆ្នាំ១៩៧៨ ទី បានទៅរាយការណ៍ជូន ខៀវ នៅកំពង់ត្របែក ។ ពេលរាយការណ៍ចប់ ទី បានឃើញ ណាត និង ពីន ទៅជួប ខៀវ នៅទីនោះដែរ ទាំងអស់គ្នាបានហូបបាយល្ងាចជាមួយគ្នា ។ មុនពេលចាកចេញពីកំពង់ត្របែក ទី បានទៅពិនិត្យមើលសមរភូមិជាមួយ ណាត បន្ទាប់មកអ្នកទាំងពីរធ្វើដំណើរទៅក្រុងកំពង់សោមពិនិត្យមើលកប៉ាល់ដែលទើបមកដល់ ។

នៅពាក់កណ្តាលខែ៦ឆ្នាំ១៩៧៨ វន បានប្រាប់ ទី អំពីផែនការចូលរួមធ្វើរដ្ឋប្រហារធំមួយនៅរដូវប្រាំងខាងមុខ ។ វន បានប្រគល់បណ្ណបញ្ចេញគ្រាប់គ្រប់ធុនឲ្យ ទី ដើម្បីរៀបចំគ្រាប់សម្រាប់ផ្តល់ឲ្យ ខៀវ រៀបចំផែនការវាយបក្ស ។ បណ្ណនោះមានបោះត្រាគណៈកម្មាធិការ៨៧០ និងមានហត្ថលេខារបស់ វន ។ នៅក្នុងបណ្ណនោះមានបញ្ជាក់បីចំណុចគឺ ១) ការទុកដាក់និងរៀបចំអាវុធនិងគ្រាប់រំសេវ ២) ការរៀបចំនិងត្រៀមលក្ខណៈមធ្យោបាយដឹកជញ្ជូន ៣) ការត្រៀមកម្លាំងសម្រាប់ប្រើប្រាស់ ។

ទី បានបើកកិច្ចប្រជុំពិភាក្សាជាមួយ ម៉ូត, ធឹម, និង ដុន លើបួនចំណុច ១) ស្នើរៀបចំគ្រាប់តាមប្រភេទ តាមឃ្លាំងមួយៗឲ្យច្បាស់លាស់ ២) រៀបចំកាំភ្លើងគ្រប់ធុនតាមប្រភេទ ៣) រៀបចំមធ្យោ

បាយដឹកជញ្ជូនទាំងខាងជើងទឹកនិងជើងគោក និង៤) រៀបចំកម្លាំងសម្រាប់ប្រើប្រាស់ពេលចេញចូល ។ ដើម្បីគ្រប់គ្រងផ្នែកនីមួយៗឲ្យច្បាស់លាស់ អង្គប្រជុំបានចែកមុខសញ្ញាដូចតទៅ ៈ ទី ជាអ្នករៀបចំកម្លាំងនៅចម្ការដូង, ម៉ុត ទៅរៀបចំខាងឡាន និង ប្រេង, ធឹម ត្រួតពិនិត្យឃ្លាំងគ្រាប់រំសេវ, និង ផុន រៀបចំកម្លាំងតាមក្រុម ។

ថ្ងៃទី២៩ ខែ៦ឆ្នាំ១៩៧៨ នួន ជា ហៅ បងទី២ បានចាត់តាំង ទី ឲ្យចេញពីភស្តុការសេនាធិការមកធ្វើការនៅក្រសួងការបរទេសជាមួយ វ៉ាន់ (អៀង សារី) ។

នៅថ្ងៃ១២ខែ៩ឆ្នាំ១៩៧៨ ទី ធ្វើដំណើរទៅចូលរួមប្រជុំមហាសន្និបាតនៅទីក្រុងញូវយ៉កជាមួយគណៈប្រតិភូដែលដឹកនាំដោយ វ៉ាន់ ហើយបន្តដំណើរទៅទស្សនកិច្ចនៅប្រទេសហ្វីលីពីន និងប្រទេសឥណ្ឌូនេស៊ី នៅថ្ងៃទី១៦ ខែ១០ ។

## ផែនការធ្វើឃាតមេដឹកនាំធំៗ និងភ្ញៀវរបស់បក្ស

នៅខែ១១ឆ្នាំ១៩៧៨ នៅពេលត្រឡប់មកដល់កម្ពុជាវិញ ទី បានទៅជួប នី កន ដែលជាប្អូនប្រុសរបស់ខៀវ នៅក្រសួងការបរទេស ។ កន បាននិយាយពីផែនការដែល ខៀវ ដាក់ឲ្យធ្វើ មាន ១) សម្លាប់បងទី១ ដោយប្រើថ្នាំបំពុល ២) សម្លាប់បង វ៉ាន់ ដោយលបបាញ់ ៣) សម្លាប់គណៈប្រតិភូចិន តឹង យុងគុយ ដោយប្រើថ្នាំបំពុលនិងបាញ់ ៤) សុំជំនួយពីស្ថានទូតឡាវក្នុងការទាក់ទងជាមួយវៀតណាម ។

នារីអាត ប្រពន្ធរបស់ ខៀវ ទទួលការចាត់តាំងឲ្យដាក់ថ្នាំបំពុលក្នុងម្ហូបអាហាររបស់បងទី១ ក៏ប៉ុន្តែផែនការនេះមិនបានសម្រេចទេ ព្រោះម្ហូបអាហាររបស់បងទី១ចម្អិនដោយកងការពារ ហើយមិនមានអ្នកណាអាចទៅក្បែរបានទេ ។ ផែនការលបបាញ់ វ៉ាន់ ក៏មិនបានសម្រេច ពីព្រោះ វ៉ាន់ ធ្វើដំណើរទៅណាមកណាមិនឲ្យដំណឹងជាមុនទេ ។

ផែនការសម្លាប់គណៈប្រតិភូចិនឈ្មោះ តឹង យុងគុយ ក៏មិនបានសម្រេចដែរ ព្រោះមានការយាមកាមតឹងរ៉ឹង ។

## ការចាប់ខ្លួននិងចម្លើយសារភាព

ទី ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១០ ខែ១២ឆ្នាំ១៩៧៨ក្នុងអាយុ៤០ឆ្នាំ រួចបញ្ជូនទៅមន្ទីរអប់រំដើម្បីសួរចម្លើយ ។

ចម្លើយសារភាពរបស់ទីជាឯកសារវាយអង្គុលីលេខ ចុះកាលបរិច្ឆេទថ្ងៃទី១៤ខែ១២ ឆ្នាំ១៩៧៨ ថ្ងៃទី២៤និង២៥ ខែ១២ ឆ្នាំ១៩៧៨ ។ នៅជាប់នឹងឯកសារវាយអង្គុលីលេខមានក្រដាសមួយសន្លឹកដែល ស៊ិន ទី សរសេរដោយដៃមានន័យអង្វរករបក្សឲ្យអនុគ្រោះដល់ខ្លួន ដែលមានខ្លឹមសារថា ÷

*គោរពជូនបងលេខា (តាមរយៈសមមិត្តឌុច ជាមិត្ត)*

*សូមគោរពបក្ស ជាទីគោរពលើសជីវិត*

*សូមគោរពសមមិត្ត-មិត្ត*

*ខ្ញុំខុសហើយ ខ្ញុំអត់ក្បត់បក្សទេ មុនខ្ញុំមិនឆ្លើយ ក្រោយត្រូវដំបងធ្ងន់ខ្ញុំឆ្លើយប្រឌិតទេ ។*

*សូមបូជាជីវិតជូនបក្ស-សូមបក្សកុំចាប់ឈ្មោះដែលខ្ញុំរាយការណ៍ខុសហើយ-មិត្តយើងគេល្អទេ ។ ខ្ញុំអត់សេ.អ៊ី.អា. ឬខ្មែរសេរីទេ ខ្ញុំសូមសម្រេចចុងក្រោយបង្អស់ដែលខ្ញុំត្រូវស្លាប់-សូមបក្សនិងសមមិត្ត អនុគ្រោះដល់អាយុជីវិត ។ ខ្ញុំជាជនកុម្មុយនីស្ត-សូមបូជាជីវិតជូនបក្ស (ដោយអាវន-អាខេត្ត-អាគង់សុផល្លី ឆ្លើយដាក់ខ្ញុំថាខ្ញុំ សេ.អ៊ី.អា-ខ្មែរសេរី) ។ ខ្ញុំអត់មានចូលជាមួយវាទេ ។ ភ្នំពេញថ្ងៃ ១៥/១២/៧៨*

*ស៊ិន ទី (ហៅទាញ)*

*ប្រពន្ធខ្ញុំ ប្រពន្ធសមមិត្តណាត អត់ដឹងអីទេបង! ។*

*ជយោ បក្សកម្ពុជាដ៏រុងរឿង-មហាអស្ចារ្យ!*

*ជយោ បដិវត្តន៍កម្ពុជាដ៏មហិមា-មហាអស្ចារ្យ!*

*ជយោ ប្រជាជនកម្ពុជាដ៏ខ្លាំងក្លា-មហាអស្ចារ្យ!*

*ប្រជាជន កងទ័ពបដិវត្តន៍កម្ពុជា ដ៏ខ្លាំងពូកែមហាអស្ចារ្យ!*

*មតិនេះជាខ្លឹមសារ បងវ៉ាន់ បានអប់រំនៅមន្ទីក្រសួងការបរទេស ស្នើសុំសមមិត្តកុំហែកចោល ។ នេះជាសំឡេងចុងក្រោយបំផុតរបស់ខ្ញុំ ។ ១៥/១២/៧៨*

យោងតាមឯកសារប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ប្រពន្ធរបស់ ទី ឈ្មោះ ជា សំអាត ហៅ ផល ក៏ត្រូវអង្គការចាប់ខ្លួនដែរ ដោយឡែកពុំមានព័ត៌មានអំពីកូនប្រុសម្នាក់និងកូនស្រីពីរនាក់របស់អ្នកទាំងពីរទេ ។

យោងតាមបញ្ជីកម្ទេចអ្នកទោសនៅគុកទួលស្លែងដែលចងក្រងដោយសារមន្ទីរទួលស្លែង ស៊ិន ទី ត្រូវកម្ទេចនៅថ្ងៃទី៣១ ខែ១២ ឆ្នាំ១៩៧៨ ។

**ណាយ សុផារី**

# ឃាតកម្មនៅភូមិក្បាលហុងចាស់

មានភូមិមួយឈ្មោះ "ភូមិក្បាលហុងចាស់" គឺជាភូមិមួយដែលមានទំហំតូចល្មម ហើយប្រហែលជាកកើតនៅក្នុងអំឡុងឆ្នាំ១៩៧០ ជំនាន់របបបនក្បត់ប៉ុលពត និងមានចម្ងាយប្រហែល ២៨០០ម៉ែត្រ ពីមន្ទីរមួយស្រុកចម្ការលើ ។ កាលណោះភូមិក្បាលហុងចាស់ក៏ទទួលវាសនាអាក្រក់មិនខុសពីស្រុកខ្មែរទាំងមូលដែរ ពិសេសគឺក្លាយជាជំរំពិឃាតមនុស្សមួយសាហាវគួរឲ្យព្រឺខ្លាច ។

ក្រោយថ្ងៃមហាជ័យជម្នះលើពួកចក្រពត្តិអាមេរិក ១៧ មេសា ឆ្នាំ១៩៧៥ ពួកក្អែកខ្មៅប៉ុលពតបានជម្លៀសប្រជាជនថ្មីចំនួន៥គ្រួសារឲ្យមករស់នៅភូមិក្បាលហុងចាស់ឃុំល្វាលើ ស្រុកចម្ការលើ ខេត្តកំពង់ចាម ។

កាលណោះខ្ញុំមានអាយុប្រមាណ៧ឆ្នាំហើយ ប៉ុន្តែខ្ញុំចាំរឿងមួយដែលជារឿងឃាតកម្មគួរឲ្យឈឺចាប់ខ្លោចផ្សា ។ នៅរសៀលថ្ងៃមួយប្រហែលជាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៨ មានរឿងមួយកើតឡើងដែលសង្គមមនុស្សមិនដែលជួបប្រទះទាល់តែសោះ ។ ម៉ោងប្រហែល៤ល្ងាច ពួកឃាតករមួយក្រុមបានប្រជុំគ្នាពិភាក្សាពីការសម្លាប់មនុស្សដែលអ្នកទាំងនោះមានឈ្មោះដូចខាងក្រោម ÷

ប្រធានភូមិឈ្មោះ ទឹង (សព្វថ្ងៃនៅក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម)

អនុប្រធានឈ្មោះ យ៉េន (មិនដឹងនៅទីណា)

ប្រធានកងឈ្មោះ ភួង, អុន (ស្លាប់ឆ្នាំ១៩៧៩) ចន និង អឿន រស់នៅភូមិក្បាលហុងដដែល ។

ប្រធានកងឈ្លបឈ្មោះ អៀង, ឡាន, មួន និងសន ។

ក្រោយពីប្រជុំប្រហែល៣០នាទី ពួកវាក៏ជ្រើសរើសយកបីគ្រួសារដោយចោទថាជាខ្មាំងចូល សេ.អ៊ី.អា គ្រួសារអភ័ព្វទាំងនោះមានដូចតទៅ ÷

◆ គ្រួសារលោកពូ ហាង និង មីងរី ព្រមទាំងកូនឈ្មោះ គាល់, ស្រីតា, ទី, ស្រីនាង និងប្អូនតូចៗ២ នាក់ទៀតដែលខ្ញុំមិនចាំឈ្មោះ ។

◆ គ្រួសារលោកតា ម៉េង (ហៅតាចិន មិនចាំឈ្មោះប្រពន្ធនិងកូនគាត់) ស្គាល់តែកូនប្រុសពៅគាត់ម្នាក់ឈ្មោះ កាយ ។

◆ គ្រួសារតាលន់ ហៅតាបឹង និងប្រពន្ធឈ្មោះយាយ សែត ព្រមទាំងកូនប្រុសឈ្មោះ រ៉េត, បុល, ថោម, ស្រីភាព,ស្រីប៉ាក់ កូនប្រុសឈ្មោះ វ៉ាន់ ហើយចៅស្រីឈ្មោះ ចិន្តា ។ ថ្ងៃនោះពេលខ្ញុំកំពុងអង្គុយលេងល្បែងកូនក្មេងធ្វើគោដីនៅលើផ្ទះ ពូហាងជាមួយកូនប្រុសគាត់ គឺ អាគាល់ និង ធាទី ស្រាប់តែមានសំឡេងស្រែកហៅពីក្រោមផ្ទះច្បាស់ៗថា "អ៊ើ! ហាង ហ្អា!ៗ ប្រធានភូមិហៅ" ។ ពេលនោះ ពូហាង បានចុះទៅរកពួកវាដោយទឹកមុខភ័យព្រួយជាខ្លាំង ។ គួរឲ្យរន្ធត់ចិត្តណាស់ នៅខាងមុខផ្ទះមានរទេះពីរគ្រឿងកំពុងឈប់ដោយមានពួកវាជិះពីលើ និងប្រដាប់ដោយកាំបិតស្នាចនិងដំបងគល់ឫស្សី ចប បង្គី ភ្ជាប់រទេះ ទុកជាស្រេច ជនមាឧល្លិតសម្បុរខ្មៅសក់រួញឈ្មោះ ទឹង ជាប្រធានភូមិនោះពោលឡើងថា "ថ្ងៃនេះអង្គការថ្នាក់លើបានឲ្យពួកមិត្តទៅប្រជុំបែងចែកដីថ្មី!" ដូចនេះសូមស្នើសមមិត្តរៀបចំខ្លួនដើម្បីទទួលផែនការថ្មីរបស់បក្ស! ។ ពោលចប់ ពួកវាបានសើចក្អាកក្អាយ ។ ពូហាង គាត់មានអារម្មណ៍ដឹងច្បាស់ថានេះជាផែនការសម្លាប់មនុស្ស ព្រោះគាត់ជាអ្នកមានឋានៈខ្ពង់ខ្ពស់ ពិសេសទំនងជាអ្នកទស្សនវិជ្ជាផងក៏មិនដឹង ពេលនោះគាត់តមាត់ទៅពួកវាថា តើពួកមិត្តបង ចង់ឲ្យពួកខ្ញុំទៅរស់នៅឯណាវិញ? កាលណោះគាត់និយាយជាមួយពួកវាច្រើន តែខ្ញុំស្តាប់មិនបាន ព្រោះកាលណោះខ្ញុំមិនដឹងថា អ្វីជាអង្គការនៅឡើយទេ តែនៅចាំពាក្យមួយឃ្លាទៀតថា "នេះជាលើកទី២ ហើយដែលគ្រួសារខ្ញុំជួបប្រទះសេចក្តីស្លាប់ សូមមិត្តបងអាណិតគ្រួសារខ្ញុំផងទៅ ។ ប្រធានភូមិនិយាយថា មិនបានទេនេះជាបញ្ជារបស់ថ្នាក់លើ ត្រូវតែធ្វើតាមកុំប្រឆាំង ។ ពួកវាបង្ខំឲ្យគ្រួសារនេះជិះរទេះគោ ចំណែក អាគាល់ អាទីប្រហែលជាវាដឹងរឿងថាគេសម្លាប់ហើយមើលទៅបានជាវារត់គេចទៅពួនសម្ងំក្នុងបង្កន់របស់ ពូជើន នៅខាងក្រោយផ្ទះវា តែអកុសលណាស់ពួកវាតាមរកឃើញហើយចាប់យកទៅទាំងអស់ ។

រទេះគោពីរគ្រឿងក៏ចេញដំណើរទៅទិសខាងលិច កាត់គ្រាប់ភ្លៀងរលឹមតក់ៗគួរឲ្យស្រណោះរកពាក្យអ្វីនិយាយដឹមពុំបានឡើយ ។ ជាហូរហែពួកវាបានចូលចាប់ពីរគ្រួសារទៀត គឺគ្រួសារតាលន់ និងគ្រួសារ តាម៉េង ហើយក៏នាំយកទៅកន្លែងដំរំពិឃាតមនុស្សមួយឈ្មោះ ចម្កា ដែរ ដែលនៅជាប់នឹងផ្លូវលំមួយពីថ្នល់បំបែកទៅឃុំល្ហាលើ ហើយនៅមាត់ "ហុងទឹកមួយ" ដែលសម្បូរព្រៃបន្ទូរដែរ ដំរំពិឃាតនេះមានចម្ងាយប្រហែល៣០គីឡូម៉ែត្រ ឬ៤០គីឡូម៉ែត្រពីផ្លូវលំនេះ ហើយមានចម្ងាយប្រហែល២៥០០ម៉ែត្រពីទីរួមស្រុកចម្ការលើ ។

ពេលទៅដល់កន្លែងពិឃាតភ្លាម ប្រហែលជាវាចាប់ផ្តើម ឬក៏មិនទាន់សម្លាប់ភ្លាមទេក៏មិនដឹង? ព្រោះពេលដែលពួកវាបរទេះចេញនោះ ខ្ញុំក៏ត្រូវម្តាយខ្ញុំហៅទៅផ្ទះវិញដែរ ព្រោះម៉ោងប្រហែល៥ៈ៣០នាទីល្ងាច ។ គ្រប់សកម្មភាពទាំងអស់របស់ពួកវាខ្ញុំក៏លែងបានដឹងទៀតដែរ តែតាមខ្ញុំដឹងខ្លះៗថាពេលទៅដល់កន្លែងភ្លាម ពួកវាតែងតែចងជនរងគ្រោះហើយ បំបែកប្រុសម្នាងស្រីម្នាង ហើយពួកវាក៏នាំគ្នាផឹកស្រាទាល់តែស្រវឹង ។

សុរិយាអស្តង្គតរលត់រស្មីចោលភពផែនដីដ៏កម្សត់នេះឲ្យទទួលរងនូវភពខ្មៅងងឹតមួយ គ្របដណ្តប់ដោយស្បៃអន្ធការខ្ទះរស្មី ។ រាត្រីនេះធាតុអាកាសត្រជាក់ វាយោបក់រំៗប៉ះស្លឹករុក្ខជាតិទាំងឡាយលាយឡំនឹងសម្រែកសត្វ ខ្លែងស្រាកលាន់រំពងព្រៃ ហែកស្បៃរាត្រីឲ្យស្រងេះស្រងោចទឹកដីនៃមាតុភូមិខ្មែរក្រៃលែង ។

នៅខាងកើតកន្លែងពិឃាតមនុស្សនេះ គេអាចឮសូរសំឡេងទឹកហូរឈូឆរ និងផ្គាំងថ្មដាដែលដុះលូតពីក្រោមផ្ទៃទឹកហូរទង្គិចនិងផ្គាំងថ្មដាទាំងនោះប្រៀបដូចជាសំឡេងរបស់បងប្អូនអ្នកស្លូតត្រង់ខ្មែរយើងដែលស្រែកថ្ងូរយ៉ាងគ្រលួច ក្រោមអន្ទង់ដ៏សាហាវរបស់បនស្រេកឈាមប៉ុលពត មុនពេលអវសាននៃជីវិត ។

នៅលើអាកាស ពពកពណ៌ខ្មៅងងឹតៗរសាត់កាត់ផ្ទៃមេឃគ្មានបន្ទន់ផ្គរបន្ទោរផ្គរៗផ្គរចាប់គ្រហឹម លាន់ឮសូរដូចជាស្នូរស្រែកយំយ៉ាងអឺងកងរបស់ជនរងគ្រោះ ។ ស្រមោលខ្មៅងងឹតពេញមេឃជាសញ្ញាសម្គាល់ថាមេឃជិតភ្លៀងហើយ ផ្គរបន្ទោរចាំងភ្លឹត ឃើញស្រមោលមនុស្សម្នាក់មាឌធំមាំសម្បុរសណ្តែកបាយ សក់រួញអង្កាដីកំពុងតែលូនគើមៗសំដៅទៅក្នុងហុងទឹកដែលមានព្រៃទ្រុបទ្រុលទាំងជាប់ចំណង ។ ខ្លួនប្រាណជិតដាមដោយស្នាមឈាមហូររហាមសល់តែខោខ្លីមួយប៉ុណ្ណោះជាប់នឹងខ្លួនក្រៅពីចំណងខ្សែជក់ត្នោតមួយខ្សែ ។ គាត់បានលូនចម្ងាយ២០០ម៉ែត្រ ពីកន្លែងសម្លាប់មនុស្សដោយផ្ទុះសំឡេងតិចៗ នឹកស្រណោះដល់ជីវិតឪពុកម្តាយ បងប្អូន កូន ប្រពន្ធ ដែលស្លាប់មុននេះបន្តិច ។



ដោយអត់ទ្រាំនឹងរងានិងមុខរបួសផងជនរងគ្រោះក៏ដួលសន្លប់បាត់ស្មារតីក្រោមដើមចំបក់មួយធំគួរឲ្យអនិច្ចាពន់ប្រមាណ ។ ពេញមួយយប់ជនរងគ្រោះ ត្រូវដេកហាលភ្លៀងហាលខ្យល់ និងជាពិសេស ក្រោមឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងនៃរបបកម្ពុជាប្រជាធិបតេយ្យរបស់បនក្បត់ ប៉ុលពត, អៀង សារី ។

លុះដល់ពេលស្អែកឡើងពេលព្រឹកព្រលឹមស្រាងៗ ព្រះសុរិយាអើតលឹមៗប៉ប្រះមាត់ព្រៃទិសបូព៌ា ដោយបាចសាចនូវកម្ទេចរស្មីពណ៌មាស ក្រហមឆ្អិនឆ្អៅមកលើផែនពសុធាដ៏កណ្តោចកណ្តែងចាំងតាមចន្លោះស្លឹករុក្ខជាតិឲ្យទទួលអារម្មណ៍ក្តៅខណ្ឌៗឡើងវិញក្រោមមហិទ្ធិរិទ្ធិនៃព្រះភិរុណកាលពីរាត្រីកន្លងទៅ ។ ព្រះសុរិយារះផុតចុងព្រឹក្សព្រៃ បក្សាបក្សីខ្សៀវខ្សារចេញពីទ្រនំរៀងៗខ្លួនដោយគ្មានព្រួយបារម្ភពីការជួបសត្វសាហាវអ្វីឡើយ ។ ក្រោមដើមចំបក់ដ៏ធំមួយដើមដែលបែកមែកសាខាត្រឈឹងត្រឈៃគួរជាទីស្នាក់អាស្រ័យនៃពួកបក្សាបក្សី មានផ្ទាំងសីលាមួយដុំធំ ហើយខាងក្រោមផ្ទាំងសិលានោះ មានទឹកហូរប្រដេញគ្នា ។

ឱ!ជីវិតសត្វលោកកើតមកអឺក៏អភ័ព្វម្ល៉េះ?

មើលចុះ គេដេកស្តូកស្តឹងស្ទើរតែក្លាយទៅជាសាកសពទៅហើយ ដោយសារតែទម្ងន់នៃត្បូងចបនិងគល់ឫស្សី ។ ឈាមក្រហមឆ្អៅប្រឡាក់ផ្ទាំងថ្ម ខោខ្មៅរហែករយ៉ៃ ដៃជាប់ចំណង សក់ក្បាលកន្ទ្រើងកន្ទ្រើងមើលស្ទើរតែពុំស្គាល់ច្បាស់ថាជាអ្នកណា ។ កាលនោះមានអ៊ំម្នាក់ឈ្មោះ ណុង ប្រហែលអាយុ៥០ឆ្នាំ គាត់ជាប្រជាជនចាស់ (អ្នកមូលដ្ឋាន) ដោយគាត់មានផ្ទះនៅជាប់នឹងមាត់ហុង និងមានមុខងាររខាងចាំចម្ការអំពៅនៅមាត់ហុងនោះស្រាប់ គាត់ក៏បានចុះទៅក្នុងហុង ដៃកាន់កាំបិតមួយដើម្បីរកឃ្មុំឲ្យប្រពន្ធគាត់កូនខ្ចី បើតាមសម្តីរបស់គាត់និយាយថា នៅដើមចំបក់នោះមានឃ្មុំមួយដែលគាត់បានសម្ងំទុកប្រហែល១៥ថ្ងៃមកហើយ ។ គាត់បានបន្តទៀតថា ÷ ពេលកំពុងរំពៃរកឃ្មុំកន្លែងផ្សេង និងស្តាប់មាន់ព្រៃងាវផងស្រាប់តែគាត់ភ្ញាក់ក្រញាង ដោយស្រែក យ៉ាងរន្ធត់ថា ÷ យី រ៉េតៗ កើតអីហ្នឹង (សម្តីរបស់តាណុង) ?

ជនរងគ្រោះនៅតែដេកស្តូកស្តឹងដោយគ្មានតបវាចាមកវិញបន្តិចសោះតាណុងគាត់ក៏ប្រញាប់ប្រញាល់កាត់ចំណងចេញ ហើយខំផ្សំថ្នាំបុរាណក្នុងព្រៃនោះដើម្បីបិទរបួសឲ្យបានដឹងខ្លួនឡើងវិញពេលនោះទៅ ។ ពេលទទួលអារម្មណ៍នឹងន៎បន្តិច គាត់ក៏ខំប្រវេប្រវាងើបឡើងទាំងអារម្មណ៍រវើរវាយខុសប្រក្រតី ។

ប្រហែលមួយម៉ោង ក្រោយមក ពូរ៉េត ក៏បានធូរជាងមុន ដោយជាតិថ្នាំជ្រាបចូលសព្វសារពាង្គកាយ ហើយគាត់ក៏រៀបរាប់នូវដំណើររឿងដូតទៅ ÷ ពេលពួកវាដឹកគ្រួសារ ខ្ញុំមកដល់ចម្ការទៀប ប្រហែលម៉ោង៥គត់ ពេលនោះពួកវាបានបំបែកមនុស្សជា២ក្រុម ម្ខាងប្រុស ម្ខាងស្រី ហើយពួកវានាំគ្នាអង្គុយជឹកស្រាទាល់តែស្រវឹង ។ ពេលដែលពួកវាក្រោកឈរឡើងម្នាក់ៗសុទ្ធតែមានកាន់ជាប់នូវកាំបិត គល់ឫស្សី ត្បូងចបប្រកបដោយអាកប្បកិរិយាកាចសាហាវ ដូចជាសត្វខ្លាអត់ចំណីអ៊ីចឹង ។ ទាំងខ្ញុំ និងគ្រួសារបងប្អូនទាំងអស់ ម្នាក់ៗភិតភ័យតក្កមាដោយអស់សង្ឃឹមក្នុងឆាកជីវិតខ្លាំងពេក ព្រោះជីវិតគ្រួសារខ្ញុំគ្មានតម្លៃស្មើនឹងសត្វមាន់ទាឡើយ ។ អាគីមឡូន ក្រោកឈរឡើងដោយកាន់កាំបិតផ្គាក់មួយសស្វាចទំនងជាកោរសក់បានផងមើលទៅ? វាដើរសំដៅក្រុមនារី ហើយចាប់ទាញស្រីភាពប្អូនស្រីខ្ញុំឲ្យក្រោកឈរឡើងទាំងដៃជាបចំណង ហើយស្រែកឡើងថា "ម៉េចមិត្តបងកូនអ្នកភ្នំពេញស្អាតៗខ្លាំងណាស់ បើសិនជាវាងាប់ទៅដោយយើងមិនគិតគូរទេ ហាក់ដូចជាស្តាយណាស់ ហាស់!!" អាហ៊ាង ប្រធានកងឈ្លបសើចហើយនិយាយ "មិត្តឡូន ឯងនិយាយត្រូវ" ។ ពេលត្រឡប់ទៅវិញ អង្គការនឹងតែងតាំងមិត្តឲ្យឡើងជាកូនអង្គការពិតប្រាកដហើយៗមិត្តនឹងបានដើរតាមអង្គការមហាលោតផ្លោះមហាអស្ចារ្យមិនខាន ។

ខ្ញុំសែនខ្លោចផ្សាណាស់ពេលឃើញរណ្តៅជម្រៅប្រហែល ១,៥ម ចំនួន៣រណ្តៅនៅមិនឆ្ងាយពីគ្នានៅទីនោះ ហើយពិសេសទៅទៀត គឺពេលដែលឃើញប្អូនស្រីក្រមុំរបស់ខ្ញុំទាំងពីរ និងក្មួយស្រីម្នាក់ទៀតត្រូវពួកវាចាប់រំលោភធ្វើបាបយ៉ាងព្រៃផ្សៃនៅចំពោះមុខមុនពេលពួកវាសម្លាប់ចោល ។ ជងឹស្រីតរបស់ម្តាយខ្ញុំរើឡើងវិញ គាត់សន្លប់បាត់ស្មារតី ហើយពួកវាបានអូសម្តាយខ្ញុំទម្លាក់ក្នុងរណ្តៅរួចស្រែកថា អាអ្នកភ្នំពេញពូកែធ្វើពុតមែន ពេលនោះខ្ញុំទ្រាំលែងបានប្រុងស្ទុះក្រោកឡើង តែចំណងដៃខ្ញុំជាប់នឹងបងប្រុសខ្ញុំតឹងពេក ។ ពួកវាចាប់ផ្តើមសម្លាប់ប្អូនស្រីខ្ញុំនិងកូនក្មួយរបស់ខ្ញុំបន្តបន្ទាប់ រហូតដល់ បងរី ប្រពន្ធរបស់ បងហាង ពេលនោះ បងហាង ស្ទុះក្រោកឡើងទាត់អាគីម ឡែន មួយជើងយ៉ាងខ្លាំងរហូតដល់សន្លប់ ហើយគាត់ស្រែកដេរខ្លាំងថា "អាឃាតករវង្វេងជាតិសម្លាប់ខ្មែរស្លូតត្រង់ដែលគ្មានកំហុសដោយគ្មានពិចារណា! ពួកហ្អែងក៏មិនអាចរស់បានស្ថិតស្ថេរដែរ គង់មានថ្ងៃណាមួយគេ

សម្លាប់ហ្អែងជំនួសអញវិញមិនខាន" ។

អាហ៊ាងឃើញស្ថានភាពដូចនេះវាក៏យារកាំបិតមួយទំហឹងដៃកាប់ពុស្វូរខ្នាប់មកលើ បងហាង តែបងហាង គាត់គេចភ្លែតហើយទាត់វិលពីរជើងវិញចំកណ្តាលដើមទ្រូងដួលផ្ងារក្រោយ ពេលនោះ អាយ៉េន បានលួចកាប់គាត់ពីក្រោយមួយកាំបិតស្ទើរដាច់ជាពីរកំណាត់ ។ ឈាមហូរក្រហមច្រាលពេញដីចោលក្លិនឆ្អាប គួរឲ្យរន្ធត់ខ្លោចផ្សាក្រៃលែង ។ ក្នុងថ្លុកឈាមដ៏សែនទារុណនេះ ពួកវាសើចសប្បាយក្អាកក្អាយដោយឃើញ បងហាង ប្រកាច់វក់វីក្នុងថ្លុកឈាម ។ ភ្លាមនោះ អាទី និង អាតាល់ កូនគាត់ប្រុងរត់ តែពេលវាក្រោកឡើងបានបន្តិចក៏ដួលប្រុសទៅវិញដោយសារគល់ឫស្សីនិងត្បូងចបដ៏ធំរបស់ អាយ៉េន និង អាអុន សំពងពេញទំហឹងដៃ រួចអូសទម្លាក់រណ្តៅទៅ ។ ពេលនេះដល់វេនខ្ញុំនិងបងប្រុសខ្ញុំ ម្តងនេះវារាងញញើតដៃជាងមុន វាកាប់រឹបៗពីរកាំបិតចំបួនខ្ញុំនិងបងខ្ញុំដោយបាញ់ឈាមប្រឡាក់ខ្ញុំដោកហើយវាអូសទម្លាក់ក្នុងរណ្តៅ ចំណែកខ្ញុំត្រូវវាវាយចំនួនប្រាំគល់ឫស្សី ហើយទុកចោលនៅមាត់រណ្តៅនោះ ។ ពេលដែលខ្ញុំដឹងខ្លួនឡើងវិញ ខ្ញុំបានបើកភ្នែកមើលទិដ្ឋភាពជុំវិញ គ្មានឃើញអ្វីក្រៅពីសភាពខ្មោចងងឹតនិងក្លិនស្អុយយ៉ាងអសោចនៃសពគ្រួសារញាតិសន្តានរបស់ខ្ញុំ ហើយខ្ញុំបានគិតថា ៖ ទីកន្លែងនេះជាឋានរកសម្រាប់ខ្ញុំ ដូចនេះខ្ញុំត្រូវតែចេញពីទីនេះ ហើយខ្ញុំគិតថាខ្ញុំហាក់ដូចជាមានសំណាង តែខ្ញុំក៏គ្មានសំណាងដែរព្រោះខ្ញុំបែកអស់ ម៉ែឪប្រពន្ធកូនបងប្អូន បើរស់នៅតទៅទៀត ក៏គ្មានន័យអ្វីដែរ ពេលនេះបើខ្ញុំស្លាប់ក៏លែងស្តាយ តែខ្ញុំចង់រស់ដើម្បីធ្វើការសងសឹកជូនព្រលឹងគ្រួសារខ្ញុំវិញ មុនពេលដែលជីវិតខ្ញុំរលត់ទៅហើយ បើស្រុកខ្មែរសន្តិភាពខ្ញុំនឹងសរសេរប្រវត្តិសោកនាដកម្មដ៏ជូរចត់របស់ភូមិក្បាលហុងនេះឲ្យបានច្រើនដើម្បីឲ្យកូនខ្មែរជំនាន់ក្រោយបានស្គាល់ស្នាដៃរបស់ប៉ុលពតក្នុងការដឹកនាំប្រទេសតាមបែបលទ្ធិម៉ៅនេះ ។

តែខ្ញុំបារម្ភខ្លាចក្រែងតែជីវិតខ្ញុំរលត់ទៅមុនពេលដែលខ្ញុំមិនទាន់បានសរសេរប្រវត្តិសាស្ត្រនេះ ។ តែខ្ញុំសូមផ្តាំតាផងថាទោះជាយ៉ាងណាក៏ដោយសូមកុំភ្លេចនិយាយប្រាប់ក្មេងៗជំនាន់ក្រោយឲ្យបានដឹងបានស្គាល់របបកម្ពុជាប្រជាធិបតេយ្យដ៏ឆ្កួតលេលានោះផង ។ បើតាអាចធ្វើតាមបណ្តាំនេះបាន នោះតា ប្រាកដជាវីរបុរសប្រកបដោយឧត្តមគតិខ្ពង់ខ្ពស់បំផុត ។

"ខ្ញុំសែនស្អប់ជាខ្លាំងនូវរបបផ្តាច់ការរបស់ពួកឃាតកររលត់ជាតិនេះ"!!

ក្រោយពីបានពិភាក្សាអស់រយៈពេលយ៉ាងយូររួចមក តាណុង ក៏បាននិយាយថា ណ្ហើយ!ថ្ងៃត្រង់ ហើយខ្ញុំគិតទៅភូមិវិញហើយ ហើយខ្ញុំនឹងធ្វើតាមបណ្តាំឯងជានិច្ចចាំបន្តិចទៀតខ្ញុំនឹងយកបាយមកឲ្យឯងណា ។

ពេលដែល តាណុង ត្រឡប់ពីយកបាយមកវិញ ស្រាប់តែឃើញពួកវាកំពុងតែប្រវាយប្រតប់ជាមួយ ពូរ៉េត តាណុង កាន់តែភ័យស្លន់ស្លោជាខ្លាំងហើយពួនសំងំក្នុងព្រៃក្បែរនោះចាំមើលទីបញ្ចប់ដោយអស់កម្លាំងផង ពូរ៉េត ក៏ត្រូវឃាតករឈ្មោះ សន កាប់មួយកាំបិតដួលស្លាប់ក្នុងថ្លុកឈាមមួយរំពេច ។

ក្រោយមរណភាពរបស់ ពូរ៉េត នេះ តាណុងចេះតែនឹកព្រួយបារម្ភជាខ្លាំងរហូតដល់ថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ទើបគាត់បានធូរស្បើយសុខសប្បាយលែងភ័យព្រួយ ។ លុះដល់ពេលនេះខ្ញុំបានសាកសួរមតិគាត់ផ្ទាល់ ដើម្បីយកមកចងក្រងរៀបរៀងទុកជាឯកសារសម្រាប់កូនខ្មែរជំនាន់ក្រោយសិក្សាស្រាវជ្រាវបន្តទៀត ។ គួរពិចារណាថា តើអ្នកស្លាប់ទាំងនោះមានកំហុសអីចុះក្មេងៗតូចទាំងនោះមានកំហុសអ្វីដែរ? អត្ថបទសរសេរនេះទោះបីជាមានការខុសលើឃ្លាប្រយោគក្តីក៏វាជាព្រឹត្តិការណ៍ពិតមួយរបស់ភូមិក្បាលហុងចាស់កាលក្នុងរបបប៉ុលពត ។ ព្រឹត្តិការណ៍ទាំងនេះជាការពិតព្រោះខ្ញុំបានសាកសួរចាស់ៗព្រឹទ្ធាចារ្យក្នុងភូមិដែលនៅចាំច្បាស់ជាងខ្ញុំ តែគ្រាន់តែគាត់បន្ថែមឃ្លាខ្លះដើម្បីឲ្យមានភាពរលូនតែប៉ុណ្ណោះ ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរដល់លោកគ្រូអ្នកគ្រូ អ៊ំៗ ព្រមទាំងបណ្តាប្រិយមិត្តអ្នកអាននិងអ្នកជួយផ្តល់យោបល់ទាំងអស់ សូមបានជួបប្រទះតែសេចក្តីសុខគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ ។

-អ្នកជួយផ្តល់មតិលោកអ៊ំ អ៊ុក ណុង និង អ៊ុន សាន (ភូមិក្បាលហុងចាស់)

-ហាង ស្រីតា កូនស្រីពូហាង សព្វថ្ងៃរស់នៅទីក្រុងភ្នំពេញ

-ម៉េង កាយ កូនតាម៉េង សព្វថ្ងៃរស់នៅទីក្រុងភ្នំពេញ

**ឯកសារលេខ D០០៦៧១, ប៉ាន សុភាព**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយ : យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៧១៧ | ឌឿប យី ហៅ ណាង | មេក្រុម | មន្ទីរ វ-៦៦ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៧១៨ | ពៅ ម៉េត ហៅ ពុំ | អនុក្រុម | មន្ទីរ វ-៦៦ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៧១៩ | ប្រឹង ឡាន់ ហៅ ខាន់ | មេពួក | មន្ទីរ វ-៦៦ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៧២០ | ជាស សាម៉ុន ហៅ សុគុន | យុទ្ធជន | មន្ទីរ វ-៦៦ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៧២១ | ស លាញ ហៅ វឿន | មេក្រុម | មន្ទីរ វ-៦៦ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៧២២ | ហង់ លាប ហៅ ចំរើន | យុទ្ធជន | ស-២១យ | ៤-៦-៧៧ | ១០-៦-៧៧ |
| ២៧២៣ | ហែន ម៉ន | ប្រធានកងតូច | ស-២១យ | ៤-៦-៧៧ | ១០-៦-៧៧ |
| ២៧២៤ | គឹម ម៉ុន | យុទ្ធជន | ស-២១យ | ៤-៦-៧៧ | ១០-៦-៧៧ |
| ២៧២៥ | ប៉ិល ភឿន | យុទ្ធជន | ស-២១យ | ៤-៦-៧៧ | ១០-៦-៧៧ |
| ២៧២៦ | សួន ថៃ | អនុកងតូច | ស-២១យ | ៤-៦-៧៧ | ១០-៦-៧៧ |
| ២៧២៧ | នៅ សេងលី ហៅ រ៉ាត់ (ស្រី) | មេក្រុមកាត់ដេរ | ស-២១យ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៧២៨ | នួន អឿន ហៅ នាង (ស្រី) | យុទ្ធនារីកាត់ដេរ | ស-២១យ | ៨-៦-៧៧ | ១០-៦-៧៧ |
| ២៧២៩ | សូ ធា ហៅ ថេន | យុទ្ធជន | កងពល៩២០ | ៣០-៤-៧៧ | ១០-៦-៧៧ |
| ២៧៣០ | ខឹម ខុល ហៅ ផា | យុទ្ធជន | កងពល៩២០ | ៣០-៤-៧៧ | ១០-៦-៧៧ |
| ២៧៣១ | ណែម ហៃ ហៅ ហុង | សេដ្ឋកិច្ច | កងពល៩២០ | ៣០-៤-៧៧ | ១០-៦-៧៧ |
| ២៧៣២ | ស៊ូ ណាន ហៅ យក់ | សេដ្ឋកិច្ច | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៧៣៣ | សួន អុល ហៅ គឹម | យុទ្ធជន | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៧៣៤ | ម៉ែន អ៊ិន | យុទ្ធជន | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៧៣៥ | អ៊ុក ខឿន ហៅ ដុង | ពេទ្យ | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៧៣៦ | គាំ កែម | យុទ្ធជន | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៧៣៧ | ប៊ូ រិន ហៅ ចិន | យុទ្ធជន | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៧៣៨ | ឃ្លោក ឃីង | យុទ្ធជន | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៧៣៩ | ញ៉ឹក ខៀវ ហៅ រុន | ស្ទូឆ្នាំ | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៧៤០ | សៅ ខេង ហៅ វ៉ន | ប្រធានមន្ទីរ | កងពល៩២០ | ១៧-៥-៧៧ | ១០-៦-៧៧ |
| ២៧៤១ | ចាន់ វ៉ាន់ | ប្រធានសំណង់ | កងពល៩២០ | ១៣-៣-៧៧ | ១០-៦-៧៧ |
| ២៧៤២ | គឹម ស | សមាជិកសិប្បកម្ម | កងពល៩២០ | ១៨-៤-៧៧ | ១០-៦-៧៧ |
| ២៧៤៣ | គឹម ឈាង ហៅ ដា | ប្រធានពេទ្យ | កងពល៩២០ | ?-៤-៧៧ | ១០-៦-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ៣៧៤៤ | ឈុន ហុង ហៅ ហ៊ាង | និរសារ | កងពល៩២០ | ៧-៤-៧៧ | ១០-៦-៧៧ |
| ៣៧៤៥ | ដឹម ចន ហៅ ជឿន | អនុក្រុម | កងពល៩២០ | ១៨-៤-៧៧ | ១០-៦-៧៧ |
| ៣៧៤៦ | ទេព សុធុន ហៅ រី | យុទ្ធជន | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៤៧ | ចាន់ យន ហៅ យត | យុទ្ធជន | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៤៨ | សុក កាន ហៅ សែន | ពេទ្យ | កងពល៩២០ | ១៨-៥-៧៧ | ១០-៦-៧៧ |
| ៣៧៤៩ | ដោក ដៃ ហៅ រឿន | ភ័ស្តុភារ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៥០ | ណយ ម៉ៃ | យោធាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៥១ | អ៊ុម សាលួត ហៅ រ៉េត | លេខាផកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៥២ | ដូ ដេញ | ភ័ស្តុភារ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៥៣ | គង់ សាត ហៅ លាត | អនុនយោបាយ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៥៤ | ប៉ែន ទី ហៅ ទុយ | យោធាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៥៥ | ស៊ា សារឿន | លេខាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៥៦ | គុយ បឹក | ភ័ស្តុភារ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៥៧ | ឆឹង សុស ហៅ ហេង | អនុនយោបាយ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៥៨ | យ៉ែម យ៉ាត ហៅ វ៉ាត | លេខាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៥៩ | ដុំ រឿន | លេខាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៦០ | ឈឹម យ៉ាត | ភ័ស្តុភារ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៦១ | អំ ស្រុង ហៅ វ៉ាត | លេខាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៦២ | ស ឌី ហៅ ស្រល់ | យោធាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៦៣ | ប៉ែន នឹន | យោធាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៦៤ | ងី ឈាង ហៅ កៅ | លេខាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៦៥ | វង ឆេង ហៅ ណា | ភ័ស្តុភារកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៦៦ | អ៊ុម ផន ហៅ រឹម | ភ័ស្តុភារ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៦៧ | បិន សុន ហៅ ម៉ែន | លេខាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៦៨ | ត្រៃ រឿន ហៅ ចារ | លេខាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៦៩ | ងិន យុត ហៅ នន | លេខាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៧០ | ពិន អៀន ហៅ កែម | ភ័ស្តុភារ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៧១ | ស្រី សឿន ហៅ រី | លេខាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៧២ | ប៉ែន សេង ហៅ សី | អនុនយោបាយ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៧៣ | សំ គឹមសាន ហៅ គុន | លេខាកងធំ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |
| ៣៧៧៤ | ម៉ម យី ហៅ យន់ | អនុនយោបាយ | កងពល៩២០ | ៦-៥-៧៧ | ១០-៦-៧៧ |

**(នៅមានត)**

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

## ជា គឹមស្រេង

*ផែ គឹមវណ្ណនី អាយុ៣៩ឆ្នាំ រស់នៅក្រុងព្រះសីហនុ បានបង្ហាញរូបថត៤សន្លឹក ។ វណ្ណនី នៅចាំស្រពេចស្រពិលអំពីរូបថតទាំងនោះនិងអំពីឪពុកម្តាយរបស់គាត់ ។ វណ្ណនី បានរៀបរាប់អ្វីដែលគាត់ចងចាំ ÷*

ម្តាយខ្ញុំជាកូនអ្នកស្រែចម្ការនៅទន្លេបិទ ។ គាត់ជាកូនច្បងក្នុងគ្រួសារ ។ គាត់ខស្សរាប់ធ្វើដំណើរមកទីក្រុងភ្នំពេញណាស់ ។ ប្អូនស្រីរបស់គាត់ម្នាក់មានប្តីធ្វើគយ ហើយប្អូនប្រុសម្នាក់ទៀតជាអ្នកបើកយន្តហោះ ។ ឪពុកខ្ញុំជាជាងមាសនៅស្រុកកោះសូទិន ។ ឪពុកខ្ញុំបានឃើញម្តាយខ្ញុំនៅវត្ត ហើយចូលស្តីដណ្តឹងម្តាយខ្ញុំ ។ ក្រោយពេលរៀបការហើយ ឪពុករបស់ខ្ញុំនៅតែប្រកបរបរជាងមាសដដែល ចំណែកម្តាយខ្ញុំនៅផ្ទះថែរក្សាកូន ។ បងប្អូនរបស់ខ្ញុំទាំងអស់១២នាក់ក្នុងនោះ ៤នាក់ស្លាប់នៅក្នុងរបបខ្មែរក្រហម ហើយ៨នាក់ទៀតស្លាប់ក្រោយរបបខ្មែរក្រហម ។

នៅក្នុងរបបលន់នល់ ក្រុមគ្រួសារខ្ញុំបែកគ្នាជាពីរដោយសារកាលនោះម្តាយខ្ញុំនាំខ្ញុំនិងបងៗ៤នាក់មកលេងភ្នំពេញ ហើយក៏ដាច់ផ្លូវមិនអាចត្រឡប់ទៅវិញបាន ចំណែកបងៗខ្ញុំ៧នាក់ទៀតនៅជាមួយឪពុកខ្ញុំនៅខេត្តកំពង់ចាម ។ ដោយយើងមិនអាចត្រឡប់ទៅវិញបាន បងថ្លៃរបស់ខ្ញុំដែលធ្វើជាអ្នកបកប្រែនៅមណ្ឌលកុមារកំព្រាបានសុំឲ្យម្តាយខ្ញុំចូលធ្វើជាចុងភៅនៅមណ្ឌលនោះ ។ ខ្ញុំនិងបងៗចុះឈ្មោះជាកុមារកំព្រាដើម្បីបានទៅរស់នៅសហរដ្ឋអាមេរិក ។

នៅខែមេសា ឆ្នាំ១៩៧៥ យើងត្រៀមខ្លួនជាស្រេចរង់ចាំឡើងយន្តហោះនៅវត្តភ្នំ ។ កុមារកំព្រាមួយចំនួនត្រូវយន្តហោះដឹកចេញជាបណ្តើរៗហើយ យើងជាអ្នកចុងក្រោយ ។ យន្តហោះចុងក្រោយបានមកដល់ប៉ុន្តែមិនអាចចុះចតបានដោយសារសភាពការណ៍ពេលនោះជ្រួលច្របល់ខ្លាំងពេក ព្រោះកងទ័ពអាវខ្មៅបានចូលមកដល់ ។ យន្តហោះត្រឡប់ទៅវិញ យើងមិនបានឡើងយន្តហោះទៅប្រទេសអាមេរិកទេ ។ យើងសោកស្តាយណាស់ ប្រសិនបើយន្តហោះមកមុននេះតែបន្តិចយើងពិតជាបានទៅ ។

នៅឆ្នាំ១៩៧៥ ម្តាយខ្ញុំ ខ្ញុំ និងបងប្អូនខ្ញុំ ត្រូវជម្លៀសទៅស្រុកកោះធំខេត្តកណ្តាល ។ យើងចង់ធ្វើដំណើរទៅផ្ទះរបស់យើងនៅឯខេត្តកំពង់ចាម ប៉ុន្តែអង្គការដាក់ទិសឲ្យយើងទៅតាមផ្លូវតាខ្មៅ ។ យើងអត់មានរបស់របរប្រើប្រាស់ទេ សូម្បីតែសម្លៀកបំពាក់ក៏គ្មានដែរ យើងមានតែមួយកំប្លេជាប់នឹងខ្លួនដើម្បីឡើងយន្តហោះ ។ យើងរើសខោអាវនៅតាមផ្ទះដែលម្ចាស់ផ្ទះបានចាកចេញផុតទៅ យកមកស្លៀកពាក់និងយករបស់របរខ្លះទុកគ្រាន់ប្រើប្រាស់ ។ ទៅជាមួយគ្នាពេលនោះមានម្តាយខ្ញុំ រូបខ្ញុំ បងស្រីខ្ញុំ៣នាក់ បងប្រុសម្នាក់ បងថ្លៃម្នាក់ និងក្មួយម្នាក់ ។ យើងធ្វើដំណើរអស់រយៈពេល១ខែទៅដល់ភូមិព្រែកអំបិលក្នុងស្រុកកោះធំ ហើយរស់នៅទីនោះ ។

អង្គការចាត់តាំងឲ្យបងៗរបស់ខ្ញុំលើកទំនប់ ម្តាយរបស់ខ្ញុំធ្វើស្រែនិងចម្ការ ។ យើងរស់នៅជុំគ្នា ហើយមិនទាន់ហូបបាយរួមក្នុងសហករណ៍ទេ ។ ស្រុកកោះធំសម្បូរពោតណាស់ ។ យើងអាចរកបន្លែបង្ការយកមកហូបបាន ។

ក្រោយមកមិនយូរប៉ុន្មាន អង្គការបញ្ជូនប្រជាជនជម្លៀសចំនួន១០០គ្រួសារទៅខេត្តបាត់ដំបង ក្នុងនោះមានគ្រួសារខ្ញុំដែរ ។ យើងធ្វើដំណើរតាមរថយន្តទៅដល់ខេត្តពោធិសាត់ សំចតពីរ-បីយប់ទើបជិះត្រាក់ទ័របន្តទៀតទៅដល់ខេត្តបាត់ដំបង ហើយជិះរទេះគោចូលទៅភូមិ ។ យើងទៅដល់ភូមិពោរពេញស្រុកភ្នំស្រុក ដែលពាសពេញទៅដោយព្រៃឈើ ។ យើងបោះតង់ស្នាក់នៅជាបណ្តោះអាសន្នសិនទម្រាំរកបានឈើមកសង់ផ្ទះបាននៅ ។ បុរសៗត្រូវអង្គការចាត់តាំងឲ្យលើកទំនប់ ចំណែកស្ត្រីធ្វើស្រែ ។ ពីដំបូងយើងបានហូបគ្រប់គ្រាន់ លុះក្រោយមកយើងហូបតែបបរ យូរៗទើបមានបាយហូបម្តង ។

ខ្ញុំរែកអាចម៍គោនៅកងចល័តកុមារ ។ ខ្ញុំកម្របានជួបម្តាយនិងបងប្អូនរបស់ខ្ញុំណាស់ ។ ពេលណាម្តាយខ្ញុំមកផ្ទះ យើងនៅការដ្ឋាន ពេលណាបងប្អូនខ្ញុំបានមកផ្ទះម្តាយខ្ញុំនៅកង ។ មាន

ពេលមួយ ម្តាយរបស់ខ្ញុំវាយបងខ្ញុំ ។ អង្គការហៅម្តាយខ្ញុំទៅកសាងថា មិនត្រូវវាយកូនទៀតទេ ។

បងរបស់ខ្ញុំម្នាក់មានជំងឺដោយសារហូបមិនគ្រប់គ្រាន់ អង្គការបញ្ជូនគាត់ទៅមន្ទីរពេទ្យ ។ ម្តាយរបស់ខ្ញុំបានដឹងរឿងនេះ ប៉ុន្តែអង្គការមិនអនុញ្ញាតឲ្យគាត់ទៅមើលថែបងខ្ញុំទេ ។ រហូតដល់បងខ្ញុំស្លាប់នៅមន្ទីរពេទ្យក៏ម្តាយខ្ញុំមិនបានទៅមើលសាកសពដែរ ។ យើងមិនដឹងថា សាកសពរបស់បងស្រីខ្ញុំត្រូវកប់នៅកន្លែងណាទេ ។ ក្រោយមក បងខ្ញុំម្នាក់ទៀតស្លាប់ដោយសារចុកពោះនៅពេលទៅកាប់ព្រៃ ។

ចុងឆ្នាំ១៩៧៨ អង្គការបញ្ជូនយើងទៅស្រុកស្វាយស៊ីសុផុន ។ យើងរស់នៅទីនោះអស់រយៈពេល១ខែ អង្គការឲ្យយើងច្រូតស្រូវ ។ ពេលមានការបាញ់គ្នារវាងកងទ័ពវៀតណាមនិងកងទ័ពខ្មែរក្រហម យើងជិះរថយន្តកាត់តាមខេត្តសៀមរាបទៅដល់ខេត្តកំពង់ធំសម្រាកមួយយប់ទើបបន្តដំណើរទៅខេត្តកំពង់ចាម ។ មករស់នៅខេត្តកំពង់ចាមហើយទើបយើងបានទទួលដំណឹងពីបងប្អូនថា ឪពុករបស់ខ្ញុំស្លាប់ដោយជំងឺតាំងពីមុនឆ្នាំ១៩៧៥ ហើយបងរបស់ខ្ញុំពីរនាក់ទៀតស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ក្រោយមកទៀតទើបយើងមករស់នៅក្រុងព្រះសីហនុ ។


ម្តាយ ផៃ គីមវណ្ណី មុនឆ្នាំ១៩៧៥

រូបថតម្តាយរបស់ខ្ញុំមួយសន្លឹកនេះគាត់ថតនៅមុនឆ្នាំ ១៩៧៥ ។ ប្អូនជីដូនមួយរបស់គាត់រក្សារូបថតនេះទុក ហើយទើបតែប្រគល់ឲ្យគាត់វិញក្រោយរបបខ្មែរក្រហម ។


ប៉េង គា ក្នុងរបប លន់ នល់

រូបថតមួយសន្លឹកទៀតនេះគឺឈ្មោះ ប៉េងគា ត្រូវជាប្អូនរបស់ម្តាយខ្ញុំ ។ គាត់ជាអតីត ទាហានស័ក្តិ៤ បើកយន្តហោះ ។ ក្នុងរបបលន់នល់ផ្ទះរបស់គាត់នៅបឹងកេងកង ។ គ្រួសារគាត់មានជីវភាពធូរធារណាស់ ។ គ្រួសារគាត់ជម្លៀសទៅខាងស្រុកកោះធំដែរ ប៉ុន្តែនៅភូមិខុសគ្នា ពីគ្រួសារខ្ញុំ ។ ពូប៉េងគា និងកូនរបស់គាត់ ២នាក់បានបាត់ខ្លួន ។ ប្រពន្ធរបស់គាត់យល់ថាគាត់ត្រូវខ្មែរក្រហមសម្លាប់ហើយ ។ ក្រោយរបបខ្មែរក្រហម ម្តាយរបស់ខ្ញុំបានជួបប្រពន្ធ ពូប៉េងគា ដែរ ។


ជា យិចណៃ មុនឆ្នាំ១៩៧៥

រូបថតមួយសន្លឹកទៀតគឺជារូបប្អូនបង្កើតរបស់ម្តាយខ្ញុំ ឈ្មោះ ជា យិចណៃ ។ គាត់មានតែពីរនាក់ប្តីប្រពន្ធ និងកូនមួយប៉ុណ្ណោះ ។ គាត់ចិត្តល្អណាស់ ។ ពេលដែលម្តាយខ្ញុំនិងបងប្អូនខ្ញុំជាប់នៅទីក្រុងភ្នំពេញ យើងស្នាក់នៅផ្ទះរបស់គាត់ ។ នៅពេលខ្មែរក្រហមជម្លៀសយើងបែកពីគាត់ ព្រោះគាត់នៅផ្ទះឯឃ្លាំងរំសេវ ចំណែកបងប្អូនខ្ញុំនៅវត្តភ្នំដើម្បីរង់ចាំឡើងយន្តហោះ ។ យើងបែកគ្នារហូតតាំងពីពេលនោះមក ។ ◆◆◆

## ញឹម ណាន និងប្តីឈ្មោះ អ៊ុក ស៊ីវុត្ថា (អតីតគ្រូបង្រៀន)

ញឹម ណាន គឺជាស្ត្រីមេម៉ាយ ។ ប្តីនិងកូន៣នាក់របស់គាត់បានស្លាប់នៅក្នុងខ្មែរក្រហមដោយសារខ្វះអាហារ ។ បច្ចុប្បន្ន ណាន បួសជាដូនជី ។ គាត់បានរៀបរាប់អំពីបទពិសោធន៍របស់គាត់ថា ៖

ខ្ញុំឈប់រៀនត្រឹមថ្នាក់ទី៦ ព្រោះឪពុកម្តាយខ្ញុំ ចង់ឲ្យខ្ញុំរៀបការ ។ គាត់មិនចង់ឲ្យខ្ញុំរៀនសូត្រជ្រៅជ្រះទេ ព្រោះខ្លាចគ្មានអ្នកណាចូលស្តីដណ្តឹង ។ ខ្ញុំឃើញគ្រូរបស់ខ្ញុំមានចំណេះវិជ្ជាខ្ពង់ខ្ពស់ ស្លៀកពាក់ស្អាតបាតទៅបង្រៀន ហើយមិនសូវហត់នឿយ ទើបខ្ញុំចង់រៀនដែរមិនចង់នៅធ្វើស្រែទេ ។ គ្រូបង្រៀនរបស់ខ្ញុំចង់ឲ្យខ្ញុំចូលរៀនបំពេញវិជ្ជានៅសាលាកំពង់កន្ទួតដើម្បីធ្វើជាគ្រូបង្រៀន ។ ខ្ញុំបានជម្រាបឪពុកម្តាយខ្ញុំអំពីរឿងនេះ ប៉ុន្តែគាត់មិនព្រម ។ ខ្ញុំមិនហ៊ានជំទាស់ចិត្តឪពុកម្តាយខ្ញុំទេ ។

ប្តីខ្ញុំឈ្មោះ អ៊ុក ស៊ីវុត្ថា ជាគ្រូបង្រៀននៅសាលាជើងឆ្នុក ។ ស្រុកកំណើតរបស់គាត់គឺនៅស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ យើងមិនធ្លាប់ស្គាល់គ្នាពីមុនទេ ប៉ុន្តែគាត់ស្គាល់អ្នកជិតខាងរបស់

ខ្ញុំ ។ មានពេលមួយពេលវ៉ាកងធំ គាត់បានទៅលេងភូមិរបស់ខ្ញុំ ។ ពេលនោះឪពុករបស់ខ្ញុំមកពីស្រែវិញ ហើយអ្នកជិតខាងរបស់ខ្ញុំស្រែកហៅខ្ញុំឲ្យចេញទទួលគាត់ផង ។ ប្តីរបស់ខ្ញុំក៏បានឃើញខ្ញុំនៅពេលនោះ ។ ខ្ញុំទើបតែឈប់រៀនបាន៧ខែប៉ុណ្ណោះ ។ គាត់បានពឹងពាក់អ្នកជិតខាងផ្ទះខ្ញុំឲ្យជួយស៊ើបសួរអំពីខ្ញុំ ។ ដោយមានការជ្រោមជ្រែងពីអ្នកជិតខាង ឪពុកខ្ញុំក៏អនុញ្ញាតឲ្យប្តីខ្ញុំចូលស្តីដណ្តឹងខ្ញុំ ដោយបង្គាប់ថ្លៃផ្ទះចំនួន៨ពាន់រៀល ហើយយើងក៏បានរៀបការ ។

ក្រោយពេលរៀបការហើយ យើងទៅរស់នៅកំពង់ស្រឡៅ ព្រោះប្តីខ្ញុំផ្លាស់ទៅបង្រៀននៅទីនោះ ។ គាត់បង្រៀនថ្នាក់ទី៦ ។ មួយឆ្នាំក្រោយមក យើងត្រឡប់មករស់នៅខេត្តកំពង់ចាមវិញ ហើយប្តីខ្ញុំទៅបង្រៀននៅវិទ្យាល័យជើងឆ្នុក ។ ប្តីខ្ញុំបង្រៀនផ្នែកកសិកម្មផងនិងធ្វើការនៅក្នុងការិយាល័យផង ។ ក្រោយមកទៀត យើងទៅរស់នៅឃុំស្រែវាល ស្រុកស្ទឹងត្រង់ ។ ពេលមានរដ្ឋប្រហារទម្លាក់សម្តេច យើងផ្លាស់ទៅរស់នៅភូមិទួលស្បូវ ទីរួមខេត្តកំពង់ចាម ។ យើងជួលផ្ទះនៅ ។ ពេលនោះមានការជ្រើសរើសគ្រូបង្រៀនឲ្យចូលធ្វើទាហានខាងលន់នល់ដោយចុះកិច្ចសន្យារយៈពេល៦ខែ ។ បន្ទាប់ពីនោះបើអ្នកណាចង់ធ្វើទាហានបន្តទៀតក៏បាន ។ ប្តីខ្ញុំចូលធ្វើទាហានរយៈពេល៦ខែ ប៉ុន្តែមិនបានចូលសមរភូមិប្រយុទ្ធទេ ។ គាត់ទៅហាត់ក្បួនយុទ្ធសាស្ត្រទាហាននៅពាមជីកង ។ ដោយសារមានការច្បាំងគ្នានៅភូមិដែលខ្ញុំរស់នៅ យើងផ្លាស់មករស់នៅភូមិកំណើតរបស់ខ្ញុំវិញ យើងចេះតែប្តូរទីកន្លែងរស់នៅជាច្រើនកន្លែង ។ យើងរស់នៅស្រុកកំណើតបានតែ១ឆ្នាំ ក៏ផ្លាស់ទៅរស់នៅទីក្រុងភ្នំពេញ ព្រោះមានការទម្លាក់គ្រាប់បែកខ្លាំង និងការច្បាំងគ្នាកាន់តែជិតមកដល់ភូមិរបស់ខ្ញុំ ។ ឪពុកម្តាយខ្ញុំមិនមករស់នៅភ្នំពេញជាមួយខ្ញុំទេ ព្រោះគាត់ដឹងថាបើកើតមានរបបកុម្មុយនិស្តមែន ប្រជាជនពិតជាមិនរស់ទេ ដូច្នេះគាត់សុខចិត្តស្លាប់នៅស្រុកកំណើតរបស់គាត់ ។

មកដល់ភ្នំពេញ យើងជួលផ្ទះនៅផ្សារដើមថ្កូវ ។ ប្តីខ្ញុំបង្រៀននៅសាលាបាក់ទូក និងឆ្លៀតពេលធាក់ស៊ីក្លូ ។ ខ្ញុំនៅផ្ទះថែរក្សាកូន ។

មុនខែមេសា ឆ្នាំ១៩៧៥ ពេលដែលទីក្រុងភ្នំពេញកំពុងតែជ្រួលច្របល់ ។ ប្តីរបស់ខ្ញុំសុំផ្លាស់ទៅបង្រៀននៅសាលាឈើទាលក្នុងខេត្តបាត់ដំបង ។ ខ្ញុំមានបងស្រីម្នាក់នៅទីនោះ យើងស្នាក់នៅផ្ទះរបស់គាត់នៅជិតស្ថានីយរថភ្លើង ។ ពេលនោះយើងមានកូន៧នាក់ ។



ញឹម ណន និងប្តីឈ្មោះ អ៊ុក ស៊ីវុត្ថា

នៅខែមេសា ឆ្នាំ១៩៧៥ ពេលដែលកងទ័ពខ្មែរក្រហម កាន់កាប់ខេត្តបាត់ដំបង ខ្មែរក្រហមបានប្រកាសថា “ឥឡូវយើងបានសន្តិភាពហើយ ដូច្នេះត្រូវតែចេញពីខេត្តបាត់ដំបង៣ថ្ងៃសិន ដល់ពេលត្រឡប់មកវិញអ្នកណាធ្វើការមុខតំណែងអ្វីឲ្យធ្វើការនោះដដែលវិញ” ។ យើងយករបស់របរបន្តិចបន្តួចហើយដឹកដៃកូនចេញពីផ្ទះ ។ មនុស្សកកកុញតាមផ្លូវ ។ ខ្ញុំមានបំណងត្រឡប់ទៅស្រុកកំណើតខ្ញុំ ព្រោះខ្ញុំនឹកឪពុកម្តាយ ប៉ុន្តែប្តីខ្ញុំថាកុំទាន់ទៅអីនៅចាំស្តាប់សភាពការណ៍សិន ។ យើងចេះតែធ្វើដំណើរទៅដល់ភូមិកំណប់ ។ ប្រជាជនមូលដ្ឋានម្នាក់ឃាត់យើងមិនឲ្យធ្វើដំណើរទៅស្រុកកំណើតវិញទេ គាត់ឃាត់ឲ្យយើងរស់នៅទីនោះ ។

យើងរស់នៅភូមិកំណប់ ។ កូនៗរបស់ខ្ញុំនៅកងកុមារ ។ ខ្ញុំស្ទូងស្រូវ ដកសំណាប ចំណែកប្តីខ្ញុំឃ្វាលគោនិងរាស់ដី ។ ប្តីខ្ញុំធ្វើការឆ្ងាយពីភូមិ ចំណែកខ្ញុំរស់នៅក្នុងភូមិ ។ យើងរស់នៅបែកគ្នា កូនៗរបស់ខ្ញុំបែកខ្ញែកគ្នាទាំងអស់ ។

យើងគ្មានអាហារគ្រប់គ្រាន់ ហើយធ្វើការលើសកម្លាំង

ទៀត ។ ទៅដល់ទីនោះដំបូង យើងបានបាយហូប ក្រោយមក យើងហូបតែបបរមួយពេលមួយវែក ។ បើសម្រិតបបរនោះ យកកាក គ្រាប់អង្ករបានតែមួយស្លាបព្រាប៉ុណ្ណោះ ។

នៅចុងឆ្នាំ១៩៧៦ កូនៗនិងប្តីរបស់ខ្ញុំស្លាប់នៅក្នុងខែតែមួយ ដោយសារខ្វះអាហារ ។ កូនពៅរបស់ខ្ញុំស្លាប់មុន ដោយអត់ទឹកដោះជៅ ។ បន្ទាប់មកប្តីខ្ញុំស្លាប់ រួចហើយកូនទី៥ និងទី៦ ក៏ស្លាប់ជាបន្តបន្ទាប់ ។ ខេត្តបាត់ដំបងសម្បូរស្រូវអង្ករមែន ប៉ុន្តែមានហូបគ្រប់គ្រាន់តែចំពោះកម្មាភិបាលប៉ុណ្ណោះ ចំណែកយើងដែលជាប្រជាជនគ្មានអ្វីហូបទេ ។ នៅរដូវចម្រូតសម្បូរស្រូវណាស់ ហើយស្រូវល្អៗទៀតផង ប៉ុន្តែខ្ញុំមិនដឹងថាអង្គការដឹកជញ្ជូនយកទៅខាងណាអស់ទេ ។ រដូវច្រូតកាត់យើងបានហូបបាយ ប៉ុន្តែមិនយូរប៉ុន្មាន យើងហូបបបររាវដដែល ។ យើងមិនអាចបេះផលដំណាំដែលយើងដាំដោយខ្លួនយើងយកមកហូបទេ សូម្បីតែបន្លែដែលយើងដាំនៅចម្ការ ឬចេកដែលដាំនៅមុខផ្ទះ យើងក៏ដោយ ។ អង្គការនិយាយថា របស់ទាំងនោះត្រូវតែដាក់រួម ។ បើយើងហ៊ានបេះហូប អង្គការចោទថាយើងក្បត់សមូហភាព ។ យើងមានតែខោអាវមួយចង្កេះជាប់នឹងខ្លួន និង កាម៉ែលមួយប៉ុណ្ណោះ ។

នៅក្នុងសហករណ៍ដែលខ្ញុំរស់នៅមានគ្រូបង្រៀនប្រមាណ ៥-៦នាក់ ត្រូវអង្គការយកទៅសម្លាប់ចោលអស់ទាំងគ្រួសារ ។ បើប្តីខ្ញុំមិនស្លាប់ដោយអត់អាហារ គាត់ក៏ជាមុខសញ្ញាដែលអង្គការយកទៅសម្លាប់ចោលដែរ ។

បន្ទាប់ពីរបបខ្មែរក្រហមត្រូវវៀតណាមបណ្តេញចេញ ខ្ញុំនាំកូនដែលសល់៤នាក់ធ្វើដំណើរត្រឡប់មកស្រុកកំណើតរបស់ខ្ញុំនៅរកាកោងវិញ ។ ក្រោយមក កូនរបស់ខ្ញុំស្លាប់អស់២នាក់ទៀត គឺស្រី១ ប្រុស១ ។ សព្វថ្ងៃខ្ញុំនៅសល់កូន២នាក់ ។

ខ្ញុំមិនដឹងថាបដិវត្តន៍របស់ខ្មែរក្រហមជាបដិវត្តន៍អ្វីទេ ។ ខ្ញុំទើបតែជួបប្រទះជាលើកទី១ក្នុងជីវិតរបស់ខ្ញុំ ។ ប្រជាជននៅក្នុងសហករណ៍ខ្ញុំស្លាប់ពាយដោយសារអត់អាហារហូប ។ មកដល់សព្វថ្ងៃនេះខ្ញុំគ្មានសេសសល់អ្វីទៀតទេ ក្រៅពីកូន២នាក់ ។ ខ្ញុំខំធ្វើបុណ្យទាន និងឧទ្ទិសកុសលផលបុណ្យទៅឲ្យប្តីនិងកូនៗរបស់ខ្ញុំដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។

រូបថតនេះ ខ្ញុំថតជាមួយប្តីខ្ញុំក្រោយពេលរៀបការហើយ ។ យើងនៅទីរួមខេត្តកំពង់ធំ នៅពេលដែលយើងធ្វើដំណើរឆ្លងកាត់ពីកំពង់ស្រឡៅមកខេត្តកំពង់ចាម ។ យើងស្នាក់នៅផ្ទះមិត្តភក្តិប្តីខ្ញុំរយៈពេល៣ថ្ងៃ ដើម្បីរង់ចាំយករូបថត ។ សាច់ញាតិរបស់ខ្ញុំម្នាក់ដែលជាប្រជាជនមូលដ្ឋានបានរក្សាទុករូបថតនេះឲ្យខ្ញុំ ហើយគាត់ប្រគល់ឲ្យខ្ញុំវិញ ក្រោយពេលដែលរបបខ្មែរក្រហមត្រូវបញ្ចប់ ។

**ប៊ាន ពីរ័ន និង ស៊ុំ សាទីណា**



# ចំណាងឧក្រិដ្ឋកម្ម
# មន្ទីរសន្តិសុខភូមិភាគនិរតី
# ការកកើត ប្រតិបត្តិការ និង ទំនាក់ទំនង

***(តពីលេខមុន)***

***៣) ប្រតិបត្តិការនិងទំនាក់ទំនង***

***មន្ទីរឈ្លបឃុំ***

ភូមិភាគនិរតីមានឃុំសរុបចំនួន២២៥ ក្នុងនោះខ្ញុំបានទៅដល់ឃុំចំនួន១៦៥ ។ គ្រប់ឃុំដែលខ្ញុំបានទៅដល់ ខ្ញុំឃើញមានមន្ទីរឈ្លបឃុំចំនួនមួយ ដូចនេះប្រហែលជាមានមន្ទីរឈ្លបឃុំនៅគ្រប់ឃុំទាំងអស់ ហើយមន្ទីរឈ្លបឃុំនោះដើរតួជាមន្ទីរឃុំឃាំងថ្នាក់ឃុំ ។ មន្ទីរឈ្លបឃុំច្រើនតែជាអតីតផ្ទះរបស់ប្រជាជនឬសង់ជារោង ។ អ្នកទោសនៅមន្ទីរឈ្លបឃុំ ភាគច្រើនជាប្រជាជននៅតាមសហករណ៍ ដែលត្រូវអង្គការចោទប្រកាន់ថា បានលួចបេះបោចបន្លែបង្ការសមូហភាព ឬស្ពឹកស្រពន់ ខ្ជិលធ្វើការងារ ។ អ្នកទោសនៅមន្ទីរឈ្លបឃុំប្រឈមមុខនឹងករណី២ គឺទី១) ត្រូវបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរ បន្ទាប់មកត្រូវដោះលែងឲ្យវិលត្រឡប់ទៅតាមកងនិងសហករណ៍វិញ និងទី២) ត្រូវបញ្ជូនបន្តទៅមន្ទីរអប់រំស្រុក ។ មូលហេតុនៃការដោះលែងគឺដោយសារអ្នកទោសត្រូវបានប្រធានគុកមើលឃើញថាបានកែខ្លួន ហើយមូលហេតុនៃការបញ្ជូនបន្តទៅមន្ទីរអប់រំស្រុកគឺដោយសារអ្នកទោសត្រូវបានមើលឃើញថាមិនកែខ្លួន ។

នៅថ្ងៃទី១១ ខែមេសា (ឆ្នាំ១៩៧៦) សមមិត្ត ជន គណៈឃុំពពេល បានចាប់ខ្លួនអ្នកទោសម្នាក់ឃុំឃាំងនៅក្នុងមន្ទីរឈ្លបឃុំពពេលដែលមានទីតាំងស្ថិតនៅខាងលិចផ្សារដំណាក់តាសេក ។ សមមិត្ត ជន បានរាយការណ៍អំពីករណីអ្នកទោសដែលគាត់ចាប់ខ្លួន ទៅអង្គការស្រុកត្រាំកក់ថា “ខ្ញុំហៅខ្មាំងចលនាបំផុសបំផុល (ឈ្មោះ លឹម សុង) និងខ្មាំងមានបណ្តាស័ក្តិ (ទាហានរបបលន់ ណុល) មកនៅកន្លែងខ្ញុំហើយ ។ សុំអង្គការឲ្យយោបល់ ឬឲ្យសម្រេចនៅតាមមូលដ្ឋានណាខ្លះ” ។ គេង អតីតកម្មាភិបាលឃុំពពេល ស្រុកត្រាំកក់ បានប្រាប់ឲ្យដឹងថា មន្ទីរឈ្លបឃុំពពេលពិតមានទីតាំងស្ថិតនៅខាងលិចផ្សារដំណាក់តាសេកមែន ។ គាត់បញ្ជាក់ថា មន្ទីរនេះជាអតីតសាលាឃុំពពេលក្នុងរបបលន់នល់ ។ មន្ទីរនេះមានទទឹងប្រវែង៧ម៉ែត្រនិងបណ្តោយប្រវែង១០ម៉ែត្រ ។

នៅក្នុងឃុំគុស មន្ទីរឈ្លបឃុំមានទីតាំង នៅភូមិអង្គ ។ យុត ដែលធ្លាប់ជាប់ឃុំឃាំង នៅក្នុងមន្ទីរឈ្លបឃុំគុស បានប្រាប់ឲ្យដឹងថា ទីតាំងមន្ទីរឈ្លបឃុំគុស ស្ថិតនៅក្នុងភូមិអង្គ ឃុំគុស ស្រុកត្រាំកក់ ។ មន្ទីរនេះមានទំហំទទឹងប្រវែង៤ម៉ែត្រ និងបណ្តោយប្រវែង៩ម៉ែត្រ ។ ក្នុងរបាយការណ៍ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៧ របស់សមមិត្ត សើន ផ្ញើជូនអង្គការស្រុកត្រាំកក់អំពីការចាប់ខ្លួនអតីតទាហានស័ក្តិ២របប លន់ នល់ ចំនួន២នាក់ ។ នៅក្នុងរបាយការណ៍នោះ សមមិត្ត សើន បន្ទាប់ពីការសួរនាំអ្នកទោសរបស់គាត់ និងការសម្រេចរបស់គាត់ក្នុងការបញ្ជូនអ្នកទោសទាំង២ជូនអង្គការស្រុកត្រាំកក់ដើម្បីសួរបន្ត ។ សមមិត្ត សើន ចារបញ្ជាក់ថា “សូមសមមិត្តបងសួរបញ្ជាក់ថែមទៀតចុះ” ។

មន្ទីរឈ្លបឃុំក្នុងស្រុកនិងតំបន់ផ្សេងៗទៀតក៏មានលក្ខណៈទំហំ និងប្រតិបត្តិការ ដូចមន្ទីរឈ្លបឃុំពពេលនិងឃុំគុសដែរ ។ មន្ទីរឈ្លបឃុំលំចង់ក្នុងស្រុកទ្រាំងមានទីតាំងក្នុងភូមិគុល ។ មន្ទីរនេះគឺជាអតីតផ្ទះរបស់ឈ្មោះ អឿន មានទទឹងប្រវែង៦ម៉ែត្រនិងបណ្តោយប្រវែង១០ម៉ែត្រ ។ មន្ទីរនេះស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានឈ្លបឃុំ**លំចង់**ឈ្មោះ សមមិត្ត សារឿន ។ មន្ទីរឈ្លបឃុំធ្លាប្រជុំក្នុងស្រុកកោះអណ្តែតមានទីតាំងក្នុងភូមិរូង ឃុំធ្លាប្រជុំ ស្រុកកោះអណ្តែត ។ មន្ទីរនេះជាអតីតផ្ទះរបស់ឈ្មោះ សុខ មានទទឹងប្រវែង៥ម៉ែត្រនិងបណ្តោយប្រវែង៩ម៉ែត្រ ។

មន្ទីរឈ្លបឃុំសូភីក្នុងស្រុកបាទី តំបន់៣៣ គឺជាអតីតផ្ទះរបស់អតីតទាហានស័ក្តិ៣ម្នាក់នៃរបបលន់នល់ ស្ថិតនៅក្នុងភូមិចម្ការដូង ឃុំសូភី ស្រុកបាទី។ មន្ទីរនេះព័ទ្ធជុំវិញដោយដើមដូងដែលដាំលើផ្ទៃដីសរុបជិត២ហិកតា។ សមមិត្ត រឿន ប្រធានឈ្លបឃុំសូភីប្រើប្រាស់មន្ទីរនេះសម្រាប់ឃុំឃាំងអ្នកទោស។ ផ្ទះថ្មសម្រាប់ឃុំឃាំងអ្នកទោសមានទទឹងប្រវែង៥ម៉ែត្រ និងបណ្តោយប្រវែង៨ម៉ែត្រ។

មន្ទីរឈ្លបឃុំពោធិអង្ក្រង់ក្នុងស្រុកបសេដ្ឋ តំបន់៣៣ ស្ថិតនៅក្នុងភូមិពោធិប្រនាង ឃុំពោធិអង្ក្រង់ ស្រុកបសេដ្ឋ។ មន្ទីរនេះត្រូវបានសាងសង់អំពីឈើប្រក់ស្លឹកនៅកណ្តាលចម្ការស្វាយ មានទំហំទទឹង៤ម៉ែត្រ និងបណ្តោយ៦ម៉ែត្រ។ មន្ទីរនេះគ្រប់គ្រងដោយប្រធានឈ្លបឃុំឈ្មោះ នាង។

មន្ទីរឈ្លបឃុំព្រះនិព្វានក្នុងស្រុកគងពិសី តំបន់៣៣ មានទីតាំងនៅភូមិទួលឆ្នង់ ស្រុកគងពិសី។ មន្ទីរនេះជាអតីតផ្ទះរបស់ឈ្មោះ ទែល និង ខុន មានទទឹង៥ម៉ែត្រ និងបណ្តោយ៧ម៉ែត្រ និងស្ថិតក្រោមការគ្រប់គ្រងរបស់គណៈឃុំឈ្មោះ ហ៊ាន និងប្រធានឈ្លបឃុំឈ្មោះ ហាំ។

អ្នកទោសនៅមន្ទីរឈ្លបឃុំត្រូវបានបង្ខំឲ្យធ្វើការធ្ងន់ធ្ងរពីព្រលឹមដល់ព្រលប់ និងមានពេលវេលាសម្រាកតិចតួច។ ការងាររបស់អ្នកទោសមានដូចជា កាប់ព្រៃ ធ្វើស្បូង និងដាំដំណាំ និងផ្លាស់ប្តូរទីកន្លែងជារឿយៗ ជួនកាលជិតមន្ទីរ ជួនកាលឆ្ងាយពីមន្ទីរ ទៅតាមការបាត់តាំងរបស់ប្រធានឈ្លបឃុំ។ កាន់ អតីតអ្នកទោសនៅមន្ទីរឈ្លបឃុំសូភី រំឭកថា អ្នកទោសត្រូវក្រោកពីព្រលឹមចេញទៅធ្វើការងាររហូតដល់យប់។ ពេលវេលាសម្រាក គឺពេលបាយថ្ងៃត្រង់និងពេលយប់។ លុះត្រាតែមានការអនុញ្ញាតពីឈ្លបទើបអ្នកទោសអាចសម្រាកបាន។ ចំណែកឈ្លបវិញចង់សម្រាកពេលណាក៏បានស្រេចតែចិត្ត។ ឈ្លបជាអ្នកឈរមើលនិងបញ្ជាឲ្យអ្នកទោសធ្វើការ។ ញាណ អតីតឈ្លបមន្ទីរឈ្លបឃុំសូភីរៀបរាប់បញ្ជាក់ការអះអាងខាងលើថា ការងារប្រចាំថ្ងៃរបស់ឈ្លបគឺយាមអ្នកទោស ចំណែកការងាររបស់អ្នកទោសគឺកាប់ព្រៃ ច្បាចស្មៅ និងដាំដំណាំ។ ចប់ម៉ោងការងារឈ្លបនាំអ្នកទោសត្រឡប់មកមន្ទីរឃុំឃាំងវិញបញ្ចូលក្នុងបន្ទប់រួចចាក់សោ។

ពេលខ្លះ អ្នកទោសធ្វើការងារមិនឆ្ងាយពីប្រជាជនប៉ុន្មានទេ អ្នកទាំងពីរអាចមើលឃើញគ្នាទៅវិញទៅមក ប៉ុន្តែមិនអាចនិយាយស្តីទាក់ទងគ្នាបានឡើយ។ ឃុត ធ្លាប់បានឃើញអ្នកទោសនៅមន្ទីរឈ្លបឃុំអង្គតាសោមភ្ជួរស្រែនៅក្បែរកន្លែងដែលគាត់កំពុងតែភ្ជួរ។ មន្ទីរឈ្លបឃុំអង្គតាសោមស្ថិតក្រោមការគ្រប់គ្រងរបស់សមមិត្ត ឆោម។ ឃុត ប្រាប់ថា អ្នកទោសក្នុងមន្ទីរឈ្លបឃុំធ្វើការធ្ងន់ធ្ងរគ្មានពេលសម្រាក។ ពេលដែលប្រជាជនសម្រាកហូបបាយនៅម៉ោង១២ថ្ងៃត្រង់ អ្នកទោសនៅធ្វើការនៅឡើយ។ រូបរាងអ្នកទោសម្នាក់ៗមើលទៅមានតែស្បែកដណ្តប់ឆ្អឹង។ ឃុត គិតថា សូម្បីតែគាត់ជាប្រជាជនធម្មតានៅធ្វើការលំបាកលំបិនប៉ុណ្ណឹងទៅហើយ ទម្រាំតែអ្នកមានទោសពិតជាធ្វើការកាន់តែធ្ងន់ជាងគាត់ទៅទៀត។

អតីតអ្នកទោសនិងឈ្លបនៅមន្ទីរឈ្លបឃុំបានឲ្យដឹងថា ការយាមកាមអ្នកទោសនៅមន្ទីរឈ្លបឃុំមិនមានសភាពតឹងតែង


គុកសង់ ក្នុងខេត្តតាកែវ

ណាស់ណាទេ ប៉ុន្តែមានចំនួនអ្នកទោសតិចតួចបំផុតដែលសម្រេចចិត្តរត់គេច ដោយសារ ទី១) ខ្លាចឈ្លប ទី២) ទោះបីជារត់ចេញពីមន្ទីរឈ្លបឃុំទៅសហករណ៍វិញក៏នៅតែត្រូវធ្វើការងារដដែល និង ទី៣) ក្នុងករណីអ្នកទោសត្រូវចាប់ខ្លួនបានមកវិញ ពិតជាត្រូវទទួលរងនូវទារុណកម្មនិងត្រូវសម្លាប់ជាមិនខាន។ ជា អតីតឈ្លបឃុំសូភី ទទួលស្គាល់ថាអ្នកទោសពិតជាខ្លាចឈ្លបខ្លាំងណាស់។ ជា បញ្ជាក់ថា គាត់មិនដែលបានវាយធ្វើបាបអ្នកទោសណាម្នាក់ទេ ប៉ុន្តែអ្នកទោសខ្លាចគាត់ខ្លាំងណាស់។ អ្នកទោសភាគច្រើនត្រូវបានដោះលែងឲ្យត្រឡប់ទៅសហករណ៍វិញ។ យុត ប្រាប់អំពីមូលហេតុនៃការមិនរត់គេចពីមន្ទីរឈ្លបឃុំថា រត់គេចខ្លួនគឺជាការប្រថុយប្រថាននឹងគ្រោះថ្នាក់បំផុត។ វ៉ូ ត្រូវឈ្លបឃុំវាយរហូតដល់ស្លាប់បន្ទាប់ពីលួចរត់ហើយត្រូវចាប់ខ្លួនមកពីផ្ទះវិញ។ វ៉ូ ស្លាប់នៅចំពោះមុខអ្នកទោសផ្សេងទៀត ហើយឈ្លបធ្វើនេះដើម្បីជាមេរៀនសម្រាប់អ្នកទោសដទៃទៀត។ សារ៉ាត មិនរត់គេចព្រោះថា "បើទោះជារត់រួចក៏មិនដឹងទៅពួននៅឯណា។ ចូលភូមិវិញមិនបាន ទៅភូមិផ្សេងក៏រឹតតែមិនបាន។ ម្យ៉ាងទៀតយើងរត់ទៅហើយខ្លាចក្រែងប្រពន្ធកូនរស់នៅមិនបានសុខ"។

## ប្រជាជនសេរី

អ្នកទោសនៅមន្ទីរឈ្លបឃុំត្រូវសមមិត្ត សុន សេន ហៅថា "ប្រជាជនសេរី" ដែលសំដៅដល់ប្រជាជនដែលត្រូវចាប់ខ្លួនពីបទលួចបេះបោចបន្លែបង្ការរបស់សមូហភាពខ្ជិលច្រអូសក្នុងការងារឈើទម្រន់ (ឈើទន្សាយ) និងរត់គេចពីកងសហករណ៍ទៅលេងក្រុមគ្រួសារឪពុកម្តាយ ប្តីប្រពន្ធ កូនចៅ ជាដើម។ អ្នកទាំងនោះភាគច្រើនជាប្រជាជនមូលដ្ឋាន ហើយមួយចំនួនតូចជាប្រជាជន ១៧មេសា។

ប្រជាជនសេរីដែលបានប្រព្រឹត្តអំពើដូចខាងលើត្រូវចាប់ខ្លួន ហើយប្រមូលផ្តុំមួយកន្លែងដើម្បីលត់ដំ។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ និងសមមិត្ត សុន សេន មិនបានចាត់ទុក "បទល្មើសរបស់ប្រជាជនសេរី" ជាសកម្មភាពខ្មាំងប្រឆាំងជាខ្សែសន្ទាក់ ឬជាសកម្មភាពក្បត់នឹងអង្គការដែលត្រូវផ្តន្ទាទោសកម្រិតខ្ពស់បំផុត (ប្រហារជីវិត) នោះឡើយ។ កម្រិតផ្តន្ទាទោសចំពោះបទល្មើសសេរីនេះ គឺត្រូវ"អប់រំកសាងក្នុងក្របខ័ណ្ឌអង្គការរដ្ឋ" និង "ប្រមូលផ្តុំដើម្បីលត់ដំ"។ ទោះបីជាយ៉ាងនេះក្តី ការសម្លាប់នៅតែកើតឡើងចំពោះប្រជាជនសេរីក្នុងបទល្មើសខាងលើ។ សំណាង ត្រូវចាប់ខ្លួនបញ្ជូនទៅឃុំឃាំងក្នុងមន្ទីរឈ្លបឃុំលំចង់ ហើយបានបាត់ខ្លួនរហូតដល់បច្ចុប្បន្ន។ អឿន ជាឪពុករបស់ សំណាង ប្រាប់ឲ្យដឹងថា សំណាង ត្រូវឈ្លបឃុំឈ្មោះ ខន ចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៥ ដោយសារលួចបូតស្រូវសមូហភាពដែលដាំនៅតាមប្រឡាយ។ សំណាង បានបែកពីឪពុកតាំងពីអាយុមិនទាន់គ្រប់១០ឆ្នាំ។ អឿន គ្មានសង្ឃឹមថាបានជួបកូនរបស់គាត់វិញឡើយ។ គាត់បញ្ជាក់ថា "វាច្បាស់ជាងាប់ចោលខ្ញុំ


បូជនីយដ្ឋាននៅអតីតគុកក្រាំងតាចាន់

បាត់ហើយ"។ វ៉ូ ត្រូវចាប់ខ្លួនពីបទលួចបូតស្រូវដែលដាំក្នុងត្រពាំង បន្ទាប់មកត្រូវបញ្ជូនទៅមន្ទីរឈ្លបឃុំពោធិអង្គ្រង។ កាន់ ម្តាយរបស់ វ៉ូ បញ្ជាក់ថា វ៉ូ ត្រូវឈ្លបសម្លាប់នៅពេលព្យាយាមរត់គេចពីមន្ទីរឈ្លបឃុំហើយត្រូវឈ្លបចាប់បាន។

នៅមន្ទីរឈ្លបឃុំសូភីក្នុងស្រុកបាទី ខេត្តតាកែវ ប្រជាជនមូលដ្ឋាននិងអតីតឈ្លបអះអាងថា មន្ទីរឈ្លបឃុំនោះជាមន្ទីរឃុំឃាំងនិងជាទីតាំងសម្លាប់មនុស្សតែម្តង។ ក្នុងចំណោមអតីតឈ្លបឃុំសូភីចំនួន៤នាក់ដែលខ្ញុំបានជួបសម្ភាសន៍ គ្មាននរណាម្នាក់សារភាពអំពីការចូលរួមរបស់ខ្លួនក្នុងការសម្លាប់ប្រជាជន

នៅពេលនោះឡើយ ។ ញាណ ធ្លាប់ជាកងឈ្លបដែលមានអាយុក្មេងបំផុត ។ ញាណ ទទួលស្គាល់ថាមានការសម្លាប់អ្នកទោសនៅក្នុងមន្ទីរឈ្លបឃុំសូភី ប៉ុន្តែគាត់បដិសេធដាច់អហង្ការថាគាត់មិនបានចូលរួមក្នុងការសម្លាប់ទេ ។ ញាណ ពន្យល់ហេតុផលថា ដោយសារកាលនោះគាត់នៅក្មេង ដូច្នេះមេគុកមិនបានប្រគល់ភារកិច្ចសម្លាប់អ្នកទោសឲ្យគាត់ធ្វើឡើយ ។ ញាណ បញ្ជាក់ថា គាត់គ្រាន់តែជាអ្នកដាំបាយ និងការពារអ្នកទោសប៉ុណ្ណោះ ។ សាខន អតីតឈ្លបឃុំលំចង់ ទទួលស្គាល់ថាមានអ្នកទោសស្លាប់នៅក្នុងមន្ទីរឈ្លបឃុំ ប៉ុន្តែគាត់និយាយថា "ការស្លាប់របស់



អ្នកទោសនៅមន្ទីរឈ្លបឃុំប៉ុន្តែមិនមែនដោយសារការសម្លាប់ទេ គឺដោយសារអត់បាយនិងជំងឺ" ។

## របបអាហារ

របបអាហាររបស់អ្នកទោសក្នុងមន្ទីរឈ្លបឃុំមាន២ពេលក្នុងមួយថ្ងៃ គឺពេលថ្ងៃត្រង់និងពេលល្ងាច ។ អ្នកទោសភ្ញាក់ពីដំណេកនៅពេលព្រឹកព្រលឹម ហើយចាប់ផ្តើមធ្វើការរហូតដល់ម៉ោង ១១និង៣០នាទីឬម៉ោង១២ថ្ងៃត្រង់ ទើបត្រូវអនុញ្ញាតឲ្យឈប់សម្រាកហូបបាយថ្ងៃត្រង់ ។ បន្ទាប់ពីហូបបាយរួច អ្នកទោសត្រូវធ្វើបន្តការងាររហូតដល់ម៉ោង៥ឬ៦ល្ងាចទើបបានឈប់សម្រាកហូបបាយល្ងាច ។ អាហារទាំង២ពេលរបស់អ្នកទោសគឺបបរាវលាយជាមួយត្រកួន ។ ញាណ ប្រាប់ឲ្យដឹងថា ពេលខ្លះអ្នកទោសបានហូបត្រីតូចៗនិងបន្លែដែលអ្នកទោសដាំដុះឬរកបាន ប៉ុន្តែមិនញ៉ាំកញ្ជាប់និងមិនបានច្រើនតាមចិត្តចង់ឡើយ ។

សេង អតីតអ្នកទោសនៅមន្ទីរឈ្លបឃុំបត់រកាក្នុងស្រុកត្រាំកក់ រៀបរាប់អំពីរបបហូបចុករបស់អ្នកទោសនៅក្នុងមន្ទីរឈ្លបឃុំបត់រកាថា "របបអាហារប្រចាំថ្ងៃរបស់អ្នកទោសគឺ បបររាវមួយកូនចានចង្កឹះ ។ ជួនកាលបានអំបិល ជួនកាលបានដើងក្តាមមួយចែកគ្នា៤-៥នាក់" ។

បន្ទាប់ពីបានដឹងអំពីការខ្វះខាតអាហាររបស់ តាំ ដែលជាប្អូនប្រុស នៅក្នុងមន្ទីរឈ្លបឃុំពោធិអង្ក្រង ទូច បានវេចបាយមួយកញ្ចប់ធំលាក់បំពួនប្រថុយប្រថានគ្រោះថ្នាក់ដើម្បីយកទៅឲ្យប្អូនរបស់គាត់ ។ ពេលធ្វើដំណើរទៅដល់ការដ្ឋានរបស់អ្នកទោស ទូច មិនបានជួប តាំ ឡើយ ដោយសារ តាំ ត្រូវឈ្លបចាត់តាំងឲ្យទៅឃ្វាលគោបាត់ទៅហើយ ។ អ្នកទោសម្នាក់ឈ្មោះ តា អះអាងប្រាប់ ទូច ថា គាត់ត្រូវចេញទៅឃ្វាលគោជាមួយ តាំ ដូចនេះ ទូច អាចផ្ញើ កញ្ចប់បាយនោះទៅឲ្យ តាំ តាមរយៈគាត់បាន ។ ពេលនោះ ទូច បានផ្ញើកញ្ចប់បាយ តាមរយៈ តា ដើម្បីយកទៅឲ្យប្អូនរបស់ គាត់ ។ អំណាចនៃការ ឃ្លាន តា បានយកបាយ នោះទៅហូបតែម្នាក់ឯងរហូតដល់ហាល់ស្លាប់ក្នុងព្រៃ ។

## ទារុណកម្ម

ទារុណកម្មដែលអ្នកទោសក្នុងមន្ទីរឈ្លបឃុំទទួលរងមាន ២ដំណាក់កាលគឺ ទី១) នៅពេលដែលអ្នកទោសត្រូវសួរនាំដើម្បីធ្វើកំណត់ហេតុបន្ទាប់ពីបញ្ជូនមកដល់មន្ទីរឈ្លបឃុំ និងទី២) ក្នុងពេលជាប់ឃុំឃាំងអ្នកទោសត្រូវបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរនិងទទួលអាហារមិនគ្រប់គ្រាន់ ។ អ្នកទោសណាដែលត្រូវមើលឃើញថាធ្វើការងារមិនពេញដៃពេញជើង មិនពេញចិត្តឈ្លបក៏ត្រូវទទួលរងការវាយដំនិងទណ្ឌកម្មបន្ថែមការងារ ។

បន្ទាប់ពីត្រូវចាប់ខ្លួនបញ្ជូនដល់មន្ទីរឈ្លបឃុំសំរោង សារ៉ាត ត្រូវប្រធានឈ្លបឃុំទាត់ធាក់ធ្វើឲ្យវង្វេងវង្វាន់ស្មារតីអស់រយៈពេលជាច្រើនថ្ងៃ ។ សារ៉ាត រំឭកថា "ដំបូង អាឈន ប្រធានឈ្លបឃុំចងខ្ញុំឲ្យអង្គុយពាក់កណ្តាលឈរពាក់កណ្តាល ។ រួចហើយវាសួរខ្ញុំ

រឿងលួចស្រូវ ។ ពេលខ្ញុំឆ្លើយថាអត់បានលួច វាទះខ្ញុំមួយកំផ្លៀង ។ បន្ទាប់ពីនោះវាសួរខាងលិចខ្ញុំពួខាងកើត ខ្ញុំវង្វេង៧-៨ថ្ងៃ" ។

នៅខែមិថុនា ឆ្នាំ១៩៧៦ កាន់ ត្រូវឈ្លបឃុំសូភីឈ្មោះ ដើក និង ហឿន ចាប់ខ្លួនពីភូមិភ្នំតូចទៅមន្ទីរឈ្លបឃុំ ។ ក្នុងពេលសួរនាំធ្វើកំណត់ហេតុ កាន់ ត្រូវ ដើក និង ហឿន ចាប់ចងព្យួរជើងឡើងលើជាប់នឹងមែកស្វាយ រួចវាយនឹងធាងត្នោត ។ កាន់ បញ្ជាក់ថា ពេលនោះគាត់ជាប់ចោទ២ករណី ។ ទី១) ជាអតីតទាហានរបបលន់នល់ និងទី២) បានលួចបូតស្រូវសមូហភាព ។ ហឿន បដិសេធការចោទប្រកាន់នេះដោយបកស្រាយថា "ពេលនោះខ្ញុំបានវាយគាត់មែន ប៉ុន្តែខ្ញុំគ្រាន់តែយកធាងត្នោតដែលសកបន្លាចេញហើយ សល់បណ្តូលទន់ៗទៅវាយគាត់ប៉ុណ្ណោះ ខ្ញុំមិនបានវាយគាត់ខ្លាំងទេ ។ ខ្ញុំគ្រាន់តែវាយឲ្យប្រធានឈ្លបឃុំឃើញ ។ បើខ្ញុំមិនវាយ គឺច្បាស់ជាប្រធានឈ្លបឃុំរករឿងសម្លាប់ខ្ញុំចោល ព្រោះខ្ញុំមិនគោរពតាមបញ្ជាថ្នាក់លើ" ។

ទូច និងអ្នកទោសក្នុងក្រុមជាមួយគាត់ ត្រូវមិត្ត ប៉ាញ ប្រធានមន្ទីរឈ្លបឃុំព្រៃនាម បញ្ជាឲ្យយកដំបងវាយម្នាក់៣ដំបងទៅលើអ្នកទោសម្នាក់ដែលទើបចាប់មកពីភូមិព្រៃផ្អាវ ។ ទូច រៀបរាប់ថា "បើមិនវាយទេគេវាយយើង ។ ប៉ាញ បញ្ជាឲ្យយើងវាយឲ្យខ្លាំង បើយើងវាយតិចគេវាយវិញ ។ ពេលនោះខ្ញុំវាយមែនលោកអើយមិនចង់ទេ ។ ប៉ុន្មានថ្ងៃក្រោយមក អ្នកទោសម្នាក់នោះត្រូវបញ្ជូនចេញទៅវត្តជើងចាបបន្តទៀត" ។

## ដំណើរការនិងទំនាក់ទំនងនៃមន្ទីរឈ្លបឃុំ

"ការចូលរួមរបស់ប្រជាជន" គឺជាកត្តាកំណត់ជោគជ័យក្នុងការស្វែងរក និងចាប់ខ្លួនខ្មាំងបង្កប់ក្នុងអំឡុងឆ្នាំ១៩៧៦កន្លងមក ។ នេះគឺជាបទពិសោធន៍ល្អដែលត្រូវតែបន្តអនុវត្តឲ្យបានគ្រប់ទិសទីទូទាំងប្រទេស ។ បទវិចារណកថានៅក្នុងសៀវភៅទង់ក្រហមកិត្តិយសបានពន្យល់អំពីមូលហេតុនៃជោគជ័យនេះថា "យើងបំផុសមហាជន មហាជនគេទុកចិត្ត ។ បើគេទុកចិត្តលើគណៈកម្មការក្រសួងហើយ គេរាយការណ៍ប្រាប់គណៈក្រសួង ។ បើគេមិនទាន់កក់ក្តៅលើគណៈកម្មការក្រសួង គេរាយការណ៍ឲ្យមន្ទីរបក្ស រាយការណ៍នេះមិនមែនអនាមិកទេ គឺគេទទួលខុសត្រូវពេញទី ។ តាមពិសោធន៍នេះ មូលដ្ឋានក៏អាចធ្វើយ៉ាងនេះបានដែរ" ។

ជាក់ស្តែងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដំណើរការរបស់មន្ទីរឈ្លបឃុំនិងជោគជ័យក្នុងការចាប់ខ្មាំងគឺមានការចូលរួមពីប្រជាជន ប្រធានកង ប្រធានភូមិ គណៈឃុំ និងឈ្លបឃុំ ។ ប្រ-ជាជន ប្រធានកង ប្រធានភូមិ មានភារកិច្ច២គឺ ១) រាយការណ៍ និង២) ចាប់បញ្ជូនខ្លួន ។ នៅពេលពិនិត្យឃើញអំពីទោសកំហុសជាក់ស្តែងច្រើនលើកច្រើនសារបស់ប្រជាជនក្នុងភូមិឬកងរបស់ខ្លួន ប្រធានភូមិឬមេកងចាប់ខ្លួនប្រជាជននោះបញ្ជូនទៅមន្ទីរឈ្លបឃុំ ។ ទោះជាយ៉ាងនេះក៏ដោយ ការចាប់ខ្លួនភាគច្រើនកើតឡើងបន្ទាប់ពីគណៈឃុំនិងប្រធានឈ្លបឃុំពិនិត្យរបាយការណ៍របស់ប្រជាជន ប្រធានភូមិ មេកង រួចបញ្ជាឲ្យឈ្លបឃុំចុះទៅចាប់មនុស្សបញ្ជូនមកមន្ទីរឈ្លបឃុំ ។ ឧទាហរណ៍ ញ៉ែម ម៉ុក ដែលត្រូវចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៧៧ ដោយសារគាត់រអ៊ូរទាំអំពីការខ្វះខាតហូបចុកនិងការធ្វើការងារធ្ងន់ធ្ងរប្រាប់ សឿង ដែលនៅក្នុងកងជាមួយគ្នា ។ សឿង បានទៅរាយការណ៍ឲ្យគណៈឃុំអំពីការរអ៊ូរទាំរបស់ម៉ុក ។ នាង ដាំ គឺជាឧទាហរណ៍មួយទៀត ។ ដាំគឺជាអតីតកម្មាភិបាលមន្ទីរអប់រំស្រុកត្រាំកក់ពីឆ្នាំ១៩៧៣ដល់១៩៧៥ ។ ដោយសារមានកំហុសផ្នែកសង្គមកិច្ច អង្គការបានដក ដាំ ឲ្យមកបម្រើការងារនៅមូលដ្ឋាន ។ ដាំ ត្រូវចាប់ខ្លួនបញ្ជូនទៅឃុំឃាំងនៅមន្ទីរអប់រំស្រុកត្រាំកក់ជាកន្លែងដែលគាត់ធ្លាប់បម្រើការងារក្នុងតួនាទីជាកម្មាភិបាលម្នាក់ ។ ការចាប់ខ្លួនរបស់ ដាំ កើតឡើងដោយសារគាត់និយាយវាយប្រហារបដិវត្តន៍ប្រាប់ ហួ ដែលរស់នៅក្នុងភូមិជាមួយគ្នា ហើយ ហួ បានរាយការណ៍ទៅសមមិត្ត បឿន គណៈឃុំជាថ្មីទេ ។ សេចក្តីរាយការណ៍របស់ ហួ គឺ "ខ្ញុំធ្លាប់នៅនគរបាល ខ្ញុំមើលឃើញបក្សអយុត្តិធម៌ច្រើនជាង (បងឯង) ព្រោះខ្ញុំអនុវត្តផ្ទាល់ដៃ កាប់សម្លាប់អស់ច្រើនណាស់ មិនធ្វើម៉េចនៅក្រោមរដ្ឋអំណាចគេ ។ លើកឡើងដូច យ៉ាង អាយ៉ន ភូមិត្រពាំងគ្នាស្មោះត្រង់នឹងអង្គការយកគ្នាទៅវៃចោល" ។ ក្នុងឆ្នាំ២០០១ ខ្ញុំបានជួបនាង ដាំ នៅផ្ទះរបស់គាត់ដែលស្ថិតនៅក្នុងឃុំឧត្តមសុរិយា ។ ដាំ នៅចាំយ៉ាងច្បាស់អំពីមូលហេតុដែលនាំឲ្យមានការចាប់ខ្លួនគាត់ ។ នៅពេលសំណេះសំណាលជាមួយខ្ញុំ ដាំ បញ្ជាក់ថា "ឯងថាសុទ្ធតែអ្នកធ្លាប់រាប់អានគ្នាបានជានិយាយប្រាប់ ដឹងអីគេ

រាយការណ៍ចាប់ឯងដាក់គុក ។ ដល់ពេលបែកហើយខ្ញុំដើររក ។ ខ្ញុំថាឲ្យតែឃើញកាប់ចោលតែម្តង" ។

នៅថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៧៨ ថុង និង មុត ត្រូវចាប់ខ្លួន ដោយសារប្រធានកងរបស់គាត់មើលឃើញគាត់លួចដកដំឡូង ហើយរាយការណ៍ទៅគណៈឃុំ ។ របាយការណ៍របស់សមមិត្ត បេង ប្រធានកងទី៥ ផ្ញើជូនសមមិត្ត ជន គណៈឃុំពពេល បាន រៀបរាប់អំពីសកម្មភាពលួចដំឡូងរបស់យុវជន២នាក់នៅក្នុងកង ទី៥ ។ "យុវជនទាំង២នាក់នោះមានឈ្មោះ ថុង និងឈ្មោះ មុត" ។

ជា អតីតឈ្លបនៅមន្ទីរឈ្លបឃុំសូភី បានឲ្យដឹងថា គណៈឃុំ និងប្រធានឈ្លបឃុំជាអ្នកបញ្ជាឲ្យឈ្លបចុះចាប់ខ្លួនប្រជាជន ។ ការចាប់ខ្លួនកើតឡើងបន្ទាប់ពីមានការរាយការណ៍ពីប្រជាជន ប្រធានក្រុម ប្រធានភូមិ និងគណៈសហករណ៍ ។ អតីតអនុប្រធាន ឈ្លបឃុំសូភីឈ្មោះ ដើក រៀបរាប់ដំណើរការរបស់មន្ទីរឈ្លបឃុំ តាមវិធីផ្សេងមួយទៀត ។ ដើក បញ្ជាក់ថា ប្រធានក្រុមប្រធាន ភូមិមួយចំនួនបានចាប់ខ្លួនប្រជាជនដែលគាត់ពិនិត្យឃើញថាបាន ធ្វើខុសមកប្រគល់ឲ្យប្រធានឈ្លបឃុំតែម្តង ។

គេង អតីតកម្មាភិបាលឃុំពពេល រៀបរាប់ថា ប្រធានកង ប្រធានភូមិមួយចំនួនទុកឱកាសឲ្យប្រជាជនក្នុងកងក្នុងក្រុមបាន កែខ្លួន២ឬ៣ដងមុននឹងរាយការណ៍ឬចាប់ខ្លួនបញ្ជូនទៅមន្ទីរឈ្លប ឃុំ ។ គេង រៀបរាប់ "ចំពោះខ្ញុំផ្ទាល់ កាលពីខ្ញុំនៅកាន់ភូមិចិន ខ្ញុំ តែងតែណែនាំសមាជិករបស់ខ្ញុំឲ្យប្រឹងធ្វើការ ។ បើនរណាមាន កំហុស ខ្ញុំកសាងខ្លួនឯង ។ ខ្ញុំមិនដែលរាយការណ៍អំពីសមាជិក ណាម្នាក់ក្នុងក្រុមរបស់ខ្ញុំទៅគណៈឃុំទេ" ។ ហួយ អតីតគណៈឃុំ ស្រែជាខាងជើង និងស្រែជាខាងត្បូងក្នុងស្រុកដងទង់ តំបន់៣៥ អះអាងថា ការចាប់ខ្លួនប្រជាជន គឺកើតឡើងតាមរបៀបទាំងពីរ ខាងលើ ។ ការរាយការណ៍និងការចាប់ខ្លួនកើនឡើងខ្លាំងនៅឆ្នាំ ១៩៧៦ហើយបន្តរហូតដល់ចុងឆ្នាំ១៩៧៨ ។

## ទំនាក់ទំនងរវាងមន្ទីរឈ្លបឃុំនិងមន្ទីរអប់រំស្រុក

ការជាប់ឃុំឃាំងរបស់អ្នកទោសមួយចំនួននៅក្នុងមន្ទីរឈ្លប ឃុំគ្រាន់តែជាការឃុំខ្លួនបណ្តោះអាសន្នមុននឹងបញ្ជូនទៅមន្ទីរអប់រំ ស្រុកតែប៉ុណ្ណោះ ។ អ្នកទោសដែលជាប់ឃុំឃាំងបណ្តោះអាសន្ន ក្នុងមន្ទីរឈ្លបឃុំមាន២ប្រភេទ ទី១) ជាប្រជាជនដែលត្រូវចោទ ប្រកាន់ថាជាប់និន្នាការនយោបាយនិងវណ្ណៈនៅក្នុងរបបលន់នល់ និងទី២) ជាអ្នកទោសដែលប្រធានឃុំនិងប្រធានមន្ទីរឈ្លបឃុំ ពិនិត្យឃើញថាបានប្រព្រឹត្តកំហុសបន្ថែមក្នុងពេលជាប់ក្នុងមន្ទីរ ឈ្លបឃុំ ។

គុណ, ផុន, និង ចក់ ត្រូវសមមិត្ត រឿន ប្រធានឈ្លបឃុំសូភី បញ្ជូនទៅមន្ទីរអប់រំស្រុកបាទីបន្ទាប់ពីឃុំឃាំងមួយរយៈនៅមន្ទីរ ឈ្លបឃុំសូភី ។ អ្នកទាំង៣ត្រូវបានចោទប្រកាន់ថាជាខ្សែបណ្តាញ របស់ទាហានលន់នល់ ។ ចក់ រំឮកឡើងវិញថា "ពេលនោះ ដើក ជាអ្នកបញ្ជូនយើងទៅមន្ទីរអប់រំស្រុកបាទី" ។ ដើក បានបក ស្រាយថា "ខ្ញុំធ្លាប់នាំអ្នកទោសពីមន្ទីរឈ្លបឃុំទៅមន្ទីរអប់រំស្រុក ចំនួន ២ដង ប៉ុន្តែខ្ញុំមិនស្គាល់ឈ្មោះអ្នកទោសទេ ហើយក៏មិនមែន ពួចក់ ដែរ" ។ អតីតឈ្លបឃុំសូភីម្នាក់ទៀតឈ្មោះ ញាណ អះអាងថា ដើក ជាអនុប្រធានឈ្លបនិងជាអ្នកដែលទទួលខុស ត្រូវការងារច្រើន ។ ការនាំអ្នកទោសចូលនិងចេញជាភារកិច្ច របស់ប្រធាននិងអនុប្រធានឈ្លប ចំណែកឈ្លបដែលកាលនោះ មានអាយុក្មេងដូចជាគាត់ មិនសូវបានធ្វើការងារបែបនេះឡើយ ព្រោះប្រធានឈ្លបមិនទុកចិត្ត ។ តាមការសង្កេតរបស់ ញាណ មានអ្នកទោសតិចតួចប៉ុណ្ណោះដែលត្រូវបញ្ជូនពីមន្ទីរឈ្លបទៅ មន្ទីរអប់រំស្រុក ។

ឆិល ត្រូវចាប់ខ្លួនបញ្ជូនទៅមន្ទីរឈ្លបឃុំតាលន់ដោយសារ គាត់មិនអាចធ្វើកិច្ចការឲ្យចប់សព្វគ្រប់តាមការកំណត់របស់អង្គការ ដែលឲ្យគាត់ធ្វើឲ្យបានរហាត់ទឹកមួយនិងទូកមួយក្នុងរយៈពេល ១០ថ្ងៃ ។ អ្នកទោសក្នុងមន្ទីរឈ្លបចំនួន៣០នាក់ត្រូវឈ្លបបញ្ជា ឲ្យកាប់ព្រៃទំហំ៧៥ម៉ែត្រគុណនឹង១០០០ម៉ែត្រ ។ ក្នុងរយៈ ពេលស្ថិតក្នុងមន្ទីរឈ្លបឃុំ ឆិល ត្រូវកម្មាភិបាលឃុំតាលន់ឈ្មោះ ហំ ចោទថាជាកា.ហ្សេ.បេ ប្រឆាំងនឹងអង្គការដោយសារ ឆិល និយាយវាយប្រហារកម្មាភិបាលឃុំដែលនាំគ្នាវាយកម្ទេចព្រះពុទ្ធ បដិមានៅក្នុងវត្តពោធិព្រែកស្វែង ។ ឆិល ត្រូវបញ្ជូនបន្តទៅមន្ទីរ អប់រំស្រុកស្អាងដែលមានទីតាំងនៅកោះគរ ។

វ៉ាន់នី បានប្រព្រឹត្តខុស ហើយត្រូវកសាងនិងតម្រូវឲ្យធ្វើ ការងារលត់ដំដោយដឹកប្រឡាយលើកទំនប់ ។ នៅក្នុងដំណាក់ កាលលត់ដំ វ៉ាន់នី បានដេរប្រមាថអ្នកកាប់ដីដែលបានដាក់ក្នុង

ប្តីរបស់គាត់ច្រើនពេក ។ រ៉ាន់នី ត្រូវប្រធានឈ្លបឃុំបញ្ជូនទៅមន្ទីរអប់រំស្រុកត្រាំកក់ ។ "សូមសមមិត្តបងអានជ្រាប! មីនេះវាបានដេរអ្នកកាន់ចបកាប់ដែលកាប់ដីដាក់ឲ្យច្រើន" ។

សាខន អតីតឈ្លបឃុំលំចង់ និង តេង អតីតកម្មាភិបាលឃុំពពេល សុទ្ធតែធ្លាប់ឃើញការបញ្ជូនអ្នកទោសពីមន្ទីរឈ្លបឃុំទៅមន្ទីរអប់រំស្រុក ។ ការអះអាងរបស់ តេង និង សាខន បង្ហាញថាពិតជាមានការបញ្ជូនអ្នកទោសពីមន្ទីរឈ្លបឃុំទៅមន្ទីរអប់រំស្រុកត្រាំកក់ ហើយឯកសារជាច្រើនដែលបានរកឃើញនៅក្នុងស្រុកត្រាំកក់ក៏និយាយអំពីបញ្ហានេះដែរ ។ ឧទាហរណ៍របាយការណ៍ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៧ សមមិត្តជនរាយការណ៍ជូនគណៈស្រុកត្រាំកក់ អំពីការរកឃើញសាច់ញាតិខ្មាំងម្នាក់ឈ្មោះ ថាន នី និងយុវជនរត់ចោលជួរចំនួនពីរនាក់ ។ ខាងក្រោមនេះជាវិធីទាក់ទងរវាងសមមិត្ត ជន គណៈឃុំពពេល និងសមមិត្ត សាន គណៈស្រុកត្រាំកក់ ÷

សូមរាយការណ៍ជូនអង្គការស្រុកត្រាំកក់ជាទីគោរពដូចខាងក្រោមនេះ ÷

នារីនេះឈ្មោះ ថាន នី អាយុ២៤ឆ្នាំ មានកូនម្នាក់ ស្រុកកំណើតនៅក្រុងភ្នំពេញ ឪពុកធ្វើគ្រូបង្រៀន ជាប្រពន្ធរបស់ឈ្មោះ ថៅ នី ទាហានកម្ពុជាក្រោមដែលបានបញ្ជូនទៅពីថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៧៧ ។ ថ្ងៃទី៧ ខែមីនា ឆ្នាំ១៩៧៨ មានយុវជនពីរនាក់ធ្វើដំណើរដោយគ្មានសំបុត្រស្នាម ។ "យើងខ្ញុំសូមបញ្ជូនយុវជនពីរនាក់នេះជូនអង្គការដោះស្រាយ ។ ចំពោះយុវជននេះតាមយើងខ្ញុំសួរថារត់មកពីកំពង់ឆ្នាំង ។ សុំអង្គការជ្រាបហើយទទួលផងចុះ ។ គោរពដោយប្រុងប្រយ័ត្ន" ជន ។

បន្ទាប់ពីទទួលរបាយការណ៍របស់ សមមិត្ត ជន ក្នុងថ្ងៃដដែលនេះ សមមិត្ត សាន លេខាស្រុកត្រាំកក់ បានសម្រេចឲ្យបញ្ជូនអ្នកទោសទៅមន្ទីរអប់រំស្រុក ។ សាន បញ្ជាក់ប្រាប់ អាន់ អំពីករណីខ្មាំងទាំង២នេះថា "សមមិត្ត អាន់ ជ្រាប ។ ពីរនាក់នេះគឺរត់ទៅស្រុកយួនជាមួយពួកអាពីរថ្ងៃមុន ។ ថ្ងៃទី៧ ខែមីនា (១៩៧៨)" ។

ការរាយការណ៍ ចាប់ខ្លួន និងបញ្ជូនខ្លួនដូចខាងលើនេះក៏បានកើតឡើងក្នុងឃុំជាងទងនិងឃុំត្រពាំងធំខាងជើងដែរ ។ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៨ សមមិត្តបឿន គណៈឃុំជាងទង និងសមមិត្ត ម៉េង គណៈឃុំត្រពាំងធំខាងជើង បានរាយការណ៍អំពីសមាសភាពមិនល្អក្នុងឃុំរបស់ខ្លួនជូនគណៈស្រុកត្រាំកក់ ។ សមមិត្ត បឿន រាយការណ៍អំពីសកម្មភាពរបស់ស្ត្រីមេម៉ាយ ពីរនាក់ឈ្មោះ ណៃជី និង ផាណា ថា "១) វាមិនព្រមធ្វើការអ្វីទាំងអស់ ។ ២) កាលពីចុងខែកក្កដាវារត់បាត់មួយយប់ពីរថ្ងៃ ។ បញ្ជាក់ ៈ មីពីរនាក់នេះទុកមិនបានទេ ព្រោះទំនាស់ច្រើនណាស់" ។ បន្ទាប់ពីទទួលបានរបាយការណ៍របស់គណៈឃុំទាំងពីរ សមមិត្ត សាន បញ្ជាឲ្យកម្មាភិបាលមន្ទីរអប់រំស្រុកចុះទៅចាប់ខ្មាំង ÷


ខ្នោះបន្សល់ទុកនៅគុកក្រាំងតាចាន់

សមមិត្ត ឈឿន ជាទីស្នេហា!

ចំពោះអ្នកទោសនៅឃុំជាងទង សូមយកកូនណាដែលបេះមិនដាច់ពីម្តាយ បើកូនធំៗ ទៅនៅកងចល័តកងកុមាររួចទៅហើយឲ្យវានៅទីនោះចុះ ។ សាកសួរអស់រឿងរ៉ាវហើយ កម្ទេចទាំងអស់ចុះ ។ ចំពោះនារីមេម៉ាយមកពីត្រពាំងធំខាងជើងសព្វថ្ងៃនៅកន្លែងសមមិត្តម៉េង សូមកម្ទេចទាំងអស់ចុះ ។ សាន នៅក្នុងរបាយការណ៍បន្តបង្កើនផលសមមិត្ត ឆោម គណៈឃុំអង្គតាសោម បានឆ្លៀតឱកាសសួរយោបល់គណៈស្រុកត្រាំកក់អំពីខ្មាំងដែលគាត់ចាប់ខ្លួនចំនួន២នាក់គឺឈ្មោះ ដួង ផល្លា និង ប៉ែន អូន ។

បុរសទាំងពីរនាក់នេះត្រូវបានចាប់ខ្លួនឃុំឃាំងក្នុងមន្ទីរឈ្លបឃុំអង្គតាសោម ។ តាមរបាយការណ៍របស់សមមិត្ត ឆោម ទោសកំហុសរបស់អ្នកទាំងពីរគឺ "លួចបុកទម្លាយបាវដើម្បីលួចអង្ករដាំបាយស៊ី" ។ សមមិត្ត ឆោម សួរយោបល់គណៈស្រុកត្រាំកក់ថា "តើអង្គការសម្រេចយ៉ាងណា?" បន្ទាប់ពីទទួលបានរបាយការណ៍របស់សមមិត្ត ឆោម ភ្លាម សមមិត្ត សាន សម្រេច "ចំពោះ ដួង ផល្លា និង ប៉ែន អួន នេះខ្ញុំសម្រេចឲ្យ បងឆោម បញ្ជូនមកនគរបាលស្រុក១០៥ ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៧ ។ សាន" ។

ទទួលបានបញ្ជាអំពីគណៈស្រុកភ្លាម គណៈឃុំនិងប្រធាន



ឈ្លបឃុំចាប់ផ្តើមបំពេញភារកិច្ចដែលអង្គការប្រគល់ឲ្យភ្លាមដែរ ។ ដើក ប្រាប់ឲ្យដឹងថា ការចាប់និងបញ្ជូនអ្នកទោសទៅមន្ទីរអប់រំស្រុកធ្វើឡើងតាមបញ្ជារបស់គណៈឃុំឈ្មោះ ភឿង និងប្រធានឈ្លបឃុំឈ្មោះ ទូច និង រឿង ។ ដើក បញ្ជាក់ថា "ជួនកាលបញ្ជាធ្វើឡើងដោយលិខិត និងជួនកាលដោយផ្ទាល់មាត់" ។

គោលបំណងនៃការបញ្ជូនខ្លួនអ្នកទោសពីមន្ទីរឈ្លបឃុំទៅមន្ទីរអប់រំស្រុក គឺដើម្បីសួរចម្លើយតាមដានរកខ្សែសង្វាក់ក្បត់ ។ ឧទាហរណ៍ថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៧៧ សមមិត្ត ភៅ គណៈឃុំស្រែរនោង បានបញ្ជូនខ្លួនអ្នកទោសម្នាក់ជូនអង្គការស្រុកត្រាំកក់ ។ សមមិត្ត ភៅ ចារបញ្ជាក់អំពីអ្នកទោសនោះថា "ឈ្មោះ ចាយ នេះវាឆ្លើយដាក់ម្នាក់ទៀត តែវាមិនព្រមប្រាប់ឈ្មោះសោះ ដូចនេះសុំសួរឲ្យមែនទែន" ។

យុវជន ខុន អតីតទាហានស័ក្តិ៣ ត្រូវចាប់ខ្លួននៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៧ ដោយសារសមមិត្ត ចំ គណៈឃុំឧបត្របែកបានរាយការណ៍អំពីអតីតភាពរបស់គាត់ជូនសមមិត្ត គិត ។ បន្ទាប់ពីពិនិត្យរបាយការណ៍របស់ ចំ រួចហើយ សមមិត្ត គិត បញ្ជាឲ្យ ចំ ចាប់ខ្លួន ខុន បញ្ជូនទៅមន្ទីរអប់រំស្រុកត្រាំកក់ ។ ករណីចាប់ខ្លួនប្រជាជនក្នុងឃុំគុសកើតឡើងតាមរបៀបតែមួយ គឺបន្ទាប់ពីបានពិនិត្យរបាយការណ៍របស់គណៈឃុំគុស សមមិត្ត គិត ចេញលិខិតបញ្ជាឲ្យប្រធានមន្ទីរអប់រំចាត់វិធានការតាមចាប់ខ្លួន : "សមមិត្ត អាន់ ជាទីស្នេហា ស្នើទាក់ទងឃុំគុសចាប់ពួកអស់នេះផង ។ ថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៧ ។ ហត្ថលេខា គិត" ។

ដំណើរការចាប់ខ្លួនប្រជាជនតាមរបៀបនេះក៏បានកើតឡើងនៅស្រុកផ្សេងទៀតក្នុងភូមិភាគនិរតីដែរ ។ នៅមន្ទីរអប់រំស្រុកទ្រាំង ហួយ និង ធួន អតីតកម្មាភិបាលមន្ទីរអប់រំស្រុកទ្រាំង បានឲ្យដឹងថា ការចាប់ខ្លួនប្រជាជនគឺធ្វើឡើងតាមរយៈប្រធានកងមេភូមិ មេឃុំ ។ នៅកងយុវជនមានប្រធានកងជាអ្នករាយការណ៍និងចាប់ ។ នៅក្នុងសហករណ៍មានប្រធានសហករណ៍ ជាអ្នករាយការណ៍និងចាប់ ។ ធួន លើកឧទាហរណ៍មួយមកបង្ហាញថា "អាពុធ (កំបុតដៃម្ខាង) ជាប្រធានយុវជន ។ បើមានយុវជន-យុវនារីណាខុសសីលធម៌ គឺវារាយការណ៍និងឲ្យឈ្លបចុះទៅចាប់ភ្លាម" ។ ដើយ, លី និង មៀន សុទ្ធតែត្រូវគណៈឃុំចាប់បញ្ជូនខ្លួនទៅមន្ទីរអប់រំស្រុកតាមរបៀបតែមួយ ។ អ្នកទាំង៣ត្រូវគណៈសហករណ៍រាយការណ៍អំពីទោសកំហុសទៅប្រធានមន្ទីរអប់រំស្រុក ទើបប្រធានមន្ទីរអប់រំស្រុកសម្រេចឲ្យឈ្លបចាប់ខ្លួន ។ ក្នុងពេលសួរចម្លើយ ដើយ, លី និង មៀន ចាប់អារម្មណ៍ថា ប្រធានមន្ទីរអប់រំបានទទួលរបាយការណ៍អំពីទោសកំហុសរបស់គាត់រួចជាស្រេចទៅហើយ ។ តាមការពិត នៅមុនពេលសួរចម្លើយអ្នកទាំងបីមិនបានដឹងអំពីទោសកំហុសពិតប្រាកដរបស់ខ្លួនឡើយ ។

**(នៅមានត)**

**អៀ ម៉េងទ្រី**

# មេឃុំធ្វើទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញ

*សកម្មភាពរបស់មេឃុំនៅក្នុងដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញលើកទី៥ វគ្គទី១ ដែលមានមេឃុំចំនួន៥១២នាក់ អញ្ជើញមកពីខេត្តស្ទឹងត្រែង ក្រចេះ មណ្ឌលគិរី ព្រៃវែង ស្វាយរៀង កណ្ដាល តាកែវ កំពត កំពង់ស្ពឺ ក្រុងកែប និងក្រុងព្រះសីហនុ ។*













# គុកខ្មែរក្រហម

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលគ្រប់គ្រងអំណាចពីឆ្នាំ១៩៧៥ដល់១៩៧៩ ប្រជាជនកម្ពុជាប្រមាណ មួយលានប្រាំពីរសែននាក់បានត្រូវបាត់បង់ជីវិតដោយការកាប់សម្លាប់, ជំងឺ, ការធ្វើការហួសកម្លាំង និងការហូបមិនឆ្អែត ។ ក្នុងចំណោមនោះ មានអ្នកខ្លះជាអ្នកទោសរបស់ខ្មែរក្រហមដែលត្រូវចោទប្រកាន់ពីបទល្មើសផ្សេងៗ ។

ចាប់ពីឆ្នាំ១៩៧០ ក្រុមខ្មែររំដោះបានបង្កើតមន្ទីរអប់រំតូចៗនៅតាមព្រៃភ្នំ និងនៅទីកំបាំងនានាសម្រាប់អប់រំណែនាំបំពាក់បំប៉នគោលមាគ៌ាបដិវត្តន៍ដល់ប្រជាជននៅតាមជនបទឲ្យជឿ និងគោរពតាមការដឹកនាំរបស់ខ្លួន ។ នៅពេលដំបូងមន្ទីរអប់រំកែប្រែទាំងនេះគ្រាន់តែផ្តល់មតិយោបល់ល្អៗដល់ប្រជាជននៅតាមតំបន់រំដោះដើម្បីឲ្យជឿជាក់លើការដឹកនាំរបស់ខ្លួននៅពេលអនាគតប៉ុណ្ណោះ ។ ប៉ុន្តែក្នុងរយៈពេលជាបន្តបន្ទាប់មកទៀតខ្មែររំដោះបានរឹតបន្តឹងការគ្រប់គ្រងបន្តិចម្តងៗរហូតដល់មានការសម្លាប់មនុស្សជាបណ្តើរៗ ។



រណ្តៅសាកសពដែលរកឃើញក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

ក្រោយជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រចនាសម្ព័ន្ធគ្រប់គ្រងមន្ទីរសន្តិសុខរបស់ខ្មែររំដោះ នៅគ្រប់ទីកន្លែងត្រូវបានកែទម្រង់ទាំងស្រុង ។ មន្ទីរសន្តិសុខមួយចំនួនដែលបង្កើតឡើងដោយខ្មែររំដោះត្រូវបានរំលាយចោល ហើយមួយចំនួនទៀតត្រូវបានពង្រីក និងប្រែក្លាយពីមន្ទីរសន្តិសុខលាក់កំបាំងទៅជាមន្ទីរសន្តិសុខ ដែលទទួលស្គាល់ជាផ្លូវការពីសំណាក់របបខ្មែរក្រហម ។ នៅតាមមន្ទីរសន្តិសុខធំៗដូចជាមន្ទីរសន្តិសុខទួលស្លែង គុកសង់ មន្ទីរសន្តិសុខ១១៣ជាដើម សុទ្ធតែត្រូវកម្មាភិបាលសំខាន់ៗដូចជា ឌុច និង តាម៉ុក ចេញចូលត្រួតពិនិត្យជាញឹកញាប់ ។ ដើម្បីធ្វើឲ្យការគ្រប់គ្រងរបស់ខ្លួននៅតាមបណ្តាភូមិ ឃុំ ស្រុក តំបន់ និងភូមិភាគកាន់តែមានប្រសិទ្ធភាព ខ្មែរក្រហមបានបង្កើតមន្ទីរឃុំឃាំងរាប់រយកន្លែងទៀត ដែលរៀបចំឡើងតាមបែបផែនមួយស្រដៀងៗគ្នាគឺ ទី១) ការចាប់ខ្លួន ទី២) ការឃុំឃាំងនិងសួរចម្លើយ និងទី៣) ការប្រហារជីវិត ។ ចំណែកការទទួលខុសត្រូវគឺជាបន្ទុករបស់កម្មាភិបាលខ្មែរក្រហមមូលដ្ឋានលើកលែងតែមន្ទីរសន្តិសុខទួលស្លែងមួយគត់ដែលគ្រប់គ្រងដោយកម្មាភិបាលជាន់ខ្ពស់របស់បក្សផ្ទាល់ ។ រីឯការដោះលែងវិញគឺមានតិចតួចបំផុតសម្រាប់ប្រជាជនជាអ្នកមូលដ្ឋាន និងអ្នកមានអតីតភាពជាកសិករក្រវណ្ណៈក្រោម ។ អ្នកទោសជាប្រជាជនជម្លៀសរាប់ម៉ឺននាក់បានត្រូវសម្លាប់បន្ទាប់ពីជាប់ឃុំឃាំងមួយរយៈខ្លី ឬមិនទាំងបានឃុំឃាំងផង ។ នៅក្នុងបរិវេណវត្តសូភី ហៅ កកោះ ប្រជាជនជម្លៀសរាប់ពាន់នាក់ត្រូវខ្មែរក្រហមសម្លាប់ដាក់ស្រះទឹកមួយស្ថិតនៅពីមុខព្រះវិហារកាលពីខែមេសា ឆ្នាំ១៩៧៥ ។ ចំណែកនៅខេត្តបាត់ដំបង អ្នកទោសជាប្រជាជនជម្លៀសពីទីក្រុងភ្នំពេញរាប់រយនាក់ត្រូវខ្មែរក្រហមដឹកតាមរថយន្តជាច្រើនគ្រឿងយកទៅសម្លាប់ចោលដោយកុហកថាទៅទទួលសម្តេចឪ ។ នៅខេត្តផ្សេងៗទៀតក៏ដូចគ្នាដែរ អ្នកទោសសុទ្ធតែត្រូវកុហកថា អង្គការបញ្ជូនឲ្យទៅរៀនសូត្រឬផ្លាស់ប្តូរទីលំនៅ ប៉ុន្តែតាមពិតគឺយកទៅសម្លាប់ទាំងអស់ ។

ចាប់តាំងពីឆ្នាំ១៩៧៦ អ្នកទោសមានលាយចម្រុះគ្នារវាងប្រជាជនជម្លៀសនិងប្រជាជនមូលដ្ឋាន។ អ្នកទោសជាប្រជាជនមូលដ្ឋានសុទ្ធតែត្រូវខ្មែរក្រហមស៊ើបដឹងច្បាស់ថា ជាអ្នកជាប់ពាក់ព័ន្ធនឹងនិន្នាការនយោបាយពីសង្គមមុន ជាប់ខ្សែចិន ចាមយួន និងអ្នកដែលមានទ្រព្យសម្បត្តិច្រើន។ បន្ទាប់មកខ្មែរក្រហមបានតាមដានរកប្រជាជនណាដែលប្រព្រឹត្តខុសអង្គការវិន័យ ដូចជាលួចខ្សឹបខ្សៀវគ្នាពេលយប់អធ្រាត្រ ខុសសីលធម៌ ឬលួចទ្រព្យសម្បត្តិសមូហភាព យកមកដាក់ឃុំឃាំងដើម្បីអប់រំណែនាំនិងសម្លាប់ចោល ប៉ុន្តែអ្នកទោសប្រភេទនេះមានតែមួយភាគតូចប៉ុណ្ណោះ។

នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមនៅភូមិភាគបូព៌ាត្រូវអង្គការចោទប្រកាន់ពីបទក្បត់បក្ស ហើយកម្មាភិបាលខាងភូមិភាគនិរតី ជាអ្នកបោសសម្អាតជនក្បត់ និងគ្រប់គ្រងភារកិច្ចទាំងអស់ជំនួសកម្មាភិបាលភូមិភាគបូព៌ាវិញ។ ការសម្លាប់លើកនេះបានកើនឡើងទ្វេដងច្រើនជាងឆ្នាំមុនៗ ជាពិសេសឆ្នាំ១៩៧៨។



រណ្តៅសាកសពដែលរកឃើញក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

មន្ទីរសន្តិសុខ ជាច្រើននៅខេត្តស្វាយរៀង ព្រៃវែង កំពង់ចាម និងក្រចេះ ដែលបង្កើតឡើងតាំងពីឆ្នាំ១៩៧៥មក មិនត្រូវបានរំលាយចោលទេ ព្រោះកម្មាភិបាលខាងភូមិភាគនិរតីជាអ្នកមើលការខុសត្រូវបន្ត ហើយកម្មាភិបាលភូមិភាគបូព៌ាទាំងប៉ុន្មាន បានក្លាយទៅជាអ្នកទោសវិញម្តង។

ក្នុងចំណោមមន្ទីរសន្តិសុខទាំង១៨៩កន្លែងរបស់ខ្មែរក្រហម ដែលបានរកឃើញនៅតាមខេត្ត-ក្រុងទាំង២០ មានទីតាំងភាគតិចបំផុតដែលជាលំនៅឋានរបស់ប្រជាជន។ នៅគ្រប់ខេត្តទូទាំងប្រទេស ខ្មែរក្រហមបានជ្រើសរើសយកវត្តអារាមធ្វើជាមន្ទីរសន្តិសុខ និងជាទីកន្លែងសម្លាប់មនុស្ស។ ព្រះសង្ឃនិងអាចារ្យវត្ត ត្រូវបានចាប់ផ្សឹករួចបណ្តេញឲ្យទៅធ្វើស្រែចម្ការជាមួយប្រជាជនផ្សេងទៀតនៅតាមសហករណ៍ឆ្ងាយៗ។

## ខេត្តកំពង់ឆ្នាំង

### ស្រុកបរិបូរណ៍

#### ១) មន្ទីរសន្តិសុខវត្តសម្តេចមុនី

មន្ទីរសន្តិសុខប្រចាំស្រុក១០ “ស្រុកបរិបូរណ៍” មួយកន្លែងត្រូវបានបង្កើតឡើងនៅក្នុងបរិវេណវត្តសម្តេច មុនី បន្ទាប់ពីមន្ទីរសន្តិសុខនៅវត្តក្រួសត្រូវអង្គការរំលាយចោលកាលពីខែមេសា ឆ្នាំ១៩៧៥។ វត្តសម្តេចមុនី មានទីតាំងស្ថិតនៅក្នុងភូមិដក់ពរ ឃុំខុនរ៉ង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។ ប្រជាជនដែលរស់នៅក្បែររបងវត្ត ត្រូវខ្មែរក្រហមជម្លៀសឲ្យទៅកាន់តំបន់ឆ្ងាយៗ។ ព្រះសង្ឃត្រូវបង្ខំឲ្យលាចាកសិក្ខាបទ។ អាចារ្យនិងគណៈកម្មការវត្ត ត្រូវបណ្តេញចេញដោយគ្មានប្រាប់ពីមូលហេតុ។ របងមួយជាន់ទៀតនៅអែប របងចាស់ប៉ែកខាងមុខ និងខាងជើង ដែលមានបន្លាចម្រូង ត្រូវបានធ្វើឡើងដើម្បីការពារកុំឲ្យអ្នកទោសលួចរត់។ រោងចិញ្ចឹមជ្រូកមួយបានត្រូវខ្មែរក្រហមសាងសង់ឡើងដើម្បីបម្រើឲ្យសហករណ៍ និងមន្ទីរសន្តិសុខវត្តសម្តេចមុនី។ កុដិធំៗពីរ ព្រះវិហារមួយ និងព្រះពុទ្ធប្បដិមាមួយចំនួន ត្រូវកងឈ្លបវាយកម្ទេចចោលទាំងអស់ដើម្បីវាតទីឲ្យធំទូលាយដើម្បីសាងសង់កន្លែងឃុំឃាំងមនុស្ស។ សាលាឆាន់គឺជាកន្លែងធ្វើជី និងផលិតថ្នាំពេទ្យ។ ប្រជាជនត្រូវបានហាមឃាត់មិនឲ្យដើរឆ្លងកាត់ទីវត្ត និងបរិវេណជុំវិញឡើយ។ កម្មាភិបាលប្រចាំមន្ទីរ

សន្តិសុខ ត្រូវបានអនុញ្ញាតិឲ្យចាប់ឃុំឃាំងនូវជនទាំងឡាយណាដែលហ៊ានដើរឆ្លងកាត់បរិវេណហាមឃាត់នេះ ។ ប្រជាជនជាច្រើនដែលជម្លៀសមកពីខេត្តកំពង់ធំ ត្រូវកងឈ្លបចាប់ខ្លួនហើយបញ្ជូនមកដាក់ឃុំឃាំងនៅក្នុងព្រះវិហារ និងក្នុងកុដិធំៗទាំងពីរនៅវត្តសម្តេចមុនី ព្រោះមិនដឹងពីការហាមប្រាមនេះ ។

ស៊ុន ង៉ាន បច្ចុប្បន្នជាអាចារ្យវត្តសម្តេចមុនីបាននិយាយប្រាប់ថា ខ្មែរក្រហមបានចាប់មនុស្សពីគ្រប់កន្លែងក្នុងស្រុកមកដាក់ឃុំឃាំង បន្ទាប់មកយកទៅសម្លាប់ចោលទាំងអស់ ។ នៅឆ្នាំ១៩៧៥ អ្នកទោសដែលជាប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ កំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបង ត្រូវកងឈ្លបផ្ទេរពីមន្ទីរសន្តិសុខវត្តក្រួសមកឃុំឃាំងបន្តនៅមន្ទីរសន្តិសុខវត្តសម្តេចមុនីនេះ ។ អ្នកជាប់គុកចាប់ពីឆ្នាំ១៩៧៦រហូតដល់ឆ្នាំ១៩៧៨ ជាប្រភេទអ្នកខុសសីលធម៌ អ្នកធ្វើខុសនឹងអង្គការវិន័យ អ្នកជាប់និន្នាការពីសង្គមចាស់ អ្នកជាភ្នាក់ងារសេ.អ៊ី.អា. និងអ្នករស់នៅតាមសហករណ៍នានាក្នុងស្រុកបរិបូរណ៍ ។ អតីតលោកគ្រូអនុគណវត្តសម្តេចមុនី បានក្លាយទៅជាអ្នកទោសនៅវត្តនេះដែរ ហើយក្រោយមកត្រូវកងសន្តិសុខសម្លាប់ចោលនៅអែបនឹងរបងវត្តតែម្តង ព្រោះតែព្រះអង្គរឹងទទឹងមិនព្រមសឹកតាមបញ្ជាអង្គការ និងហ៊ានសូត្រធម៌នៅក្នុងព្រះវិហារ ។ វាសនារបស់អ្នកទោសដទៃទៀត ក៏មិនខុសគ្នាដែរ គឺត្រូវបានសម្លាប់ហើយកប់នៅអែបរបងវត្ត ។ អ្នកទោសមួយចំនួនធំទៀត ត្រូវកងសន្តិសុខនាំយកទៅសម្លាប់នៅព្រៃគោកល្វា ព្រៃគោកជ្រុត ភូមិត្នោត ព្រៃពោធិ៍ចារ្យ ព្រៃពោធិ៍តាមឿន និងព្រៃពោធិ៍តាកុយ ។ មុនពេលសម្លាប់ កងឈ្លបបានសួរចម្លើយ និងធ្វើទារុណកម្មអ្នកទោសទាំងនោះជាមុនសិន ។

មាន់ សារិន បាននិយាយប្រាប់ថា វិធីសួរចម្លើយមិនខុសពីគុកទួលស្លែងប៉ុន្មានទេ ព្រោះមានឧបករណ៍ធ្វើទារុណកម្មស្រដៀងគ្នាដូចជា ពាងទឹក អាងទឹក និងខ្សែពួរសម្រាប់ចងជើងអ្នកទោសព្យួរឡើងលើជាដើម ។ ឆាយ យិន និង បូ រស់នៅភូមិត្រពាំងពោធិ៍ ដួន ផល សព្វថ្ងៃធ្វើពេទ្យនៅស្រុកបរិបូរណ៍ ដែលជាអតីតអ្នកទោសនៅមន្ទីរសន្តិសុខវត្តសម្តេចមុនី និងធ្លាប់ទទួលរងការធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរ ។ សារិន បានបន្តថា នៅពេលសួរចម្លើយ អ្នកទោសខ្លះត្រូវកងឈ្លបដុតទាំងរស់ ហើយខ្លះទៀតត្រូវជ្រមុជក្បាលទៅក្នុងទឹកពាងឲ្យថប់ដង្ហើម និងមានអ្នកខ្លះស្លាប់នៅពេលសួរចម្លើយ ហើយខ្លះទៀតស្លាប់ដោយសារអត់អាហារ ។

អ្នកទោសទាំងអស់ត្រូវកងសន្តិសុខបញ្ជាឲ្យធ្វើពលកម្មផ្សេងៗនៅក្នុងបរិវេណវត្ត ។ របបអាហារត្រូវអង្គការ ផ្តល់ឲ្យតែបន្តិចបន្តួចប៉ុណ្ណោះសម្រាប់អ្នកទោសណាដែលអាចធ្វើការបាន និងមិនផ្តល់ឲ្យសោះសម្រាប់អ្នក ដែលធ្វើពលកម្មមិនកើត ។ ស៊ុន ង៉ាន់ បានឃើញអ្នកទោសដើរអូសប្រវាក់ធ្វើការយ៉ាងវេទនានៅក្នុងទីធ្លាវត្ត ។ នៅឆ្នាំ១៩៧៨ អ្នកទោសទាំងអស់ត្រូវកងសន្តិសុខសម្លាប់គ្មានសល់ម្នាក់ ។

នៅដើមឆ្នាំ១៩៧៩ មន្ទីរសន្តិសុខប្រចាំស្រុក១០ត្រូវបានរំលាយចោលបន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រធានសន្តិសុខឈ្មោះ ស្លួន បានរត់គេចខ្លួនបាត់ ចំណែកឈ្មោះ លឹម ជាអនុប្រធានមន្ទីរសន្តិសុខត្រូវប្រជាជនចាប់សម្លាប់ចោល ។ ក្រោយប្រទេសត្រូវបានរំដោះមន្ទីរសន្តិសុខប្រចាំស្រុក១០ បានបន្សល់ទុកសាកសពអ្នកទោសមួយចំនួននិងវត្ថុតាងជាច្រើន ។ សាកសពទាំងនោះត្រូវបានប្រជាជនក្នុងភូមិសែងយកទៅកប់ ។ ចំណែកឯវត្ថុតាងត្រូវប្រមូលទុកដាក់យ៉ាងមានសណ្តាប់ធ្នាប់ ។ បំណែកក្រដាសមួយសន្លឹករបស់ខ្មែរក្រហម ដែល សារិន រើសបានក្នុងមន្ទីរសន្តិសុខ និងប្រគល់ឲ្យទៅ ស៊ុន ង៉ាន់ ដើម្បីរក្សាទុកមានសរសេរពាក្យមួយឃ្លាថា “កម្ទេចបាន៣២.០០០នាក់នៅជុំវិញវត្តសម្តេចតុក” ។ សារិន បាននិយាយរំឭកពីការនាំជនរងគ្រោះមកដាក់ឃុំឃាំង និងសម្លាប់នៅវត្តសម្តេចមុនីថា ចំនួនអ្នកទោសមានលើសពីតួលេខក្នុងក្រដាសដែលខ្មែរក្រហមសរសេរ

ថា មាន៣២.០០០នាក់នោះទៅទៀត។ ការដែល សារិន និយាយដូច្នេះគឺសំអាងទៅលើជនរងគ្រោះដែលកងឈ្លបនាំយក ពីចុងភូមិខាងកើតមាត់ទន្លេ ពីផ្អកច្រូ ពីខេត្តពោធិ៍សាត់ ពីស្រុកបារាយណ៍ ខេត្តកំពង់ធំ មកសម្លាប់នៅពាក់កណ្តាលផ្លូវត្រង់ម្តុំព្រៃស្វាត់ ដោយមិនទាំងបាននាំមកដល់មន្ទីរឃុំឃាំងនៅវត្តសម្តេចមុនីដើម្បីសួរចម្លើយផងទេ។ សារិន បានចូលក្នុងទីវត្តសម្តេចមុនីមុនគេបង្អស់ជាមួយនឹងគណៈឃុំ ស៊ុន ង៉ាន់។ ស៊ុន ង៉ាន់ និយាយថា បានឃើញរនុកសឹកខ្នោះបួនជួរនៅក្នុងព្រះវិហារ និងមានខ្នោះយ៉ាងច្រើននៅក្នុងកុដិធំៗពីរទៀត។ ក្រៅពីនេះ គាត់ឃើញមានស្នាមឈាមប្រឡាក់ជាប់ជញ្ជាំងមន្ទីរសួរចម្លើយនៅឡើយ។ នៅក្បែររណ្តៅជាង១០០ដែលបានគាស់រួច គាត់ឃើញមានដំបង ព្រនង់ ត្បូងចប គល់ពីងពង់ និងដែកក្បៀរទេះ ប្រឡាក់ឈាមគរមួយពំនូក។ សារិន បានចូលរួមគាស់រណ្តៅសាកសពនៅអែបរបងវត្តជាមួយនឹងប្រជាជនដទៃទៀតក្នុងភូមិ ដើម្បីយកអដ្ឋិធាតុមកតម្កល់ទុក។ ខ្នោះឃ្នាងទាំងអស់ ក៏ត្រូវប្រជាជនប្រមូលទុកមួយគំនរដែរ។ ប៉ុន្តែក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ខ្នោះឃ្នាងទាំងអស់នោះត្រូវបានលក់ទៅឲ្យមនុស្សមិនស្គាល់ឈ្មោះម្នាក់ ដោយគ្រាន់តែដឹងថា មនុស្សនោះជាអាណិកជនមកពីប្រទេសក្រៅក្នុងតម្លៃ៣០០ដុល្លារអាមេរិក។ ជាមួយគ្នានេះ កុដិធំដែលជាមន្ទីរសួរចម្លើយនៅជំនាន់ខ្មែរក្រហម ត្រូវបានប្រជាជនរុះរើ ដោយជ្រើសរើសយកតែសសរណានៅល្អប៉ុណ្ណោះដើម្បីកសាងសាលារៀនសម្រាប់ក្មេងៗនៅក្នុងភូមិ។

**ទិន្នន័យសង្ខេប និងការប្រើប្រាស់ម៉ាស៊ីនកំណត់ទីតាំងភូមិសាស្ត្រពិភពលោក**

**ទីតាំង** ៖ វត្តសម្តេចមុនី ស្ថិតនៅក្នុងភូមិដក់ពរ ឃុំខុនរ៉ង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។

**ស្ថិតិ** ៖ មន្ទីរសន្តិសុខប្រចាំស្រុក១០"ស្រុកបរិបូរណ៍" ត្រូវបានបង្កើតឡើងក្នុងវត្តក្រួសនៅឆ្នាំ១៩៧៥ បន្ទាប់មកក៏បានរើទៅដាក់ក្នុងបរិវេណវត្តសម្តេចមុនីវិញនៅឆ្នាំ១៩៧៦ បន្ទាប់ពីវត្តក្រួស ត្រូវខ្មែរក្រហមយកធ្វើជាកន្លែងស្នាក់នៅរបស់ខ្លួន។ អ្នកទោសជាច្រើនបានជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខប្រចាំស្រុក១០ ហើយក្រោយមកបានត្រូវសម្លាប់ចោលទាំងអស់។ ក្រោយ ថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ មន្ទីរសួរចម្លើយនេះត្រូវបានប្រជាជនរុះរើ ហើយផ្នែកខ្លះនៃកុដិដូចជាសសរជាដើម ត្រូវអ្នកស្រុកជញ្ជូនយកទៅធ្វើសាលារៀនសម្រាប់ក្មេងៗក្នុងភូមិ។

**អ្នកផ្តល់ព័ត៌មាន** ៖ ១) ស៊ុន ង៉ាន់ រស់នៅភូមិដក់ពរ ឃុំខុនរ៉ង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។ ២) មាន់ សារិន រស់នៅភូមិដក់ពរ ឃុំខុនរ៉ង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង។

**ទិន្នន័យកុំព្យូទ័រ** ៖ រយៈកម្ពស់ (N) 12º 26' 24:18", រយៈទទឹង (E) 104º 28' 23:30", និងលេខកូដ (ID No.) 040101 ។

## ស្រុកជលគីរី

### ៧) មន្ទីរសន្តិសុខកោះស្វែង

កោះស្វែងជាកោះមួយស្ថិតនៅកណ្តាលទន្លេមេគង្គក្នុងទឹកដីភូមិកោះស្វែង ឃុំកោះថ្កូវ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង និងមានចម្ងាយប្រហែល៨គីឡូម៉ែតពីសាលាស្រុកជលគីរី។ រោងប្រក់ស័ង្កសីប្រាំខ្នងត្រូវបានសាងសង់ ឡើងនៅលើកោះស្វែង ដែលរោងនីមួយៗមានទទឹង១៥ម៉ែត្រ និងបណ្តោយ២០ម៉ែត្រ។ មន្ទីរសន្តិសុខកោះស្វែង ជាសាខាមួយរបស់មន្ទីរសន្តិសុខចុងឈើគ្រាច ដែលជាមន្ទីរសន្តិសុខប្រចាំតំបន់។

រ័ត្ន ហំ អាយុ៤២ឆ្នាំ បច្ចុប្បន្នរស់នៅភូមិកោះថ្កូវ ឃុំកោះថ្កូវ ស្រុកជលគីរីបាននិយាយពីអ្នកទោសនៅមន្ទីរសន្តិសុខកោះស្វែង ថា មានប្រមាណពី២.០០០ទៅ៣.០០០នាក់ ហើយអ្នកទោសទាំងនោះជាប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញពីគ្រប់ឃុំទូទាំងស្រុក អ្នកជាប់និន្នាការនយោបាយពីសង្គមចាស់ និស្សិត និងកម្មាភិបាលខ្មែរក្រហមដែលធ្វើខុសបទបញ្ជារបស់អង្គការ។ តាកណ្តុរ ដែលជាអតីតគណៈស្រុក១៨ កាលពីឆ្នាំ១៩៧៥-៧៦

និងអតីតប្រធានសហករណ៍ព្រៃរាំងឈ្មោះ ត្រា បានត្រូវចាប់ខ្លួន មកដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខកោះស្វែង ព្រោះអង្គការរកឃើញ ថាអ្នកទាំងពីរមានកំហុសខាងសីលធម៌ ។ វើត គឺជាកម្មាភិបាល គ្រប់គ្រងមន្ទីរសន្តិសុខកោះស្វែង តាំងពីដំបូងរហូតដល់មន្ទីរ ត្រូវរលាយនៅឆ្នាំ១៩៧៩ ។ អ្នកទោសទាំងអស់ក្រៅពីអ្នកជាប់ ខ្នោះនៅក្នុងរោង គឺត្រូវធ្វើការងារដាំដុះ និងបង្កបង្កើនផលថែម ទៀត ។ អ្នកទោសត្រូវទទួលការសួរចម្លើយ និងបញ្ជូនទៅសម្លាប់ ជារៀងរាល់ថ្ងៃ ។ អោម សំអឿន អាយុ៤៤ឆ្នាំ ជាអភិបាលរង ទី១ស្រុកជលគិរីបានរៀបរាប់ថា គាត់ធ្លាប់ឃើញ អ្នកទោស អង្គុយទាំងជើងជាប់ខ្នោះជាជួរៗក្នុងរោងឃុំឃាំងដែលមាននៅ លើកោះស្វែងដោយ ផ្ទាល់ភ្នែក ព្រោះកាល នោះគាត់ត្រូវអង្គការ អនុញ្ញាតឲ្យទៅកាន់ កោះស្វែង ដើម្បីយក ក្របីដែលបាត់ហើយ ដែលត្រូវកងសន្តិសុខ រកឃើញនៅទីនោះ ។ នៅចុងឆ្នាំ១៩៧៨ កងសន្តិសុខប្រចាំមន្ទីរបានសម្លាប់អ្នកទោសស្ទើរតែទាំងអស់ ដោយពុំមានការសួរចម្លើយឡើយ ពីព្រោះពួកគេខឹងនឹងអ្នកទោស ទាំងអស់ដែលមិនរាយការណ៍ឲ្យដឹងពីការលួចរត់របស់អ្នកទោស ៤នាក់កាលពីយប់កន្លងមក ។ អ្នកទោសត្រូវនាំយកទៅសម្លាប់ នៅចុងកោះស្វែងតាមវិធីវាយទម្លាក់ទឹក ។ នៅដើមឆ្នាំ១៩៧៩ គឺមុនថ្ងៃរំដោះបន្តិច អ្នកទោសដែលនៅសេសសល់ទាំងប៉ុន្មាន ត្រូវកងសន្តិសុខបាញ់រះសម្លាប់ទាំងអស់នៅក្នុងមន្ទីរឃុំឃាំង ។


រណ្តៅសាកសពដែលរកឃើញក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ វើត ដែលជាអ្នកគ្រប់គ្រង មន្ទីរ និងកម្មាភិបាលមួយចំនួនទៀត ត្រូវប្រជាជនសម្លាប់ ហើយ ខ្លះទៀតបានរត់គេចខ្លួនបាត់អស់ ។ ចំពោះវត្ថុតាងនានាដែលមាន នៅសេសសល់លើកោះស្វែង ត្រូវប្រជាជនប្រមែប្រមូលទុក ដាក់យ៉ាងត្រឹមត្រូវ ។

**ទិន្នន័យសង្ខេប និងការប្រើប្រាស់ម៉ាស៊ីនកំណត់ទីតាំងភូមិសាស្ត្រពិភពលោក**

**ទីតាំង** ៖ កោះស្វែងជាកោះមួយស្ថិតនៅកណ្តាលទន្លេមេគង្គ ក្នុងទឹកដីភូមិកោះស្វែង ឃុំកោះថ្កូវ ស្រុកជលគិរី ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** ៖ កោះស្វែងត្រូវបានជ្រើសរើសយកធ្វើជាមន្ទីរសន្តិសុខដើម្បីឃុំឃាំងអ្នកទោសប្រមាណពី២.០០០ទៅ៣.០០០ នាក់តាំងពីឆ្នាំ១៩៧៥ម៉្លេះ ។ អ្នកទោសម្នាក់ៗត្រូវឆ្លងកាត់ការ ឃុំឃាំងសួរចម្លើយនិង សម្លាប់តាមវិធីវាយ ទម្លាក់ទឹកទន្លេនិងបាញ់ រះដោយកាំភ្លើង ។ ក្រោយថ្ងៃរំដោះឆ្នាំ ១៩៧៩ វើត ដែលជា ប្រធានមន្ទីរសន្តិសុខ ត្រូវបានសម្លាប់រួមជា មួយនឹងបក្ខពួករបស់ ខ្លួន ហើយមួយចំនួនទៀតបានរត់ភៀសខ្លួនទៅកាន់កន្លែងផ្សេងៗ ។

**អ្នកផ្តល់ព័ត៌មាន** ៖ ១) អោម សំអឿន ជាអភិបាលរងទី១ ស្រុកជលគិរី ។ ២) រ័ត្ន ហំ រស់នៅភូមិកោះថ្កូវ ឃុំកោះថ្កូវ ស្រុក ជលគិរី ខេត្តកំពង់ឆ្នាំង ។

**ទិន្នន័យកុំព្យូទ័រ** ៖ រយៈកម្ពស់ (N) 12º 07' 04:54", រយៈទទឹង (E) 104º 48' 10:63", និងលេខកូដ (ID No.) 040201 ។

## ស្រុកកំពង់លែង

### ៣) មន្ទីរសន្តិសុខព្រៃខ្សាច់ "មន្ទីរតាបេង"

មន្ទីរសន្តិសុខមួយកន្លែងត្រូវបានបង្កើតឡើងបន្ទាប់ពីមូលដ្ឋាន កងទ័ពរបស់ខ្មែររំដោះនៅស្រុកកំពង់លែង ត្រូវរំលាយចោល

ក្រោយថ្ងៃជ័យជម្នះទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ មន្ទីរសន្តិសុខនេះមានឈ្មោះហៅថា មន្ទីរព្រៃខ្សាច់ ឬមន្ទីរតាបេង ។ តាបេង ជាមេខ្មែររំដោះម្នាក់នៅស្រុកកំពង់លែង ដែលបានបង្កើតមូលដ្ឋានកងទ័ពមួយកន្លែងតាំងពីឆ្នាំ១៩៧០ បន្ទាប់ពីការផ្តួលរំលំរបបរាជានិយមនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ តាបេង ជាអ្នកគ្រប់គ្រងមូលដ្ឋាននេះដោយផ្ទាល់តាំងពីឆ្នាំ១៩៧០ រហូតដល់ ខែមេសា ឆ្នាំ១៩៧៥ ។ នៅឆ្នាំ១៩៧៣ មូលដ្ឋានកងទ័ពនេះ បានបង្កើតមន្ទីរឃុំឃាំងមួយសម្រាប់ឃុំឃាំងតែប្រភេទអ្នកទោសជាទាហានរបបសាធារណរដ្ឋខ្មែរដែលចាប់បាននៅពេលប្រយុទ្ធគ្នាប៉ុណ្ណោះ ។ ឈ្លើយសឹកដែលចាប់បានត្រូវខ្មែរក្រហមសម្លាប់ទាំងអស់ នៅមុនថ្ងៃជ័យជម្នះខែមេសា ឆ្នាំ១៩៧៥ ។ ម៉ី សាឡន បច្ចុប្បន្នរស់នៅ ភូមិល្ងាឃុំស្វាយរំពា ស្រុកកំពង់លែង បានប្រាប់ថា ចាប់តាំងពីឆ្នាំ១៩៧៥មក ជនរងគ្រោះដែលខ្មែរក្រហមបញ្ជូនមកកាន់មន្ទីរសន្តិសុខព្រៃខ្សាច់ ឬមន្ទីរ តាបេង សុទ្ធតែជា ប្រជាជនជម្លៀសទាំងគ្រួសារៗ អ្នកខុសសីលធម៌ និងអ្នកជាប់និន្នាការនយោបាយពីសង្គមចាស់ ។ ក្នុងឆ្នាំដដែលនោះ តាបេង ត្រូវអង្គការផ្លាស់ចេញ ហើយ ម៉ែត បានចូល មកគ្រប់គ្រងមន្ទីរសន្តិសុខព្រៃខ្សាច់ជំនួសតាបេង វិញ ។ មួយរយៈ ក្រោយមក មន្ទីរសន្តិសុខនេះបានត្រូវពង្រីកកាន់តែធំជាងមុន ហើយការបញ្ជូនអ្នកទោសមកមន្ទីរសន្តិសុខក៏កើនឡើងដែរ ។ បន្ទាប់ពីឆ្នាំ១៩៧៦ អ្នកទោសចាស់ត្រូវកងឈ្លបនាំយកទៅសម្លាប់អស់មួយចំនួនធំ ហើយយកអ្នកទោសថ្មីៗមកដាក់បន្ថែមទៀត ដោយកុហកប្រជាជនដែលរស់នៅតាមសហករណ៍នានា ក្នុងឃុំ-ស្រុកថា ឲ្យមកធ្វើប្រវត្តិរូប ដើម្បីចម្រាញ់អ្នកជាប់និន្នាការនយោបាយទៅបំពាក់បំប៉នឲ្យយល់ពីមាគ៌ាបដិវត្ត ។ អ្នកទោសត្រូវបាននាំយកទៅសម្លាប់ទាំងគ្រួសារៗនៅព្រៃខ្សាច់ស អូរតាប៊ុន និងនៅក្បាលខ្មោច ។ ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខព្រៃខ្សាច់ចាប់ពីឆ្នាំ១៩៧៥រហូតដល់ចុងឆ្នាំ១៩៧៨ មានប្រហែល៦.០០០នាក់ និងស្លាប់នៅក្នុងរណ្តៅរាប់រយ ។


រណ្តៅសាកសពដែលរកឃើញក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

បន្ទាប់ពីថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ មន្ទីរសន្តិសុខតាបេង បានរលត់រលាយដោយគ្មានបន្សល់ទុកភស្តុតាងអ្វីឡើយ ។ នៅអំឡុងទសវត្សរ៍៨០ អតីតមន្ទីរសន្តិសុខព្រៃខ្សាច់បានក្លាយជាទីតាំងរបស់កងសេនាជន ប្រចាំឃុំស្វាយរំពានៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយដែលកាលនោះមានឈ្មោះ ជា ជាប្រធាន ។

**ទិន្នន័យសង្ខេប និងការប្រើប្រាស់ម៉ាស៊ីនកំណត់ទីតាំងភូមិសាស្ត្រពិភពលោក**

**ទីតាំង :** មន្ទីរសន្តិសុខព្រៃខ្សាច់ "មន្ទីរតាបេង" មានទីតាំងស្ថិតនៅក្នុងភូមិល្ងា ឃុំស្វាយរំពារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ :** មន្ទីរសន្តិសុខព្រៃខ្សាច់ ឬមន្ទីរតាបេង បានបង្កើតឡើងតាំងពីឆ្នាំ១៩៧០ ដើម្បីឃុំឃាំងឈ្លើយសឹក ។ នៅក្រោយថ្ងៃរំដោះខែមេសា ឆ្នាំ១៩៧៥ មន្ទីរនេះបានប្រែក្លាយទាំងស្រុងទៅជាមន្ទីរសន្តិសុខដែលមានឃុំឃាំងប្រជាជនជាអ្នកជម្លៀស អ្នកជាប់និន្នាការ និងអ្នកមូលដ្ឋាន ដែលប្រព្រឹត្តខុសឆ្គងនឹងអង្គការបដិវត្តន៍ ។

**អ្នកផ្តល់ព័ត៌មាន** ៖ មុី សាឡុន រស់នៅក្នុងភូមិល្វា ឃុំស្វាយរំពា ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

**ទិន្នន័យកុំព្យូទ័រ** ៖ រយៈកម្ពស់ (N) 12º 19' 15:21", រយៈទទឹង (E) 104º 47' 22:08", និងលេខកូដ (ID No.) 040402 ។

## ស្រុកកំពង់លែង

### ៤) មន្ទីរសន្តិសុខរកបាល

ផ្ទះក្បឿងចំនួនបីខ្នងនៅក្នុងឃុំត្រងិល ស្រុកកំពង់លែង ត្រូវខ្មែរក្រហមប្រើប្រាស់ធ្វើជាមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងអ្នកទោសប្រភេទធ្ងន់ ។ ដំបូងឡើយមានតែអ្នកទោសប្រមាណ ២០ នាក់ប៉ុណ្ណោះដែលជាប់នៅក្នុងមន្ទីរឃុំឃាំងនេះ ។ អ្នកទោសម្នាក់ៗសុទ្ធតែជាប់ខ្នោះដៃ ជើង និងចង្កេះ ។ នៅពេលក្រោយៗមកទើបមានអ្នកទោសជាប់នៅក្នុងមន្ទីរឃុំឃាំងរកបាលនេះកាន់តែច្រើនឡើងៗ ។ អៀម យ៉ុម រស់នៅឃុំត្រងិល ស្រុកកំពង់លែង បានរៀបរាប់ថា នៅពេលដែលគាត់ដើររកដីកក្តួច គាត់បានសង្កេតឃើញអ្នកទោសជាច្រើននាក់ជាប់នៅលើផ្ទះទាំងបីក្នុងមន្ទីរសន្តិសុខរកបាលនេះ ។ អ្នកទាំងនោះត្រូវកងឈ្លបសម្ងាប់នៅប៉ែកខាងជើងខាងត្បូងនិងខាងលិចមន្ទីរសន្តិសុខ ។ នៅឆ្នាំ១៩៨១ រណ្តៅទាំងអស់ត្រូវប្រជាជនគាស់កកាយដើម្បីស្វែងរកមាស ។ អដ្ឋិធាតុដែលនៅលើដីពាសវាលកាលត្រូវបាននាំយកទៅដាក់តម្កល់ក្នុងសាលារៀនមួយ នៅឃុំត្រងិល ។ កេត ស្រឿន ដែលរស់នៅឃុំត្រងិល ស្រុកកំពង់លែង បានជួយជីកគាស់ និងរើក្បាលខ្មោចចេញពីរណ្តៅទៀតដែរ ។ បច្ចុប្បន្ននេះ អតីតមន្ទីរសន្តិសុខរកបាលគឺជាព្រៃឫស្សីយ៉ាងក្រាស់និងមានដើមត្នោតដុះជុំវិញ ។

**ទិន្នន័យសង្ខេប និងការប្រើប្រាស់ម៉ាស៊ីនកំណត់ទីតាំងភូមិសាស្ត្រពិភពលោក**

**ទីតាំង** ៖ មន្ទីរសន្តិសុខរកបាល ស្ថិតនៅក្នុងឃុំត្រងិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

**ស្ថិតិ** ៖ មន្ទីរសន្តិសុខរកបាលពុំមានសាងសង់រោងសម្រាប់ឃុំឃាំងជនរងគ្រោះឡើយ ប៉ុន្តែខ្មែរក្រហមបានយកផ្ទះប្រជាជនចំនួនបីខ្នងធ្វើជាមន្ទីរសន្តិសុខតែម្តង ។ មន្ទីរនេះត្រូវបានបង្កើតឡើងភ្លាមៗ បន្ទាប់ពីពេលបែកភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

**អ្នកផ្តល់ព័ត៌មាន** ៖ ១) អៀម យ៉ុម រស់នៅឃុំត្រងិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។ ២) កេត ស្រឿន រស់នៅឃុំត្រងិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។

**ទិន្នន័យកុំព្យូទ័រ** ៖ រយៈកម្ពស់ (N) 12º 17' 06:70", រយៈទទឹង (E) 104º 43' 37:02", និងលេខកូដ (ID No.) 040404 ។

**(នៅមានត)**

**ផេង ពង្សរ៉ាស៊ី**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ៖

- វិទ្យុ FM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ល្ងាច ។
- វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង ៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០ រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ឡាត់ សោភ័ណ និង ឡេង រតនៈ**

# អង្គជំនុំជម្រះវិសាមញ្ញ ៖ សំណូមពរឱ្យមានអង្គភាពវាយតម្លៃដែលមានជំនាញច្បាស់លាស់និងសុចរិតភាព

ខណៈដែលមតិសាធារណៈផ្តោតលើក្តីសង្ឃឹមផ្សេងៗគ្នាចេញពីតុលាការពិសេសនៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ដូចជាយុត្តិធម៌តាមច្បាប់ព្រហ្មទណ្ឌ យុត្តិធម៌សង្គម និងការធ្វើឲ្យរសាយចិត្តនោះ ក៏មានការលើកឡើងផងដែរថាតើអានុភាពគតិយុត្តិនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលហៅកាត់ថា "កិច្ចព្រមព្រៀង"និងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលហៅកាត់ថា"ច្បាប់ពិសេស"មានលក្ខណៈយ៉ាងដូចម្តេចនៅក្នុងប្រព័ន្ធច្បាប់ក្នុងស្រុករបស់កម្ពុជានិងច្បាប់អន្តរជាតិ ។ តើនៅពេលដែលភាគីណាមួយមិនអនុវត្តតាមកិច្ចព្រមព្រៀងនេះនឹងមានអ្វីកើតឡើងទាក់ទងនឹងការបកស្រាយនិងអនុវត្តច្បាប់ដែលពាក់ព័ន្ធនេះ? ។ ដើម្បីបង្ការកុំឲ្យមានបញ្ហាជាយថាហេតុកើតឡើង គួរតែមានយន្តការអ្វីខ្លះ? មុននឹងចូលដល់ការវិភាគស៊ីជម្រៅអំពីបញ្ហាទាំងនេះជាការចាំបាច់ត្រូវស្វែងយល់ប្រវត្តិសង្ខេបទាក់ទងនឹងការបង្កើតច្បាប់ទាំងពីរនេះបន្តិច ។

ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧ សហនាយករដ្ឋមន្ត្រីកម្ពុជាបានស្នើដល់អង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិឲ្យជួយជ្រោមជ្រែងក្នុងការកាត់សេចក្តីជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រោយពីចរចាអស់រយៈពេលជាច្រើនឆ្នាំរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដោយមានការជួយអន្តរាគមន៍ពីបណ្តារដ្ឋនានាដូចជាជប៉ុន បារាំង សហរដ្ឋអាមេរិក អូស្ត្រាលី ឥណ្ឌា និង ហ្វីលីពីន និងបណ្តាអង្គការមួយចំនួនទៀត ក៏បានលេចឡើងជាច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាអនុម័តនៅឆ្នាំ២០០១"ហៅកាត់ថាច្បាប់ពិសេស" និងវិសោធនកម្មនៅឆ្នាំ២០០៤និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ហៅកាត់ថា "កិច្ចព្រមព្រៀង" ។នៅខែឧសភា ឆ្នាំ២០០៣ មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តយល់ព្រមទៅលើកិច្ចព្រមព្រៀងមួយផ្តល់នូវជំនួយអង្គការសហប្រជាជាតិក្នុងការរៀបចំបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ នៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០០៣ អង្គការសហប្រជាជាតិចុះកិច្ចព្រមព្រៀងនៅសាលចតុមុខ ។ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤ សភាជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តទៅលើកិច្ចព្រមព្រៀង ហើយនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០០៥ កិច្ចព្រមព្រៀងនេះ បានចូលជាធរមាន ។

អត្ថបទនេះមានគោលបំណងលើកឡើងនូវគោលបំណងនៃការបង្កើតច្បាប់ទាំងពីរ ចរិតលក្ខណៈ នៃអង្គជំនុំជម្រះវិសាមញ្ញ អានុភាពគតិយុត្តិ កាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់អន្តរជាតិដែលទាក់ទងជាពិសេសការអនុវត្តទៅនិងការចាប់ខ្លួនជនសង្ស័យ វិបាកកើតចេញពីការមិនគោរពកិច្ចព្រមព្រៀង វិធីសាស្ត្រក្នុងការវាយតម្លៃទៅលើដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញ និងការដោះស្រាយវិវាទប្រសិនបើមាន ។ គោលគំនិតនៃអត្ថបទនេះមិនចង់រិះគន់អំពីច្បាប់ទាំងនេះទេ ប៉ុន្តែខ្ញុំចង់ផ្តល់ជូននូវការបរិយាយត្រួសៗអំពីអ្វីដែលអាចកើតឡើងចេញពីច្បាប់ពិសេសនិងកិច្ចព្រមព្រៀងជាពិសេសទាក់ទងនឹងច្បាប់អន្តរជាតិដែលពាក់ព័ន្ធ ។

## គោលបំណងនិងលក្ខណៈអង្គជំនុំជម្រះវិសាមញ្ញ

គោលបំណងនៃការបង្កើតយន្តការតាមផ្លូវតុលាការនេះមានគោលដៅពីរច្បាស់លាស់ ។ ទីមួយ គឺដើម្បីដោះស្រាយនូវបញ្ហានិទ្ទណ្ឌភាព ។ ដូចយើងជ្រាបស្រាប់ហើយ ក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យចំនួន២៧ឆ្នាំមកនេះពុំទាន់មានយន្តការដ៏មានប្រសិទ្ធភាពណាមួយទោះជាផ្លូវច្បាប់ ឬនយោបាយក្តីក្នុងការដោះស្រាយនូវបទឧក្រិដ្ឋនានាដែលត្រូវបានដាក់កំហុសទៅលើមេដឹកនាំជាន់ខ្ពស់ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។ គោលបំណងទីពីរ គឺការរក្សាបាននូវអធិបតេយ្យភាពរបស់ព្រះរាជា-

ណាចក្រកម្ពុជា ។ ចំណុចនេះស្តែងឲ្យឃើញតាមរយៈការបង្កើតចេញនូវរូបមន្ត"មតិភាគច្រើនលើសលុប" ពោលគឺ មានសហព្រះរាជអាជ្ញា និងសហចៅក្រមចម្រុះជាតិនិងអន្តរជាតិ ។

អង្គជំនុំជម្រះវិសាមញ្ញនេះត្រូវបានអ្នកស្រាវជ្រាវផ្នែកយុត្តិធម៌សម័យអន្តរកាលហៅថា តុលាការជំនាន់ទី៣ ។ តុលាការជំនាន់ទី១ នោះមានដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិនៅប្រទេសរ៉្វាន់ដា និងអតីតយូហ្គោស្លាវី ។ តុលាការជំនាន់ទីពីរគឺតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ។ ចំណែក តុលាការជំនាន់ទី៣ គឺច្បាប់លេខ៦៤ ដែលបង្កើតអង្គជំនុំជម្រះនៅកូសូវ៉ូ និងនៅប្រទេសទីម័រខាងកើត ព្រមទាំងអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ។ អង្គជំនុំជម្រះវិសាមញ្ញមានលក្ខណៈខុសគ្នាជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗទៀតនៅត្រង់ថា តុលាការព្រហ្មទណ្ឌទាំងនោះបង្កើតឡើងក្នុងលក្ខណៈចាំបាច់សម្រាប់នាំមកនូវការស្តារឡើងវិញនូវសន្តិភាព និងសន្តិសុខអន្តរជាតិ ដោយយោលតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិក្រោមជំពូកទីVII ។ ឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីត្រូវបានបង្កើតឡើងដោយអនុលោមតាមសេចក្តី សម្រេចលេខ៨២៧ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៩៣ ។ តុលាការព្រហ្មទណ្ឌពិសេសសម្រាប់ប្រទេសរ៉្វាន់ដាស្ថាបនាឡើង តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខលេខ៩៥៥ ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ ។ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខមួយទៀតទាក់ទងនឹងការផ្តល់វត្តមានអន្តរជាតិជាលក្ខណៈស៊ីវិលនៅក្នុងប្រទេសកូសូវ៉ូ ដើម្បីគ្រប់គ្រងប្រទេសនេះ ជាបណ្តោះអាសន្ន ។ ការគ្រប់គ្រងប្រទេសទីម័រខាងកើត នៅក្នុងសម័យអន្តរកាលក៏ធ្វើឡើងដោយមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខពិភពលោកនេះផងដែរគឺលេខ១២៧២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩៩ ។ ក៏ប៉ុន្តែការចេញសេចក្តីសម្រេចទាំងនេះ មិនមែនជាការងាយស្រួលឡើយ បើខ្វះឆន្ទះរបស់បណ្តាប្រទេសមហាអំណាច ជាពិសេសរដ្ឋជាសមាជិកអចិន្ត្រៃយ៍ទាំង៥ ។ ការលំបាកនេះបានកើតឡើងរួចហើយមកលើប្រទេសកម្ពុជាក្នុងពេលដែលកម្ពុជាប្រជាធិបតេយ្យកំពុងកាន់អំណាច និងរយៈពេលក្រោយមកទៀតនៅពេលដែលរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាគ្រប់គ្រងអំណាច ។ ប៉ុន្តែដោយសារអត្ថបទនេះមិនពិភាក្សាអំពីបញ្ហានេះ ខ្ញុំក៏មិនអាចនិយាយឲ្យបានលម្អិតផងទេ ។


មេឃុំចូលរួមស្តាប់ការស្រាយបំភ្លឺរបស់មន្ត្រីតុលាការនៅក្នុងសវនាការអង្គជំនុំជម្រះវិសាមញ្ញ

អង្គជំនុំជម្រះវិសាមញ្ញមិនមែនជាអង្គតុលាការដែលបង្កើតឡើងដោយសន្ធិសញ្ញាដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិ "អាយស៊ីស៊ី"នោះទេ ។ កិច្ចព្រមព្រៀងមិនមែនជាច្បាប់ស្នូលក្នុងការកាត់សេចក្តី បទឧក្រិដ្ឋដែលកើតឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ច្បាប់ដែលសំខាន់សម្រាប់ យកមកអនុវត្តផ្ទាល់គឺជាច្បាប់ពិសេស ។ កិច្ចព្រមព្រៀងធ្វើឡើងគ្រាន់តែដើម្បី"កំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា"ប៉ុណ្ណោះ ។ ទោះជាយ៉ាងណាច្បាប់ទាំងពីរនេះមានលក្ខណៈគតិយុត្តិដូចគ្នាដែលអាចអនុវត្តបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ការតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់អន្តរជាតិ

ចំពោះការអនុវត្តជាទូទៅ ៖ អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់សន្ធិសញ្ញាមាត្រា២(១) “ក-សន្ធិសញ្ញាមានន័យថាជាកិច្ចព្រមព្រៀងរវាងរដ្ឋនិងរដ្ឋក្នុងទម្រង់ជាលាយលក្ខណ៍អក្សរនិងគ្រប់គ្រងដោយច្បាប់អន្តរជាតិ ទោះជាស្ថិតនៅក្នុងលិខិតូបករណ៍មួយឬពីរ ឬច្រើនដែលទាក់ទងគ្នា និងទោះជាមានគោលបំណងជាក់លាក់ណាមួយក៏ដោយ ។ ដូចនេះយើងឃើញថាកិច្ចព្រមព្រៀងនេះ មិនមែនជាសន្ធិសញ្ញារវាងរដ្ឋនិងរដ្ឋទេ ហើយពុំមានអង្គភាពឬច្បាប់ណាគ្រប់គ្រងលើកិច្ចព្រមព្រៀងនេះទេ ។ ចំណែកឯ អនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៨៦ ស្តីពីច្បាប់សន្ធិសញ្ញារវាងរដ្ឋនិងអង្គការអន្តរជាតិ ឬរវាងអង្គការអន្តរជាតិដូចគ្នានោះមិនទាន់ចូលជាធរមាននៅឡើយ ។ តាមរយៈមាត្រា២(២) កិច្ចព្រមព្រៀងនេះ ភាគីទាំងពីរទទួលយកនូវការអនុវត្តទៅតាមអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់សន្ធិសញ្ញា១៩៦៩ ។ កម្ពុជាពុំអាចយកហេតុផលផ្សេងៗ ដោយផ្អែកលើច្បាប់ក្នុងស្រុករួចមិនអនុវត្តកាតព្វកិច្ចអន្តរជាតិនោះទេ ។ ប៉ុន្តែនេះមិនមែនជាបញ្ហាទេ ។ កិច្ចព្រមព្រៀងនិងច្បាប់ពិសេស រួមទាំងការអះអាងរបស់មន្ត្រី អង្គជំនុំជម្រះវិសាមញ្ញសុទ្ធតែមានលក្ខណៈស្របគ្នាថាបើច្បាប់ក្នុងស្រុកមិនគ្រប់គ្រាន់នឹងមានការស្វែងរកមកបំពេញបន្ថែមនូវបទដ្ឋានឬច្បាប់នានាដែលមានលក្ខណៈអន្តរជាតិ ។ ហាក់ដូចជាគ្មានមន្ទិលសង្ស័យទេថាការយោងទៅលើច្បាប់អន្តរជាតិនេះគឺផ្តោតតែទៅលើច្បាប់នីតិវិធីប៉ុណ្ណោះពោលមិនផ្តោតទៅលើច្បាប់សារធាតុដែលកំណត់នៅក្នុងច្បាប់ពិសេសនោះឡើយ ។

## ការនាំខ្លួនជនសង្ស័យ

ដូចបានបង្ហាញស្រាប់ហើយថាអង្គជំនុំជម្រះវិសាមញ្ញបង្កើតឡើងដោយកិច្ចព្រមព្រៀងរវាងអង្គការអន្តររដ្ឋាភិបាល (អង្គការសហប្រជាជាតិ) និងព្រះរាជាណាចក្រកម្ពុជា ដែលខុសពីអង្គតុលាការអន្តរជាតិពិសេស ឬក្អូនកាត់ផ្សេងៗនៅលើពិភពលោក ។ ក្នុងករណីអង្គជំនុំជម្រះវិសាមញ្ញ អង្គការសហប្រជាជាតិពុំមានសិទ្ធិចាប់បង្ខំព្រះរាជាណាចក្រកម្ពុជានិងរដ្ឋជាសមាជិកដទៃទៀតឲ្យធ្វើអ្វីលើសពីកិច្ចព្រមព្រៀងឡើយដោយសារខ្វះអំណាចដែលផ្តល់តាមរយៈជំពូកទីVII នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។ ដោយសារតែពុំមានសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខនេះហើយបានជាត្រូវការពេលយ៉ាងយូរទាក់ទងនឹងការរៀបចំរចនាសម្ព័ន្ធ សមាសភាព និងច្បាប់សម្រាប់អនុវត្តនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ដែលកម្ពុជាទាមទារនូវអធិបតេយ្យភាពស្របច្បាប់របស់ខ្លួនទៅតាមធម្មនុញ្ញអង្គការសហប្រជាជាតិ ។

មាត្រា២៥ នៃកិច្ចព្រមព្រៀងបង្កើតជាកាតព្វកិច្ចដល់កម្ពុជាឲ្យអនុវត្ត “ដោយគ្មានការពន្យារពេលតាមការស្នើសុំជំនួយរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ឬអង្គជំនុំជម្រះវិសាមញ្ញ” ។ ការស្នើសុំនិងបទបញ្ជារបស់មន្ត្រីតុលាការនិងតុលាការនេះរួមមានការរកអត្តសញ្ញាណនិងទីកន្លែងរបស់បុគ្គលណាមួយ ការផ្តល់ឯកសារ ការចាប់ខ្លួនឬឃុំខ្លួន និងការបញ្ជូនជនជាប់ចោទមកកាន់អង្គជំនុំជម្រះវិសាមញ្ញ ។ សកម្មភាពទាំងនេះមិនមែនជាការងាយស្រួលឡើយ ។ ជនសង្ស័យអាចគេចខ្លួនទៅជ្រក នៅប្រទេសផ្សេងៗនៅលើពិភពលោក ហើយការស្វែងរកឬនាំខ្លួនជនទាំងនេះត្រូវការសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរនៃប្រទេសដែលទទួលជនសង្ស័យនេះ ។ យោងតាមធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខមានលក្ខណៈចាប់បង្ខំឲ្យរដ្ឋជាសមាជិកអង្គការសហប្រជាជាតិអនុវត្តទៅតាមខ្លឹមសារនៃសេចក្តីសម្រេចនោះ ។ ប៉ុន្តែក្នុងករណីអង្គជំនុំជម្រះវិសាមញ្ញ ព្រះរាជាណាចក្រកម្ពុជា ត្រូវការចុះកិច្ចព្រមព្រៀងបត្យាប័នជាមួយប្រទេសនានាដែលអាចជាជម្រករបស់ជនសង្ស័យដើម្បីសម្រួលការនាំខ្លួនទៅតាមដីការបស់តុលាការពិសេសនេះ ។ ទោះជាយ៉ាងណា ក៏មានសញ្ញាល្អមួយចំនួនដែរទាក់ទងនឹងការជួយគ្នាទៅវិញទៅមកទាក់ទងនឹងការបញ្ជូនខ្លួនឧក្រិដ្ឋជនពីប្រទេសកម្ពុជាទៅប្រទេសផ្សេងៗទៀត ។ ជាអាទិ៍ ប្រទេសថៃបានសំដែងសុឆន្ទៈក្នុងការផ្តល់កិច្ចសហប្រតិបត្តិការក្នុងបញ្ហានេះដូចដែលរបាយការណ៍របស់ក្រុមអ្នកជំនាញការច្បាប់របស់អង្គការសហប្រជាជាតិបានបញ្ជាក់ស្រាប់ ។

## វិបាកដែលអាចកើតចេញពីការមិនព្រមអនុវត្តតាមកិច្ចព្រមព្រៀងនិងយន្តការដែលមាន

កិច្ចព្រមព្រៀងនេះមិនបានចែងបទបញ្ញត្តិច្រើនស្តីអំពីការដាក់ពិន័យដល់ភាគីណាមួយដែលពុំបានអនុវត្តតាមនោះទេ ។ ច្បាប់នេះគ្រាន់តែផ្តល់ជាការព្រមានរបស់ភាគីមួយទៅលើភាគី

មួយទៀតប៉ុណ្ណោះ ពោលគឺអង្គការសហប្រជាជាតិរក្សាសិទ្ធិដកខ្លួនពីកិច្ចសហប្រតិបត្តិការទាំងមូលរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ការដាក់ពិន័យចំពោះការខកខានមិនបានអនុវត្តទៅតាមអ្វីដែលបានព្រមព្រៀងជាមួយគ្នានោះ នឹងមានការឈប់ផ្តល់ជំនួយទាក់ទងនឹងការបង្កើតនិងដំណើរការអង្គជំនុំជម្រះវិសាមញ្ញ ដែលការផ្តល់នេះគឺជាកាតព្វកិច្ចរបស់អង្គការសហប្រជាជាតិ ។ មាត្រា២៨ដែលចែងអំពីការដកខ្លួនចេញពីកិច្ចសហប្រតិបត្តិការនោះចែងថា“ប្រសិនបើរាជរដ្ឋាភិបាលផ្លាស់ប្តូររចនាសម្ព័ន្ធ ឬការរៀបចំអង្គជំនុំជម្រះវិសាមញ្ញឬក៏ធ្វើយ៉ាងណាឲ្យអង្គជំនុំជម្រះដំណើរការតាមរបៀបណាមួយដែលមិនសមស្របជាមួយខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អង្គការសហប្រជាជាតិរក្សាសិទ្ធិក្នុងការផ្អាកជំនួយឧបត្ថម្ភជាហិរញ្ញវត្ថុឬជាអ្វីផ្សេងទៀតដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ” ។ បញ្ហានៅទីនេះស្ថិតនៅត្រង់ថា តើលក្ខណៈវិនិច្ឆ័យអ្វីខ្លះដែលនាំដល់ការដកខ្លួនរបស់អង្គការសហប្រជាជាតិ ហើយថាតើស្ថាប័នណា ឬក្រុមណាមួយដែលមានសិទ្ធិពិនិត្យនិងសម្រេចករណីនេះ ។ ពីព្រោះមកដល់ពេលនេះពុំទាន់មានយន្តការណាមួយ ដើម្បីត្រៀមដោះស្រាយបញ្ហាដែលអាចកើតឡើងនេះទេ ។ ជាការពិតណាស់មិនទាន់ដល់ពេលចាប់ផ្តើមប្រតិបត្តិពេញបន្ទុកផង ក៏ចាប់មានមតិរិះគន់ និងវាយប្រហារមកលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញទៅហើយ ។ ការរិះគន់និងវាយប្រហារទាំងនេះផ្តោតលើទិដ្ឋភាពផ្សេងៗគ្នា ដូចជាការជ្រើសរើសចៅក្រម ព្រះរាជអាជ្ញានិងបុគ្គលិកខ្មែរ ការធ្វើដំណើរយឺតៗរបស់ស្ថាប័ននេះ និងការព្រួយបារម្ភផ្សេងៗទៀត ។ ថ្មីៗនេះហាក់លេចចេញនូវក្រុមបណ្តាប្រទេសដែលមានចំណាប់អារម្មណ៍លើបញ្ហាតុលាការ នេះដែលមានឈ្មោះថា“មិត្តរបស់តុលាការ” ។ នៅពុំទាន់ច្បាស់ថាមិត្តរបស់តុលាការនេះមានន័យយ៉ាងណាឲ្យពិតប្រាកដ ហើយវាជាអង្គភាពមានរចនាសម្ព័ន្ធច្បាស់លាស់យ៉ាងណានោះទេ ។ ប៉ុន្តែតាមការសង្កេតមើលបទពិសោធន៍កន្លងមក ជាពិសេសនៅប្រទេសសេរ៉ាឡេអូន “មិត្តតុលាការ”នេះមានសិទ្ធិផ្តល់នូវទស្សនីករណ៍ទាក់ទងនឹងអ្វីដែលគេបានស្រាវជ្រាវឃើញ ឧទាហរណ៍អង្គការយូនីសេហ្វបានឡើងផ្តល់បទពិសោធន៍បង្ហាញចំពោះមុខតុលាការពិសេសនៅសេរ៉ាឡេអូនអំពីទិដ្ឋភាពច្បាប់និងផលវិបាកចេញពីការជ្រើសរើសកុមារឲ្យធ្វើជាកងទ័ព ។ ប៉ុន្តែអង្គការយូនីសេហ្វមិនបាន ឬអាចមិនមានសិទ្ធិពិនិត្យ និងវាយតម្លៃទៅលើដំណើរការទាំងមូលរបស់តុលាការពិសេសនៅសេរ៉ាឡេអូននោះទេ ។

បើទុកជាពុំមានបទបញ្ញត្តិចែងច្បាស់អំពីបញ្ហានេះក្តី លោកអគ្គលេខាធិការអង្គការសហប្រជាជាតិអាចសម្រេចចិត្តដោយខ្លួនឯងអំពីការដកថយនេះ ពីព្រោះពុំមានប្រការណាមួយចែងអំពីកាតព្វកិច្ចរបស់លោកក្នុងការរាយការណ៍ជូនមហាសន្និបាតអង្គការសហប្រជាជាតិឡើយ ។ ជាក់ស្តែងដូចជាការដកថយរបស់អង្គការសហប្រជាជាតិនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ ឈប់ចរចាជាមួយកម្ពុជា លោកអគ្គលេខាធិការគ្រាន់តែចេញលិខិតបង្គាប់ការដល់ទីប្រឹក្សាច្បាប់របស់ខ្លួនឲ្យប្រកាសជាផ្លូវការតែប៉ុណ្ណោះ ។ ប៉ុន្តែទោះជាយ៉ាងណាក្តីប្រទេសមហាអំណាចអាចមានតួនាទីសំខាន់ក្នុងការជួយទប់ស្កាត់មិនឲ្យអង្គការសហប្រជាជាតិដកថយបានទោះបីជាមានហេតុផលត្រឹមត្រូវតាមច្បាប់ក៏ដោយ ដូចដែលអ្នកស្រាវជ្រាវមួយរូបឈ្មោះ វីលៀម សារ៉ា បានប្រមើលទុក ។ ទោះបីជាពុំមានយន្តការពិនិត្យនិងវាយតម្លៃអំពីការសម្រេចចិត្តដកថយចេញពីកិច្ចសហប្រតិបត្តិការនេះក៏ដោយ ក៏តំណាងនៃរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ (ជាពិសេសអ្នកការទូតនានាប្រចាំប្រទេសកម្ពុជា) មានសិទ្ធិចូលរួមបាន ។ យោងតាមមាត្រា១២នៃកិច្ចព្រមព្រៀងចែងថា “ក្នុងផលប្រយោជន៍ធានាឲ្យមានសវនាការជាសាធារណៈហើយដំណើរការត្រឹមត្រូវនិងទុកចិត្តបានត្រូវយល់ថាតំណាងរដ្ឋសមាជិកនៃអង្គការសហប្រជាជាតិតំណាងរបស់លោកអគ្គលេខាធិការតំណាងបណ្តាញព័ត៌មាននិងអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិនឹងអាចចូលរួមស្តាប់ការជំនុំជម្រះក្តីបានគ្រប់ពេលវេលាទាំងអស់” ។ ប៉ុន្តែមាត្រាដដែលនេះបង្ការទុកជាមុនអំពីករណីចាំបាច់បំផុតដែលប៉ះពាល់ដល់ប្រយោជន៍យុត្តិធម៌ ។ បញ្ញត្តិនេះមានលក្ខណៈស្របទៅនឹងមាត្រា៣៤នៃច្បាប់ពិសេសដែលចែងថា“អង្គជំនុំជម្រះវិសាមញ្ញត្រូវធ្វើជាសាធារណៈលើកលែងតែក្នុងកាលៈទេសៈពិសេសអង្គជំនុំជម្រះវិសាមញ្ញសម្រេចថាត្រូវជំនុំជម្រះជាសម្ងាត់ដោយមានមូលហេតុត្រឹមត្រូវដោយយោងតាមនីតិវិធីជាធរមាន” ។ ដូចដែលមានចែងនៅត្រង់មាត្រា

១៨នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយផងដែរ សិទ្ធិទទួលបានការកាត់សេចក្តីជាសាធារណៈពុំមានលក្ខណៈដាច់ខាតឡើយ ។ បទបញ្ញត្តិច្បាប់ទាំងនេះផ្តល់សិទ្ធិដល់រដ្ឋជាសមាជិកនិងតំណាងអង្គការនានាចូលរួមសង្កេតការណ៍ហើយការវាយតម្លៃរបស់ភាគីដែលចូលរួមទាំងនេះពិតជាមានសារសំខាន់ ។ បញ្ហាស្ថិតនៅត្រង់ថាតើការវាយតម្លៃទាំងអស់នេះត្រូវដាក់ជូនស្ថាប័នឬយន្តការណាមួយសម្រាប់ពិនិត្យនិងសម្រេចចុងក្រោយថាដំណើរការនៃអង្គជំនុំជម្រះប្រព្រឹត្តទៅដោយយុត្តិធម៌ផ្អែកតាមបទដ្ឋានដែលអរិយប្រទេសបាននិងកំពុងអនុវត្ត ។

ការផ្តល់ប៉ាន់ប្រមាណនិងវាស់វែងអំពីការអនុវត្តទៅតាម



មេឃុំសួរសំណួរទៅមន្ត្រីតុលាការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ

កិច្ចព្រមព្រៀងនិងច្បាប់ដែលមានជាធរមានទាំងនេះជាបញ្ហាមួយទៅហើយ ។ បញ្ហាមួយទៀតនោះគឺប្រសិនបើមានបញ្ហាមិនចុះសម្រុងនឹងគ្នាអំឡុងពេលប្រតិបត្តិការ តើស្ថាប័ន ឬអង្គការណាមួយ ដែលមានអំណាចសម្រេចកាត់សេចក្តីថាភាគីណាមួយមិនគោរពតាមកិច្ចព្រមព្រៀង ។ មាត្រា២៩ ដែលនិយាយយោងដល់របៀបដោះស្រាយជម្លោះចែងថា “ជម្លោះណាមួយរវាងភាគីទាំងសងខាងទាក់ទងនឹងការបកស្រាយ ឬអនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយតាមការចរចា ឬដំណោះស្រាយផ្សេងទៀតដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង” ។ កិច្ចព្រមព្រៀងហាក់ដូចជាពុំបានចែងដំណោះស្រាយផ្សេងៗក្រៅតែអំពីការចរចានោះទេ ។ ដំណោះស្រាយអាចមានពីរយ៉ាង ។ ទីមួយ វិវាទអាចដាក់ជូនដល់តុលាការអន្តរជាតិជាអ្នកដោះស្រាយ ។ ប៉ុន្តែបើយោងតាមមាត្រា៣៤នៃលក្ខន្តិកៈតុលាការអន្តរជាតិ (អាយស៊ីជេ) មានតែរដ្ឋទេដែលអាចជាភាគីនៃរឿងក្តីចំពោះតុលាការនេះបាន ។ ក្នុងករណីនេះមានតែមហាសន្និបាតអង្គការសហប្រជាជាតិទេដែលអាចរៀបចំរឿងក្តីនេះដាក់ជូនតុលាការអន្តរជាតិដើម្បីសុំជាយោបល់ណែនាំដូចដែលមានចែងនៅក្នុងជំពូក៤នៃលក្ខន្តិកៈតុលាការនិងស្របតាមមាត្រា៩៦(១)នៃធម្មនុញ្ញអង្គការសហប្រជាជាតិហើយការសម្រេចសេចក្តីដែលមានលក្ខណៈណែនាំនេះពុំមានលក្ខណៈចាប់បង្ខំមកលើភាគីទាំងពីរឡើយ ។ ភាគីទាំងពីរអាចសម្រេចថា ត្រូវអនុវត្តតាមក៏បានមិនអនុវត្តតាមក៏ពុំមានបញ្ហាដាក់ទណ្ឌកម្មដែរ ។ លទ្ធភាពទីពីរគឺថា ដោយសារអំណាចក្នុងការផ្តល់ជំនួយបង្កើតនិងប្រតិបត្តិការអង្គជំនុំជម្រះវិសាមញ្ញធ្វើឡើងដោយមហាសន្និបាតអង្គការសហប្រជាជាតិ ទំនងជាអាចនិយាយបានថារាល់ការមិនព្រមអនុវត្តតាមកិច្ចព្រមព្រៀងណាមួយត្រូវបានបញ្ជូនទៅមហាសន្និបាតដើម្បីពិនិត្យនិងសម្រេច ។ ប៉ុន្តែការសម្រេចនេះមានលក្ខណៈជានយោបាយ មិនមែនជាការសម្រេចតាមផ្លូវច្បាប់នោះទេ ។ ចំពោះការប្តឹងតវ៉ាអំពីការមិនគោរពបទដ្ឋាននីតិវិធីដែលមានចែងនៅក្នុងច្បាប់ជាធរមាននិងបទដ្ឋានអន្តរជាតិនានា និងភាពមិនឯករាជ្យរបស់តុលាការនោះគេអាចដាក់ជូនដល់គណៈកម្មាធិការសិទ្ធិមនុស្សដើម្បីពិនិត្យ និងជូនជាយោបល់ ។ ប៉ុន្តែដោយសារថាព្រះរាជាណាចក្រកម្ពុជាពុំមែនជាភាគីហត្ថលេខីនៃពិធីសារបន្ថែមទេនោះ គណៈកម្មាធិការសិទ្ធិមនុស្សមិនអាចទទួលបណ្តឹងពីបុគ្គលឯកជនដែលមិនពេញចិត្តនឹងដំណើរការនេះបានឡើយ ។ អ្វីដែលគណៈកម្មាធិការអន្តរជាតិនេះមានអំណាច (យោងតាមមាត្រា២៨) ដោះស្រាយបញ្ហា

នេះគឺគ្រាន់តែវិភាគរបាយការណ៍នានារបស់រដ្ឋនិងធ្វើការវាយតម្លៃទៅលើភាពជោគជ័យ និងភាពមិនជោគជ័យរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតែប៉ុណ្ណោះ ។ គណៈកម្មាធិការនេះអាចលើកជាអនុសាសន៍និងសេចក្តីអង្កេតជាលក្ខណៈសន្និដ្ឋានចុងក្រោយតែប៉ុណ្ណោះ ។ ជម្រើសមួយទៀតគឺការដាក់ពាក្យបណ្តឹងរវាងរដ្ឋជាសមាជិក កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។ រដ្ឋផ្សេងៗអាចដាក់ពាក្យប្តឹងចំពោះកម្ពុជាបានទាក់ទងនឹងការគោរពកាតព្វកិច្ចរបស់ខ្លួនដូចដែលមានចែងក្នុងសន្ធិសញ្ញា ប៉ុន្តែលុះត្រាតែកម្ពុជា និងរដ្ឋដែលចង់ប្តឹងនោះទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការនេះផងដែរ ដូចដែលមានចែងនៅត្រង់មាត្រា៤១ ។ នេះជាបញ្ហាដ៏សំខាន់ទាក់ទងនឹងការទូតរវាងបណ្តាប្រទេសដែលមានទំនាក់ទំនងល្អជាមួយកម្ពុជា ហើយក៏មិនមានអ្វីចម្លែកទេថាមកទល់នឹងពេលនេះ សឹងតែពុំមានរដ្ឋណាមួយដាក់ពាក្យបណ្តឹងគ្នាទៅវិញទៅមកនោះទេ ទីមួយបញ្ហាទំនាក់ទំនងការទូតទីពីរមិនប្រាកដថារដ្ឋដែលប្តឹងរដ្ឋមួយទៀត នោះអនុវត្តតាមកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយបានត្រឹមកម្រិតណានោះដែរ ។ ឧទាហរណ៍ សហរដ្ឋអាមេរិកបារាំងនិងបណ្តាប្រទេសផ្សេងៗទៀតនៅអឺរ៉ុបសុទ្ធតែទទួលរងនូវការរិះគន់ចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានល្អទាក់ទងនឹងការចាប់ និងឃុំខ្លួនជនសង្ស័យ និងការអនុវត្តសិទ្ធិផ្សេងៗ ទៀតរបស់ពលរដ្ឋខ្លួន និងពលរដ្ឋដទៃដែលរស់នៅលើទឹកដីរបស់ខ្លួន ។ ក្នុងករណីអង្គជំនុំជម្រះវិសាមញ្ញ គណៈកម្មាធិការសិទ្ធិមនុស្សច្បាស់ជាមានការរួញរាក្នុងការវាយតម្លៃដោយសារថាតុលាការនេះមានលក្ខណៈចម្រុះជាតិនិងអន្តរជាតិ គ្រាន់តែធ្វើឡើងនៅក្នុងប្រព័ន្ធយុត្តិធម៌ក្នុងស្រុកប៉ុណ្ណោះ ។ បុគ្គលិករដ្ឋបាល និងមន្ត្រីតុលាការតែងតាំង នឹងជ្រើសរើសដោយ អង្គការសហប្រជាជាតិក៏មានចំណែកចូលរួមអនុវត្តកិច្ចព្រមព្រៀងនេះដែរ ។ នៅពេលមានកំហុសក្នុងប្រព័ន្ធតុលាការពិសេសនេះ មិនមែនតែកម្ពុជាទេដែលទទួលរិះគន់ ។ ភាគីអង្គការសហប្រជាជាតិក៏គួរប្រុងប្រយ័ត្នផងដែរ ។

បញ្ហាទាំងនេះសុទ្ធតែអាចកើតឡើងទាំងអស់ ហើយកើតចេញពីកិច្ចព្រមព្រៀងច្បាប់ពិសេសនិងច្បាប់អន្តរជាតិមួយចំនួនដែលកម្ពុជាចូលជាភាគី ។ ច្បាប់ពិសេសនិងកិច្ចព្រមព្រៀងនេះកើតចេញពីការតថ្លៃគ្នាទាក់ទងនិងការរក្សាអធិបតេយ្យភាពបទដ្ឋានយុត្តិធម៌អន្តរជាតិឯករាជ្យនិងភាពមិនលំអៀងរបស់តុលាការសន្តិភាព និងការធ្វើឲ្យសាយចិត្តដល់ជនរងគ្រោះ និងជនសង្ស័យ ។ ការរកបញ្ហាឲ្យឃើញវាជារឿងពិបាកមួយហើយ ។ រីឯបញ្ហាលំបាកមួយទៀតនោះ គឺការរកដំណោះស្រាយសមស្របនិងអនុវត្តឲ្យមានប្រសិទ្ធភាព ។


នួន ជា ក្នុងឆ្នាំ២០០៦


មេឃុំចូលរួមស្តាប់ការស្រាយបំភ្លឺរបស់មន្ត្រីតុលាការនៅក្នុងសវនាការអង្គជំនុំជម្រះវិសាមញ្ញ

## ការបង្ការកុំឲ្យមានវិបាកដែលអាចកើតឡើង

ដើម្បីចៀសវាងវិបាកដែលអាចកើតឡើងដូចដែលបានរៀបរាប់ខាងលើមានវិធីមួយចំនួនដូចខាងក្រោម ។ ទីមួយ បណ្តារដ្ឋជាសមាជិកអង្គការសហប្រជាជាតិ ជាពិសេសបណ្តារដ្ឋដែលមានបេសកកម្មការទូតនៅកម្ពុជាគួរតែផ្តោតការយកចិត្តទុកដាក់និងចូលរួមឲ្យបានជិតដល់ក្នុងដំណើរការរបស់តុលាការ ។ រដ្ឋទាំងនោះមិនគួរឃ្លាំមើលដំណើរការពេលដែលមានសវនាការនោះទេ ។ ករណីស្រដៀងគ្នានេះទាក់ទងនឹងអង្គការជាតិនិងអន្តរជាតិ ។ អង្គការទាំងនោះគួរមានអ្នកជំនាញឲ្យបានច្បាស់លាស់ ដើម្បីអាចធ្វើការវាយតម្លៃត្រឹមត្រូវបានទៅលើតុលាការពិសេសនេះ ចៀសវាងយកឥទ្ធិពលនយោបាយរបស់រដ្ឋផ្តល់ជំនួយមកជះឥទ្ធិពលដោយគ្មានភាពចាំបាច់ ។ ហើយឥទ្ធិពលបែបនេះក៏សាធារណជនមិនអាចទទួលយកបានដែរ ។ រដ្ឋនិងអង្គការនីមួយៗត្រូវមានអង្គភាពតូចៗដែលមានជំនាញលើវិស័យណាមួយច្បាស់លាស់មុននឹងមកធ្វើការវាយតម្លៃដល់តុលាការជៀសវាងការវាយតម្លៃដែលខ្វះភាពស៊ីជម្រៅនិងប្រាសចាកពីច្បាប់និងបទដ្ឋានជាធរមាន ។ ទីពីរត្រូវមានការពិភាក្សាគ្នាឲ្យបានច្បាស់រវាងភាគីអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលទាក់ទងនឹងមាត្រា២៨នៃកិច្ចព្រមព្រៀងស្តីពីការដកខ្លួនថយពីដំណើរការនេះ ។ មាត្រានេះមានលក្ខណៈមិនទាន់ច្បាស់លាស់នៅឡើយ ហើយត្រូវការការកំណត់ឲ្យបានច្បាស់ជាងនេះដោយផ្អែកទៅលើឯកសារ និងដំណើរការចរចាកន្លងមក ។ ទីបីភាគីទាំងពីរ និងរដ្ឋព្រមទាំងអង្គការជាតិនិងអន្តរជាតិដែលពាក់ព័ន្ធគួរយល់ឲ្យបានច្បាស់នូវការរំពឹងទុករបស់ជនរងគ្រោះ និងយុត្តិធម៌តាមច្បាប់ព្រហ្មទណ្ឌ និងសិទ្ធិមនុស្ស ។ ជាការពិតយុត្តិធម៌អាចមានន័យច្រើន និងពិបាកនិយាយឲ្យន័យច្បាស់លាស់ណាស់ ។ ឧទាហរណ៍ អ្នកស្រុកអាចគិតថាឲ្យតែមានតុលាការកាត់ទោសមេដឹកនាំកម្ពុជាប្រជាធិបតេយ្យនោះនឹងមានយុត្តិធម៌ហើយ ។ អ្នកខ្លះទៀតយល់ថា កម្មាភិបាលថ្នាក់ក្រោមក៏គួរនាំមកឡើងតុលាការដែរ ។ អ្នកខ្លះទៀតឆ្ងល់ថាមេដឹកនាំជាន់ខ្ពស់ជាអ្នកណា ហើយជនដែលទទួលខុសត្រូវខ្ពស់បំផុតអាចជាកម្មាភិបាលថ្នាក់ណា ។ ស្រទាប់មហាជនផ្សេងទៀតចង់ដឹងថាតើបទដ្ឋានអន្តរជាតិមានន័យយ៉ាងដូចម្តេច ហើយមានប្រភពនៅទីណា ។ សំណួរទាំងអស់នេះអាចជះឥទ្ធិពលដល់រដ្ឋជាសមាជិកអង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបើពុំបានដោះស្រាយដោយសមស្របទេនោះ ។ ទីបួន អង្គជំនុំជម្រះវិសាមញ្ញជាពិសេស សហព្រះរាជអាជ្ញាគួរមានផែនការយុទ្ធសាស្ត្រច្បាស់លាស់អំពីទំហំនិងវិធីសាស្ត្រស៊ើបអង្កេតដើម្បីឲ្យមានប្រសិទ្ធភាពនិងគុណភាព និងផ្សព្វផ្សាយព័ត៌មានទាន់សភាពការណ៍ដល់ភាគីទាំងអស់ដែលមានការពាក់ព័ន្ធនៅក្នុងរឿងក្តីជាពិសេសជនទាំងឡាយណាដែលអាចជាដើមចោទនិងសាក្សី និងអ្នកផ្សេងទៀតដែលចង់ដឹងចង់ឮអំពីដំណើរការតុលាការនេះ ។ ទីប្រាំអ្នកវាយតម្លៃត្រូវបែងចែកឲ្យច្បាស់អំពីបទបញ្ញត្តិផ្សេងៗដែលមានចែងនៅក្នុងច្បាប់ និងបទដ្ឋានជាធរមាន ចៀសវាងផ្អែកទៅលើឥទ្ធិពលនយោបាយ ។ ទីប្រាំមួយ ដើម្បីឲ្យដំណើរការរបស់តុលាការប្រព្រឹត្តដោយប្រសិទ្ធភាពនិងគ្មានបញ្ហា ពុំចាំបាច់វិធាននៃនីតិវិធីនិងភស្តុតាង គួរតែរៀបចំឡើងដោយមន្ត្រីតុលាការដែលមានសមត្ថកិច្ចធ្វើយ៉ាងណាប្រមូលផ្តុំរាល់បទបញ្ញត្តិក្នុងស្រុកនិងអន្តរជាតិទាក់ទងនឹងយុត្តិធម៌តាមផ្លូវព្រហ្មទណ្ឌនិងសិទ្ធិមនុស្ស ។ ប្រការនេះនឹងបង្កលក្ខណៈងាយស្រួលដល់សហព្រះរាជអាជ្ញានិងចៅក្រមទាំងជាតិនិងអន្តរជាតិ អាចធ្វើការបានលឿននិងត្រឹមត្រូវអាចទទួលយកបានពីបណ្តារដ្ឋជាសមាជិកអង្គការសហប្រជាជាតិអង្គការក្នុងស្រុកនិងអង្គការអន្តរជាតិ ។

ដំណោះស្រាយទាំងនេះអាចអនុវត្តទៅបានលុះត្រាតែមានអង្គភាពមួយជាក់លាក់ចម្រុះទៅដោយអ្នកជំនាញការច្បាស់លាស់មកពីបណ្តារដ្ឋជាសមាជិកអង្គការសហប្រជាជាតិដែលមានការចាប់អារម្មណ៍អង្គការក្នុងស្រុកនិងអន្តរជាតិ រាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ ។ បើពុំនោះសោតនឹងពុំមានការវាយតម្លៃមួយដែលសមស្របទៅតាមបច្ចេកទេសនិងកិច្ចព្រមព្រៀងដែលនិងច្បាប់ ដែលពាក់ព័ន្ធឡើយ ។ អង្គភាពនេះពុំចាំបាច់មានហិរញ្ញវត្ថុដាច់ដោយឡែកនោះទេ ។ រដ្ឋឬអង្គការណា ដែលពាក់ព័ន្ធអាចបញ្ជូនបុគ្គលិកជំនាញរបស់ខ្លួនជាមួយនឹងហិរញ្ញវត្ថុផងឲ្យជួយឃ្លាំមើលនិងវាយតម្លៃទៅលើដំណើរការប្រព្រឹត្តទៅរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

**សួ ប៊ុនស៊ូ**

# សំណងចំពោះជនរងគ្រោះនៃរបបខ្មែរក្រហម គឺជាបញ្ហាដែលលំបាកដោះស្រាយ

អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាកំពុងរៀបចំពាក្យបណ្តឹងចំពោះមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ នៅត្រង់ចំណុចនេះ ការលើកឡើងអំពីបញ្ហាសំណងគឺជារឿងលំបាកបំផុត ពីព្រោះសំណងអាចនាំឲ្យសៅហ្មងដល់អត្ថន័យនៃយុត្តិធម៌ ។

ការលើកឡើងថា "តាមច្បាប់នៅប្រទេសមួយចំនួន ជនរងគ្រោះបានទទួលទាំងយុត្តិធម៌និងសំណង" អាចបំផ្លាញនូវការរំពឹងរបស់ជនគ្រោះអំពីយុត្តិធម៌ ការផ្សះផ្សា និងនីតិរដ្ឋ ។ តាមការសង្កេតរបស់ខ្ញុំ លទ្ធភាពទទួលបានសំណងមិនមែនជាហេតុផលរបស់ជនរងគ្រោះនៃរបបខ្មែរក្រហមឡើយ ។ ជនរងគ្រោះភាគច្រើនគ្រាន់តែចង់ឃើញយុត្តិធម៌តែប៉ុណ្ណោះ ។

ជាការពិតដែលក្នុងប្រព័ន្ធច្បាប់របស់ប្រទេសនៅអឺរ៉ុប ជនរងគ្រោះពីឧក្រិដ្ឋកម្មអាចប្តឹងទាមទារសំណងនៅក្នុងសវនាការ ។ នៅក្នុងប្រព័ន្ធច្បាប់ ខមិនឡូ (Common Law) ជនរងគ្រោះអាចធ្វើបណ្តឹងរដ្ឋប្បវេណី ដោយឡែកឲ្យស្របនឹងនីតិវិធីព្រហ្មទណ្ឌ ។ ទោះជាយ៉ាងនេះក្តីមានកត្តាជាច្រើនបង្ហាញថាយើងមិនគួរលើកអំពីបញ្ហាសំណងនៅពេលនេះទេ ។

ទី១ : មកដល់បច្ចុប្បន្នមិនមានយុត្តិសាស្រ្តស្តីអំពីសំណងដល់ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឡើយ ។

ទី២ : ទាំងច្បាប់អន្តរជាតិនិងច្បាប់ទំនៀមទម្លាប់អន្តរជាតិមានចែងតិចតួចអំពីសំណងដល់ជនរងគ្រោះនៃឧក្រិដ្ឋកម្មអន្តរជាតិ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ច្បាប់អន្តរជាតិកំពុងបង្កើនការព្យាយាមដោះស្រាយបញ្ហាសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាន"សំណង" ។ បញ្ហានេះទាមទារឲ្យចៅក្រមសម្រេចថាតើត្រូវគណនាការខូចខាតតាមរបៀបណា និងតើត្រូវសងជនរងគ្រោះតាមរបៀបណា ដោយរាប់បញ្ចូលគ្រប់កត្តានានានៅពីក្រោយឧក្រិដ្ឋកម្មនេះ ។ រឿងនេះជំរុញឲ្យចៅក្រមមានភាពច្នៃប្រឌិតក្នុងការបង្កើតសំណងមិនមែនជាទឹកប្រាក់ ដែលសំណងនោះអាចជាបូជនីយដ្ឋាន ឬទិវានៃការចងចាំជាដើម ។

ទី៣ : ការកំណត់ចំនួនជនរងគ្រោះ និងការគណនាសំណងជាសរុបគិតចាប់តាំងពី២៧ឆ្នាំមុន គឺជាកិច្ចការដែលស្ទើរតែមិនអាចធ្វើទៅបាន ។ ជាងនេះទៅទៀត អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាទំនងជាគ្មានលទ្ធភាពក្នុងការចេញសំណងដល់ជនរងគ្រោះទាំងអស់នៃរបបប្រល័យពូជសាសន៍នៅកម្ពុជាឡើយ ។

ទី៤ : ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនរាប់លាននាក់បានស្លាប់ ហើយទ្រព្យសម្បត្តិជាច្រើនត្រូវខ្មែរក្រហមរឹបអូសនិងបំផ្លាញអស់ ។ អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាប្រហែលជាអាចដោះស្រាយបញ្ហាសំណងនៅក្នុងដែនកំណត់មួយជាក់លាក់ ប៉ុន្តែពេលវេលាកាន់តែទៅមុខ ហើយការសងទ្រព្យសម្បត្តិក្នុងចំនួនដ៏ច្រើនឲ្យទៅម្ចាស់ដើមវិញគឺជារឿងដែលមិនអាចធ្វើទៅបាន ។

ទោះបីជាច្បាប់ក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញមិនបានចែងពីសំណង ប៉ុន្តែនេះមិនមែនមានន័យថាគ្មានមធ្យោបាយក្នុងការដោះស្រាយឲ្យមានសំណងទេ ។ មាត្រា៣៩នៃវិសោធនកម្មច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញមានបញ្ជាក់អំពីការរឹបអូសទ្រព្យសម្បត្តិរបស់មេដឹកនាំខ្មែរក្រហមដែលទទួលបានពីអំពើខុសច្បាប់ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ នៅក្នុងមាត្រានេះបញ្ជាក់ថា : "ទ្រព្យសម្បត្តិដែលរឹបអូសបានត្រូវប្រគល់ជូនរដ្ឋ" ។ មាត្រា៣៩បើកផ្លូវឲ្យមានលទ្ធភាពទទួលសំណងនៅក្នុងព្រំដែនក្របខ័ណ្ឌផ្លូវច្បាប់នៃតុលាការ ។ ហេតុនេះហើយ ក្រោយពេលរដ្ឋាភិបាលទទួលបានទ្រព្យសម្បត្តិដែលរឹបអូសបានប្រជាជនអាចធ្វើសំណើរទៅរដ្ឋាភិបាលសុំឲ្យមានសំណងផ្សេងៗក្រោមរូបភាពជាសំណងនិមិត្តរូបដល់ជនរងគ្រោះ ។ ដោយប្រើប្រាស់ទ្រព្យសម្បត្តិដែលរឹបអូសបានសំណងនិមិត្តរូបអាចជាការសាងសង់មជ្ឈមណ្ឌលជាតិផ្នែកផ្លូវចិត្តសម្រាប់ជនរងគ្រោះ ដោយផ្តល់សេវាព្យាបាលឥតគិតថ្លៃ ។

ជាទីបញ្ចប់ ការស្វែងរកសំណងនៅក្នុងកាលៈទេសៈនេះអាចបង្វែរប្រជាជនកម្ពុជាចេញពីការជ្រោមជ្រែងអង្គជំនុំជម្រះវិសាមញ្ញដែលផ្តល់យុត្តិធម៌ជូនជនរងគ្រោះដោយការបញ្ចប់នូវភាពគ្មានទោសរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ **វ៉ាន់ថាន់ ពៅដារ៉ា**

# សង្គ្រាមគឺជាអំពើឃោរឃៅ ប៉ុន្តែជួនកាលការធ្វើសង្គ្រាមគឺជារឿងត្រឹមត្រូវ

សង្គ្រាមគឺជាអំពើព្រៃផ្សៃ ដោយសារសង្គ្រាមសម្លាប់មនុស្សជាច្រើន ប៉ុន្តែពេលខ្លះសង្គ្រាមគឺ ជាវិធីល្អមួយក្នុងការជួយសង្គ្រោះជីវិតមនុស្ស ។ ឧទាហរណ៍ សង្គ្រាមដែលប្រទេសវៀតណាមបានធ្វើដើម្បីរំដោះប្រទេសកម្ពុជានៅចុងឆ្នាំ១៩៧៨ ។ ប្រជាជនកម្ពុជាប្រមាណពីរលាននាក់បានស្លាប់នៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានស្គាល់ជាទូទៅថាជារបបខ្មែរក្រហមនៅក្នុងរយៈកាលពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ សហគមន៍អន្តរជាតិមិនបានខិតខំប្រឹងប្រែងដើម្បីបញ្ឈប់ការកាប់សម្លាប់នេះទេ ទោះបីជាប្រទេសមួយចំនួនដឹងថា របបនេះកំពុងប្រព្រឹត្តការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរក៏ដោយ ។ ផ្ទុយទៅវិញ ប្រទេសក្បែរខាងមួយបានចូលធ្វើអន្តរាគមន៍និងបណ្តេញរបបកម្ពុជាប្រជាធិបតេយ្យចេញពីអំណាច ។ អាចមានប្រជាជនកម្ពុជាច្រើនជាងនេះ (ឬប្រហែលជាទាំងអស់) នឹងស្លាប់ដោយការស្រេកឃ្លាន ជំងឺ ធ្វើការហួសកម្លាំង ទារុណកម្ម និងការសម្លាប់ ប្រសិនបើកងទ័ពវៀតណាមមិនបានមករំដោះប្រទេសកម្ពុជា ។

## ទ្រឹស្តីយុត្តិកម្មសង្គ្រាម

សាសនាធំៗបីនៅលើពិភពលោកបានពន្យល់អំពីការអនុវត្ត "ទ្រឹស្តីយុត្តិកម្មសង្គ្រាម" ដូចតទៅ ÷

## គ្រិស្តសាសនា

ទ្រឹស្តីនេះត្រូវបានជឿជាទូទៅថា មានប្រភពចេញមកពីគ្រិស្តសាសនា ។ បើទោះបីជាគ្រិស្តសាសនិកម្នាក់ឈ្មោះ អូហ្គោសស្ទីន ត្រូវបានអ្នកស្រាវជ្រាវទូទៅចាត់ទុកថាជាអ្នកបង្កើតទ្រឹស្តីនេះ ក៏ដោយ ក៏មានទស្សនវិទូមួយចំនួន ជាពិសេស អារីស្តូត និង ស៊ីសេរ៉ូ បានរួមចំណែកក្នុងការបង្កើតទ្រឹស្តីនេះ តាំងពីមុនគ្រិស្តសករាជម្ល៉េះ ។ សារសំខាន់នៃគំនិតរបស់ អារីស្តូត គឺការសិក្សាអំពីសីលធម៌ក្នុងន័យ វិន័យប្រកបដោយវិចារណញ្ញាណ ។ អារីស្តូតក៏បានព្យាយាមផ្សារភ្ជាប់សកម្មភាពដ៏សមរម្យរបស់មនុស្សទៅនឹងការអភិវឌ្ឍនៃចរិតលក្ខណៈ ដោយផ្តោតជាសំខាន់ទៅលើតួនាទីនៃការអប់រំចំពោះបញ្ហាសង្គ្រាម ។ អារីស្តូត បានអះអាងថា កងទ័ពត្រូវបានបង្ហាត់សម្រាប់គោលបំណងបីគឺ ៖ "(១) ការពារប្រទេសរបស់ខ្លួនពីការត្រួតត្រារបស់ប្រទេសដទៃ ។ (២) រក្សាការគ្រប់គ្រងទៅលើប្រទេសផ្សេងៗ ទៀតដើម្បីតែផលប្រយោជន៍ប្រទេសរបស់ខ្លួន ប៉ុន្តែមិនមែនដើម្បីដាក់នឹមត្រួតត្រាលើប្រទេសទាំងនោះទេ ។ (៣) ដាក់នឹមត្រួតត្រាលើប្រទេសទាំងឡាយណាដែលគ្មានលទ្ធភាពគ្រប់គ្រងប្រទេសដោយខ្លួនឯង" ។

ស៊ីសេរ៉ូ បានអះអាងតបថា "គ្មានយុត្តិកម្មសង្គ្រាមណាមួយអាចត្រូវបានធ្វើជាដាច់ខាត លើកលែងតែក្នុងគោលបំណងដាក់ទណ្ឌកម្មឬបណ្តេញខ្មាំងសត្រូវចេញពីប្រទេស" ។ អូហ្គោស្ទីន ក៏បានអះអាងបន្ថែមលើមតិនេះដែរដោយបានបញ្ជាក់ថា ច្បាប់នៃសេចក្តីស្រលាញ់បានជំរុញឲ្យគ្រិស្តសាសនិកជួយគ្នាទៅវិញទៅមក ។ នេះបញ្ជាក់ថា ការប្រើប្រាស់កម្លាំងក្នុងការដាក់ទណ្ឌកម្មអ្នកដែលប្រព្រឹត្តកំហុសគឺជាទង្វើត្រឹមត្រូវ ។ ថូម៉ាស់ អាគីណាស់ យល់ស្របនឹងគំនិតរបស់ អូហ្គោស្ទីន ស្តីអំពីសង្គ្រាម ហើយបានផ្តល់នូវសម្មតិកម្មបន្ថែមដើម្បីពន្យល់ពីភាពត្រឹមត្រូវនេះថា ៖ "(១) រដ្ឋអំណាចស្របច្បាប់មួយដែលបង្កើតឡើងដោយរដ្ឋធម្មនុញ្ញគួរតែជាអ្នកសម្រេចចិត្តក្នុងការធ្វើសង្គ្រាម (២) សង្គ្រាមគួរតែ ត្រូវធ្វើឡើងក្នុងបុព្វហេតុត្រឹមត្រូវនិង(៣) ថ្នាក់ដឹកនាំប្រទេសគួរតែមើលទៅលើការធ្វើសង្គ្រាមក្នុងចេតនាល្អ" ។ ទស្សនវិទូនិងទេវវិទូ ហ្វ្រង់ស៊ីស្កូ ដឺ វីកតូរៀល និង ហ្វ្រង់ស៊ីស្កូ ស៊ូអារេ បន្ថែមលក្ខខណ្ឌបីទៀត "(៤) ផលប៉ះពាល់នៃការធ្វើសង្គ្រាមជាពិសេសការបាត់បង់ជីវិតមនុស្សគួរតែសមាមាត្រទៅនឹងអំពើអយុត្តិធម៌ ដែលត្រូវតែបង្ការនិងព្យាបាលដោយការធ្វើសង្គ្រាម (៥) មធ្យោបាយសន្តិភាពក្នុងការទប់ស្កាត់ឬកែកុនអំពើអយុត្តិធម៌គួរតែត្រូវបានប្រើឲ្យអស់លទ្ធភាព ។ (៦) យុត្តិកម្មសង្គ្រាមគួរត្រូវធ្វើឡើងក្នុងក្តីសង្ឃឹមទទួលបានជោគជ័យដោយសមហេតុផល" ។ គោលការណ៍ទាំងនេះត្រូវបានហៅថាច្បាប់ស្តីអំពីការប្រើប្រាស់

កម្លាំងទ័ព (*Jus ad bellum*) ដែលនិយាយអំពីការធ្វើសេចក្តីសម្រេចចិត្តក្នុងការធ្វើសង្គ្រាម ។ ទ្រឹស្តីដែលហៅថាច្បាប់យុត្តិធម៌សង្គ្រាម បានចែងអំពីការប្រព្រឹត្តនៅក្នុងកំឡុងពេលសង្គ្រាម ដែលជនស៊ីវិលនឹងមិនមែនជាគោលដៅនៃសង្គ្រាម ការធ្វើទុក្ខទោស ត្រូវតែសមមាត្រនឹងគោលដៅដែលចង់បាន ហើយត្រូវកាត់បន្ថយការខូចខាតឲ្យបានជាអប្បបរិមាណក្នុងពេលប្រយុទ្ធ ។

## សាសនាអ៊ីស្លាម

សាសនាអ៊ីស្លាមក៏អនុញ្ញាតឲ្យមានសង្គ្រាមក្នុងកាលៈទេសៈជាក់លាក់មួយ ។ ព្រះមហាម៉ាត់ ដែលសាសនិកអ៊ីស្លាមទាំងអស់ចាត់ទុកថាជានិរសាររបស់ព្រះជាម្ចាស់ ទទួលស្គាល់តម្រូវការនៃការចាត់វិធានការវាយលុកដោយកម្លាំងយោធា ដើម្បីការពារប្រជាជនពីក្រុមអ្នកឈ្លានពាន ។ ជាឧទាហរណ៍ នៅពេលដែលព្រះមហាម៉ាត់ ក្លាយជាមេដឹកនាំក្រុងមេឌីណា លោកបានស៊ូះស្វែងការពារសហគមន៍របស់លោកពីសត្រូវនៃក្រុងមេកកា ។ ជាងនេះទៅទៀត បន្ទាប់ពីលោកចាប់ផ្តើមគ្រប់គ្រងបណ្តាប្រទេសនៅអារ៉ាប់ទាំងអស់ ព្រះមហាម៉ាត់ គឺជាមនុស្សទីមួយដែលទទួលជោគជ័យក្នុងការប្រមូលផ្តុំអំណាចកងទ័ពនិងកងកម្លាំងប៉ូលិសទាំងអស់ ។ ក្រោយពីការចូលមរណភាពរបស់ព្រះមហាម៉ាត់ក្នុងគ្រិស្តសករាជ៦៣២ សាវ័ករបស់លោកបានចាប់ផ្តើមធ្វើចម្បាំងឈ្លានពានប្រទេសដទៃ ដើម្បីផ្សព្វផ្សាយសាសនាអ៊ីស្លាមទៅមនុស្សផ្សេងទៀតនៅទូទាំងពិភពលោក ។ បន្ទាប់ពីការឈ្លានពានចូលប្រទេសអាមេនៀ ពែរ្ស (បច្ចុប្បន្នជាប្រទេសអ៊ីរ៉ង់) ស៊ីរី ប៉ាឡេស្ទីន អ៊ីរ៉ាក់ អាហ្វ្រិកខាងជើង និងអេស្ប៉ាញ កងទ័ពអ៊ីស្លាមបានឆ្លងកាត់តាមជួរភ្នំពីរ៉េណេសចូលទៅកាន់ប្រទេសបារាំង ប៉ុន្តែត្រូវបានវាយឲ្យបរាជ័យដោយមេទ័ពបារាំងម្នាក់ឈ្មោះ ឆាលែស ម៉ាតែល ក្នុងចម្បាំងនៅតំបន់តួស៍នៅគ្រិស្តសករាជ ៧៣៣ ។ ប្រសិនបើកងទ័ពអ៊ីស្លាមទទួលជោគជ័យនៅក្នុងសង្គ្រាមនេះ ប្រទេសលោកខាងលិចទាំងអស់នឹងក្លាយទៅជាប្រទេសអ្នកកាន់សាសនាអ៊ីស្លាម ។ សម្រាប់ហេតុផលបែបនេះ មនុស្ស ជាច្រើន ជាពិសេសគ្រិស្តសាសនិកមានជំនឿថាលក្ខណៈពិសេសមួយរបស់ព្រះមហាម៉ាត់ គឺការប្រើកម្លាំងទ័ពក្នុងការបង្កើតសាសនា ។

សម្រាប់អ្នកកាន់សាសនាអ៊ីស្លាម ភាពដ៏ពិសិដ្ឋត្រូវបានអនុញ្ញាត ។ គម្ពីរកូរ៉ានចែងថា "ប្រយុទ្ធក្នុងបុព្វហេតុដើម្បីព្រះជាម្ចាស់ប្រឆាំងនឹងអ្នកដែលវាយអ្នក ប៉ុន្តែកុំប្រព្រឹត្តបំពានបម្រាមព្រះជាម្ចាស់ ។ ព្រះជាម្ចាស់មិនសព្វព្រះទ័យនឹងអ្នកដែលបំពានពាក្យទូន្មានរបស់ព្រះអង្គឡើយ ។ វាយអ្នកទាំងនោះរហូតដល់លែងមានការធ្វើទុក្ខបុកម្នេញ ហើយសាសនាគឺដើម្បីព្រះជាម្ចាស់ ។ ប៉ុន្តែ ប្រសិនបើសត្រូវដកខ្លួនចេញពីការប្រយុទ្ធ សូមកុំឲ្យមានការប្រយុទ្ធគ្នាតទៅទៀត លើកលែងតែការប្រយុទ្ធប្រឆាំងនឹងជនដែលប្រព្រឹត្តអំពើបាប" ។ ហេតុដូច្នេះហើយ អ្នកកាន់សាសនាអ៊ីស្លាមបានបង្កើតឡើងនូវការប្រៀនប្រដៅស្តីអំពីសង្គ្រាមនៅក្នុងបរិបទនៃច្បាប់ប្រើប្រាស់កម្លាំងទ័ព (Jus ad bellum) ។ គោលការណ៍នៃច្បាប់នេះមានលក្ខណៈដូចតទៅ "(១) តាមទ្រឹស្តី សង្គ្រាមមានភាពត្រឹមត្រូវនិងអាចធ្វើទៅបាននៅក្នុងវិធានការការពារនិងក្នុងករណីចាំបាច់បំផុតដូចជា ការពារសេរីភាពសាសនា វាយបណ្តេញការឈ្លានពាន ទប់ស្កាត់អំពើអយុត្តិធម៌ និងការពារសណ្តាប់ធ្នាប់សង្គម...។ (២) ជាងនេះទៅទៀត នៅពេលទទួលបានការអនុញ្ញាតឲ្យធ្វើសង្គ្រាមដើម្បីការពារខ្លួន សង្គ្រាមនេះត្រូវដាក់ឲ្យនៅក្រោមច្បាប់របស់អ៊ីស្លាម ដើម្បីរឹតបន្តឹងបទបញ្ញាត្តិនិងក្បួនច្បាប់ក្នុងសាសនា ។ ៣) ហេតុដូច្នេះហើយ សេចក្តីប្រកាសសង្គ្រាមត្រូវផ្តល់ជាលាយលក្ខណ៍អក្សរឲ្យសត្រូវជាមុន ។ បទប្បញ្ញត្តិលម្អិតផ្សេងៗត្រូវកំណត់អំពីការប្រើប្រាស់វិធីសាស្ត្រក្នុងការធ្វើសង្គ្រាម និងការប្រព្រឹត្តដោយយុត្តិធម៌ចំពោះសត្រូវនិងទ្រព្យសម្បត្តិរបស់អ្នកទាំងនេះ" ។ ស្រដៀងនឹងគោលការណ៍ច្បាប់សង្គ្រាមរបស់គ្រិស្តសាសនាដែរ គម្ពីរកូរ៉ានចែងថា ប្រជាជនស៊ីវិលដូចជាស្ត្រី កូនក្មេង និងចាស់ជរា មិនមែនជាគោលដៅនៃសង្គ្រាមទេ ហើយអ្នកបួសក៏មិនត្រូវទទួលរងនូវការធ្វើឲ្យមានកាយវិកលកម្មដែរ ។

ក្នុងពុទ្ធសាសនា ខុសពីគ្រិស្តសាសនិកដែលមានជំនឿលើច្បាប់នៃសេចក្តីស្រលាញ់ ពុទ្ធសាសនិកមាន ជំនឿលើកម្មផលដែលបានចែងថា អំពើទាំងអស់កើតចេញពីហេតុនិងផល ។ អ្នកដែលប្រព្រឹត្តអំពើបាបក្នុងជាតិបុព្វជាតិមុននឹងទទួលផលកម្មនៅជាតិក្រោយ ។ អ្នកធ្វើអំពើល្អទទួលបានផលល្អ ហើយអ្នកធ្វើអំពើអាក្រក់នឹងទទួលផលអាក្រក់ ។ ការសម្លាប់មនុស្សមានបាបកម្ម ។

ដើម្បីអប់រំមនុស្សឲ្យធ្វើអំពើល្អ រូបគំនូរនៅតាមជញ្ជាំងក្នុងវត្ត បង្ហាញពីផលនៃការសាងបាបកម្មផ្សេងៗ ។

ព្រះពុទ្ធជាម្ចាស់បានទូន្មានមនុស្សអំពីធម៌អហិង្សានិងគោលការណ៍សន្តិភាពដែលផ្សព្វផ្សាយទូទាំងសកលលោក ។ ព្រះពុទ្ធមិនអនុញ្ញាតឲ្យប្រព្រឹត្តអំពើហិង្សានិងសម្លាប់ជីវិតមនុស្ស ហើយបានប្រកាសថា មិនមានសង្គ្រាមណាមួយត្រឹមត្រូវឡើយ ។ ពីព្រោះគោលការណ៍ទីមួយរបស់ពុទ្ធសាសនាគឺ “ការមិនសម្លាប់” ពុទ្ធសាសនាត្រូវបានចាត់ទុកថាជាសាសនាសន្តិភាពនិយម ។ ព្រះពុទ្ធបង្រៀនចេញពីវិន័យក្នុងគម្ពីភាសាបាលីដំបូងបង្អស់ដែលពុំមានចែងអំពីការអនុញ្ញាតឲ្យប្រើប្រាស់កម្លាំងអាវុធ ដើម្បីដោះស្រាយជម្លោះរវាងបុគ្គល សហគមន៍ ឬប្រទេសជាតិ ហើយសូម្បីតែការប្រើកម្លាំងអាវុធដើម្បីការពារខ្លួនក៏គ្មានដែរ ។ អំពើហិង្សាមិនអាចនាំមកនូវសន្តិភាពនិងយុត្តិធម៌បានទេ ប៉ុន្តែផ្ទុយទៅវិញបង្កើតឲ្យមានអំពើហិង្សាកាន់តែច្រើនឡើង ។ ព្រះពុទ្ធមានពុទ្ធដីកាអំពីធម៌អហិង្សាថា ៖

ចូរពុទ្ធបរិស័ទទាំងអស់មើលពីវិធីដែលមារធ្វើទុក្ខទោសនិងវាយតថាគត ។ មើលពីវិធីដែលមារវាយផ្តួលហើយប្លន់តថាគត ។ ជីវិតរស់នៅក្នុងគំនិតបែបនេះគឺរស់នៅក្នុងសេចក្តីស្អប់ ។ ចូរពុទ្ធបរិស័ទមើលពីវិធីដែលមារធ្វើទុក្ខទោសនិងវាយតថាគត ។ មើលវិធីដែលមារផ្តួលនិងប្លន់តថាគត ។ ចូរបោះបង់ចោលគំនិតបែបនេះ ហើយរស់ក្នុងសេចក្តីស្រលាញ់ ។ នៅក្នុងលោកយើងនេះ សេចក្តីស្អប់មិនអាចរំលត់សេចក្តីស្អប់បានទេ ។ មានតែសេចក្តីស្រលាញ់ទេដែលអាចរំលត់សេចក្តីស្អប់បាន ។

## ប្រវត្តិជម្លោះរវាងកម្ពុជានិងវៀតណាម

រដ្ឋកម្ពុជាប្រជាធិបតេយ្យ ត្រូវបានបង្កើតឡើងដោយបក្សកុម្មុយនិស្តកម្ពុជាដឹកនាំដោយ ប៉ុល ពត ។ បន្ទាប់ពីរដ្ឋកម្ពុជាប្រជាធិបតេយ្យត្រូវបានប្រកាសបង្កើតឡើងនៅឆ្នាំ១៩៧៥ របបនេះបានចាប់ផ្តើមបង្កជម្លោះជាមួយវៀតណាម ដោយធ្វើការវាយប្រហារកោះមួយចំនួនក្នុងឈូងសមុទ្រថៃ ដែលធ្លាប់ត្រូវបានកាន់កាប់និងធ្វើការកាន់កាប់ជាថ្មីដោយភាគីជម្លោះទាំងពីរ ។ កត្តាសំខាន់ៗទាំងឡាយ ដែលបង្កឲ្យមានការប្រយុទ្ធនេះ គឺអំនួតរបស់កម្ពុជាប្រជាធិបតេយ្យ ដែលតាំងខ្លួនថាជាអង្គការតែមួយគត់ក្នុងការទទួលបានជោគជ័យលើរបបសាធារណរដ្ឋខ្មែររបស់លោកសេនាប្រមុខ លន់ នល់ ការមិនពេញចិត្តចំពោះគំនិតដែលថាវៀតណាមបានជួយឧបត្ថម្ភគាំទ្របក្សកុម្មុយនិស្តកម្ពុជាតាំងពីដើមទី ភាពឃើតយ៉ាវរបស់វៀតណាមក្នុងការដកកងទ័ពចេញពីកម្ពុជា (ជាពិសេសភាគឦសានប្រទេស) និងជម្លោះព្រំដែនសមុទ្ររវាងប្រទេសទាំងពីរ ។ កម្ពុជាប្រជាធិបតេយ្យចង់ឲ្យវៀតណាមគោរពតាមកិច្ចព្រមព្រៀងស្តីពីបញ្ហាព្រំដែន ដែលវៀតណាមបានព្រមព្រៀងជាមួយរាជរដ្ឋាភិបាលរបស់សម្តេច ព្រះបាទនរោត្តម សីហនុ នាទសវត្សរ៍ឆ្នាំ១៩៦០ ។ ជាងនេះទៅទៀត ប៉ុល ពត ស្អប់ខ្ពើមប្រទេសវៀតណាមហើយ បានជំរុញឲ្យប្រជាជនកម្ពុជាស្អប់វៀតណាមដែរ ។

នៅចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៦ មានការលុកលុយនិងការប្រយុទ្ធគ្នាជាច្រើនតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរ តែមិនត្រូវបានផ្សព្វផ្សាយជាសាធារណៈទេ ។ បន្ទាប់ពីធ្វើសង្គ្រាមរវាងគ្នាឯង នៅក្នុងប្រទេសអស់រយៈពេលជិត៣០ឆ្នាំមក វៀតណាមស្ទាក់ស្ទើរក្នុងការចាប់ផ្តើមវាយលុកប្រទេសមួយទៀត ។ ដូច្នេះវៀតណាមស្នើបើកការចរចាជាមួយកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែសំណើទាំងនេះត្រូវភាគីកម្ពុជាប្រជាធិបតេយ្យបដិសេធ ។

ប្រជាជនវៀតណាមភាគច្រើនដែលរស់នៅប្រទេសកម្ពុជាក្នុងរបប លន់ នល់ ត្រូវចាកចេញពីកម្ពុជា ប៉ុន្តែមួយចំនួនតូចបន្តរស់នៅក្នុងកម្ពុជារហូតដល់ឆ្នាំ១៩៧៧ (ភាគច្រើនជាស្ត្រីវៀតណាមដែលរៀបការជាមួយបុរសខ្មែរ) ។ ប្រជាជនវៀតណាមទាំងនេះត្រូវបានសម្លាប់ ។ នៅខែមីនា ឆ្នាំដដែលនោះ កងទ័ពភូមិភាគបូព៌ានៃកម្ពុជាប្រជាធិបតេយ្យបានធ្វើដំណើរទៅកាន់ព្រំដែនវៀតណាមដើម្បីរៀបចំធ្វើការវាយប្រហារ ។ កងទ័ពទាំងនេះបានឆ្លងព្រំដែននិងធ្វើការបំផ្លិចបំផ្លាញទីប្រជុំជនមួយចំនួនរបស់វៀតណាមដូចជាចូវដុក និងហាទៀង ព្រមទាំងធ្វើឲ្យជនស៊ីវិលជាច្រើននាក់រងរបួស ។ មេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានធ្វើការប៉ាន់ស្មានថាភាគខាងត្បូងវៀតណាម ដែលមានព្រំដែនជាប់កម្ពុជា និងប្រជាជនភាគច្រើនជាជនជាតិខ្មែរ និងចូលរួមជាមួយបុព្វហេតុរបស់កម្ពុជាប្រជាធិបតេយ្យដើម្បីផ្តួលរំលំវៀតណាម ប៉ុន្តែរឿងនេះមិនបានកើតឡើងទេ ។ ជាលទ្ធផល ប៉ុល ពត សន្និដ្ឋានថា កម្មាភិបាល

របស់គាត់ជាច្រើននាក់មិនស្មោះត្រង់ ហើយបានចាប់ផ្តើមធ្វើវិសុទ្ធកម្មសម្លាប់វណ្ណៈអ្នកទាំងឡាយណា ដែល ប៉ុល ពត ចាត់ទុកថាជាសត្រូវប្រឆាំងនឹងរដ្ឋ ។ ទោះជាការវាយប្រហារយោរយៅជាច្រើនបានបន្តកើតមានឡើងក្តី មិនមានភាគីណាមួយទទួលស្គាល់ការវាយប្រហារទាំងនេះជាសាធារណៈឡើយ ។ នៅខែមិថុនា ឆ្នាំ១៩៧៧ វៀតណាមស្នើឲ្យមានបទឈប់បាញ់គ្នាមួយទៀត ប៉ុន្តែសំណើនេះត្រូវភាគីកម្ពុជាប្រជាធិបតេយ្យទាត់ចោល ។

ក្នុងគោលបំណងនាំប្រទេសវៀតណាមចូលទៅក្នុងភ្លើងសង្គ្រាម ប៉ុល ពត បានធ្វើដំណើរទៅកាន់ទីក្រុងប៉េកាំង ដើម្បីពង្រឹងសម្ព័ន្ធភាពជាមួយប្រទេសចិន ដែលវៀតណាមចាត់ទុកថាទង្វើនេះបានធ្វើឲ្យស្ថានការណ៍កាន់តែមាន សភាពធ្ងន់ធ្ងរឡើង ។ ដើម្បីរក្សាតុល្យភាពអំណាច វៀតណាមបានចងសម្ព័ន្ធភាពជាមួយសហភាពសូវៀត ។ នៅចុងខែធ្នូ ឆ្នាំ១៩៧៧ វៀតណាមបានពង្រឹងកងកម្លាំងរបស់ខ្លួនដើម្បីវាយសងសឹកនឹងការវាយប្រហាររបស់កម្ពុជាប្រជាធិបតេយ្យទៅលើខេត្តតៃនីញ នៅក្នុងខែសីហានិងខែកញ្ញា ដែលនៅពេលនោះកងទ័ពកម្ពុជាប្រជាធិបតេយ្យបានសម្លាប់ប្រជាជនស៊ីវិលវៀតណាមអស់រាប់រយនាក់ ចាប់ចំណាប់ខ្មាំងវៀតណាមជាច្រើននាក់ និងបានប្លន់យកគោក្របី ហើយដឹកមកកម្ពុជា ។ កងទ័ពវៀតណាមបានវាយចូលជ្រៅក្នុងទឹកដីកម្ពុជាជាង២០គីឡូម៉ែត្រ ក្នុងគោលបំណងបង្ខំឲ្យកម្ពុជាប្រជាធិបតេយ្យទទួលយកបទឈប់បាញ់គ្នា ។


កងទ័ពខ្មែរក្រហម

ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃទី២៥ ខែធ្នូ កម្ពុជាប្រជាធិបតេយ្យបានសម្រេចកាត់ផ្តាច់ទំនាក់ទំនងជាមួយវៀតណាម ហើយចាប់ផ្តើមធ្វើសង្គ្រាមឃោសនា ។ បន្ទាប់ពីការវាយប្រយុទ្ធគ្នាអស់មួយសប្តាហ៍ វៀតណាមបានដកថយទៅវិញ ដោយនាំយកទៅជាមួយនូវអ្នកភូមិនិងឈ្លើយសឹករាប់ពាន់នាក់ ។ នៅថ្ងៃបន្ទាប់ កម្ពុជាប្រជាធិបតេយ្យបានផ្សាយថា ការដកថយរបស់វៀតណាមជាជ័យជម្នះជាប្រវត្តិសាស្ត្រមួយ ហើយបានចាប់ផ្តើមធ្វើការបោសសម្អាតប្រជាជននៅភូមិភាគបូព៌ា (តំបន់ក្បែរព្រំដែនវៀតណាម) ដែលមេដឹកនាំកម្ពុជាប្រជាធិបតេយ្យចោទថាបានឃុបឃិតជាមួយវៀតណាម ។ នៅខែមករានិងខែកុម្ភៈ ឆ្នាំ១៩៧៨ កងទ័ពកម្ពុជាប្រជាធិបតេយ្យចាប់ផ្តើមវាយប្រហារលើប្រទេសវៀតណាម ដោយបានសម្លាប់ប្រជាជនជាច្រើន ដុតផ្ទះសំបែង និងធ្វើឲ្យរាំងស្ទះដល់ការប្រកបអាជីវកម្មរបស់ប្រជាជនវៀតណាមទាំងនោះ ។ ជាថ្មីម្តងទៀត វៀតណាមបានស្នើឲ្យមានកិច្ចចរចាបញ្ចប់ជម្លោះរវាងប្រទេសទាំងពីរ ប៉ុន្តែកម្ពុជាប្រជាធិប-

តេយ្យ បានបដិសេធចំពោះសំណើនេះ ។ នៅថ្ងៃទី ១៧ ខែមករា ឆ្នាំ១៩៧៨ ប៉ុល ពត បានថ្លែងសុន្ទរកថាកោតសរសើរយ៉ាងខ្លាំងចំពោះជ័យជម្នះ និងសម្តែងជំនឿចិត្តដែលថាវៀតណាមនឹងត្រូវផ្តួលរំលំ ។

ដើម្បីពង្រីងជំហររបស់ខ្លួន កម្ពុជាប្រជាធិបតេយ្យបានព្យាយាមសាបព្រោះទំនាក់ទំនងជាមួយ ពិភពលោកខាងក្រៅ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។ ទន្ទឹមគ្នានោះ ទាហានវៀតណាមប្រមាណមួយសែននាក់បានប្រមូលផ្តុំគ្នានៅតាមបណ្តោយព្រំប្រទល់ ហើយនៅដើមខែធ្នូ ឆ្នាំ១៩៧៨ វៀតណាមបានប្រកាសថា រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាត្រូវបានបង្កើតឡើងដើម្បីរំដោះប្រទេសកម្ពុជា ។

នៅថ្ងៃទី២៥ ខែធ្នូ វៀតណាមបានវាយប្រហារមកលើកម្ពុជាប្រជាធិបតេយ្យ ។ ៦ថ្ងៃក្រោយមក វៀតណាមកាន់កាប់បានផ្លូវជាតិសំខាន់ៗជាច្រើន ។ ទីក្រុងភ្នំពេញជាតំបន់ដែលត្រូវរំដោះចុងក្រោយបង្អស់ ហើយនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាទាំងមូលស្ថិតនៅក្រោមការត្រួតត្រារបស់វៀតណាម ។ ក្រុមខ្មែរក្រហមបានរត់ភៀសខ្លួនទៅភាគខាងលិចប្រទេសកម្ពុជា ដែលនៅទីនោះ អ្នកទាំងនេះរស់នៅរបៀបជាក្រុមឧទ្ទាម ។ ប្រជាជនកម្ពុជាស្ទើរគ្រប់រូបទទួលស្គាល់របបថ្មីដែលមានឈ្មោះថា "សាធារណរដ្ឋប្រជាមានិតកម្ពុជា" ដែលបង្កើតឡើងដោយវៀតណាម ។ ប្រជាជនកម្ពុជាភាគច្រើនមានការសប្បាយរីករាយយ៉ាងខ្លាំងជាមួយនឹងការដួលរលំរបស់កម្ពុជាប្រជាធិបតេយ្យ ដោយហេតុថាប្រជាជនកម្ពុជាស្ទើរគ្រប់រូបបានជួបប្រទះនឹងការរងទុក្ខវេទនាយ៉ាងខ្លាំង និងអំពើហិង្សាក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយគិតថាការរំដោះនេះបានជួយសង្គ្រោះជីវិតរបស់ខ្លួន ។

បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យព័ត៌មានស្តីពីស្ថានភាពដ៏អាក្រក់ក្នុងរយៈកាលនៃរបបនេះត្រូវបានដឹងជាសាធារណៈ ។ យោងតាមការប៉ាន់ស្មានផ្សេងៗគ្នាជាច្រើន ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាពី៨សែននាក់ទៅ៣លាននាក់បានស្លាប់ដោយការអត់អាហារ ការធ្វើការហួសកម្លាំង និងការធ្វើទុក្ខបុកម្នេញ ។ ជាងនេះទៅទៀត យ៉ាងហោចណាស់ប្រជាជនយ៉ាងតិចមួយសែននាក់ត្រូវបានចោទថាជាសត្រូវរបស់រដ្ឋ ហើយត្រូវបានសម្លាប់ដោយគ្មានការជំនុំជម្រះក្តីអ្វីទាំងអស់ ។ ក្នុងចំណោមអ្នកទាំងនោះ ប្រជាជនប្រហែលពីរម៉ឺននាក់ត្រូវបាននាំយកទៅគុកទួលស្លែងដែលជាមន្ទីរសន្តិសុខថ្នាក់មជ្ឈិមហើយសម្លាប់ ។ ហេតុដូច្នេះហើយ នៅខែសីហា ឆ្នាំ១៩៧៩ របបថ្មីគឺសាធារណរដ្ឋប្រជាមានិតកម្ពុជា បានកាត់ទោសកំបាំងមុខប្រហារជីវិតមេដឹកនាំកម្ពុជាប្រជាធិបតេយ្យពីររូបគឺ ប៉ុល ពត និង អៀង សារី ។ ក្រុមសកម្មជនសិទ្ធិមនុស្សក៏មានបំណងនាំយក ប៉ុល ពត មកកាត់ទោសនៅតុលាការយុត្តិធម៌អន្តរជាតិ ក្នុងប្រទេសហូឡង់ដែរ ប៉ុន្តែមិនបានជោគជ័យ ។ ប៉ុល ពត កំពុងរស់នៅនិរទេសខ្លួនក្នុងប្រទេសថៃ ដែលមិនព្រមប្រគល់ ប៉ុល ពត ឲ្យតុលាការ ។

## ការឆ្លើយតបពីសហគមន៍អន្តរជាតិ

មួយសប្តាហ៍បន្ទាប់ពីថ្ងៃរំដោះ សហភាពសូវៀតបានផ្ញើសំបុត្រមួយច្បាប់ជូនប្រមុខរដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយបានប្រកាសទទួលស្គាល់រដ្ឋាភិបាលថ្មីនេះ ដែលបានរំដោះ និងបានធ្វើការតស៊ូដើម្បីទាមទារឯករាជ្យជូនប្រទេសកម្ពុជា ។ នៅថ្ងៃបន្តបន្ទាប់ ប្រទេសទាំងឡាយនៅអឺរ៉ុបខាងកើតក៏បានទទួលស្គាល់របបថ្មីនេះដែរ ។ ប៉ុន្តែប្រទេសចិនបានបដិសេធមិនទទួលស្គាល់ ដោយចោទប្រកាន់ថា វៀតណាមព្យាយាមគ្រប់គ្រងប្រទេសកម្ពុជា ក្នុងគោលបំណងបង្កើតសហព័ន្ធឥណ្ឌូចិន ។ រដ្ឋាភិបាលថៃដែលមិនទុកចិត្តប្រទេសវៀតណាមបានព្យាយាមចងសម្ព័ន្ធភាពជាមួយចិនពីរសប្តាហ៍ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្រោមសម្ព័ន្ធភាពនេះ ប្រទេសថៃនឹងផ្តល់កន្លែងជ្រកកោនដល់កងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យ ហើយចិនបន្តផ្តល់ជំនួយសព្វាវុធ ។ សហរដ្ឋអាមេរិកដែលបានចាប់ផ្តើមធ្វើឲ្យទំនាក់ទំនងជាមួយប្រទេសចិនមានភាពប្រសើរឡើងនោះ មានការខ្វល់ខ្វាយយ៉ាងខ្លាំងអំពីសភាពការណ៍វិវត្តន៍ផ្នែកនយោបាយនៅតំបន់អាស៊ី ហើយបានបដិសេធមិនគាំទ្រចលនារំដោះជាតិនេះទេ ។

នៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៩ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានជួបប្រជុំ ដើម្បីពិភាក្សាលើសំណើព្រៀងសេចក្តីសម្រេចមួយ ដែលចិនបានស្នើឡើងឆ្លើយតបទៅ

នឹងការវាយរំដោះប្រទេសកម្ពុជានេះ ។ សមាជិកអចិន្ត្រៃយ៍ក្រុមប្រឹក្សាសន្តិសុខទាំងអស់បានបោះឆ្នោតគាំទ្រសេចក្តីសម្រេចនេះ លើកលែងតែសហភាពសូវៀត ដែលបានប្រើសិទ្ធិវេតូបោះឆ្នោតប្រឆាំង ។ នៅពេលទន្ទឹមគ្នានោះ សហរដ្ឋអាមេរិកបានព្យាយាមប្រទេសវៀតណាមនិងប្រទេសកម្ពុជាឯកោ ដោយជំរុញឲ្យប្រទេសនានា អង្គការមនុស្សធម៌ អង្គការជំនួយអន្តរជាតិ អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក មិនឲ្យផ្តល់ជំនួយដល់ប្រទេសទាំងពីរ ។ នៅខែកញ្ញា ឆ្នាំ១៩៧៩ នៅមហាសន្និបាតអង្គការសហប្រជាជាតិ ប្រទេសចិន សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តរបស់ខ្លួន ហើយរួមទាំងប្រទេសនៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ផង បានអនុម័តយល់ព្រមលើសេចក្តីសម្រេចមួយដែលទទួលស្គាល់សិទ្ធិរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការកាន់កាប់អាសនៈរបស់កម្ពុជា នៅមហាសន្និបាតអង្គការសហប្រជាជាតិ ។ ដូច្នេះសហរដ្ឋអាមេរិកក៏ដូចជាប្រទេសពីរទៀត ដែលនៅពីក្រោយជម្លោះ ពោលគឺសហភាពសូវៀតនិងប្រទេសចិនត្រូវតែទទួលនូវការរិះគន់ចំពោះការប្រើប្រាស់ប្រទេសទន់ខ្សោយទាំងពីរធ្វើជាឧបករណ៍បម្រើឲ្យផលប្រយោជន៍របស់ខ្លួននៅក្នុងល្បែងសង្គ្រាមត្រជាក់ ។

## តើសង្គ្រាមគឺជារឿងត្រឹមត្រូវដែរឬទេ?

ជាប្រពៃណី បុព្វហេតុត្រឹមត្រូវមួយឬការការពារខ្លួនត្រូវបានមើលឃើញថា ជាកត្តាស្របតាមក្រមសីលធម៌និងសំខាន់បំផុត តែមួយគត់ក្នុងការធ្វើសង្គ្រាម ។ គោលការណ៍នេះអាចត្រូវបានយកមកថ្លឹងថ្លែងក្នុងករណីនៃការធ្វើសង្គ្រាមរបស់វៀតណាម ។ នៅពេលចូលកាន់កាប់អំណាចភ្លាម កម្ពុជាប្រជាធិបតេយ្យចាប់ផ្តើមធ្វើការវាយប្រហារនៅតាមបណ្តោយព្រំដែនវៀតណាម ហើយពេលខ្លះបានចូលជ្រៅទៅក្នុងទឹកដីវៀតណាមថែមទៀត ។ ក្រោយមក កងទ័ពកម្ពុជាប្រជាធិបតេយ្យសម្លាប់ជនស៊ីវិលវៀតណាមរាប់រយនាក់ និងធ្វើឲ្យជីវិតរស់នៅរបស់ប្រជាជនវៀតណាមតាមព្រំដែនទទួលរងទុក្ខវេទនាយ៉ាងខ្លាំង ។ ការឈ្លានពានរបស់កម្ពុជាប្រជាធិបតេយ្យចូលទឹកដីវៀតណាមជាយុត្តិកម្មមួយយ៉ាងធំសម្រាប់វៀតណាមក្នុងការធ្វើសង្គ្រាមដើម្បីការពារប្រជាជនរបស់ខ្លួន ។

ហេតុផលមួយទៀតអាចមើលឃើញនៅក្នុងគោលការណ៍ជម្រើសចុងក្រោយ ដែលសង្គ្រាមត្រូវបានចាត់ទុកថាត្រឹមត្រូវក្នុងករណីដែលជម្រើសអហិង្សាទាំងឡាយដែលប្រើដើម្បីទប់ស្កាត់សង្គ្រាមត្រូវបរាជ័យ ។ ដូចបានកត់សម្គាល់ពីដើម វៀតណាមបានព្យាយាមជាច្រើនដង ក្នុងការផ្តល់ជម្រើសសន្តិវិធីជាច្រើន ដើម្បីដោះស្រាយបញ្ហាជម្លោះ ។ ឧទាហរណ៍ វៀតណាមបានស្នើសុំឲ្យមានការចរចានៅចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៦ ស្នើឲ្យមានបទឈប់បាញ់គ្នានៅឆ្នាំ១៩៧៧ និងយល់ព្រមបើកកិច្ចចរចាជាច្រើនដងក្នុងឆ្នាំ១៩៧៨ ។ ទោះជាយ៉ាងណាក៏ដោយរាល់សំណើទាំងនេះត្រូវបានភាគីកម្ពុជាប្រជាធិបតេយ្យច្រានចោលជានិច្ច ។

តាមគោលការណ៍នៃការសម្រេចដោយរដ្ឋអំណាចស្របច្បាប់ សង្គ្រាមមានភាពត្រឹមត្រូវ លុះត្រាតែការធ្វើសង្គ្រាមនេះអនុលោមទៅតាមសេចក្តីសម្រេចរបស់រដ្ឋអំណាចស្របច្បាប់ដែលរដ្ឋអធិបតេយ្យមួយមានសិទ្ធិប្រកាសសង្គ្រាម ដើម្បីការពារពលរដ្ឋរបស់ខ្លួនប្រឆាំងនឹងសត្រូវ ។ ជាក់ស្តែង ប៉ុល ពត បានប្រកាសថា រដ្ឋាភិបាលរបស់គាត់ត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តួលរំលំវៀតណាម ។ ឆ្លើយតបទៅនឹងការគំរាមកំហែងនិងការវាយប្រហារចុងក្រោយរបស់កងទ័ពខ្មែរក្រហម នៅខែធ្នូ ឆ្នាំ១៩៧៨ វៀតណាមបានប្រកាសជាសាធារណៈថា ខ្លួនបានបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលសមាសភាពរួមមានកម្មាភិបាលខ្មែរក្រហម ដែលរត់ចោលជួរក្នុងឆ្នាំ១៩៧៧-១៩៧៨ ក៏ដូចជាជនជាតិខ្មែរមួយចំនួនដែលកំពុងរស់នៅនិរទេសខ្លួនក្នុងប្រទេសវៀតណាម ក្នុងបំណងបញ្ឈប់ការឈ្លានពានរបស់កម្ពុជាប្រជាធិបតេយ្យមកលើទឹកដីវៀតណាម និងដើម្បីរំដោះប្រទេសកម្ពុជា ។

ការផ្តួលរំលំកម្ពុជាប្រជាធិបតេយ្យមិនលំបាកទេ ។ ក្នុងឆ្នាំ១៩៧៧ វៀតណាម (ដែលមានចំនួនប្រជាជនសរុបជិត៥០លាននាក់) មានកងទ័ពប្រហែល៦១៥.០០០នាក់ ក្នុងពេលដែលកម្ពុជាប្រជាធិបតេយ្យ (ដែលមានចំនួនប្រជាជនសរុបប្រាំពីរលាននាក់) មានកងទ័ពតែប្រមាណ៧០.០០០នាក់ប៉ុណ្ណោះ ។ កម្ពុជាប្រជាធិបតេយ្យមានតែរថក្រោះធុនស្រាលមួយចំនួនតូច រថយន្តដឹកទាហាន២០០គ្រឿង និងស្ទើរតែគ្មានកងទ័ពជើង

អាកាស នៅពេលវៀតណាមមានរថក្រោះធុនស្រាលនិងធុនមធ្យមប្រហែល៩០០គ្រឿង កងទ័ពជើងអាកាស១២.០០០នាក់ យន្តហោះចម្បាំង៣០០គ្រឿង កងទម្លាក់គ្រាប់បែកមួយកងពល និងកងប្រយុទ្ធដែនគោកចំនួនប្រាំបីកងពល ដែលមានជំនួយពីយន្តហោះ ចម្បាំងចំនួន១៥០គ្រឿងផ្សេងទៀត ។ កត្តាសំខាន់បំផុតនោះគឺលក្ខខណ្ឌមិនស៊ីគ្នារវាងប្រទេសទាំងពីរ ។ ទោះបីជាវៀតណាមជាប្រទេសក្រីក្រក៏ដោយ ជីវភាពរបស់ប្រជាជនមានកម្រិតអាចទ្រាំទ្របាន ។ ផ្ទុយទៅវិញ ប្រជាជនកម្ពុជាយ៉ាងតិចហាសិបភាគរយទទួលរងនូវការបំផ្លិចបំផ្លាញទាំងសតិបញ្ញានិងរូបរាងកាយ ដោយសារតែការអត់ឃ្លាននិងជំងឺ ។ ដូច្នេះកងទ័ពវៀតណាមចំណាយពេលតែពីរសប្តាហ៍ប៉ុណ្ណោះ ក្នុងការវាយរំដោះកម្ពុជា ។

ការវាយរំដោះនោះមិនត្រឹមតែបានការពារប្រជាជនវៀតណាមប៉ុណ្ណោះទេ ថែមទាំងបានជួយសង្គ្រោះប្រជាជនកម្ពុជារាប់លាននាក់ដែលហៀបនឹងស្លាប់ថែមទៀត ។ ឡេ ដុកថូ ជាសមាជិកការិយាល័យនយោបាយបក្សកុម្មុយនិស្តវៀតណាម បានមានប្រសាសន៍ក្នុងសុន្ទរកថានាខែធ្នូ ឆ្នាំ១៩៧៩ ថា "ការវាយបករបស់យើងប្រឆាំងនឹងកងទ័ព ប៉ុលពត អៀងសារី មិនគ្រាន់តែជាវិធានការការពារខ្លួនទេ ថែមទាំងជាការរួមចំណែករំដោះប្រជាជនកម្ពុជាពីរបបប្រល័យពូជសាសន៍ ប៉ុលពត អៀងសារី ទៀតផង" ។ ក្រៅពីការស្លាប់ដោយសារការអត់អាហារ ការធ្វើការហួសកម្លាំង ជំងឺ និងការកាប់សម្លាប់បក្សកុម្មុយនិស្តកម្ពុជាបានចាប់ផ្តើមធ្វើវិសុទ្ធកម្មទៅលើសមាជិកបក្សរបស់ខ្លួនក្នុងឆ្នាំ១៩៧៧ ។ "ប្រសិនបើកងទ័ពវៀតណាមមិនបានវាយកាន់កាប់ទីក្រុងភ្នំពេញ ក្នុងខែ មករា ឆ្នាំ១៩៧៩នោះ ទេ មិនមានភស្តុតាងណាមួយអាចបញ្ជាក់ បានថា ការធ្វើវិសុទ្ធកម្មរបស់កម្ពុជាប្រជាធិបតេយ្យនឹងត្រូវបញ្ចប់នោះទេ ។ ជាលទ្ធផល កត្តាទាំងអស់នេះបញ្ជាក់ថាការវាយរំដោះរបស់ វៀតណាមត្រូវបានមើលឃើញថា បានធ្វើឲ្យស្ថានការណ៍មានភាពល្អប្រសើរជាងការគ្មានអន្តរាគមន៍ ដែលប្រការនេះត្រូវបានបញ្ជាក់បន្ថែមនៅក្នុងគោលការណ៍នៃការគិតត្រូវ ។


កងទ័ពខ្មែរក្រហម

យោងតាមច្បាប់សង្គ្រាម ការវាយប្រហារឬសម្លាប់ជនមិនមែនជាកងទ័ពគឺជាប្រការខុសឆ្គង ដោយហេតុថា ផ្ទុយពីកងទ័ពអ្នកទាំងនោះជាប្រជាជនស្លូតត្រង់ ។ គោលការណ៍នេះមិនតែត្រឹមជាទំនៀមទម្លាប់ផ្នែកសីលធម៌ប៉ុណ្ណោះទេ ថែមទាំងត្រូវបានបញ្ជាក់បន្ថែមនៅក្នុងច្បាប់អន្តរជាតិសម័យទំនើបទៀត

ផង ។ ក្នុងអំឡុងពេលនៃការចូលលុកលុយរបស់វៀតណាម ប្រជាជនស៊ីវិលមានសេរីភាព វិលត្រលប់ទៅកាន់ភូមិកំណើតរបស់ខ្លួនវិញ ក្រោមកិច្ចការពារពីកងទ័ពវៀតណាម ។ ជាងនេះទៅទៀត ទាហានវៀតណាមទាំងនេះមិនបានធ្វើទុក្ខទោសប្រជាជនកម្ពុជាស៊ីវិលទេ ហើយថែមទាំងស្វាគមន៍កងទ័ពកម្ពុជាប្រជាធិបតេយ្យក្នុងការវិលត្រលប់មកភូមិកំណើត ហើយរួមរស់នៅជាមួយក្រុមគ្រួសាររបស់ខ្លួនវិញផង ។ បន្ថែមពីលើនេះទៀត បន្ទាប់ពីវាយរំដោះបានភ្លាម របបថ្មីមួយត្រូវបានបង្កើតឡើងដើម្បីកសាងប្រទេសជាតិឡើងវិញ ហើយបានបើកសាលារៀន ផ្សារ មន្ទីរពេទ្យ និងទីសក្ការៈគោរពបូជា ដែលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យកន្លែងអស់ទាំងនេះត្រូវបានបិទចោលទាំងស្រុង ។

បន្ថែមលើទ្រឹស្តីយុត្តិកម្មសង្គ្រាម កាតព្វកិច្ចការពារបានអនុញ្ញាតឲ្យមានអន្តរាគមន៍ ផ្នែកយោធា ក្នុងគោលបំណងដើម្បីការពារជីវិតមនុស្ស ។ ទង្វើបែបនេះប្រៀបបាននឹងបុព្វហេតុត្រឹមត្រូវមួយសម្រាប់អន្តរាគមន៍ផ្នែកយោធា ។ កាតព្វកិច្ចការពាររួមមានប្រភេទសកម្មភាព ដូចខាងក្រោម ដែលក្នុងចំណោមនោះ អន្តរាគមន៍ផ្នែកយោធាគឺជា វិធានការដោយឡែកនិងពិសេសមួយ ៖

១) "ការបាត់បង់អាយុជីវិតយ៉ាងច្រើន ដោយការវាយប្រហារធ្វើឲ្យគ្រោះថ្នាក់ជាក់ស្តែង ឬដោយការចាប់ខ្លួនប្រហារជីវិតតាមផ្លូវច្បាប់ ដោយមានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬដោយអចេតនាក្តី ដែលទាំងនេះអាចជាទង្វើដោយចេតនារបស់រដ្ឋមួយ ឬជាការធ្វេសប្រហែស ឬអសមត្ថភាពរបស់រដ្ឋក្នុងការចាត់វិធានការការពារ ឬអាចជាស្ថានភាពបរាជ័យរបស់រដ្ឋមួយ ឬ ២) "ការសម្លាប់បំបាត់ជាតិពន្ធុមួយក្នុងទ្រង់ទ្រាយធំ" ដោយការវាយប្រហារធ្វើឲ្យគ្រោះថ្នាក់ជាក់ស្តែង ឬដោយការចាប់ខ្លួនប្រហារជីវិតតាមផ្លូវច្បាប់ទោះជាទង្វើនេះត្រូវបានធ្វើ ឡើងដោយការសម្លាប់ ការបណ្តេញចេញដោយបង្ខំ អំពើហិង្សា ឬការចាប់រំលោភ ។

ឃ្លាទាំងពីរនេះមានន័យថា វាគឺជាវិធានការត្រឹមត្រូវតាមផ្លូវសីលធម៌ សម្រាប់បណ្តាប្រទេសទាំងឡាយនៅលើពិភពលោក ក្នុងការចូលធ្វើសង្គ្រាមក្នុងនាមជនទាំងឡាយ ដែលកំពុងប្រឈមមុខនឹងអំពើប្រល័យពូជសាសន៍ ឬការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដទៃទៀត ដែលប្រព្រឹត្តឡើងដោយរដ្ឋាភិបាលរបស់ខ្លួន ។ ដូចបានកត់សម្គាល់ពីខាងដើម របបកម្ពុជាប្រជាធិបតេយ្យត្រូវបានដឹងជាទូទៅថា បានរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។ ប្រជាជនប្រមាណជិតពីរលាននាក់បានស្លាប់ដោយការអត់អាហារ ជំងឺ ការធ្វើការហួសកម្លាំង ឬការសម្លាប់ ។ ជាងនេះទៅទៀត ប្រជាជនត្រូវបានបណ្តេញចេញទាំងបង្ខំឲ្យចាកចេញពីទីក្រុងនិងទីប្រជុំជន ។ សាលារៀន និងវត្តអារាមត្រូវបិទទ្វារ ។ គ្រួសារទាំងឡាយត្រូវបំបែកពីគ្នា ក្រោមរបបមួយដែលបានសម្លាប់ប្រជាជនរបស់ខ្លួនជិតមួយភាគបួននៃចំនួនប្រជាជនសរុប ។ ដូចនេះ ការវាយរំដោះរបស់វៀតណាមត្រូវបានចាត់ទុកថាជាទង្វើអាចទទួលយកបាននៅក្រោមគោលការណ៍ទ្រឹស្តីយុត្តិធម៌សង្គ្រាមនិងគោលការណ៍កាតព្វកិច្ចក្នុងការការពារ ។

## តើសង្គ្រាមគឺជាទង្វើមិនត្រឹមត្រូវឬ?

លោក ស្តេហ្វេន ម៉ូរីស យល់ឃើញថា សង្គ្រាមមិនមែនជាទង្វើត្រឹមត្រូវទេ ដោយលោកបានលើកហេតុផលថា វៀតណាមវាយរំដោះប្រទេសកម្ពុជាដោយសារតែមហិច្ឆតាចង់បានអំណាចរបស់ខ្លួន ។ ម៉ូរីស អះអាងថា មហិច្ឆតានយោបាយរបស់វៀតណាមគឺត្រួតត្រាលើប្រទេសទន់ខ្សោយ ដែលនៅជិតខាងខ្លួនគឺប្រទេសឡាវនិងប្រទេសកម្ពុជា ។ បើពិនិត្យមើលប្រវត្តិសាស្ត្រនាសតវត្សរ៍ទី១៩ មុនសម័យកាលដែលបារាំងត្រួតត្រាឥណ្ឌូចិន មហិច្ឆតាចង់បានអំណាចជាប្រពៃណីនេះគឺជាភស្តុតាង ដែលស្តែងឲ្យឃើញមហិច្ឆតារបស់វៀតណាមក្នុងការត្រួតត្រាកម្ពុជា ។ គោលបំណងរបស់អ្នកនយោបាយជាន់ខ្ពស់វៀតណាមគឺបង្កើតរដ្ឋសហព័ន្ធឥណ្ឌូចិនមួយ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួន ។ មហិច្ឆតាចង់បានអំណាចនេះបានបង្ហាញឲ្យឃើញកាន់តែច្បាស់ឡើង នៅពេលដែលកុម្មុយនិស្តវៀតណាម បានដាក់កងកម្លាំងរបស់ខ្លួនក្នុងប្រទេសឡាវនៅឆ្នាំ១៩៧៥ ។

នៅដើមឆ្នាំ១៩៧៩ គឺជាលើកទីមួយ ហើយចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៥០មក ដែលកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលរបស់រដ្ឋាភិបាលបរទេស ។ មុនទទួលយកកិច្ចព្រមព្រៀងសន្តិភាពដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិកុម្មុយនិស្ត

វៀតណាមហាក់ដូចជាទទួលប្រយោជន៍រយៈពេលវែងពីការសម្រេចចិត្តរបស់ខ្លួនក្នុងការឈ្លានពានចូលប្រទេសកម្ពុជា ។ បន្ទាប់ពីទទួលជ័យជម្នះលើរបបកម្ពុជាប្រជាធិបតេយ្យភ្លាម វៀតណាមបានលើកបន្តុបរបបថ្មីមួយនៅក្នុងទីក្រុងភ្នំពេញ ដែលមានឈ្មោះថា "សាធារណរដ្ឋប្រជាមានិតកម្ពុជា" ។ របបនេះទទួលខុសត្រូវក្នុងការធ្វើឲ្យប្រទេសកម្ពុជាក្លាយទៅជាវៀតណាម ។

ទំនាក់ទំនងនេះអាចវាយតម្លៃបានតាមវិធីពីរយ៉ាង ។ ទីមួយ វៀតណាមគ្រប់គ្រងផ្ទាល់លើរដ្ឋបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាដែលក្រោយមកក្លាយជារដ្ឋកម្ពុជា ។ ទីប្រឹក្សាវៀតណាមត្រួតត្រាលើរដ្ឋបាលគ្រប់កម្រិតទាំងអស់ ។ ទីប្រឹក្សាសំខាន់ជាងគេគឺឯកអគ្គរដ្ឋទូតវៀតណាម ប្រចាំសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ សេចក្តីណែនាំទាំងឡាយត្រូវបានបញ្ជូនជារៀងរាល់ថ្ងៃពីទីក្រុងហាណូយតាមរយៈឯកអគ្គរដ្ឋទូតរូបនេះ ។ ដូច្នេះ ជារៀងរាល់ព្រឹក ឯកអគ្គរដ្ឋទូតវៀតណាមជួបជាមួយរដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីពិភាក្សាពីផែនការឬហេតុការណ៍ផ្សេងៗដែលត្រូវសម្រេច ។ ក្នុងចំណោមដប់បួននាយកដ្ឋាននៃក្រសួងការបរទេស មានទីប្រឹក្សាវៀតណាមពី១៥ទៅ១៧នាក់សម្រាប់ត្រួតពិនិត្យកិច្ចការប្រចាំថ្ងៃនៅក្នុងក្រសួង ។ ទីប្រឹក្សាទាំងអស់នោះស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលក្រុងហាណូយ ។ រាល់ពេលដែលរដ្ឋមន្ត្រីការបរទេសកម្ពុជាចេញទៅក្រៅប្រទេស ទីប្រឹក្សាវៀតណាមម្នាក់នឹងអមដំណើរទៅជាមួយដើម្បីកត់ត្រាការពិភាក្សាទាំងឡាយ ។ មន្ត្រីជាន់ខ្ពស់កម្ពុជាមួយចំនួនបានរៀបការជាមួយស្ត្រីវៀតណាម ដែលជាអ្នករាយការណ៍អំពីសកម្មភាពប្តីរបស់ខ្លួនទៅឲ្យរដ្ឋាភិបាលក្រុងហាណូយ ។ ជាងនេះទៅទៀត អ្នករដ្ឋការនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាទាំងអស់ត្រូវបានតម្រូវឲ្យរៀនភាសាវៀតណាម ។ ចំណុចចុងក្រោយ តំណែងខ្ពស់ៗក្នុងរដ្ឋាភិបាលត្រូវបានផ្តល់ឲ្យអ្នកទាំងឡាយណាដែលគោរពតាមបញ្ជារបស់វៀតណាម ហើយមេដឹកនាំជាន់ខ្ពស់ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានទៅសិក្សានយោបាយនៅវៀតណាមជាច្រើនខែ ។

ទីពីរ ក្រោយឆ្នាំ១៩៧៩ ប្រជាជនវៀតណាមរាប់សែននាក់បានចូលមករស់នៅលើទឹកដីកម្ពុជា ។ ឆ្លើយតបទៅនឹងបញ្ហានេះ វៀតណាមបានអះអាងថា ជនជាតិវៀតណាមទាំងនេះធ្លាប់រស់នៅកម្ពុជាតាំងពីមុនឆ្នាំ១៩៧៥ម្ល៉េះ ប៉ុន្តែអ្នកទាំងនោះបានរត់ភៀសខ្លួនទៅវៀតណាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះជាយ៉ាងនេះក្តី ជនជាតិវៀតណាមប្រមាណពីបួនសែនទៅប្រាំមួយសែននាក់បានចូលមករស់នៅក្នុងទឹកដីកម្ពុជាចាប់តាំងពីឆ្នាំ១៩៧៩ ។ ជាងនេះទៅទៀត ក្រឹត្យចុះខែកញ្ញា ឆ្នាំ១៩៨៣ បានចែងថា ប្រជាជនកម្ពុជាត្រូវតែចែកដីឲ្យប្រជាជនវៀតណាម ហើយត្រូវជួយសង់ផ្ទះសំបែងឲ្យប្រជាជនវៀតណាមថែមទៀត ។ ដូចនេះ គ្រប់ឃុំនៅតំបន់ដាច់ស្រយាលទូទាំងប្រទេសត្រូវបានតម្រូវឲ្យទទួលយកជនជាតិវៀតណាមមួយចំនួនមករស់នៅ ។

## សេចក្តីសន្និដ្ឋាន

ការវាយរំដោះរបស់វៀតណាមត្រូវបានចាត់ទុកថា ជាទង្វើអាចទទួលយកបានក្នុងនាមជួយសង្គ្រោះជីវិតប្រជាជនកម្ពុជារាប់លាននាក់ពីរបបកម្ពុជាប្រជាធិបតេយ្យ ។ វាជារឿងដែលអាចយល់បាន ដែលថាការឈ្លានពានរបស់កម្ពុជាប្រជាធិបតេយ្យចូលទឹកដីវៀតណាម ជាហេតុផលស្របច្បាប់សម្រាប់ការវាយរំដោះរបស់វៀតណាម ។ ប្រសិនបើកម្ពុជាប្រជាធិបតេយ្យមិនបង្កសង្គ្រាមជាមួយវៀតណាមនោះទេ សង្គ្រាមនឹងមិនអាចផ្ទុះឡើងបានឡើយ ។ ព្រោះនៅពេលនោះ វៀតណាមស្ថិតនៅក្នុងស្ថានភាពមិនទាន់នឹងន ដោយសារតែសង្គ្រាមជាច្រើនទសវត្សរ៍ជាមួយសហរដ្ឋអាមេរិកនិងចិន ហើយវៀតណាមត្រូវការពេលវេលាដើម្បីស្តារប្រទេសជាតិឡើងវិញ ។ ទោះបីជាប្រជាជនកម្ពុជាត្រូវរំដោះផុតពីរបបវាលពិឃាតក៏ដោយ ក៏ផលវិបាកនៃការរំដោះនេះនៅតែបន្តប៉ះទង្គិចដល់ជីវិតរស់នៅប្រចាំថ្ងៃដដែល ។ ក្នុងអំឡុងពេលដប់ឆ្នាំនៃសង្គ្រាមស៊ីវិលកម្ពុជានៅឯកោពីពិភពលោក ហើយសេដ្ឋកិច្ចជាតិនៅមិនទាន់បានស្តារឡើងវិញនៅឡើយ ។ បទពិសោធន៍នេះជាមេរៀនសម្រាប់អង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិ ដែលមិនបានចាត់វិធានការអន្តរាគមន៍ណាមួយក្នុងពេលដែលបក្សកុម្មុយនិស្តកម្ពុជាគ្រប់គ្រងប្រទេសម្ពុជា ហើយថែមទាំងបានគាំទ្រខ្មែរក្រហមក្នុងខណៈដែលប្រទេសទាំងនោះកំពុងតែបន្តប្រជែងនៅលើឆាកអន្តរជាតិដើម្បីតែផលប្រយោជន៍រៀងៗខ្លួន ។

**ព្រុំ ផល្លា**

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្ដើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្ដុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន : ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនិទ្ទេសបង្ហាញពីរណ្ដៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

"ការិយាល័យព័ត៌មានសាធារណៈ" មានផ្ដល់ជូននូវសេវា៣យ៉ាង :

**១) បណ្ណាល័យ** : នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្ដី ស្ដាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** : មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** : ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្ដល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អែម សុខឃីម តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។



កូនស្រី និងកូនប្រុសារ របស់ គីម សារិន (រូបថត)



ជន់ សែម

# ប្រឈមមុខនឹងអតីតកាល

បុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរឆ្នាំ២០០៦នេះគឺជាខួបទី៣១នៃការដួលរលំនៃទីក្រុងភ្នំពេញទៅក្នុងកណ្តាប់ដៃខ្មែរក្រហម ។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃចាប់ផ្តើមនៃការឈឺចាប់របស់មនុស្សជំនាន់ខ្ញុំ និងជាថ្ងៃដែលប្រទេសកម្ពុជាធ្លាក់ទៅក្នុងសភាពថោកទាប ។ ប្រជាជនកម្ពុជាកំពុងតែព្យាយាមគណនាទំហំនៃការបាត់បង់របស់ខ្លួន ហើយប្រទេសកម្ពុជានៅតែប៉ះទង្គិចដោយសាររបបកម្ពុជាប្រជាធិបតេយ្យ ។

នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៦ ខ្ញុំភ្ញាក់ពីដំណេកជាមួយនឹងគំនិតរវើរវាយ ។ បន្ទាប់ពីជិះរថយន្តតាក់ស៊ីអស់រយៈពេលពីរម៉ោងមក ខ្ញុំបានមកដល់ភូមិជ្រៃដែលខ្ញុំធ្លាប់រស់នៅក្នុងសភាពភ័យខ្លាចកាលពីជិត៣០ឆ្នាំមុន ។ នៅក្នុងខែមេសា ក្រុមគ្រួសាររបស់ខ្ញុំបានផ្លាស់មករស់នៅក្នុងភូមិជ្រៃ ស្រុកមោងឫស្សីជាមួយអ្នកស្រុកអ្នកភូមិនៅទីនោះដែលយើងមិនធ្លាប់ស្គាល់ ។ យើងរស់នៅទីនោះរហូតដល់ពេលដែលក្រុមគ្រួសាររបស់ខ្ញុំចាកចេញពីភូមិជ្រៃនៅចុងឆ្នាំ១៩៧៨ ។

ពេលដែលខ្ញុំឈានជើងចេញពីរថយន្តតាក់ស៊ីដែលឈប់នៅក្នុងស្រុកមោងឫស្សី ហើយពេលដែលខ្ញុំមានអារម្មណ៍ថាជើងរបស់ខ្ញុំកំពុងជាន់ដី ខ្ញុំស្រាប់តែឃើញភ្លាមថា ខ្ញុំបានឈរស្តាប់ការណែនាំរបស់ខ្មែរក្រហមនៅទីនេះ ។ វាធ្វើឲ្យខ្ញុំមានអារម្មណ៍ចម្លែកដែលមិនអាចពន្យល់ប្រាប់បាន ព្រោះខ្ញុំឈរតែម្នាក់ឯងនៅត្រង់កន្លែងដែលខ្ញុំធ្លាប់ស្គាល់ ។

ខ្ញុំសម្លឹងមើលរថយន្តតាក់ស៊ីបើកចេញទៅទិសខាងជើងឆ្ពោះទៅខេត្តបាត់ដំបង ។ ខ្ញុំឈរនៅកន្លែងដែលក្រុមគ្រួសាររបស់ខ្ញុំធ្លាប់ឈរជាច្រើនឆ្នាំកន្លងមកហើយ ។ ផ្លូវធំទូលាយជាងមុន និងមានដើមឈើពីរបីដើម ។ បច្ចុប្បន្ន សងខាងផ្លូវនេះពេញទៅដោយរានលក់ម្ហូបអាហារ និងម៉ូតូឌុបដែលកំពុងរង់ចាំដឹកអ្នកដំណើរ ។ របងរាំងផ្លូវដែលខ្មែរក្រហមដាក់កាត់ទទឹងផ្លូវជាតិដើម្បីការពារកុំឲ្យមនុស្សធ្វើដំណើរឆ្លងកាត់ក្នុងអំឡុងរបបខ្មែរក្រហមឥឡូវនេះលែងមានទៀតហើយ ។ មានផ្ទះច្រើនជាងមុននៅតាមបណ្តោយផ្លូវ ។ ផ្សារមោងបានបើកលក់ឡើងវិញ និងមានគ្លីនិកមួយទល់មុខវត្តដែលប្អូនប្រុសរបស់ខ្ញុំ តារា បានស្លាប់ ។

មិនយូរប៉ុន្មានខ្ញុំក៏បានដើរមកដល់ផ្លូវក្រួសក្រហម ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានវិលត្រឡប់មករកទីកន្លែងដែលខ្ញុំបានចាកចេញជាង៣០ឆ្នាំកន្លងមកហើយ ។ ខ្ញុំចាប់ផ្តើមរកមនុស្សដែលខ្ញុំធ្លាប់ស្គាល់ ឧទាហរណ៍បងប្រុសខ្ញុំឈ្មោះ អមរិទ្ធ ដែលបាត់ខ្លួនក្នុងពេលដែលគាត់កំពុងតែលើកទំនប់នៅក្នុងឆ្នាំ១៩៧៧ ។

ដំបូង ខ្ញុំគិតថាស្វែងរកទំនប់នោះមុន ។ ទើបតែប៉ុន្មានខែមុនពេលវៀតណាមវាយលុកចូលប្រទេសកម្ពុជា ខ្មែរក្រហមបានយករថយន្តនិងរទេះគោដែលផ្ទុកទៅដោយមនុស្សមកបើកបរពីលើទ្វារទឹកនៃទំនប់នោះដើម្បីវាស់ស្ទង់ភាពរឹងមាំរបស់វា ។

## ទំនប់មោង-ជ្រៃ

ខ្ញុំឈរនៅលើច្រាំងទន្លេមើលបុរសម្នាក់កំពុងតែជួតទឹកនិងបោកគក់សម្លៀកបំពាក់ គិតក្នុងចិត្តអំពីពេលមួយដែលខ្ញុំបានចូលរួមកសាងទំនប់នេះ ។ ខ្ញុំចាំបានថាខ្ញុំឈរជាជួរហុចបង្គីផ្ទុកទៅដោយដីទៅឲ្យអ្នកបន្ទាប់ពីខ្ញុំ ។ បុរសម្នាក់ឈ្មោះ រី ជាអ្នកមើលខុសត្រូវការងារនោះ ។ ពេលដែល រី កំពុងតែដើរពិនិត្យមើលប្រជាជនធ្វើការងារ សមមិត្តសាយ ដើរចុះឡើងបណ្តើរដក់បារីបណ្តើរនិងស្រែកគំហកដាក់ប្រជាជនដែលត្រូវបង្ខំឲ្យស្តាប់ចម្រៀងបដិវត្តន៍ដែលចាក់តាមមេក្រូ ។ បងប្រុសក្មេករបស់ខ្ញុំឈ្មោះ ផល ធ្វើការនៅក្នុងក្រុមផ្សេងមួយទៀតនៅតាមទំនប់នេះដែរ ។

ដោយសម្លឹងរកអ្វីដែលខ្ញុំអាចសម្គាល់បាន ខ្ញុំឃើញដើមពោធិ៍ធំមួយនៅមាត់ស្ទឹងត្រើយម្ខាងទល់មុខខ្ញុំ ។ ដើមពោធិ៍នោះមិនខ្ពស់ជាងមុនទេ ប៉ុន្តែវាមានអាយុចំណាស់ជាងមុន ។ មានអគារតូចពីរនៅខាងក្រោយដើមពោធិ៍នោះ អគារមួយចាស់បន្តិចធ្វើអំពីឈើនិងអគារការិយាល័យធ្វើអំពីថ្មដែលកំពុងតែសាងសង់ ។ វត្តជ័យត្រូវបានកសាងឡើងវិញដោយប្រាក់វិភាគទានពីសំណាក់ប្រជាជនខ្មែររស់នៅក្នុងសហរដ្ឋអាមេរិកនិងបារាំង ។ ពុទ្ធសាសនិកជនកសាងចេតិយដើម្បីគោរពបូជាសមាជិកគ្រួសារដែលបាន

ស្លាប់ក្នុងសម័យខ្មែរក្រហម ។

ទល់មុខនឹងមាត់ស្ទឹងមានគ្លីនិកសុខភាពមួយជំនួសមណ្ឌលសហគមន៍ដែលកសាងនៅដើមឆ្នាំ១៩៧៦ ។ ពីមុនទីនេះជាទីកន្លែងដែលខ្មែរក្រហមចាប់ឃុំខ្លួន ប៊ុនថន មុនពេលបញ្ជូនគាត់ទៅសម្លាប់នៅវត្តធម្មយុត្តិ ។

ពេលនេះខ្ញុំចងចាំឡើងវិញបានច្រើន ដូចជាដើមឈើដែលខ្ញុំធ្លាប់ឡើង ថ្មុកត្រពាំងដែលខ្ញុំធ្លាប់ហែល និងកន្លែងដែលខ្ញុំលាក់របស់របរពីភ្នែកខ្មែរក្រហម ។

ពេលកំពុងជិះទូកឆ្លងកាត់ស្ទឹង មនុស្សដំបូងដែលខ្ញុំនឹកឃើញគឺសមមិត្ត ដាស ប្រពន្ធ និងកូនប្រុសគាត់ពីរនាក់ឈ្មោះ ទុយ និង រួន ប៉ុន្តែគ្មានសញ្ញាណាមួយបង្ហាញថាអ្នកទាំងនោះ នៅរស់ឬស្លាប់ឡើយ ។ តាមផ្លូវឆ្ពោះទៅខ្ទមរបស់យើង ខ្ញុំបានសួរអ្នកភូមិរកមនុស្សដែលខ្ញុំធ្លាប់ស្គាល់ ។ អ្នកភូមិជាច្រើននាក់បានប្រាប់ខ្ញុំរឿងរ៉ាវដែលមិនដូចគ្នា ។ បើខ្ញុំចាំមិនខុសទេ មានដើមត្នោតប្រាំដើមនៅខាងក្រោយខ្ទមស្បូវ ។ ព្រឹកមួយ បុរសម្នាក់បានធ្លាក់ពីលើចុងត្នោតស្លាប់ក្នុងខណៈពេលដែលគាត់កំពុងតែកាត់ស្លឹកត្នោតយកមកធ្វើដំបូលប្រក់ខ្ទមគាត់ ។ ឆ្លងផ្លូវនេះគឺ ជាផ្ទះរបស់សមមិត្ត ដាស ហើយទៅស្ដាំដៃគឺជាផ្ទះរបស់សមមិត្ត សុទ្ធ ។

## ខ្ទមដំបូងរបស់យើងនៅពីមុខដើមត្នោតប្រាំដើម

ខ្ទមដំបូងរបស់យើងមានផ្ទៃក្រឡា១,៨ម៉ែត្រគុណនឹង២,៤ម៉ែត្រនិងកម្ពស់៣តឹក ។ ចំពោះខ្ញុំ ផ្ទះនេះគ្រាន់តែជាកន្លែងសម្រាប់ដេកប៉ុណ្ណោះ (ព្រោះគ្មានផ្ទះបាយទេ) ។ នៅរដូវវស្សារៀងរាល់ឆ្នាំទឹកជំនន់លិចរនាបផ្ទះកម្ពស់២,៥សង់ទីម៉ែត្រ ។ ក្នុងរយៈពេលពីរបីខែដំបូងដែលយើងមកដល់ទីនោះ ខ្ញុំអង្គុយនៅក្នុងខ្ទមយោលជើងលេង មើលអ្នកជិតខាង និងរីករាយជាមួយនឹងពេលទំនេរ ។ ម្ដាយខ្ញុំជម្រះស្មៅនៅក្បែរផ្ទះដើម្បីដាំបន្លែនិងដំឡូង ។ គាត់ធ្វើរបងការពារកុំឲ្យមាន់ចូលចឹកដំណាំនិងកុំឲ្យអ្នកដទៃចូលលួចបេះ ក៏ប៉ុន្តែអ្វីដែលគួរឲ្យកត់សម្គាល់នោះគឺថានេះជាវិធីដែលគាត់កំណត់ទីតាំងរបស់គាត់ ។

ការរស់នៅក្នុងពិភពមួយដែលគ្មានពណ៌គឺពិបាកនឹងស្រមៃ ។ នៅឆ្នាំ១៩៧៦ អ្វីៗដែលធម្មជាតិមិនបានសម្លាប់ គឺខ្មែរក្រហមសម្លាប់ ។ ភូមិជ្រៃសម្បូរទៅដោយដីមានជីជាតិនិងទន្លេដែលផ្ដល់ភាពងាយស្រួលដល់ការដាំស្រូវ ពោត ដំឡូង ក្រូចឆ្មារគ្រប់ប្រភេទនិងដំណាំហូបផ្លែ ដែលផ្ដល់ដល់កសិករមិនត្រឹមតែផលដំណាំប៉ុណ្ណោះទេ ថែមទាំងមច្ឆានិងទឹកបរិបូណ៌ពេញមួយឆ្នាំ ។ ក៏ប៉ុន្តែពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយសប្ដាហ៍ទៅមួយសប្ដាហ៍ ពីមួយឆ្នាំទៅមួយឆ្នាំ ខ្ញុំអង្គុយនៅក្នុងខ្ទមមើលស្លឹកឈើជ្រុះពីលើដើមបន្តិចម្ដងៗ ។

ចុងឆ្នាំ១៩៧៧ ដោយសារតែមានមនុស្សស្លាប់កាន់តែច្រើន ភូមិជ្រៃបានក្លាយទៅជាវាលកប់ខ្មោច ។ នៅពេលយប់ភូមិជ្រៃងងឹតឈឹងនិងស្ងាត់ជ្រងំ មានតែឆ្កែព្រៃដែលចេញដើរស្វែងរកចំណីនិងស្រែកលូ ។ ម្ដាយខ្ញុំនៅតែម្នាក់ឯងស្ទើរតែរាល់យប់ និងព្រួយបារម្ភអំពីជីវិតរបស់គាត់ ។ គាត់រស់នៅទីនោះរហូតដល់ពេលដែលប្រជាជននៅក្នុងភូមិជ្រៃត្រូវបំបែកទៅកន្លែងផ្សេងដែលមានចម្ងាយពីរឬបីគីឡូម៉ែត្រក្នុងភូមិនោះដដែល ។

អស់រយៈពេលជិតបួនឆ្នាំ ខ្ទមស្បូវមួយនេះជាជីវិតរបស់ខ្ញុំទាំងមូលទៅហើយ ។ របបកម្ពុជាប្រជាធិបតេយ្យបានបង្រៀនខ្ញុំមិនឲ្យដើរទៅណាផ្ដេសផ្ដាសប្រសិនបើអង្គការមិនចាត់តាំង ។ ស្ទើរតែរៀងរាល់ថ្ងៃខ្ញុំខំប្រឹងប្រែងដើម្បីតែបបរមួយចានគោម ។ ក៏ប៉ុន្តែ វាច្បាស់ណាស់ហើយថា ផ្ទះគឺផ្ទះ គឺជាកន្លែងសំខាន់នៅក្នុងវប្បធម៌ខ្មែរ ។ ប្រាកដណាស់ ខ្ញុំចង់រស់នៅជាមួយនឹងម្ដាយរបស់ខ្ញុំ ហើយអារម្មណ៍ដែលគិតថាគាត់នៅរស់បានលួងលោមខ្ញុំ ។

ហួសពីផ្ទះខ្ញុំបន្តិចមានមណ្ឌលសុខភាពមួយកន្លែងដែលយកមើមនិងឫសឈើមកធ្វើជាឱសថព្យាបាលជំងឺ ។ ខ្ញុំបានទៅមណ្ឌលសុខភាពនោះបួនដប់លើកដែរ ប៉ុន្តែមិនមែនព្រោះតែខ្ញុំមានជំងឺនោះទេ គឺព្រោះតែថ្នាំមួយចំនួនផ្សំជាមួយនឹងស្ករត្នោត ហើយខ្ញុំត្រូវការជាតិស្ករដើម្បីប៉ូវកម្លាំង ។ ជាញឹកញាប់ កន និងខ្ញុំ លួចបេះផ្លែស្វាយរាល់ពេលដែលមានព្យុះភ្លៀង ។

មានការលំបាកបន្តិចក្នុងការដើរទៅវាលស្រែពីក្រោយដើមឈើដែលដុះជាជួរៗ ។ ខ្ញុំឈរសម្លឹងរកមើលតំបន់ដែលខ្ញុំគិតថាមានផ្ទះរបស់ប្អូនប្រុសក្មេងរបស់ខ្ញុំឈ្មោះ ដល នៅទីនោះ ។ ខ្ញុំគិតពីវត្តមានរបស់គាត់គ្រប់ពេលវេលា ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំស្និទ្ធស្នាលនឹងគាត់ជាងពីមុន ។ ខ្ញុំនៅចំណាំដើមឈើមួយដើម ដើរទៅមុខបន្តិចទៀតគឺជាត្រពាំងទឹកតូចមួយដែលបងប្រុសខ្ញុំនិងខ្ញុំធ្លាប់

ហែលលេង ឥឡូវនេះវាលែងមានទៀតហើយ ។ មានកន្លែងជាច្រើនទៀតដែលឆ្លាក់ជាប់ក្នុងការចងចាំរបស់ខ្ញុំ ។ ទីកន្លែងទាំងអស់នោះនៅទីនេះ លើកលែងតែមនុស្សដែលបាត់រូបរាងទៅដូចជាប្អូនប្រុសភ្លោះរបស់ខ្ញុំដែលមានអាយុ១៨ឆ្នាំ ។

ផល គឺជាអ្នកទីមួយក្នុងគ្រួសាររបស់ខ្ញុំដែលបានស្លាប់ក្នុងកណ្តាប់ដៃខ្មែរក្រហម ។ នៅពេលគាត់ស្លាប់ ខ្ញុំអស់កម្លាំងពេកបានជាមិនមានអារម្មណ៍ទុក្ខព្រួយ ខ្ញុំគ្រាន់តែយកដៃទ្រក្បាលរបស់គាត់ប៉ុណ្ណោះ ។ ភ្លាមៗនោះ នារីពេទ្យពីរនាក់ចាប់ផ្តើមជីកដីដើម្បីកប់សាកសពរបស់គាត់ ព្រោះចង់យកសាកសពចេញឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ។ ក្នុងពេលដែលនារីពេទ្យទាំងពីរនាក់នោះកំពុងតែជីកដី ខ្ញុំឱនទៅជិតសាកសពគាត់ចាប់ដៃដែលត្រជាក់របស់គាត់ទាំងពីរ ហើយនិយាយថា "បង! កុំទៅចោលខ្ញុំ" ។ ពេលនោះខ្ញុំពិតជាមានអារម្មណ៍ចម្លែកណាស់ គឺខ្ញុំមិនបានយំសោះ ។ ក្នុងចិត្តខ្ញុំហាក់ដូចជាស្ងប់ស្ងាត់រកនិយាយមិនត្រូវ ។ ទឹកមុខរបស់ ផល បានប្រាប់ខ្ញុំថាគាត់លែងមានការឈឺចាប់ទៀតហើយ ។ អ្វីៗបានកើតឡើងដូច្នេះទៅហើយ ។ ខ្ញុំមិនដឹងថាធ្វើយ៉ាងម៉េចឲ្យល្អទេ ពីព្រោះអ្វីៗច្របូកច្របល់និងដូចជាការយល់សប្តិ ។ យើងទាំងប្រាំនាក់ គឺនារីពេទ្យពីរនាក់ ម្តាយខ្ញុំ ប្អូនស្រីម្នាក់ និងខ្ញុំ គោរពសពនៅចំពោះមុខផ្ទះដែលនៅក្បែរគុម្ពោតព្រៃ ។ ទឹកមុខម្តាយខ្ញុំបង្ហាញអំពីអារម្មណ៍សោកសៅចំពោះការបាត់បង់កូនប្រុសរបស់គាត់ ។ ប្អូនស្រីខ្ញុំ អមរិន លែងមាត់លែងក ។ របស់សំខាន់មួយ គឺបងប្រុសរបស់ខ្ញុំ បានបាត់បង់ពីភូមិជ្រៃ ។ ខ្ញុំបាត់បង់បងប្រុសរបស់ខ្ញុំ ។

អារម្មណ៍សោកសៅនោះមានរយៈពេលជិតមួយឆ្នាំ ។ យប់មួយ នៅពេលដែលខ្ញុំដាក់ខ្លួនដេក ស្រាប់តែខ្ញុំនឹកគាត់ហើយមានអារម្មណ៍សោកស្តាយដែលមិនបាននិយាយឬធ្វើអ្វីដើម្បីគាត់ជាលើកចុងក្រោយ ។ ខ្ញុំស្រមៃឃើញព្រលឹងរបស់គាត់កំពុងហោះហើរទៅកាន់បរលោកដែលជាទីស្នាក់អាស្រ័យចុងក្រោយរបស់គាត់ ។ ខ្ញុំមានអារម្មណ៍ថាខ្ញុំកំពុងតែឃ្លាតឆ្ងាយពីគាត់បន្តិចម្តងៗ ។ ពិភពលោកក្នុងពេលនោះគឺស្រស់ស្អាតខ្លាំងណាស់ ហើយភាពងងឹតបានជួយលួងលោមខ្ញុំ ។ ភាពងងឹតធ្វើឲ្យការឈឺចាប់របស់ខ្ញុំចុះថយ និងធ្វើឲ្យខ្ញុំមានអារម្មណ៍ថាខ្លួនឯងនៅជិតទីក្រុងភ្នំពេញ ។

ត្រឡប់ទៅមើលនៅក្នុងមន្ទីរពេទ្យ នៅលើគ្រែដែល ផល ដេកជាមួយម្តាយរបស់ខ្ញុំពីរបីយប់ចុងក្រោយ សម្លៀកបំពាក់របស់គាត់នៅមានកម្តៅរយៈពេល១៥នាទីបន្ទាប់ពីការបញ្ចុះសពរបស់គាត់ ។ ស្បោងក្រណាត់តូចមួយដែលគាត់ធ្លាប់ស្ពាយ ព្យួរនៅលើបង្គោលឬស្សីចុងគ្រែ ។ អីវ៉ាន់របស់គាត់ស្ថិតនៅក្នុងស្បោងនោះនៅឡើយ ដូចជាស្លាបព្រាអាលុយមីញ៉ូម កំប៉ុងទឹកដោះគោ អំបិលពីរបីគ្រាប់ បាយក្រៀម ក្រមាក្រហម និងអាវដៃវែងកខុកមួយ ។ ម្តាយខ្ញុំចែករបស់របរទាំងនោះឲ្យទៅអ្នកជំងឺដទៃទៀតនៅក្នុងមន្ទីរពេទ្យ បន្ទាប់មកយើងចាកចេញ ។ ខ្ញុំមានបំណងមករស់នៅក្នុងភូមិជ្រៃម្តងទៀត ។ គំនិតរបស់ខ្ញុំគឺខ្ញុំចង់បានដីមួយកន្លែងនៅក្បែរផ្នូររបស់ ផល ដែលអាចសង់ផ្ទះតូចមួយ និងចាប់ផ្តើមជីវិតនៅទីនេះ ។ ទន្ទឹមនឹងនោះដែរ នៅពេលម្តាយខ្ញុំមកលេងលើកក្រោយ យើងនឹងសាងសង់ចេតិយមួយនៅក្នុងវត្តជ្រៃ ដើម្បីរំឭកដល់វិញ្ញាណក្ខន្ធសមាជិកគ្រួសាររបស់ខ្ញុំដែលបានស្លាប់ទៅ ។

បច្ចុប្បន្នមានអ្នកស្រុកមករស់នៅភូមិជ្រៃច្រើនជាងកាលពីពេលដែលខ្ញុំបានចាកចេញពីភូមិជ្រៃ នៅក្នុងឆ្នាំ១៩៧៨ ។ ភាគច្រើនអ្នកដែលរស់នៅក្នុងភូមិនេះគឺជាកូនរបស់អតីតកម្មាភិបាលខ្មែរក្រហម ។ អ្នកស្រុកដែលខ្ញុំធ្លាប់ស្គាល់បានផ្លាស់ទៅរស់នៅកន្លែងផ្សេងៗ ឬស្លាប់ហើយក៏មិនដឹង ។ អ្នកផ្សេងទៀតចាកចេញពីភូមិនេះដូចយើងដែរ ។ អ្នកខ្លះបានទៅរកការងារធ្វើនៅទីក្រុង ។ អ្នកភូមិម្នាក់សួរខ្ញុំថាតើខ្ញុំចាកចេញពីភូមិជ្រៃតាំងពីពេលណា ។ ខ្ញុំទ្រឹងបន្តិច ព្រោះវាហាក់ដូចជាខ្ញុំរស់នៅទីនោះអស់មួយជីវិតរបស់ខ្ញុំអ៊ីចឹង ។ ក្នុងខណៈនោះ ទីក្រុងភ្នំពេញនិងសហរដ្ឋអាមេរិកគ្រាន់តែជាអ្វីដែលនៅក្នុងការស្រមៃរបស់ខ្ញុំប៉ុណ្ណោះ ។

ខ្ញុំបានធ្វើដំណើរតាមបណ្តោយទំនប់សំដៅទៅភូមិរាមគន់ដែលមានវត្តធម្មយុត្តិ ជាទីកន្លែងឃុំឃាំងនិងធ្វើទារុណកម្មដ៏ល្បីល្បាញមួយក្នុងសម័យខ្មែរក្រហម ។ ទីវាលដ៏ធំល្វឹងល្វើយនេះលាតសន្ធឹងរហូតដល់ផ្លូវជាតិ នឹងលិចបាត់នៅពេលដែលទូរទឹកបិទជិត ។ បរិវេណវត្តពោធិ៍ដែលជាមន្ទីរពេទ្យបណ្តោះអាសន្នដែលប្អូនប្រុសរបស់ខ្ញុំ តារា បានស្នាក់នៅប៉ុន្មានថ្ងៃចុងក្រោយ

មុនពេលដែលគាត់ស្លាប់ ត្រូវបានសាងសង់សាជាថ្មីនិងប្តូរមកជាបន្ទប់រៀនវិញ ។ នៅជាប់នេះមានរោងដំបូលស័ង្កសីមួយដែលប្រើប្រាស់ជាផ្ទះបាយនិងបន្ទប់ដេកសម្រាប់នារីពេទ្យនិងឈ្លបក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ។ សព្វថ្ងៃរោងនេះក្លាយជាអគាររដ្ឋបាលទៅហើយ ។ សួនបន្លែបានក្លាយជាសួនច្បារដែលមានដងទង់ជាតិ ។ ត្រពាំងទឹកតូចមួយក្បែរនោះដែលត្រូវបានប្រើប្រាស់ជារណ្តៅកប់ខ្មោចនៅក្នុងសម័យខ្មែរក្រហមត្រូវបានចាក់ដីលុបបំពេញ ។ ខ្ញុំអង្គុយនៅលើកៅអីវែងយ៉ាងយូរសម្លឹងរកមើលទីតាំងផ្ទះរបស់ តារា ។ មានអ្វីមួយប្រាប់ខ្ញុំថាសាកសពរបស់វាកប់នៅទីនេះ ។



នី អមរិទ្ធ នៅជំរំជនភៀសខ្លួនខ្មែរ-ថៃ ក្នុងទសវត្សរ៍ឆ្នាំ១៩៨០

តារាជាកូនប្រុសពៅក្នុងគ្រួសារ វាកើតនៅឆ្នាំ១៩៦៥ ។ ជំងឺស្វិតដៃជើងបានធ្វើឲ្យវាពិការមួយកំណាត់ខ្លួនត្រឹមចង្កេះចុះក្រោម ។ ខ្មែរក្រហមយល់ថាជនពិការរូបរាងកាយឬសតិបញ្ញាមិនស័ក្តិសមនឹងរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយបានប៉ុនប៉ងសម្លាប់វាជាច្រើនដង ។ ម្តាយរបស់ខ្ញុំបានសុំឲ្យអង្គការខ្មែរក្រហមទុកជីវិតឲ្យកូនប្រុសពៅរបស់គាត់ ។ ពីរបីថ្ងៃក្រោយមក ខ្មែរក្រហមបញ្ជាឲ្យ តារា ជញ្ជូនឈើ ដោយចងឈើនៅនឹងចង្កេះ ហើយទាញ ។ ការងារនេះបានសង្គ្រោះជីវិត តារា ពីការសម្លាប់លើកមុនៗ ។

ខ្ញុំធ្វើដំណើរទៅស្ថានីយ៍រថភ្លើងមោងឫស្សី កន្លែងដែល ផល និងខ្ញុំធ្លាប់ដើរតាមរទេះគោដឹកអង្ករទៅរថភ្លើងដែលកំពុងតែរង់ចាំនៅឯស្ថានីយ៍ ។ ស្ថានីយ៍រថភ្លើងនោះត្រូវបានបោះបង់ចោលនិងកខ្វក់យ៉ាងខ្លាំង ។ អ្នកភូមិសម្រាកនៅក្នុងបន្ទប់រង់ចាំសម្រាប់អ្នកដំណើរនិងស្តង់លក់សំបុត្រ ចំណែកឃ្លាំងទំនិញនិងហាងកាត់សក់ត្រូវទុកចោល ។ ឃ្លាំងអង្ករនៅតែដំណើរការដដែល ។ នៅក្នុងរបបខ្មែរក្រហម ខ្ញុំបានលួចអង្ករពីឃ្លាំងនេះហើយរត់កាត់ព្រៃត្រឡប់មកដល់ភូមិជ្រៃវិញ ។ ក្រោមកម្តៅព្រះអាទិត្យហួតហែងខែមេសា ខ្ញុំមើលនាឡិការបស់ខ្ញុំនៅពេលនោះគឺម៉ោង២:៤២នាទី ខ្ញុំគិតថាខ្ញុំបានឃើញអ្វីៗដែលខ្ញុំចង់ឃើញហើយ ។ ចំណុចដែលខ្ញុំត្រូវឈប់បន្ទាប់ទៀតគឺក្រុងបាត់ដំបង ។ នៅទីនោះខ្ញុំបានទៅមើលសាលារៀនដែលប្អូនប្រុសខ្ញុំនិងខ្ញុំធ្លាប់រៀនពីរបីឆ្នាំមុនពេលដែលខ្មែរក្រហមបិទទ្វារសាលារៀននេះចោលនៅក្នុងឆ្នាំ១៩៧៥ ។

ផ្ទះដែលយើងធ្លាប់រស់នៅរយៈពេលពីរឆ្នាំបានបាត់រូបរាងទៅហើយ នៅសល់តែដីទទេប៉ុណ្ណោះ ។ ឥឡូវដីនេះមានផ្លាកដាក់លក់ជាមួយនឹងដីបីឡូត៍ទៀតជុំវិញនេះ ។

ខ្ញុំត្រឡប់ទៅស្រុកដូនទាវ ហើយបន្តដំណើរចុះតាមបណ្តោយដងស្ទឹងសង្កែ ។ ខ្ញុំស្គាល់តែពីរបីកន្លែងប៉ុណ្ណោះ ។ វិទ្យាល័យដូនទាវ ដែលយើងធ្លាប់ស្នាក់នៅជាច្រើនយប់ត្រូវបានកសាងនិងលាបថ្នាំថ្មី ។

ខ្ញុំបានសិក្សារឿងរ៉ាវដ៏គួរឲ្យរន្ធត់នៅជំរំ អូស៊ីច មេដឹកនាំណាហ្ស៊ី អាដុល ហ៊ីត្លែរ និងជនរងគ្រោះ ដូចជា អាន់ ហ្វ្រែង ជាដើម ក៏ប៉ុន្តែគ្មានរឿងរ៉ាវណាអាចធៀបនឹងអ្វីដែលខ្ញុំបានឃើញគុកទួលស្លែង (ស-២១) ទេ ។ ការមន្ទិលសង្ស័យរបស់ខ្ញុំអំពីការសម្លាប់ដ៏ព្រៃផ្សៃនៅគុកទួលស្លែងត្រូវបានបញ្ជាក់អះអាងដោយអ្នកយកព័ត៌មានម្នាក់របស់កាសែត ដេលី មៀរី របស់អូស្ត្រាលី ឈ្មោះ ចន ភីលជឺ ដែលបានហៅ ប៉ុល ពត ថា “ហ៊ីត្លែរនៅអាស៊ី” នៅក្នុងអត្ថបទរបស់គាត់ “សំឡេងរបស់អូស៊ីច” ។ ដោយសារ ចន ភីលជឺ និងអ្នកដទៃទៀតដែល មានចិត្តក្លាហាន

សរសេររឿងរ៉ាវក្នុងរបបខ្មែរក្រហមដូចជា ហ៊ឹម ចាន់បុទ្ធី (*នៅពេលអំបែងអណ្តែត ៖ ធំដឹងក្តីនៅក្នុងរបបខ្មែរក្រហម*), ឌិត ប្រន (*អ្នកបង្កើតនិងជាប្រធានគម្រោងស្វែងយល់ការសម្លាប់រង្គាល ឌិត ប្រន*), វ៉ាន់ ណាត (*រូបគំនូររបស់ខ្មែរម្នាក់នៅក្នុងគុក*), និង លឿង អ៊ឹង (*មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ ៖ ការចងចាំរបស់កុមារីកម្ពុជាម្នាក់*) ដែលធ្វើឲ្យខ្ញុំដឹងរឿងរ៉ាវរបបខ្មែរក្រហមកាន់តែច្បាស់ ។ សូមថ្លែងអំណរគុណដល់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ឆាំង យុ និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចំពោះការស្វែងរកយុត្តិធម៌ ។ រឿងរ៉ាវដំបូងដែលខ្ញុំបានអានអំពីអំពើព្រៃផ្សៃដែលប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា គឺអត្ថបទមួយក្នុងកម្រងអត្ថបទសង្ខេបរបស់មិត្តអ្នកអាន ដែលមានចំណងជើងថា "ការសម្លាប់រង្គាលនៅក្នុងទឹកដីដ៏ទន់ភ្លន់" ដោយ អានថូនី ផូល និង ចន បារុន ដែលយកគំរូតាម "កម្ពុជាឆ្នាំសូន្យ" របស់ ហ្វ្រង់ស័រ ប៉ុងហ្សូ និងរឿងរ៉ាវលម្អិតដោយ វីលៀម សក្រោះ "*ព្រឹត្តិការណ៍បន្ទាប់បន្សំ ៖ ឃីស៊ីងចឺ, និកសុន និងការបំផ្លិចបំផ្លាញនៅកម្ពុជា*" ។

ខ្ញុំបានអានម្តងហើយម្តងទៀតនូវរឿងរ៉ាវទាំងប៉ុន្មានខាងលើនេះ ដើម្បីឲ្យច្បាស់ថាខ្ញុំនឹងមិនភ្លេចអ្នកដែលស្លាប់ទៅ ។ ខ្ញុំបានបាត់បង់បងប្អូនប្រុសបីនាក់ និងបងស្រីពីរនាក់នៅក្នុងសម័យខ្មែរក្រហម ។ បងស្រីខ្ញុំទាំងពីរនាក់ ដែលម្នាក់មានកូនពីរ និងបងស្រីម្នាក់ទៀតមានកូនប្រុសមួយនិងកំពុងតែមានផ្ទៃពោះប្រាំមួយខែ ត្រូវខ្មែរក្រហមសម្លាប់ទាំងពីរនាក់នៅចុងឆ្នាំ១៩៧៦ ។ បងប្អូនប្រុសខ្ញុំពីរនាក់ទៀតស្លាប់ដោយអត់អាហារនិងជំងឺនៅភូមិជ្រៃ ចន្លោះឆ្នាំ១៩៧៦-១៩៧៨ ។ បងប្រុសម្នាក់ទៀតបាត់ខ្លួន ហើយទំនងជាស្លាប់ដែរក៏មិនដឹង ។


រី អមរិទ្ធ មុនឆ្នាំ១៩៧៥

## បងប្រុស នី អមរិទ្ធ (បាត់ខ្លួន)

ការបាត់ខ្លួន អមរិទ្ធ ដក់ជាប់ក្នុងអារម្មណ៍របស់ខ្ញុំរហូតដល់សព្វថ្ងៃ ។ ម្តាយខ្ញុំរស់នៅដោយពិបាកចិត្តជាមួយនឹងការបាត់ខ្លួនរបស់អមរិទ្ធនៅពាក់កណ្តាលឆ្នាំ១៩៧៧ ។ ទោះជាយើងនៅមានក្តីសង្ឃឹមថាប្រហែលជា អមរិទ្ធ នៅរស់ក៏ដោយបច្ចុប្បន្ននេះការវិលទៅរកសុទិដ្ឋិនិយមនៅពេលនោះគឺជាការឈឺចាប់ ។

ប្រជាជនកម្ពុជាជាច្រើននាក់សុទ្ធតែធ្លាប់ឆ្លងកាត់វាលពិឃាត ក៏ប៉ុន្តែខ្ញុំពិបាកនឹងទទួលស្គាល់ថាបងប្រុសស្ថិតនៅក្នុងចំណោមជនរងគ្រោះនៅភូមិជ្រៃនេះណាស់ ។ តាំងពីពេលដែលខ្ញុំវិលត្រឡប់មកទីក្រុងភ្នំពេញនៅក្នុងខែតុលាឆ្នាំ២០០៣ ខ្ញុំទៅទស្សនាមជ្ឈមណ្ឌលទារុណកម្មទួលស្លែងម្តងហើយម្តងទៀត ដោយមិនសង្ឃឹមថាបានឃើញរូបថតគាត់នៅទីនោះឡើយ ក៏ប៉ុន្តែសង្ឃឹមថាបានយល់កាន់តែច្រើនអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលនៅរុំព័ទ្ធក្នុងភាពអាថ៌កំបាំង ។

តើបងប្រុសរបស់ខ្ញុំត្រូវខ្មែរក្រហមចាប់បញ្ជូនមកគុកទួលស្លែង ដើម្បីសួរចម្លើយឬសម្លាប់មែនទេ? ខ្ញុំដើរមើលបន្ទប់ដាក់អ្នកទោសពីមួយទៅមួយ ។ នៅពេលមកដល់បន្ទប់តាំងរូបថតអ្នកទោសជាមួយនឹងឧបករណ៍ធ្វើទារុណកម្ម ខ្ញុំក្រឡេកឃើញអ្វីដែលខ្ញុំធ្លាប់បានឃើញផ្ទាល់ភ្នែកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បទពិសោធន៍មួយនេះតាមរំខានខ្ញុំរហូតដល់ពេលបច្ចុប្បន្ន ។ វិធីសាស្ត្រដែលខ្មែរក្រហមប្រព្រឹត្តចំពោះអ្នកទោសនៅទីនេះលក្ខណៈព្រៃផ្សៃស្រដៀងនឹងវិធីសាស្ត្រដែលខ្មែរក្រហមប្រើនៅក្នុងភូមិជ្រៃដែរ ។

អមរិទ្ធ បានចាកចេញពីភូមិជ្រៃដោយមិនបារម្ភនឹងសេចក្តីស្លាប់ ។ គាត់ជាមនុស្សរឹងរូសនិងមានជំនឿចិត្ត ។ ថ្មីៗនេះ បុរសពីរនាក់ ម្នាក់អាយុប្រហែល៥០ឆ្នាំ ម្នាក់ទៀតអាយុស្រករនឹងខ្ញុំបានអះអាងថាធ្លាប់បានរស់នៅក្នុងភូមិជ្រៃនៅក្នុងរយៈពេលប៉ុន្មានឆ្នាំនោះនិងស្គាល់តំបន់នោះយ៉ាងច្បាស់ ក៏ប៉ុន្តែគ្មាននរណាស្គាល់ឬដឹងអំពីកន្លែងរបស់ អមរិទ្ធ ឡើយ ។

រយៈពេលដែល អមរិទ្ធ រស់នៅជាមួយយើងគឺខ្លីណាស់ ។ ខ្ញុំសង្ឃឹមថាការបាត់ខ្លួនរបស់គាត់នាំគាត់ទៅរកសេរីភាពនិងជីវិតដែលគាត់ប្រាថ្នាចង់បាន ។ អមរិទ្ធ នៅពេលនោះទើបតែមានអាយុ១៧ឆ្នាំប៉ុណ្ណោះ ។ បន្ទាប់ពីកងទ័ពវៀតណាមវាយលុកភ្លាម ឪពុករបស់ខ្ញុំបានត្រឡប់ទៅកាន់ភូមិមួយនៅក្នុងខេត្តកំពង់ចាមដែលគាត់ធ្លាប់រស់នៅក្នុងរបបខ្មែរក្រហម ។ ផ្ទះខ្ទមដែលគាត់រស់នៅត្រូវទុកចោលគ្មាននរណាម្នាក់ប៉ះពាល់ឡើយ ។ ដើមចេកនិងល្ហុង

នៅក្បែរផ្ទះមានផ្ទៃធំ ហើយស្មៅដែលនៅជុំវិញផ្ទះដុះកម្ពស់ក្បាលជង្គង់ ។ សម្លឹងមើលពីចម្ងាយ ឪពុកខ្ញុំមានអារម្មណ៍ថាមាននរណាម្នាក់បានមករស់នៅនិងរង់ចាំគាត់នៅក្នុងខ្ទមនោះ ។ ដោយឃើញទ្វារចំហបន្តិច គាត់ដើរចូលទៅក្នុងខ្ទម ហើយឃើញអក្សរសរសេរនៅលើជញ្ជាំងថា "ខ្ញុំស្រលាញ់ពុក" ។ អក្សរនោះមើលទៅហាក់ដូចជាអក្សររបស់បងស្រីខ្ញុំឈ្មោះ ចន្ទរ៉េត ។ ឪពុកខ្ញុំអង្គុយនៅទីនោះមួយសន្ទុះ ទើបបន្តដំណើរទៅមុខទៀត ។

### បងស្រី នី ចន្ទរ៉េត

ទោះជាប្រទេសកម្ពុជាជួបសំណាងល្អខ្លះក៏ដោយ ប៉ុន្តែបើគិតអំពីការខាតបង់គឺកម្ពុជាចំណាយរយៈពេល៣០ឆ្នាំនៅក្នុងសង្គ្រាមនិងជីវិតមនុស្សរាប់លាននាក់ ។ ប្រវត្តិសាស្ត្រសម័យទំនើបរបស់យើងគឺជាផ្នែកមួយនៃសោកនាដកម្មដែលបន្តមិនចេះចប់ ហើយលទ្ធផលនៃសោកនាដកម្មនេះគឺភាពសោកសៅរបស់ជាតិ ។ ការបាត់បង់ជីវិតមនុស្សដោយមិនសមហេតុផលនឹងដក់ជាប់ក្នុងអារម្មណ៍កូនខ្មែរជំនាន់ក្រោយ ។ ក៏ប៉ុន្តែ ខ្ញុំសង្ឃឹមថាប្រវត្តិសាស្ត្រនឹងផ្តល់ឲ្យយើងនូវមេរៀនមួយចំនួន ។ ម្យ៉ាងវិញទៀត របបខ្មែរក្រហមគឺជារបត់មួយសម្រាប់យើងទាំងអស់គ្នា ហើយការផ្លាស់ប្តូរនេះទាមទារការប្តេជ្ញាចិត្តនិងការលះបង់ ។ យើងអាចផ្លាស់ប្តូរបាន លុះត្រាតែយើងមានមនសិការច្បាស់លាស់និងមានឯកភាពជាតិ ។

ព្រឹត្តិការណ៍ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បាននាំមហន្តរាយមកឲ្យប្រទេសកម្ពុជា និងបានធ្វើឲ្យកម្ពុជាផ្លាស់ប្តូរជាមូលដ្ឋាន ។ ខ្ញុំក៏យល់អំពីអ្នកដែលមិនចង់ឮនិងមិនចង់រំឭកអំពីអតីតកាលដ៏ល្វីងជូរចត់របស់ប្រទេសកម្ពុជា ពីព្រោះខ្ញុំបន្ទប់ខ្លួនឯងដោយបដិសេធថាគ្មានព្រឹត្តិការណ៍ថ្ងៃ១៧ ខែមេសា កើតឡើងដែរ ។

តើប្រជាជនកម្ពុជាចងចាំព្រឹត្តិការណ៍ថ្ងៃ១៧ខែមេសាដោយរបៀបណា? ក្នុងនាមខ្ញុំជាប្រជាជនកម្ពុជាម្នាក់ ខ្ញុំមិនត្រូវភ្លេចព្រឹត្តិការណ៍នេះឡើយ ។ ខ្លួនខ្ញុំមួយចំណែកបានស្លាប់ជាមួយនឹងព្រឹត្តិការណ៍នេះទៅហើយ ។

ប្រទេសជាច្រើនចាត់ទុកសង្គ្រាមជាមធ្យោបាយដោះស្រាយបញ្ហា ។ សម្រាប់ប្រជាជនកម្ពុជា យើងត្រូវការពេលវេលាបន្ថែមដើម្បីដោះស្រាយបញ្ហា ។ ទន្ទឹមនឹងនោះ យើងអាចសម្រេចចិត្តដោយប្រើប្រាស់បទពិសោធន៍អតីតកាលរបស់យើងនិងរបស់អ្នកដទៃ ។ ខ្ញុំសង្ឃឹមថាលទ្ធផលគឺនាំមកឲ្យយើងម្នាក់ៗនូវអនាគតដ៏ភ្លឺស្វាងដែលអាចជាគំរូសម្រាប់កូនខ្មែរជំនាន់ក្រោយ ។ ជាមួយនឹងលទ្ធផលនេះ ខ្ញុំសុំនិយាយយ៉ាងស្មោះត្រង់ថា ប្រជាជនខ្មែរនឹងនៅដើមដំបូងនៃយុគសម័យថ្មីមួយជាមួយនឹងឱកាសដែលមិនមានពីមុនមក និងការចាប់កំណើតជាថ្មីនៃឧត្តមគតិរបស់ប្រជាជនខ្មែរគ្រប់ៗរូប ។ ខ្ញុំមិនចង់បានអ្វីក្រៅពីចង់ឃើញកម្ពុជារីកចម្រើនថ្កុំថ្កើងនិងរួបរួមគ្នាដោយសន្តិភាពនោះទេ ។ ប្រជាជនកម្ពុជាមួយចំនួនត្រូវបង្ខំចិត្តគ្រប់គ្រងអារម្មណ៍ឈឺចាប់របស់ខ្លួនឯង និងបន្តរស់នៅជាមួយនឹងជីវិតថ្មី ។ ក៏ប៉ុន្តែ គ្មាននរណាម្នាក់គេចផុតពីការឈឺចាប់បានឡើយ សូម្បីតែអ្នកដែលរួចពីការឈឺចាប់ក៏ជឿថាខ្លួនមិនអាចគេចផុតពីការឈឺចាប់ដែរ ។ កេរដំណែលមួយក្នុងចំណោមកេរដំណែលដែលសល់ពីសង្គ្រាមនិងជម្លោះប្រដាប់អាវុធក្នុងជំនាន់របស់ខ្ញុំ ប្រជាជនកម្ពុជាស្ទើរតែទាំងអស់បានបាត់បង់បងប្អូនម្នាក់ឬច្រើនជាងនេះ ។ ជាងនេះទៅទៀត ប្រជាជនកម្ពុជាភាគច្រើនចាកចោលផ្ទះដោយបង្ខំចិត្តនិងបាត់បង់ជីវិតក្នុងស្ថានភាពដែលគួរឲ្យភ័យខ្លាច និងដែលមិនអាចពន្យល់បាន ។

ឆ្នាំនេះម្តាយរបស់ខ្ញុំអាយុ៨១ឆ្នាំហើយ ។ គាត់មានការនឿយហត់ទាំងផ្លូវចិត្តនិងផ្លូវកាយ ។ គាត់ភ្លេចភ្លាំងច្រើន ហើយភ្នែកទាំងពីររបស់គាត់ស្រវាំងមើលអ្វីពុំច្បាស់ ។ គាត់អង្គុយស្តាប់យ៉ាងអត់ធ្មត់ និងមើលរូបថតទីកន្លែងដែលគាត់រស់នៅពីមុន និងរូបថតចៅៗរបស់គាត់ដែលភាគច្រើនស្លាប់យ៉ាងទុគ៌ត ។ ខ្ញុំដឹងយ៉ាងច្បាស់ថារូបថតអស់ទាំងនេះធ្វើឲ្យគាត់នឹកឃើញនូវបទពិសោធន៍អតីតកាលទាំងល្អនិងអាក្រក់ ។ ខ្ញុំដឹងថាគាត់កំពុងតែព្យាយាមទទួលស្គាល់ការបាត់បង់និងសោកនាដកម្មរបស់គាត់ ហើយគាត់កំពុងតែនៅចន្លោះបញ្ហានោះ ។

នៅខេត្តកំពង់ចាម ពុំមានចម្លើយណាមួយចំពោះសំណួរពាក់ព័ន្ធនឹងការស្លាប់របស់បងប្អូនស្រីទាំងពីររបស់ខ្ញុំទេ ។ សំណួរនេះគ្មានទីបញ្ចប់ឡើយ ហើយវានឹងគ្មានចម្លើយជារៀងរហូត ។ អ្នកស្រុកអ្នកភូមិអះអាងថាគាត់បានឮចម្រៀងបដិវត្តន៍នៅពេលណាមានការសម្លាប់មនុស្ស ។

**ប្អូនស្រី អមរិន**

មនុស្សគ្រប់រូបសុទ្ធតែមានរឿងរ៉ាវផ្ទាល់ខ្លួន ។ រឿងរ៉ាវទាំងនោះតែងតែខុសៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ។ ចំណែកខ្ញុំក៏មិនខុសពីអ្នកដទៃដែរ ។ ក្នុងនាមជាប្រជាជនកម្ពុជាខ្ញុំព្យាយាមស្វែងយល់អំពីប្រទេសកម្ពុជាដែលជានិច្ចកាលហាក់ដូចជានៅតែស្រពេចស្រពិលនិងលិចទៅក្នុងអតីតកាល ។ បន្ទាប់ពីរស់នៅសហរដ្ឋអាមេរិកអស់ជាច្រើនទសវត្សរ៍ នៅពេលណាដែលខ្ញុំគិតដល់រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមនិងអានរឿងរ៉ាវទាំងនោះ អតីតកាលរបស់ខ្ញុំជាស់តឿនខ្ញុំអំពីអតីតកាលនិងអនាគតរបស់ខ្ញុំ ។

ក្នុងអំឡុងជាច្រើនឆ្នាំដែលខ្ញុំរស់នៅសហរដ្ឋអាមេរិក ខ្ញុំធ្វើកិច្ចការក្នុងគម្រោងសរសេរសៀវភៅ ។ ខ្ញុំបានសរសេររឿងរ៉ាវអតីតកាលដែលទាក់ទិននឹងជីវិតក្រុមគ្រួសារខ្ញុំ ។ ភាគច្រើននៃសាច់រឿងជិតជាប់យ៉ាងជ្រៅនៅក្នុងការចងចាំរបស់ខ្ញុំ ហើយមានលក្ខណៈផ្ទាល់ខ្លួនខ្លាំងពេកដែលពេលខ្លះខ្ញុំមិនអាចបញ្ចប់កថាខណ្ឌក្នុងរយៈពេលជាច្រើនថ្ងៃ ។ រឿងរ៉ាវទាំងនោះធ្វើឲ្យខ្ញុំមិនសប្បាយចិត្ត ។ មុនដំបូងខ្ញុំសរសេរដោយដៃ បន្ទាប់មកទើបវាយបញ្ចូលទៅក្នុងកុំព្យូទ័រ ។ ក្នុងពេលដែលខ្ញុំកំពុងតែសរសេរ ខ្ញុំគិតអំពីអ្នកដទៃ ដូចជាអ្នកដែលស្លាប់ដោយមិនបានរៀបរាប់រឿងរ៉ាវរបស់ខ្លួនឲ្យអ្នកដទៃបានដឹង ។ គាត់មានសេរីភាពតិចតួចបំផុត ។ ការសរសេរសៀវភៅអំពីកម្ពុជាគឺត្រូវជម្នះការប៉ះពាល់ទាំងទឹកចិត្តនិងសតិអារម្មណ៍ ។ លោកអ្នកអាចអានសៀវភៅនេះទៅតាមរបៀបដែលអ្នកយល់អំពីជីវិត ។ សម្រាប់អ្នកដែលឆ្លងកាត់ជម្លោះនៅកម្ពុជានិងឆ្លងកាត់របបខ្មែរក្រហម សៀវភៅនេះរំឭកយើងនៅពេលនេះនិងពេលអនាគត ប្រាប់ពិភពលោកឲ្យដឹងអំពីរឿងរ៉ាវដែលបានកើតឡើង និងទប់ស្កាត់មិនឲ្យអំពើបែបនេះកើតឡើងម្តងទៀត ។ ខ្ញុំដាក់ចំណងសៀវភៅនេះថា "*លទ្ធិបាតដៃទទេ ៖ ឆ្នាំ១៩៧៥ គឺជាឆ្នាំដ៏ចម្លែក*" ។ ចំណងជើងនេះស្តាប់ទៅដូចជាមិនសូវត្រូវ ក៏ប៉ុន្តែវាផ្តោតសំខាន់ទៅលើប្រជាជនកម្ពុជាទាំងអស់ដែលរស់នៅឆ្លងកាត់រឿងរ៉ាវដូចៗគ្នា ។

នៅឆ្នាំ១៩៨៤ នៅក្នុងពេលដែលខ្ញុំកំពុងតែរស់នៅទីក្រុងហ្វីឡាដែលហ្វៀ រដ្ឋផេនស៊ីវេនៀ ខ្ញុំតាំងចិត្តថានឹងសរសេរសៀវភៅមួយនេះ ។ នៅឆ្នាំ១៩៩៨ ខ្ញុំនៅទីក្រុងឃីកលែន រដ្ឋវ៉ាស៊ីនតោន ដែលនៅទីនោះខ្ញុំចាប់ផ្តើមប្រមូលសៀវភៅកំណត់ហេតុនិងកត់ត្រាការចងចាំរបស់ខ្ញុំ ។ អស់រយៈពេលជាច្រើនឆ្នាំខ្ញុំចម្លងគំនិតរបស់ខ្ញុំដាក់ទៅលើក្រដាសហើយមិនឲ្យអ្នកណាម្នាក់មើលវាឡើយ ។ កំណត់ហេតុទាំងនោះគឺជាប្រភពឯកសារដំបូងសម្រាប់សៀវភៅរបស់ខ្ញុំមួយនេះ ។ ស្នាដៃបែបនេះមិនអាចសម្រេចទៅបានដោយងាយៗក្នុងរយៈពេលតែប៉ុន្មានថ្ងៃឬប៉ុន្មានខែឡើយ ។ វាត្រូវការពេលជាច្រើនឆ្នាំដើម្បីប្រមែប្រមូលឡើងវិញនូវការចងចាំដែលបាត់បង់និងដែលមិនទាន់ច្បាស់ ។

ពេលខ្ញុំសរសេរ កំណត់ហេតុនិងការចងចាំទាំងនោះរំឭកខ្ញុំអំពីអ្វីដែលខ្ញុំត្រូវតែចងចាំ រួមទាំងលទ្ធភាពដែលថាជនដៃដល់នៃអំពើកាប់សម្លាប់នឹងអានសៀវភៅនេះនៅថ្ងៃណាមួយ ។ ការយកការចងចាំរបស់ខ្ញុំមកសរសេររៀបរាប់ជាអត្ថបទគឺជាដំណើរដ៏វែងឆ្ងាយដែលពោរពេញទៅដោយឧបសគ្គមិនមានភាពស្រពេចស្រពិល ។ ខ្ញុំមិនប្រញាប់ប្រញាល់អ្វីឡើយ ហើយខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ប្រជាជនកម្ពុជាដែលមានរឿងរ៉ាវដូចខ្ញុំនឹងធ្វើដូចខ្ញុំដែរ ។

ខ្ញុំបន្តការសរសេរនិងចែករំលែករឿងរ៉ាវរបស់ខ្ញុំជាមួយអ្នកដទៃ ជាពិសេសអ្នកដែលនៅរស់រានមានជីវិត អ្នកដែលមានជីវិត សាវតា និងបទពិសោធន៍ខុសៗគ្នា ។ ខ្ញុំយល់ថា បើយើងទាំងអស់គ្នាចែករំលែករឿងរ៉ាវជាមួយគ្នាក្នុងការស្វែងរកសេចក្តីស្រលាញ់និងសន្តិភាព យើងនឹងទទួលបានការស្រលាញ់តបវិញជាមិនខាន ។ ដូច្នេះបន្តិចម្តងៗ សៀវភៅនេះនឹងដាក់បញ្ចូលនូវការសន្ទនា ការរិះគន់របស់ប្រជាជនកម្ពុជា និងការរិះគន់របស់ប្រជាជនកម្ពុជា ហេតុដូច្នេះហើយទើបបានជាមកដល់ពេលនេះ សៀវភៅនេះមានអ្វីៗច្រើនជាងគ្រាន់តែជារឿងរ៉ាវរបស់ខ្ញុំ ។ សៀវភៅនេះផ្ទុកនូវគំនិតផ្ទាល់ខ្លួនរបស់ខ្ញុំ ហើយខ្ញុំសង្ឃឹមថានឹងឆ្លើយតបគុណរបស់អ្នកទាំងនោះដោយការបញ្ចូលគំនិតរបស់គាត់ទៅក្នុងសៀវភៅនេះ ។ សៀវភៅនេះប្រៀបដូចជារឿងរ៉ាវមួយដែលគ្មានទីបញ្ចប់ ។

ការសរសេរសៀវភៅនេះមានគោលបំណងមួយ ។ រឿងរ៉ាវដែលរៀបរាប់ក្នុងសៀវភៅនេះមិនមែនត្រឹមតែអំពីឈ្មោះប៉ុណ្ណោះទេ ថែមទាំងអំពីការចងចាំដែលនៅតែរស់រវើកក្នុង

បេះដូងយើង ។

ខ្ញុំគ្មានបំណងសរសេរប្រវត្តិផ្ទាល់ខ្លួនខ្ញុំទេ ។ ផ្ទុយទៅវិញ ខ្ញុំចង់ផ្តោតទៅលើរឿងរ៉ាវអតីតកាល គឺក្នុងជំនាន់ខ្ញុំ ។ ថ្ងៃព្រហស្បតិ៍ ទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺជាការចាប់ផ្តើមនូវអ្វីដែល ខ្មែរក្រហមហៅថា "ឆ្នាំសូន្យ" ។ របៀបរបបរស់នៅក្នុងសង្គមចាស់ ត្រូវបានកាត់ផ្តាច់លែងឲ្យមានទៅទៀត ហើយខ្មែរក្រហមចាប់ផ្តើមស្វែងរករបស់មកបំពេញដំណើរការបដិវត្តន៍របស់ខ្លួន ។ ខ្ញុំសរសេររឿងរ៉ាវនេះមិនមែនដើម្បីការសងសឹកឡើយ ក៏ខ្ញុំមានគោលបំណងលាតត្រដាងការពិតនៃរបបខ្មែរក្រហមប៉ុណ្ណោះ ។

រឿងរ៉ាវនេះចាប់ផ្តើមពីចំណុចដែលព្រលឹងរបស់មនុស្សត្រូវបញ្ចប់ ។ រឿងរ៉ាវនេះរៀបរាប់អំពីជីវិតនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងនាមជាអ្នកនិពន្ធម្នាក់ ខ្ញុំគ្មានបំណងស្វែងរកភាពល្បីល្បាញនិងភាពមានបានឡើយ ។ ដើម្បីជាប្រយោជន៍ដល់អក្សរសាស្ត្រខ្មែរ ខ្ញុំចង់សរសេររឿងរ៉ាវល្អមួយអំពីកម្ពុជាសម្រាប់កូនខ្មែរជំនាន់ក្រោយ និងអ្នកទាំងឡាយដែលទាក់ទងនឹងជីវិតរបស់ខ្ញុំ ព្រមទាំងអ្នកដែលឲ្យតម្លៃដល់រឿងរ៉ាវនេះ ។

យុគសម័យខ្មែរក្រហមគឺជាយុគសម័យដ៏ចម្លែកមួយ ។ វាមិនមែនជាសម័យកាលដ៏សាមញ្ញដែលប្រជាជនកម្ពុជាចង់ចាំឡើយ ។ នោះគឺជាសម័យកាលដែលមានកលយុតផ្នែកមនោគមវិជ្ជា ដែលនាំទៅដល់ការបំផ្លិចបំផ្លាញជាតិឯង ។ ក្រោយពីយុគសម័យនោះត្រូវបានបញ្ចប់ កម្ពុជាត្រូវបានពិភពលោកស្គាល់ដោយពាក្យ "ប្រល័យពូជសាសន៍ឯង" "ជំរំអូស្វិចនៅអាស៊ី" "ប៉ុលពត" "អ៊ីត្លែរនៅអាស៊ី" "ការសម្លាប់រង្គាលនៅអាស៊ី" "សំឡេងនៃជំរំអូស្វិច" "ការសម្លាប់" "គំរូណាហ្ស៊ី" "ទួលស្លែង" និងដូចដែលវៀតណាមហៅថា "ដែនដីនៃលោហិតនិងទឹកភ្នែកគឺដែនដីនរក" មុនពេលវាយលុកចូលកម្ពុជានៅក្នុងឆ្នាំ១៩៧៨ ។

ក្នុងបទសម្ភាសន៍ដែលធ្វើឡើងនៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០០៣ ផ្សាយតាមវិទ្យុជាតិមួយ តារាភាពយន្ត ចន ម៉ាល់ខូវិច (តួសម្តែងនៅក្នុងខ្សែភាពយន្ត វាលពិឃាត) បានហៅបញ្ហានៅកម្ពុជាថា "ជាបញ្ហាដែលរកថាមិនត្រូវ" ។ អតីតប្រធានាធិបតីសហរដ្ឋអាមេរិក ជីមី ខាតឌឺ បានចាត់ទុករបបខ្មែរក្រហមជា "អ្នករំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតនៅលើពិភពលោក" ។ នាយករដ្ឋមន្ត្រីអង់គ្លេស វីនស្តុន ឆឺឈៀល បានហៅអំពើប្រល័យពូជសាសន៍កម្ពុជាថាជា "ឧក្រិដ្ឋកម្មគ្មានឈ្មោះ" ។ នោះគឺកម្ពុជា ។

ការស្វាបស្ទង់មតិជាទូទៅបង្ហាញការចាប់អារម្មណ៍ស្រដៀងគ្នាស្តីអំពីប្រទេសកម្ពុជា ។ សៀវភៅនេះនឹងជួយរំឭកយើងនូវអ្វីដែលបានកើតឡើងយ៉ាងពិតប្រាកដនៅកម្ពុជា ។

ប្រវត្តិសាស្ត្រពិតជាកើតឡើងដដែលៗ ។ ពិភពលោកបែរជានៅស្ងៀម ខណៈដែលការប្រល័យពូជសាសន៍កើតឡើងម្តងទៀតនៅក្នុងប្រទេសកម្ពុជា៣០ឆ្នាំកត់ ក្រោយពីសង្គ្រាមលោកលើកទីពីរត្រូវបានបញ្ចប់ ។ តើពិភពលោកបណ្តោយឲ្យប្រវត្តិសាស្ត្របែបនេះកើតឡើងយ៉ាងដូចម្តេច? ណាហ្ស៊ីអាល្លឺម៉ង់និងខ្មែរក្រហមសុទ្ធតែមានសមត្ថភាពកំណាចដែលអាចផ្លាស់ប្តូរការជឿទុកចិត្តនិងភាពស្មោះត្រង់របស់មនុស្ស ។ គួរឲ្យហួសចិត្ត អូស្ការ ស៊ីនឡឺ (ជនជាតិអាល្លឺម៉ង់) និងកម្មាភិបាលខ្មែរក្រហមឈ្មោះ គៀត (កម្ពុជា) ប្រែទៅជាមនុស្សល្អក្នុងចំណោមមនុស្សអាក្រក់ដោយបានជួយសង្គ្រោះជីវិតមនុស្សជាច្រើននាក់ ។

៣០ឆ្នាំក្រោយមក ការសម្រេចចិត្តកាត់ទោសមេដឹកនាំខ្មែរក្រហមដែលមានវ័យចាស់ជរានៅមានលក្ខណៈចម្រូងចម្រាសនៅឡើយ ជាពិសេសប្រសិនបើគិតតាមទម្រង់របស់តុលាការ នូរ៉ឹមប៊ឺកនៅក្រោយសង្គ្រាមលោកលើកទី២ ។ ខ្ញុំបានអានសៀវភៅកំណត់ហេតុរបស់ខ្ញុំម្តងហើយម្តងទៀត ។ ការរំឭកឡើងវិញនូវរបបខ្មែរក្រហមគឺពិតជាឈឺចាប់ណាស់ ហើយខ្ញុំខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីបំភ្លេចវា ។ ខ្ញុំអានកំណត់ហេតុរបស់ខ្ញុំហាក់បីដូចជាវាជួយសង្គ្រោះជីវិតខ្ញុំ ហើយប្រហែលជាវាជួយមែនតាមវិធីណាមួយ ។ ប្អូនស្រីរបស់ខ្ញុំចងចាំតិចតួចណាស់នូវអ្វីដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ។ នាងព្យាយាមរកវិធីជាច្រើនដើម្បីបំភ្លេចរឿងរ៉ាវអតីតកាលរបស់នាង និងចាប់ផ្តើមជីវិតថ្មី ។

ទំនប់ទឹកដែលជាចំណុចប្រសព្វរវាងស្ទឹងមោងនិងស្ទឹងជ្រៃនឹងដើរតួជាទីកន្លែងរំឭកអតីតកាលនិងអនាគត ។ ទំនប់នេះនឹងជាសក្ខីភាពដ៏សំខាន់មួយសម្រាប់អ្នកដែលបានចូលរួមកសាងទំនប់នេះក្រោមលទ្ធិបាតទទេ ។

ពិភពលោកដ្ឋាស់ប្តូរ៦០ឆ្នាំមកហើយចាប់តាំងពីមានការកាត់ទោសនៅនូរិមប៊ឺក ។ ទាក់ទិននឹងសាលាក្តីខ្មែរក្រហមបច្ចុប្បន្ន ខ្ញុំសង្ឃឹមថានឹងមានយុត្តិធម៌ ហើយទំព័រប្រវត្តិសាស្ត្រថ្មីមួយនឹងអាចបើកឡើងជាមិនខាន ។ ដំណើររបស់ខ្ញុំទៅភូមិជ្រៃលើកនេះ បានជួយឲ្យខ្ញុំចងចាំឡើងវិញនូវពេលវេលាសប្បាយរីករាយ ហើយ លើសពីអ្វីៗទាំងអស់ វាជួយរក្សាសំឡេងនិងផ្ទៃមុខរបស់សមាជិកគ្រួសាររបស់ខ្ញុំដែលខ្ញុំស្រលាញ់ជាទីបំផុត ។ ការសរសេរជួយឲ្យខ្ញុំនឹកឃើញមនុស្សដែលខ្ញុំបាត់បង់ ។ **ឆី ខរៈ**

# សូមតុលាការជួយរកយុត្តិធម៌ឱ្យឪពុក ប្តី និងបងប្អូនរបស់ខ្ញុំ

ណារី កូនស្រី និងកូនប្រុស បានមកដល់បន្ទប់ព័ត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈអ្នកជិតខាងម្នាក់ដែលប្រាប់គាត់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាជាអង្គការមួយជួយជនរងគ្រោះដែលបាត់បង់សាច់ញាតិក្នុងរបបខ្មែរក្រហម ។ គោលបំណងរបស់ ណារី នៅពេលនេះគឺស្វែងរកព័ត៌មានបន្ថែមអំពីឪពុក ប្តី និងសាច់ញាតិ៨នាក់ទៀតដែលគាត់បានដឹងថាត្រូវខ្មែរក្រហមសម្លាប់ ។ ក្នុងចំណោមសាច់ញាតិ ១០នាក់ដែលបានស្លាប់ យើងបានរកឃើញរូបថតចំនួនប្រាំសន្លឹក គឺជារូបថត ឪពុក ប្តី ពូបង្កើត ពូជីដូនមួយ និងបងថ្លៃ។ ដោយក្តីរំភើបពេក ណារី សម្លឹងមើលរូបថតទាំងរលីងរលោងទឹកភ្នែក ហើយនិយាយថា "គេចោទថាគ្រួសារខ្ញុំចូលដៃជើងវៀតណាម បានជាគេយកទៅសម្លាប់ ហើយគេមកចាប់ខ្ញុំទៅទៀត" ។ រូបថតទាំង៥សន្លឹករំឭក ណារី អំពីហេតុការណ៍ដែលឪពុក ប្តី និងសាច់ញាត់របស់គាត់ត្រូវស្លាប់ ។


កែវ ណារី និងកូនស្រី

កែវ ណារី មានអាយុ៥០ឆ្នាំ ជាស្ត្រីមេម៉ាយសព្វថ្ងៃរស់នៅនិងប្រកបមុខរបរចិញ្ចឹមជីវិតនៅខេត្តបន្ទាយមានជ័យ ។ នៅក្នុងអំឡុងពេលខ្មែរក្រហមគ្រប់គ្រងអំណាចក្រុមគ្រួសាររបស់ កែវ ណារី ជាសមាជិកកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៨អ្នកទាំងនោះត្រូវកម្មាភិបាលភូមិភាគនិរតីចាប់យកទៅសម្លាប់ដោយចោទថាបានចូលដៃជើងជាមួយវៀតណាម ។

សាច់ញាតិរបស់ ណារី ចំនួន១០នាក់រួមមាន ឪពុក ប្តី ពូ បងប្អូនជីដូនមួយ និងបងថ្លៃដែលមានតួនាទីជាគណៈឃុំ ប្រធានយោធាតំបន់ យោធា និងជាសមាជិកឃុំ ត្រូវកម្មាភិបាលកិបាលខ្មែរក្រហមភូមិភាគនិរតីយកទៅសម្លាប់ជាបន្តបន្ទាប់ ។

ឪពុករបស់ ណារី ឈ្មោះ កែវ ខាត់ ជាសមាជិកឃុំចម្លង ។ ក្រោយពីមើលឃើញ ខាត់ ធ្វើការងារល្អ គណៈគ្រប់គ្រងផ្លាស់ឲ្យធ្វើជាគណៈឃុំចំបក់ជំនួសមេឃុំចំបក់ពីមុនដែលត្រូវអង្គការដកចេញពីតំណែង ។ មិនដល់រយៈពេលមួយខែផង ខាត់ ត្រូវកម្មាភិបាលភូមិភាគនិរតីដែលទើបតែមកគ្រប់គ្រងចោទថាក្បត់ ហើយចាប់យកទៅសម្លាប់ ។

កែវ ខាត់ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ ១៩៧៨ មកឃុំឃាំងនៅមន្ទីរស-២១ នៅក្នុងផ្ទះ៣៣ បន្ទប់ធំ៣

និងកម្មុចនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៨ ។ នៅក្នុងថ្ងៃចាប់ខ្លួននោះ សាច់ញាតិរបស់ ណារី បីនាក់ទៀតក៏ត្រូវបានចាប់ខ្លួនដែរ ១)ពូឈ្មោះ ទៀ ឈុំ ជាសមាជិកឃុំចម្លង ២)ជាពូជីដូនមួយឈ្មោះ សេក អ៊ុល ជាសមាជិកឃុំចម្លង និង៣)បងថ្លៃឈ្មោះ អ៊ុយ ផាន់ ជាប្រធានឃុំឈើទាល ។









ណារី រំឭកថា “ឪពុកខ្ញុំស្លូតណាស់ ប្រជាជនស្រឡាញ់គាត់គ្រប់ៗគ្នាពីព្រោះគាត់ចិត្តល្អ ចំពោះប្រជាជនណាគ្មានបាយហូបឪពុកខ្ញុំបានប្រាប់ឲ្យលួចដាំបាយហូបខ្លះកុំឲ្យស្មោះត្រង់ពេក ។ មិនតែប៉ុណ្ណោះគាត់បានជួយសង្គ្រោះជីវិតប្រជាជន១៧មេសា បានប្អូននាក់ពីការតាមចាប់ខ្លួនរបស់សន្តិសុខ សព្វថ្ងៃមានម្នាក់កំពុងរស់នៅទីក្រុងភ្នំពេញ ឈ្មោះ ឈឹម រដ្ឋា បានសុំម្តាយខ្ញុំធ្វើជាម្តាយធម៌” ។

ឪពុករបស់ ណារី មិនដាច់ចិត្តរត់ចោលប្រពន្ធនិងកូនៗឡើយ គាត់សុខចិត្តឲ្យអង្គការចាប់គាត់ខ្លួនតែម្នាក់ឯង ។ ណារី និយាយថា “ឪពុកខ្ញុំបានឡើងតវ៉ាជាមួយគណៈគ្រប់គ្រងថ្មី ហេតុនេះបានជាគេចាប់គាត់ទៅ ។ ឪពុកខ្ញុំដឹងខ្លួនថាគេនឹងចាប់ គាត់បានប្រាប់ម្តាយខ្ញុំថា យើងថ្ងៃនេះគេចាប់ទៅហើយ យើងរស់មិនបាននៅទេ យើងមិនដឹងថាទៅប្រកណារួចទេ ។ ថ្ងៃដែលឪពុកខ្ញុំទៅគាត់ពាក់វ៉ែនតា ពាក់មួក នាឡិកាដៃ ស្ពាយកាំភ្លើងប៉េអា ហើយពួកនិរតីដកយកទាំងអស់ ហើយចងដៃគាត់ទៅក្រោយ ។ ប្អូនប្រុសខ្ញុំម្នាក់វាធ្វើការនៅពេទ្យយោធាតំបន់ វាឃើញឪពុកខ្ញុំដែរ ដល់ពេលបាត់ឪពុកខ្ញុំយូរពេក វាក៏ទៅរកមើលឃើញសន្តិសុខឲ្យគាត់ដក់បារី ។ ឪពុកខ្ញុំមិនចេះដក់បារីទេ គាត់យំហើយប្រាប់ប្អូនខ្ញុំថា ផ្តាំទៅម៉ែផងគេចាប់ពុកទៅហើយ” ។

ឪពុករបស់ ណារី និងសាច់ញាតិទាំងបីនាក់ត្រូវខ្មែរក្រហមនាំយកទៅដាក់មន្ទីរមួយដើម្បីបញ្ជូនដាក់គុកនៅភ្នំពេញ ។ សន្តិសុខបានឲ្យអ្នកទោសទាំងបួនហូបបាយមុននឹងដឹកយកទៅ ។ ណារី បន្តថា “មុនយកឪពុកខ្ញុំទៅ គេឲ្យគាត់ហូបបាយ ប៉ុន្តែគាត់ហូបមិនចូលទេ ទឹកភ្នែកគាត់ហូររហាម ។ សន្តិសុខចាប់ឪពុកខ្ញុំ និងបងប្អូនខ្ញុំដាក់ក្នុងបាវបោះដាក់លើឡានឮសូរគ្រាំងៗ រួចកាប់ស្នឹកដំឡូងឈើគ្របពីលើ ។ ឡានបានបើកទៅដល់ក្បែរវត្តតាសួស ក៏ដាច់ផុង ហើយសន្តិសុខបានឲ្យបុគ្គលិកពេទ្យនិងប្អូនខ្ញុំជួយរុញឡាន ។ ពេលមកដល់ក្រោលគោ បងថ្លៃជីដូនមួយខ្ញុំលោតទម្លាក់ខ្លួនពីលើឡានទាំងនៅក្នុងបាវហើយស្លាប់ពេលនោះ” ។

បីខែក្រោយមក ប្តីរបស់ ណារី ដែលជាប្រធានយោធាតំបន់២៣ ត្រូវចាប់ខ្លួនម្នាក់ទៀត ។ ណារី បានកាន់រូបថតប្តីរបស់គាត់ ហើយនិយាយថា “បងសារិន ត្រូវចាប់ខ្លួនបន្ទាប់ពីមេៗរបស់គាត់ ។ មុនថ្ងៃចាប់ខ្លួន ខ្ញុំបានទៅលេងគាត់នៅកន្លែងធ្វើការ ខ្ញុំជួបគាត់បានមួយភ្លែត ហើយឃើញសំបុត្រពីរអញ្ជើញគាត់ទៅប្រជុំ ។ មុនពេលចេញទៅគាត់ប្រាប់ឲ្យខ្ញុំចាំគាត់សិន ។ ពេលត្រឡប់ពីប្រជុំវិញ គាត់បានឲ្យនិរសារគាត់ជូនខ្ញុំត្រឡប់មកផ្ទះ ហើយផ្តាំខ្ញុំថា បើបាត់គាត់ប្រហែលមួយឆ្នាំរកប្តីទៀតទៅ ។ ពេលនោះខ្ញុំយំ ខ្ញុំសួរថាម៉េចក៏និយាយដូច្នេះ ។ ពេលគាត់ចេញទៅខ្ញុំកំពុងមានផ្ទៃពោះមួយខែកន្លះ ហើយគាត់ក៏ដឹងដែរ” ។



គីម សារិន

ណារី និង សារិន រៀបការនៅក្នុងរបបខ្មែរក្រហម ។ ណារី ជូតទឹកភ្នែកចេញពីថ្ពាល់ ហើយបន្តថា “យើងរៀបការនៅក្នុងឆ្នាំ១៩៧៦ ។ ប្តីខ្ញុំធ្វើការនៅតំបន់

*ខ្ញុំធ្វើជាគ្រូបង្រៀនក្មេងៗ ។ គាត់បានស្នើសុំអង្គការរៀបការជាមួយខ្ញុំ ។ អង្គការបានតាមដានប្រវត្តិគ្រួសារខ្ញុំមុននឹងឲ្យយើងទាំងពីររៀបការ ដោយសារក្រុមគ្រួសារខ្ញុំសុទ្ធតែជាអ្នកបម្រើការអង្គការដូចគ្នា ដូច្នេះអង្គការក៏អនុញ្ញាត ។ អង្គការយកខ្ញុំទៅរៀបការនៅកន្លែងគាត់ធ្វើការ ហើយនៅថ្ងៃរៀបការនោះមានកម្មាភិបាលចំនួន៦៩គូទៀត ។ ខ្ញុំទាំងពីរឡើងចាប់អារម្មណ៍នៅចំពោះមុខ ប្រធាន អនុប្រធាន និងសមាជិកដែលអង្គុយនៅខាងមុខប្តេជ្ញាចិត្តថា រស់នៅជាមួយគ្នារហូតដល់ថ្ងៃអនាគត ។ អង្គការបានរៀបចំពិធីជប់លៀងមួយឲ្យពួកខ្ញុំ ។ ខ្ញុំទៅសម្រាកនៅកន្លែងធ្វើការគាត់មួយយប់ ស្អែកឡើងគាត់ជូនខ្ញុំត្រឡប់មកផ្ទះ ហើយគាត់ត្រឡប់ទៅអង្គភាពវិញ"* ។

បន្ទាប់ពីការចាប់ខ្លួនឪពុក ពូ និងប្តីរបស់ ណារី បងប្អូនរបស់ណារី ទាំងប៉ុន្មានដែលបម្រើការឲ្យអង្គការបដិវត្តន៍ ត្រូវរំសាយពីការងារបញ្ជូនទៅសហករណ៍ និងចាប់ខ្លួនជាបន្តបន្ទាប់ ។ ប្អូនប្រុសរបស់ ណារី ឈ្មោះ កែវ វ៉ូ ជាយោធាភូមិភាគក៏ត្រូវអង្គការចាប់ខ្លួនជាមួយប្រធានយោធាស្រុកស្វាយរៀងនិងយោធាផ្សេងទៀតប្រហែលមួយពាន់នាក់ យកទៅសម្លាប់ចោលនៅឃុំកន្សោមអក ក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ។ ណារី រំឭកថា *"វ៉ូ ផ្តាំតាមប្អូនស្រីពៅខ្ញុំឈ្មោះ កែវ រ៉ាត់ ដែលធ្វើពេទ្យមកប្រាប់ម្តាយខ្ញុំថា វាសុំលាហើយ"* ។ ក្រោយមក រ៉ាត់ ក៏ត្រូវបញ្ឈប់ពីការងារ ហើយឃុំឃាំងរយៈពេលបីថ្ងៃទើបបញ្ជូនទៅការដ្ឋាន ។ ឈ្លបគំរាម រ៉ាត់ ថា "បងប្អូនចូលដៃជើងយួនហើយនៅយំស្រែកអីទៀត ចង់ទៅចូលគុកទាំងអស់គ្នាឬ?" ។ ចាប់តាំងពីពេលនោះមក ក្រុមគ្រួសាររបស់ ណារី ស្ថិតក្រោមការឃ្លាំមើលរបស់សន្តិសុខទាំងយប់ទាំងថ្ងៃ ។ ណារី និងម្តាយលួចយំមិនហ៊ានឲ្យអ្នកដទៃឃើញទេ ព្រោះខ្លាចឈ្លបចាប់យកទៅសម្លាប់ទៀត ។ ទ្រព្យសម្បត្តិនៅក្នុងផ្ទះទាំងប៉ុន្មានត្រូវសន្តិសុខដកហូតយកអស់ ។ *"គោមួយនឹម រទេះមួយ មាន់៤៧ក្បាល កង់ វិទ្យុ និងរបស់របរផ្សេងៗទៀត ត្រូវសន្តិសុខប្រមូលយកទៅទាំងអស់ ។ ខោអាវខ្ញុំនៅសល់មួយចំនួន ខ្ញុំយកទៅលាក់ទុកផ្ទះបងស្រីខ្ញុំនៅខាងលិចភូមិ"* ។ បន្ទាប់មកសន្តិសុខបានមកតាមចាប់ ណារី ម្នាក់ទៀត ប៉ុន្តែប្រធានភូមិបានអង្វរសុំឲ្យរង់ចាំដល់ ណារី សម្រាលកូនរួចសិន ។ ប្រហែលជាពីរខែក្រោយមក កងទ័ពវៀតណាមចូលរំដោះប្រទេស ណារី ក៏រួចផុតពីការចាប់ខ្លួនយកទៅសម្លាប់ ។

ណារី និងម្តាយបានរត់គេចខ្លួនមកដល់កំពង់ចម្លងអ្នកលឿង ។ ស្ថិតក្នុងសភាពការណ៍ច្របូកច្របល់ គ្រាប់បែកបានផ្ទុះឡើង ណារី ស្ទើរតែបាត់បង់កូនរបស់គាត់ ។ ណារី ឲ្យដឹងទៀតថា *"អម្បែងខ្ទាតត្រូវសំពត់ខ្ញុំរហែកអស់ ។ ខ្ញុំរត់គេចគ្រាប់ជាមួយមនុស្សជាច្រើន ខ្ញុំទាក់សំពត់ខ្លួនឯងដួលរបូតកូនខ្ទាតចេញពីដៃ ។ ខ្ញុំនិងម្តាយដើររកកូនអស់រយៈពេលជាងបីម៉ោងទម្រាំរកកូនឃើញ ដោយសារវាស្រែកយំខ្លាំងព្រោះមានរបួសពេញខ្លួន"* ។

ក្រោយឆ្នាំ១៩៧៩ ណារី បានមកមើលគុកទួលស្លែងជាមួយបងធម៌របស់គាត់ ហើយបានឃើញរូបថតឪពុកនិងប្តីព្យួរនៅទីនោះ ។ ពេលនោះគាត់រន្ធត់ចិត្តពេករហូតដល់ដួលសន្លប់បាត់ស្មារតី ។ តាំងពីពេលនោះ មកគាត់មិនបានមកមើលរូបថតនោះទៀតទេ ទើបតែដើមឆ្នាំ២០០៦នេះ ណារី បានមកមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីសុំថតចម្លងរូបថតឪពុក ប្តី និង ពូបង្កើតពូជីដូនមួយ និងបងថ្លៃ ដើម្បីទុកឲ្យកូនរបស់គាត់មើល ។

ណារី នៅតែមិនអាចបំភ្លេចនូវអតីតកាលដ៏ឈឺចាប់នេះបានឡើយ ។ គាត់នៅតែបន្ទោសថាដោយសាររបបកម្ពុជាប្រជាធិបតេយ្យទើបធ្វើក្រុមគ្រួសារប្តីឪពុកនិងបងប្អូនស្លាប់ បងទីពីរពិការជើងម្ខាង និងប្អូនប្រុសទីបីពិការដៃម្ខាង ហើយទ្រព្យសម្បត្តិក៏រលាយអស់ ធ្វើឲ្យគ្រួសាររបស់គាត់ធ្លាក់ខ្លួនក្ររហូតដល់សព្វថ្ងៃ ។ ណារី សំណូមពរឲ្យតុលាការជួយរកយុត្តិធម៌ឲ្យក្រុមគ្រួសារគាត់ផង ហើយគាត់ពេញចិត្តនឹងធ្វើជាសាក្សីនៅពេលតុលាការត្រូវការគាត់ ។

**លី សុផល**

## ពាក្យស្លោកខ្មែរក្រហម

- ផ្ដែកឱ្យរឹងមាំលើវណ្ណៈអធន សាមគ្គីយ៉ាងជិតស្និទ្ធជាមួយកម្លាំងប្រជាជាតិទាំងមូល មកខាងបដិវត្តន៍ឯកោ ខ្មាំងសត្រូវមួយក្ដាប់តូចជាអតិបរមា!

*(សៀវភៅកំណត់ហេតុលេខ១០៧៦)*

## សេចក្តីប្រកាសរកឪពុកឈ្មោះ ដួងស៊ីង សាន




ខ្ញុំបាទឈ្មោះ ណាថារី ដួងស៊ីង សូមសួររកឪពុកឈ្មោះ ដួងស៊ីង សាន កើតនៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៣៧ ស្រុកកំណើតនៅខេត្តសៀមរាប ។ គាត់ជាប្រធានផ្នែកខាងការសិក្សាសេដ្ឋកិច្ចនិងផែនការនៃក្រសួងកសិកម្មនៅក្នុងរបបសាធារណរដ្ឋខ្មែរ ។ នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមចូលទីក្រុងភ្នំពេញ ក្រុមគ្រួសារគាត់បានភៀសខ្លួនចូលស្ថានទូតបារាំង ។ ពេលនោះស្ថានទូតបារាំងត្រូវកងទ័ពខ្មែរក្រហមឡោមព័ទ្ធជិត ហើយគាត់និងប្រជាជនកម្ពុជាដែលបានរត់ទៅជ្រកកោនក្នុងស្ថានទូតនោះត្រូវបានបណ្តេញចេញ ។ ចាប់តាំងពីពេលនោះមកលែងមានដំណឹងអំពីគាត់ទៀត ។

បើបងប្អូនណាបានដឹងដំណឹងនេះឬស្គាល់សូមទំនាក់ទំនងមកខ្ញុំបាទតាមអាស័យដ្ឋានខាងក្រោម ៖ ប្រអប់សំបុត្រ៨៤៥ ភ្នំពេញ ទូរស័ព្ទលេខ ០៩២ ៩៦២ ៣៥៦ ឬ ០១២ ៨៧៦ ៥៣២ ឬតាមអាសយដ្ឋាន Buchsstr.20, D-73252 Lenningen, Germany, Tel: +49 7026 2104 or Email: peer_gatter@hotmail.com ។

## សេចក្តីប្រកាសសួររកបងប្រុស

នាងខ្ញុំឈ្មោះ អាន់ ណាស់ បច្ចុប្បន្នរស់នៅភូមិទឹកចេញ សង្កាត់បឹងតាព្រហ្ម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ។ ម្តាយឈ្មោះ ម៉ាន រស់ ។ នាងខ្ញុំមានបងប្អូនបីនាក់ ទី១ឈ្មោះ អាន សុះ, ទី២រូបខ្ញុំនិងប្អូន ទី៣ឈ្មោះ អាន់ មុត ។ នាងខ្ញុំសូមសុំសួររកប្អូនឈ្មោះ អាន់ មុត សព្វថ្ងៃមិនដឹងប្អូនរស់នៅទីណាទេ ហើយបើប្អូនបានឮដំណឹងហើយសូមប្អូនវិលមកជួបបងប្អូនតាមអាសយដ្ឋានខាងលើកុំខាន ។ សូមអរគុណ ។

## សេចក្តីប្រកាសរកកូននិងប្អូនប្រុស

នាងខ្ញុំឈ្មោះ អ៊ី វ៉ាន់ណេី អាយុ៦៥ឆ្នាំ រស់នៅក្នុងភូមិថ្លា ឃុំប្រវៀង ស្រុកកំពង់ធំ ខេត្តកំពង់ធំ ប្តីឈ្មោះ គុល ឡេង ខ្មែរក្រហមយកទៅសម្លាប់នៅឆ្នាំ១៩៧៧ សូមសួររកកូនប្រុសឈ្មោះ គុល មុន្នីវណ្ណ ដែលបានបាត់ខ្លួនតាំងពីអាយុ១២ និងប្អូនប្រុសឈ្មោះ អ៊ី ស្រ៊ុន បាត់ខ្លួនតាំងពីឆ្នាំ១៩៧៥ ។ បើកូននិងប្អូនបានឃើញសេចក្តីប្រកាសនេះសូមមករកម្តាយនិងបងតាមអាសយដ្ឋានខាងលើ ឬបើញាតិមិត្តណាបានស្គាល់សូមជួយផ្តល់ដំណឹងផង ។ សូមអរគុណ ។

## សេចក្តីប្រកាសរកបងប្រុស ពិន ចាន់ថុល

ខ្ញុំបាទឈ្មោះ ពិន ថែត អាយុ៤៣ឆ្នាំ ស្រុកកំណើតនៅភូមិមហាលាភ ឃុំពាមប្រធ្នោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម សព្វថ្ងៃជាអគ្គលេខាធិការរងទី១ សាលាខេត្តមណ្ឌលគិរី ។ ឪពុកឈ្មោះ ពិន ប៊ិន (ស្លាប់) ម្តាយឈ្មោះ ចឹក អួន សព្វថ្ងៃរស់នៅភូមិមហាលាភ ឃុំពាមប្រធ្នោះ ស្រុកកោះសុទិន ខេត្តកំពង់ចាម ។ សូមសួររកបងប្រុសឈ្មោះ ពិន ចាន់ថុល បាត់ដំណឹងនៅឆ្នាំ១៩៧៧ កាលនោះឮថាអង្គការយកទៅធ្វើការរោងចក្រ ប៉ុន្តែរហូតមកដល់សព្វថ្ងៃនេះគ្មានដំណឹងសោះ ។ បើបងប្រុសទទួលបានដំណឹង ឬញាតិមិត្តណាបានស្គាល់ឈ្មោះនេះ សូមទាក់ទងមកខ្ញុំ បាទតាមទូរស័ព្ទលេខ ០៩២ ៩២៨ ៥៧៩ ។ សូមអរគុណ ។

## សេចក្តីប្រកាសរកបងស្រីឈ្មោះ អយ សាន្ត

ខ្ញុំបាទឈ្មោះ ខៀក សារឿន អាយុ៤៦ឆ្នាំ រស់នៅភូមិកណ្តាល ឃុំស្ពានមានជ័យ ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី សូមសួររកបងស្រីបង្កើតឈ្មោះ អយ សាន្ត ធ្វើពេទ្យសម័យខ្មែរក្រហម ប្តីឈ្មោះ ញឹម សុផល ។ បើបងស្រីបានទទួលដំណឹង ឬញាតិមិត្តបានស្គាល់ឈ្មោះនេះ សូមទាក់ទងតាមទូរស័ព្ទលេខ ០១២ ៧៦៦ ០៨២ ឬតាមរយៈ មជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។








**ពិធីសច្ចាប្រណិធានស្បថចូលកាន់មុខតំណែងរបស់ចៅក្រម សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត អន្តរជាតិ និងកម្ពុជា នៅក្នុងព្រះបរមរាជវាំង នារសៀលថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៦**


*ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក*

*អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩*



**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨*

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.



A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 78, June 2006 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.